# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## បឋមភាគ ២

ផ្ដើមប្រែរៀបរៀងតាមច្បាប់ដើមដោយ

កល្យាណធម្មោ សុន្ទរ៍-សារមឿន

រាជធានីភ្នំពេញ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥៥៧ គ. ស. ២០១៣

# អដ្ឋសាលិនី

## បឋមភាគ

## ២

ព. ស.

២៥៥៧

រក្សាសិទ្ធិ

បោះពុម្ពលើកទី ៣

រក្សាសិទ្ធិ (ហាមថតចម្លង)

# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះថា ធម្មសង្គណី

## បឋមភាគ ២

### អមដោយៈ

- ព្រះអភិធម្មបិដកខ្មែរ បឋមភាគ ៧៨
- អដ្ឋសាលិនី ធម្មសង្គណី ភាសាបាលីភាគ១
- អដ្ឋសាលិនី មូលដីកា-អនុដីកា ភាសាបាលីភាគ១
- អដ្ឋសាលិនី អត្ថយោជនា ភាសាបាលីភាគ១

ផ្ដើមម័ុបរៀបរៀងតាមច្បាប់ដើមដោយ

កល្យាណធម្មោ សុន្ទរ៍-សាមឿន

ព. ស. ២៥៥៧ គ. ស. ២០១៣

# នមត្ថុ រតនត្តយស្ស

# ឧប្បត្តិកថា

បុព្វហេតុដែលនាំឱ្យខ្ញុំផ្ដើមប្រែរៀបរៀង គម្ពីរអដ្ឋកថាព្រះអភិធម្មនេះឡើង មិនមែនដោយហេតុដែលខ្ញុំជាអ្នកស្ទាត់ជំនាញ ឈ្លាសវៃនោះទេ, តែដោយហេតុ ៖-

-ចង់ចេះ, ព្រោះធម៌ព្រះអភិធម្មនេះ ជាធម៌ជ្រាលជ្រៅ ល្អិតសុខុម គម្ភីរភាពណាស់; បុគ្គលដែលរៀនធម៌នេះ បើមិនព្យាយាមយកចិត្តទុកដាក់ ពិចារណាពិច័យឱ្យបានច្រើនៗ មួយអន្លើដោយការបដិបត្តិទេ មិនអាចយល់បានច្បាស់លាស់ឡើយ ។

-ចង់ឱ្យគម្ពីរព្រះពុទ្ធសាសនា មានមូលដ្ឋានច្បាស់លាស់ពិតប្រាកដ អាចយកជាផ្លូវការបាន, ព្រោះកន្លងមក នៅក្នុងប្រទេសកម្ពុជាយើងនេះ ក្រៅពីព្រះត្រៃបិដក មិនទាន់ឃើញមានគម្ពីរណាមួយ ដែលជាគម្ពីរបន្ទាប់បន្សំពីព្រះត្រៃបិដក ត្រូវបានអ្នកប្រាជ្ញទាំងឡាយពីជំនាន់មុនប្រែ និងរៀបរៀងបានទាំងស្រុងនៅឡើយ ។ យើងសង្កេតឃើញដោយច្រើនៗតែកូនសៀវភៅបកិណ្ណកៈផ្សេងៗ ដែលអ្នកប្រាជ្ញបានដកស្រង់ពីព្រះត្រៃបិដកខ្លះ, ព្រះអដ្ឋកថាជាដើមខ្លះ មករៀបរៀងតាមដែលខ្លួនធ្លាប់បានរៀនមក ពីសំណាក់លោកគ្រូអាចារ្យផ្សេងៗ ហើយយកមកផ្សំជាមួយនឹងគំនិតរបស់ខ្លួន ។ សៀវភៅបែបនេះ គឺមានច្រើនណាស់ រហូតដល់ច្រើនពេកទៅ អ្នកសិក្សាបដិបត្តិទាំងឡាយមិនដឹងថា នឹងយកតាមសៀវភៅណាឱ្យបានពិតប្រាកដ បើភៅសៀវនេះថាអ៊ីចេះ សៀវភៅនោះថាអ៊ីចុះ ។ ល ។ ឯសៀវភៅនេះ មិនមែនជាសៀវភៅដែលខ្ញុំប្រែ

រៀបរៀងតាមគំនិតរបស់ខ្លួនផ្ទាល់ទេ, គឺប្រែរៀបរៀងទៅតាមច្បាប់ដើមទាំងស្រុង ។ ក្នុងការប្រែ និងរៀបរៀងទៀតសោត ខ្ញុំបានពឹងឱ្យភិក្ខុសាមណេរ និងឧបាសកខ្លះជួយសរសេរចម្លងតាមច្បាប់ដើម គឺច្បាប់ដែលគេប្រែរួចហើយ ឱ្យលោកជួយពិនិត្យឱ្យបានត្រឹមត្រូវតាមច្បាប់ដើម ។ បន្ទាប់មក ខ្ញុំយកមកពិនិត្យ ផ្ទៀងផ្ទាត់តាមច្បាប់ដើមផង, តាមអដ្ឋកថាបាលីផង, អដ្ឋសាលិនី អត្ថយោជនាបាលីផង និងមូលដីកា អនុដីកាបាលីផង ។ តែទុកជាយ៉ាងនេះក៏ដោយ ក៏មិនអាចជៀសផុតពីការខុសភ្លាំងភ្លាត់បានឡើយ, ហេតុដូច្នេះហើយ ខ្ញុំសូមពឹងលើអ្នកប្រាជ្ញ និងអ្នកសិក្សាទាំងឡាយ មេត្តាជួយកែសម្រួល ដោយកុសលចេតនាផងចុះ ។

-អ្នកកាន់ព្រះពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា នឹងមានសេចក្ដីប្រតិបត្តិត្រូវផ្លូវគ្នា ព្រោះមានគម្ពីរអដ្ឋកថានេះជាគ្រូ ប្រាប់ខុសត្រូវ ជាគោលចារិក សម្រាប់អាងត្រូវគ្នាតែបែបមួយ ហើយនឹងបានកម្ចាត់បង់នូវអស្មិមានះ គឺប្រកាន់ខុសថា ត្រូវនោះចេញ ។

-អដ្ឋកថាព្រះអភិធម្មបិដកនេះ ទុកជាប្រទីបជ្វាលា ឆ្លុះបំភ្លឺដល់អស់មហាជនឱ្យឃើញសេចក្ដីខុស នឹងត្រូវជាក់ មិនភាន់ច្រឡំ នាំឱ្យកើតមានប្រាជ្ញាស្មារតីល្អ ចេះអៀនខ្មាស់ រង្កៀសរអា ស្អប់ខ្ពើមអំពើអាក្រក់ ឱ្យខ្មីឃ្មាតសង្វាត ខំប្រឹងប្រព្រឹត្តសុចរិតស្លូតត្រង់ដែលជាពូជបង្កើតសេចក្ដីសុខឱ្យមានបរិបូណ៌ឡើង ។ កាលបើមហាជន មានសេចក្ដីអៀនខ្មាស់ ជ្រេញចិត្តនឹងអំពើអាក្រក់ហើយ ព្រះពុទ្ធសាសនាក៏នឹងថ្កុំថ្កើងរុង

រឿង មានកេរ្តិ៍ឈ្មោះក្រអូបសាយទៅក្នុងលោកទាំងមូល ពីព្រោះធម៌សុចរិត មានក្លិនក្រអូបជាទីបំផុត ជាងក្លិននៃគ្រឿងក្រអូបទាំងអស់ ។

## អំពីរបៀបប្រែរៀបរៀង របស់អ្នកផ្ដើមប្រែរៀបរៀង

របៀបមុខការគ្រប់យ៉ាង ដែលបានរៀបចំព្រះអដ្ឋកថានេះ ខ្ញុំជាអ្នកផ្ដើមប្រែរៀបរៀង បានធ្វើដោយកម្លាំងព្យាយាមដ៏មាំមួន ព្រមទាំងបានពិនិត្យ ពិច័យ ដោយល្អិតល្អន់ ដូចមានសេចក្ដីរាយដំណើរការតទៅនេះ ៖-

១-គម្ពីរ**អដ្ឋកថាព្រះអភិធម្ម** ជាពាក្យអធិប្បាយសេចក្ដីក្នុងព្រះអភិធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគគឺ

**១. បឋមភាគ** ឈ្មោះ **អដ្ឋសាលិនី** អធិប្បាយគម្ពីរ **ធម្មសង្គណី**

**២. ទុតិយភាគ** ឈ្មោះ **សម្មោហវិនោទនី** អធិប្បាយគម្ពីរ **វិភង្គ**

**៣. តតិយភាគ** ឈ្មោះ **បរមត្ថទីបនី** អធិប្បាយគម្ពីរ**បញ្ចបករណ៍** តាំងពី**ធាតុកថា** រហូតដល់ចប់គម្ពីរ **បដ្ឋាន** ទាំងអស់ ។

បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ហើយយើងមិនបានធ្វើទៅតាមលំដាប់លំដោយទេ ពោលគឺយើងធ្វើតែភាគ ឬលេខណាដែលស្រួលៗ មុន ។

២-ខ្ញុំបានយកគម្ពីរអដ្ឋកថាព្រះអភិធម្មបិដកច្បាប់ដើម (ច្បាប់ដែលគេប្រែរួច) ហើយចាត់ឱ្យលោកចម្លងស្រង់យកប្រែខ្លះ បាលីខ្លះ ទើបបានយកគម្ពីរអដ្ឋកថាព្រះអភិធម្មបិដកបាលីជាច្រើន មកធ្វើជាច្បាប់ផ្ទៀងផ្ទៀបគ្នារវាងប្រែ និងបាលី ។ បើផ្ទៀងផ្ទៀបគ្នាទៅហើយ ឃើញមានសព្ទប្រែត្រង់ណាដែលផ្សេងពីបាលីខ្លះ ខ្ញុំបានកែប្រែសព្ទដែលប្រែនោះ ឱ្យមកតាមលំនាំនៃសព្ទបាលី ជួនកាលដាក់សព្ទដែលមានលំនាំសេចក្ដីប្រហែលគ្នា ក្នុងវង្វង់ក្រចក (---) ដើម្បីធ្វើសព្ទនោះ ឱ្យមានភាពទូលំទូលាយងាយយល់ ។

៣-ឯការផ្ទៀងផ្ទៀបគ្នានោះ ខ្ញុំបានយកគម្ពីរមូលដីកា, អនុដីកា និងយោជនាមកមើលជាដរាប ដើម្បីឱ្យឃើញសេចក្ដីជាក់ប្រាកដ; ប៉ុន្តែ មិនបានដាក់សេចក្ដីតាមន័យក្នុងដីកាទាំងពីរ និងយោជនានោះទាំងអស់ទេ, ផ្ទៀងតាមលំអានអដ្ឋកថាបាលីព្រះអភិធម្មបិដក គឺថាបាលីនោះ មានសេចក្ដីប៉ុន្មាន ខ្ញុំប្រែឱ្យគត់តែត្រឹមប៉ុណ្ណោះឯង, តែបើប្រែប្រយោគណា មានសេចក្ដីចង្អៀតពិបាកយល់នោះ ខ្ញុំបន្ថែមពាក្យ ឬសេចក្ដីខ្លះតាមន័យក្នុងដីកាទាំងពីរ និងយោជនាដាក់ក្នុងវង់ក្រចក ( --- ) ។

ម្យ៉ាងទៀត ប្រយោគខ្លះ មានដំណើរបាលីលំបាកប្រែរៀងសេចក្ដីសម្រួលមកជាសម្រាយនោះពេក លុះតែប្រែបញ្ចូលពាក្យថែមមកខ្លះ ទើបមិនងាប់សេចក្ដី, កាលបើដូច្នោះ ខ្ញុំដាក់ក្នុងវង់ក្រចក (---) នេះដែរ ដូចជាពាក្យថា (នេះ) (នោះ) ជាដើម ដើម្បីឱ្យស្រួលតាមលំនាំសេចក្ដីភាសាខ្មែរ, ប៉ុន្តែការដាក់វង់ក្រចកនេះ មិនបានគ្រប់

អន្លើទេ ។

៤-ពាក្យ ឬប្រយោគណា ដែលមានសេចក្ដីជ្រៅកំបាំងពេក បើមិនទាញយកមកអធិប្បាយពន្យល់ផងទេ មុខជានឹងមិនអាចយល់ចូលចិត្តសេចក្ដីបានឡើយ ។ ដូច្នេះ ខ្ញុំបានស្រង់យកសេចក្ដីអធិប្បាយ មកដាក់ជាលេខយោងឱ្យប្រាកដឡើង ដោយប្រើសញ្ញាផ្កាយ (*) សម្គាល់ឱ្យដឹងថា ពាក្យ ឬសេចក្ដីនោះបញ្ចូលថែមមក ដែលមានប្រាប់ឈ្មោះគម្ពីរក្នុងទីនោះៗ ស្រាប់ ។

៥-ដោយសារតែអត្ថសេចក្ដីនៃព្រះអភិធម្មមានគម្ភីរភាព, ក្នុងការរៀបរៀង ខ្ញុំបានប្រើអក្សរដែលមានទ្រង់ទ្រាយតូចធំព្រមទាំងនិមិត្តសញ្ញាផ្សេងៗ ទៀត ប្រយោជន៏ដើម្បីសាធុជនបានអានរៀនសូត្រឆាប់យល់ ។

* ប្រសិនបើនៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ។

នៅក្នុងសេចក្ដីនៃអដ្ឋកថានេះ គឺព្រះអរហន្តទាំងឡាយ ពន្យល់បកស្រាយទៅតាមព្រះពុទ្ធវចនៈ ដែលមាននៅក្នុងព្រះអភិធម្មបិដក, ព្រោះហេតុដូច្នោះ មុននឹងសាធុជនសិក្សាសៀវភៅនីមួយៗ សូមអានគម្ពីរព្រះអភិធម្មបិដក ទៅតាមលំដាប់ភាគ វគ្គ សេចក្ដីកណ្ឌនីមួយៗ សិន, កាលបើសាធុជនសិក្សាដូច្នេះ នឹងអាចយល់សេចក្ដីបានយ៉ាងឆាប់រហ័ស ។

**នត្ថិ បញ្ញា សមា អាភា** ពន្លឺស្មើដោយបញ្ញាមិនមានឡើយ!។

**នត្ថិ សន្តិបរំ សុខំ** សុខដទៃក្រៅអំពីសេចក្តីស្ងប់មិនមានឡើយ!។

រាជធានីភ្នំពេញ

ពិនិត្យផ្ទៀងផ្ទាត់ចប់នៅថ្ងៃទី ១០, ខែ កញ្ញា : ព. ស. ២៥៥៧ / គ. ស. ២០១៣

*ខ្ញុំព្រះករុណា ខ្ញុំបាទ* ***សុន្ទរ៍_សារមឿន***

អតីតសមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតជំនាន់ទី ៣, ទូរសព្ទ:

០៩២ ៩០ ៨២ ៦៥, ០៩៧ ២៣ ៣០ ២១៥,

០២៣ ៦៣ ០១ ០២២, ០១៦ ៤៦ ៥២ ៣៤ ៕

## អ្នកដែលមានឧបការៈក្នុងការងារធម្មទាននេះ

១_លោកខន្តិធីរោ **រ៉េន_ភិរម្យ** ជួយចម្លង និងផ្ទៀងតាមច្បាប់ដើម

២_លោកខន្តិជាតិកោ **ថៃ_ភិរក្ស** ជួយចម្លង និងផ្ទៀងតាមច្បាប់ដើម

៣_លោកធម្មរក្ខិតោ **គង់_ទន** ជួយផ្ទៀងតាមច្បាប់ដើម

៤_ឧបាសក **ចៅ_សារអែម** ជួយដំណើរការផ្សេងៗ

៥_ លោក **សួន ឱសថ** ជួយដំណើរការផ្សេងៗ

៦_លោកញាណប្បទីបោ **គ្រឿង_ប៊ុនធឿន** ការីកុំព្យូទ័រ

៧-លោក **ហេង សុវណ្ណារ៉ា** និងក្រុមគ្រួសារ ឧបត្ថម្ភកុំព្យូទ័រ

៨- ឧបាសក **ស្រួង ចាន់ណា** និងក្រុមគ្រួសារ ឧបត្ថម្ភកុំព្យូទ័រ ៕

## ឈ្មោះអ្នកចូលរួមជួយកែសម្រួល

១_លោក **សេង_សុមុនី** អតីតនៃអគ្គាធិការរងក្រសួងធម្មការ

២_ព្រះមហាសីលប្បញ្ញោ **ស៊ាង_ឈុនលី** (វត្តសំពៅមាស)

៣_ភិក្ខុធម្មបាល **រិត_សោរឌី** (វត្តឧណ្ណាលោម)

៤_ភិក្ខុសុវណ្ណប្បជោត **គង_ណារ៉ំ** (ចៅអធិការវត្តសំពៅមាស)

៥_លោកធម្មយោគោ **មិន_ណារ៉ុល** ជួយពិនិត្យផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ

៦_ក្រុមទ្រទ្រង់ព្រះត្រៃបិដក (ប្រចាំវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ)

៧_ក្រុមសមណៈសិស្សពហុស្សូត **វត្តនិគ្រោធវ័ន** (គល់ទទឹង)

៨_ក្រុមសមណៈសិស្សពហុស្សូត **វត្តសុវណ្ណបទុម** (ចំបក់មាស)

៩_ក្រុមសមណៈសិស្សពហុស្សូត **វត្តធុតង្គ** (ចំការដូង)

១០_លោក **រស់_សារេឌន** (សាស្ត្រាចារ្យមហាវិទ្យាល័យព្រះសីហនុរាជ )

១១_លោក **ម៉ម_ឈុំ** (ពុទ្ធសាសនបណ្ឌិត្យ)

១២_លោក **ជិត_ជន** (សាស្ត្រាចារ្យមហាវិទ្យាល័យព្រះសីហនុរាជ)

១៣_លោក **ជា_ក្រស្នា** (សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត)

១៤_លោកបណ្ឌិត **ស្ងួន ឱសថ** (អតីតក្រុមទ្រទ្រង់ព្រះត្រៃបិដក)

១៥-លោក **ស៊ីវ៉េង វណ្ណា** (អតីតក្រុមឈ្វេងយល់ព្រះត្រៃបិដក)

១៦_លោក **ស៊ឹម រតនៈ** (អតីតសមណៈសិស្សពុទ្ធិកវិទ្យាល័យអ៊ឹង ធួង)៕

# ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង និងក្រៅប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាលដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស និងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗរូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

***ដោយអំណាចនៃមហាកុសលផលធម្មទាននេះ សូមឱ្យ ៖***

*-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ*

*-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា*

*-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ*

*-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕*

# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## បឋមភាគ ២

**មាតិកាធម៌** **ទំព័រ**

### កាមាវចរកុសល និងទ្វារកថា


សម្តែងអំពីកាយកម្ម និងទ្វារ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១

កថាសម្តែងអំពីទ្វារនៃវចីកម្ម ..... ..... ..... ..... ..... ..... ..... ..... .... .... .... ១២

កថាសម្តែងអំពីទ្វារនៃមនោកម្ម ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៦

កថាសម្តែងអំពីកម្ម ៣ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៨

អធិប្បាយអំពីវិញ្ញាណ ៥ ជាដើម ..... ..... ..... ..... ..... ..... ..... ..... .... .... ៣៦

កថាសម្តែងអំពីអកុសលកម្មបថ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៤១

អង្គរបស់បាណាតិបាត ៥ ... ..... ..... ..... ..... ..... ..... ..... ..... ..... .... .... ៤៣

បាណាតិបាតមានប្រយោគ ៦ ... ..... ..... ..... ..... ..... ..... ..... ..... ..... .... ៤៣

សម្តែងអំពីអទិន្នាទាន ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៤៤

អទិន្នាទានមានអង្គ ៥ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៤៥

សម្តែងអំពីកាមេសុមិច្ឆាចារ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៤៦

អគមនីយដ្ឋាន ២០ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .... ៤៧

កាមេសុមិច្ឆាចារមានអង្គ ៤ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៤៩

សម្តែងអំពីមុសាវាទ ..... ..... ..... ..... ..... ..... ..... ..... ..... .... .... .... ៥០

មុសាវាទមានអង្គ ៤ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៥១

សម្តែងអំពីបិសុណាវាចាជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៥២

ផរុសវាចាមានអង្គ ៣ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៥៦

សម្តែងអំពីអកុសលកម្មបថ ៥ ប្រភេទ ..... ..... ..... ..... ..... .... .... ..... .... ៥៩

កថាសម្តែងអំពីកុសលកម្មបថ ១០ ..... ..... ..... ..... ..... ..... ..... ..... ៦៣

សម្តែងអំពីកុសលកម្មបថ ៥ ប្រភេទ ..... ..... ..... ..... ..... ..... ..... ..... ....៦៧

អធិប្បាយពាក្យថាធម៌មានផស្សៈជាដើម ..... ..... ..... ..... ..... ..... ..... ..... ៧៦

អត្ថនៃពាក្យថាផស្សៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៨០

អត្ថនៃពាក្យថាវេទនា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៨៤

អត្ថនៃពាក្យថាសញ្ញា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៨៧

អត្ថនៃពាក្យថាចិត្ត ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .... ៩៣

អត្ថនៃពាក្យថាវិតក្កៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ៩៩

អត្ថនៃពាក្យថាវិចារៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១០១

អត្ថនៃពាក្យថាបីតិ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ១០៣

អត្ថនៃពាក្យថាសុខ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ១០៨

អធិប្បាយអំពីឯកគ្គតានៃចិត្ត ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១១១

អត្ថនៃពាក្យថាសទ្ធិន្ទ្រិយ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១១៣

អត្ថនៃពាក្យថាវីរិយិន្ទ្រិយ ..... ..... ..... ..... ..... ..... ..... ..... ..... ..... .....១១៦

អត្ថនៃពាក្យថាសតិន្ទ្រិយ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១១៩

អត្ថនៃពាក្យថាសមាធិន្ទ្រិយ ..... ..... ..... ..... ..... ..... ..... ..... ..... ....... ១២២

អត្ថនៃពាក្យថាបញ្ញិន្ទ្រិយ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១២២

លក្ខណាទិចតុក្កៈនៃបញ្ញា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១២៤

អត្ថនៃពាក្យថាមនិន្ទ្រិយ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ១២៥

អត្ថនៃពាក្យថាសោមនស្សិន្ទ្រិយ ..... ..... ..... ..... ..... ..... ..... ....... ១២៥

អត្ថនៃពាក្យថាជីវិតិន្ទ្រិយ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១២៦

អធិប្បាយអំពីសម្មាទិដ្ឋិជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... .....១២៧

អធិប្បាយអំពីសទ្ធាពលៈជាដើម ..... ..... ..... ..... ..... ..... ..... ..... ...... ១២៨

អត្ថនៃពាក្យថាអលោភៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៣៦

លក្ខណាទិចតុក្កៈនៃអទោសៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៣៧

អត្ថនៃពាក្យថាអនភិជ្ឈា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ១៤៤

អធិប្បាយលោកបាលធម៌ ២ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ..... ១៤៤

អត្ថនៃយុគលធម៌ ... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៤៥

អធិប្បាយពាក្យថាយេវាបនកន័យ ..... ..... ..... ..... ..... ..... ..... ..... ..... ១៤៩

អធិប្បាយពាក្យថាឆន្ទៈជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... .... ១៥២

## អដ្ឋកថាចិត្តុប្បាទកណ្ឌ

លក្ខណាទិចតុក្កៈនៃខន្ធ ៥ ..... ..... ..... ..... ..... ..... ..... ..... ..... ........ ១៦៧
អធិប្បាយវេទនានិទ្ទេសជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... ១៧៣
អធិប្បាយវិតក្កនិទ្ទេសជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៨៥
អធិប្បាយសង្គហវារៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ... ២១៧

### អធិប្បាយសុញ្ញតវារៈ

ចិត្តដួងទី ១ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .....២២៣
អធិប្បាយចិត្តដួងទី ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ២២៥
អធិប្បាយចិត្តដួងទី ៣ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២២៧
អធិប្បាយចិត្តដួងទី ៤ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. ២២៧
អធិប្បាយចិត្តដួងទី ៥ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២២៨
អធិប្បាយចិត្តដួងទី ៦ ជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... .. ២២៩
កថាសម្តែងអំពីបុញ្ញកិរិយាវត្ថុជាដើម ..... ..... ..... ..... ..... ..... ..... ..... ២២៩
សម្តែងអំពីអនន្ត វត្ថុមិនមានទីបំផុត ៤ យ៉ាង .. ..... ..... ..... ..... ..... ..... ២៣៩

## អធិប្បាយអំពីរូបាវចរកុសល

ពណ៌នាអំពីបឋមជ្ឈានចតុក្កន័យ ... ..... ..... ..... ..... ..... ..... ..... ..... ..... ២៤៥
សម្តែងអំពីអង្គឈាន ... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៥៥
សម្តែងអំពីបឋវីកសិណ ... ..... ..... ..... ..... ..... ..... ..... ..... ..... ..... . ២៦០
អធិប្បាយអំពីទុតិយជ្ឈាន ... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៦២

អធិប្បាយអំពីតតិយជ្ឈាន .... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៦៩
សម្តែងអំពីឧបេក្ខា ១០ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៧១
អធិប្បាយអំពីចតុត្ថជ្ឈាន ... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៨៣
អធិប្បាយអំពីឈានបញ្ចកន័យ ... ..... ..... ..... ..... ..... ..... ..... ..... ..... ២៩២
អធិប្បាយអំពីបដិបទា ៤ .... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣០០
អធិប្បាយអំពីអារម្មណ៍នៃឈាន ៤ ..... ..... ..... ..... ..... ..... ..... ..... .... ៣០៥
អធិប្បាយអំពីអារម្មណ៍ និងបដិបទាបញ្ចូលគ្នា ..... ..... ..... ..... ..... ..... ៣០៦
អធិប្បាយអំពីអាបោកសិណជាដើម ..... ..... ..... ..... ..... ..... .... .... .... ៣១០
អធិប្បាយអំពីអភិភាយតនៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣១៥
អធិប្បាយអំពីអភិភាយតនៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣២១
អធិប្បាយអំពីព្រហ្មវិហារជ្ឈាន ..... ..... ..... ..... ..... ..... ..... ..... ..... .. ៣២៥
លក្ខណាទិចតុក្កៈនៃមេត្តា ... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣២៨
លក្ខណាទិចតុក្កៈនៃករុណា ... ..... ..... ..... ..... ..... ..... ..... ..... ..... ... ៣២៨
លក្ខណាទិចតុក្កៈនៃមុទិតា ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. ៣២៩
លក្ខណាទិចតុក្កៈនៃឧបេក្ខា ... ..... ..... ..... ..... ..... ..... ..... ..... ..... .... ៣៣០

# ឈ្មោះគម្ពីរផ្សេងៗ
## ដែលប្រើជាអក្សរកាត់ ក្នុងបឋមភាគ ២ នេះគឺៈ-

| | |
|---|---|
| អភិ. | = អភិធម្មបិដក |
| អំ. អដ្ឋក. | = អង្គុត្តរនិកាយ អដ្ឋកនិបាត |
| អំ. ឯក. | = អង្គុត្តរនិកាយ ឯកកនិបាត |
| អំ. ចតុក្ក. | = អង្គុត្តរនិកាយ ចតុក្កនិបាត |
| អំ. ឆក្ក. | = អង្គុត្តរនិកាយ ឆក្កនិបាត |
| អំ. តិក. | = អង្គុត្តរនិកាយ តិកនិបាត |
| អំ. ទុក. | = អង្គុត្តរនិកាយ ទុកនិបាត |
| អំ. នវក. | = អង្គុត្តរនិកាយ នវកនិបាត |
| អំ. បញ្ចក. | = អង្គុត្តរនិកាយ បញ្ចកនិបាត |
| អដ្ឋ. យោ. | = អដ្ឋសាលិនី អត្ថយោជនា |
| ខុ. ឥតិ | = ខុទ្ទកនិកាយ ឥតិវុត្តក |
| ខុ. ចូឡ. | = ខុទ្ទកនិកាយ ចូឡនិទ្ទេស |
| ខុ. បដិ. | = ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ខុ. មហា. | = ខុទ្ទកនិកាយ មហានិទ្ទេស |
| ខុ. សុ. | = ខុទ្ទកនិកាយ សុត្តនិបាត |
| ទី. បា. | = ទីឃនិកាយ បាដិកវគ្គ |
| ទី. ម. | = ទីឃនិកាយ មហាវគ្គ |

ទី. សី. = ទីឃនិកាយ សីលក្ខន្ធវគ្គ

ម. អ. = មជ្ឈិមនិកាយ អដ្ឋកថា

ម. ឧ. = មជ្ឈិមនិកាយ ឧបរិបណ្ណាសក

ម. មូ. = មជ្ឈិមនិកាយ មូលបណ្ណាសក

ម. ម. = មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក

មិលិន្ទ. = មិលិន្ទបញ្ហា

មូល. = មូលដីកា

វិនយ. = វិនយបិដក

វិសុទ្ធិ. = វិសុទ្ធិមគ្គ

សី. ម. = សីលក្ខន្ធវគ្គ មហាវគ្គ

សំ. ខ. = សំយុត្តនិកាយ ខន្ធវគ្គ ឬសំយុត្តនិកាយ ខន្ធវារវគ្គ

សំ. និ. = សំយុត្តនិកាយ និទានវគ្គ

សំ. សឡា. = សំយុត្តនិកាយ សឡាយតនវគ្គ

សំ. ម. = សំយុត្តនិកាយ មជ្ឈិមបណ្ណាសក

សំ. ស. = សំយុត្តនិកាយ សគាថវគ្គ ៕

# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះថា ធម្មសង្គណី

## បឋមភាគ ២

ព. ស. ២៥៤៧

# អដ្ឋសាលិនី

# អដ្ឋកថាព្រះអភិធម្មបិដក

## បឋមភាគ ២

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៕*

## អដ្ឋកថាចិត្តុប្បាទកណ្ឌ

### កាមាវចរកុសល និងទ្វារកថា

### សម្តែងអំពីកាយកម្ម និងទ្វារ

ក៏ដើម្បីប្រកាសសេចក្តីនេះ ក្នុង មហាអដ្ឋកថា លោកពោលទ្វារកថាទុកក្នុងទីនេះ ។ ក្នុងទ្វារកថានោះ ឈ្មោះថា ការតាំងមាតិកា ក្នុងទ្វារកថានេះមានប្រមាណប៉ុណ្ណេះ គឺ

| | |
|---|---|
| ~កម្ម ៣ | ~ទ្វារនៃកម្ម ៣ |
| ~វិញ្ញាណ ៥ | ~ទ្វារនៃវិញ្ញាណ ៥ |
| ~ផស្សៈ ៦ | ~ទ្វារនៃផស្សៈ ៦ |
| ~អសំវរៈ ៨ | ~ទ្វារនៃអសំវរៈ ៨ |

**-សំវរៈ ៨ -ទ្វារនៃសំវរៈ ៨**

**-អកុសលកម្មបថ ១០ -កុសលកម្មបថ ១០**[១] ។

ក្នុងការតាំងមាតិកាទាំងនេះ កម្ម ៣ យ៉ាង លោកពោលទុកមុន ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា លោកក៏វៀរកម្មទាំង ៣ នោះ ហើយសម្តែងចែកទ្វារនៃកម្ម ៣ ដោយកាលជាខាងដើមមុន ។

**សួរថា** ទ្វារនៃកម្មទាំង ៣ តើដូចម្តេច?

ឆ្លើយថា ទ្វារនៃកាយកម្ម ទ្វារនៃវចីកម្ម និងទ្វារនៃមនោកម្ម ។

ក្នុងទ្វារនៃកាយកម្មនោះ កាយមាន ៤ គឺឧបាទិន្នកកាយ (កាយដែលមានចិត្តគ្រប់គ្រង) ១, អាហារសមុដ្ឋានកាយ (កាយដែលមានអាហារជាសមុដ្ឋាន) ១, ឧតុសមុដ្ឋានកាយ (កាយដែលមានរដូវជាសមុដ្ឋាន) ១ និងចិត្តសមុដ្ឋានកាយ (កាយដែលមានចិត្តជាសមុដ្ឋាន) ១ ។ បណ្តាកាយទាំង ៤ នោះ រូបមានកម្ម ជាសមុដ្ឋាន ៨ គឺមានចក្ខាយតនៈនេះជាដើម [២] មានជីវិតិន្ទ្រិយជាទីបំផុតក្តី, រូប ៨ គឺធាតុ ៤, វណ្ណៈ, គន្ធៈ, រសៈ និងឱជាដែលមានកម្មជាសមុដ្ឋានក្តី, ឈ្មោះថា **ឧបាទិន្នកកាយ** ។

[១] តាមច្បាប់ខ្លះថា លោករៀងកុសលកម្មបថទុកមុនអកុសលកម្មបថ ។

[២] ចក្ខុសោតឃាន ជីវ្ហាកាយឥត្ថីបុរិសជីវិតិន្ទ្រិយរូប ។

រូបទាំង ៨ នោះឯងកើតអំពីអាហារ ឈ្មោះថា **អាហារសមុដ្ឋានិកកាយ** ។ រូប ៨ កើតអំពីឧតុ ឈ្មោះថា **ឧតុសមុដ្ឋានិកកាយ** ។ រូប ៨ កើតអំពីចិត្ត ឈ្មោះថា **ចិត្តសមុដ្ឋានិកកាយ** ។

ក្នុងឧបាទិន្នកកាយជាដើម ទាំងនោះ ពាក្យថា **“ទ្វារនៃកាយកម្ម”** មិនបានជាឈ្មោះនៃឧបាទិន្នកកាយទេ, មិនបានជាឈ្មោះនៃកាយក្រៅនេះទេ ។ តែក្នុងរូប ៨ មានចិត្តជាសមុដ្ឋាន មានវិញ្ញត្តិរូបមួយ, រូបនេះ ឈ្មោះថា **ទ្វារនៃកាយកម្ម**, តាមដែលពោលទុកថា “រូបដែលឈ្មោះថា **កាយវិញ្ញត្តិ** នោះតើដូចម្តេច? ដែលព្រះមានជោគទ្រង់ត្រាស់ហើយ ព្រោះបំណងយករូបណា ការតឹងរឹង គឺតឹងរឹងដោយល្អ កិរិយាដែលតឹងរឹងដោយល្អ ការកម្រើកកាយឱ្យដឹងសេចក្តីការដែលសម្តែងឱ្យដឹងសេចក្តី ភាវៈដែលអ្នកដទៃដឹងសេចក្តីរបស់កាយនៃអ្នកមានចិត្តជាកុសល ឬអ្នកមានចិត្តជាអកុសល ឬអ្នកមានចិត្តជាអព្យាកតៈ ឬអ្នកឈានទៅខាងមុខ ឬថយក្រោយ ឬក្រឡេកមើលខាងមុខ ឬក្រឡេកមើលទិសផ្សេងៗ ឬថាបត់ដៃជើង ឬក៏ថាលាតដៃជើងណា, រូបនេះនុ៎ះឯង ហៅថា **កាយវិញ្ញត្តិ** ”[៣] ។

---

[៣] អភិ. ។

ពិតណាស់ ចិត្តដែលកើតឡើងថា "អញនឹងឈានទៅមុខ នឹងថយក្រោយ" រមែងញ៉ាំងរូបឱ្យតាំងឡើង, ក្នុងខណៈដែលចិត្តកើតឡើងនោះ វាយោធាតុ មានចិត្តជាសមុដ្ឋាន ក្នុងខាងក្នុងនៃរូបកលាបៈទាំង ៨ នេះគឺ បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ, វណ្ណៈ, គន្ធៈ, រសៈ និងឱជៈដែលអាស្រ័យធាតុទាំង ៤ នោះ, វាយោធាតុនោះ រមែងផ្គប់ផ្គល់ គឺទ្រទ្រង់ទុក ញ៉ាំងរូបកាយដែលកើតព្រមនឹងខ្លួននោះឱ្យកម្រើក ឱ្យឈានទៅមុខ ឱ្យថយក្រោយ ។

ក្នុងរូបកលាបៈ ៨ នេះ វាយោធាតុដែលតាំងឡើងដោយចិត្តដួង ដំបូងក្នុងបណ្តាជវនចិត្ត ៧ ដួង ក្នុងអាវជ្ជនវីថិមួយរមែងអាចផ្គប់ផ្គល់តាំងទុកនូវរូបកាយដែលកើតព្រមនឹងខ្លួនបាន, តែមិនអាចដើម្បីឱ្យកម្រើកទៅវិញទៅមក; សូម្បីក្នុងជវនចិត្តដួងទី ២ ជាដើម ក៏ន័យនេះដែរ ។ ចំណែកវាយោធាតុ ដែលតាំងឡើងដោយជវនចិត្តដួងទី ៧ បានវាយោធាតុដែលតាំងឡើងដោយជវនចិត្ត ៦ ខាងដើម ជាបច្ច័យឧបត្ថម្ភហើយ រមែងអាចដើម្បីផ្គប់ផ្គល់ ដើម្បីទ្រទ្រង់ទុក ដើម្បីញ៉ាំងរូបដែលកើតព្រមនឹងខ្លួនឱ្យកម្រើក ឱ្យឈានទៅមុខ ឱ្យថយក្រោយ ឱ្យក្រឡេកមើលទៅមុខ ឱ្យក្រឡេកមើលទិសផ្សេងៗ ឱ្យបត់ចូល ឱ្យលាចេញ, ព្រោះហេតុនោះ ទើបឈ្មោះថា កើតការដើរទៅ, កើតការដើរមក ឈ្មោះថាកើតការដើរទៅ និងកើតការដើរមក, គឺរមែងដល់ពាក្យដែលបុគ្គលគប្បីពោល

ថា “ទៅបាន ១ យោជន៍, ទៅបាន ១០ យោជន៍” ។

ដូចយ៉ាងថា កាលរទេះដែលគោគប្បីអូសទៅដោយនឹម ៧ នឹម គោដែលទឹមហើយក្នុងនឹមគូដំបូង រមែងអាចដើម្បីផ្ចប់ផ្ចល់ ដើម្បីទ្រទ្រង់នឹមទុកបានមុន, តែមិនអាចឱ្យកង់វិលទៅបាន; សូម្បីគូទី ២ ជាដើម ក៏ដូចគ្នា, តែថា ក្នុងកាលណា សារថីអ្នកឆ្លាតទឹមគូគោទី ៧ ហើយអង្គុយលើខ្នង់រទេះ កាន់ខ្សែយកចុងជន្លួញចាក់គួចគោចាប់ដើមពីគូគោដំបូងទាំងអស់, ក្នុងកាលនោះ គូគោទាំងអស់ដែលទឹម ក៏រួមកម្លាំងគ្នាទ្រទ្រង់នឹម នឹងឱ្យកង់វិលទៅបាន រមែងដល់ពាក្យដែលបុគ្គលគប្បីនិយាយបានថា “គោអូសរទេះទៅបាន ១០ យោជន៍, អូសទៅបាន ២០ យោជន៍” យ៉ាងណា, ពាក្យឧបមាជាគ្រឿង ញុំាងឧបមេយ្យឱ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះ ។

បណ្ដាកាយទាំង ៤ នោះ មានឧបាទិន្នកកាយជាដើម កាយដែលមានចិត្តជាសមុដ្ឋានឯណា, កាយដែលមិនមានចិត្តជាសមុដ្ឋានទុំះ មិនមែនវិញ្ញត្តិទេ; តែវិការនៃអាការមួយដែលអាចដើម្បីជាបច្ច័យ ដើម្បីឱ្យផ្ចប់ផ្ចល់ ទ្រទ្រង់ទុកនូវរូបកាយ ដែលកើតព្រមជាមួយវាយោធាតុ ដែលមានចិត្តជាសមុដ្ឋាន ឱ្យកម្រើកបាន, នេះឈ្មោះថា **វិញ្ញត្តិ** ។ វិញ្ញត្តិនោះ មិនមែនមានចិត្តជាសមុដ្ឋានដូចរូប ៨ យ៉ាងទេ ។ ដូចយ៉ាង មានពាក្យជាអាទិ៍ថា “ម្នាលភិក្ខុទាំងឡាយ ជរា

និងមរណៈ ឈ្មោះថា **មិនទៀង** ជាសង្ខតៈ” ព្រោះការដែលធម៌ទាំងឡាយមានប្រភេទ ដែលមិនទៀងជាដើម ត្រូវចាស់ និងស្លាប់ យ៉ាងណា, សូម្បីវិញ្ញត្តិនោះ ឈ្មោះថា មាន**ចិត្តជាសមុដ្ឋាន** ព្រោះការដែលរូបទាំងឡាយ មានចិត្តជាសមុដ្ឋាន ជាសភាពប្រកាសឱ្យដឹងយ៉ាងនោះដែរ ។

ក៏វិញ្ញត្តិនោះ ហៅថា **វិញ្ញត្តិ** ព្រោះប្រកាសឱ្យដឹង ។ ប្រកាសឱ្យដឹងអ្វី?, ប្រកាសឱ្យដឹងផ្លូវ (ហេតុ, កិរិយា) នៃកាយម្យ៉ាង; ពិតណាស់ បុគ្គលឈរនៅក្នុងគន្លងនៃចក្ខុ រមែងលើកដៃ ឬជើង, អង្រួនក្បាល ឬញាក់ចិញ្ចើម; អាការនៃដៃជាដើមនេះ ជាការឱ្យដឹងបានដោយចក្ខុ, សូម្បីវិញ្ញត្តិ ក៏មិនដឹងបានដោយភ្នែក, តែដឹងបានដោយចិត្តប៉ុណ្ណោះ; ព្រោះថា បុគ្គលឃើញពណ៌ជាអារម្មណ៍ប្រព្រឹត្តទៅផ្សេងៗ ដោយអំណាចនៃការកម្រើកដៃជាដើម, តែថា បុគ្គលគិតដល់រូបដែលប្រកាសឱ្យដឹង ដោយចិត្តផ្លូវមនោទ្វារហើយទើបដឹងថា “បុគ្គលនេះប្រហែលឱ្យអញធ្វើវត្ថុនេះ និងវត្ថុនេះ”។

ដូចយ៉ាងថា ពួកមនុស្សឱ្យចងស្លឹកត្នោតជាដើមលើចុងដើមឈើក្នុងស្ថានទីដែលមានទឹកក្នុងរដូវប្រាំងក្នុងព្រៃ ដោយបំណងថា “ជនទាំងឡាយនឹងដឹងនូវការដែលទឹកមានក្នុងទីនេះ ដោយសញ្ញានេះ” , ឬបង្ហូតទង់ឡើងលើទ្វាររោងស្រា, ឬខ្យល់បក់ដើមឈើខ្ពស់ឱ្យញ័រ, ឬកាលត្រីហែលនៅក្នុងទឹក ពពុះទឹក

ក៏ប៉ោងឡើងខាងលើ, ឬកំទេចស្មៅ និងស្លឹកឈើដែលត្រូវទឹកបន្សាត់ទៅជាប់នៅនឹងផ្លូវទៅរបស់មេទឹកធំ; ក្នុងកាលនោះ បុគ្គលឃើញស្លឹកត្នោត ទង់មែកឈើ ពពុះទឹក កម្ទេចស្មៅ និងស្លឹកឈើ សូម្បីមិនឃើញដោយភ្នែក តែរមែងដឹងដោយមនោវិញ្ញាណថា "ទីនេះ ទឹកនឹងមាន, ស្រានឹងមាន, ដើមឈើនេះត្រូវខ្យល់បក់, ត្រីនឹងមានក្នុងទឹក, មេទឹក (ទឹកជំនន់) នឹងហូរជន់លិច ទីដែលមានប្រមាណប៉ុណ្ណេះ" យ៉ាងណា, សូម្បីវិញ្ញត្តិ ក៏យ៉ាងនោះដែរ មិនដឹងដោយភ្នែក, តែដឹងដោយចិត្ត; ព្រោះថា បុគ្គលរមែងឃើញពណ៌ជាអារម្មណ៍កម្រើកទៅមកដោយអំណាចវិការៈនៃដៃជាដើម ដោយភ្នែកប៉ុណ្ណោះ, តែគេគិតនូវវិញ្ញត្តិដោយចិត្តផ្លូវមនោទ្វារ ទើបដឹងថា "បុគ្គលនេះ ប្រហែលជាឱ្យអញធ្វើយ៉ាងនេះៗ" ។

ក៏វិញ្ញត្តិនេះ ឈ្មោះថា **វិញ្ញត្តិ** ព្រោះការប្រកាសឱ្យដឹងតែម្យ៉ាង ក៏មិនមែន, តែឈ្មោះថា **វិញ្ញត្តិ** ព្រោះអ្នកដទៃគប្បីដឹងបាន; ព្រោះថា វិញ្ញត្តិនេះរមែងប្រាកដដល់ពួកជនដទៃ ដោយហោចទៅ សូម្បីសត្វតិរច្ឆានខ្លះ ។ ពិតណាស់ សត្វតិរច្ឆានទាំងឡាយមានសុនខ ឆ្កែចចក ក្អែក និងគោជាដើម ដែលប្រជុំគ្នាក្នុងទីនោះៗ កាលបុគ្គលចាប់ដំបង ឬដុំដី សម្ដែងអាការប្រហារ ក៏ដឹងបានថា "អ្នកនេះ ត្រូវការប្រហារពួកយើង" រមែងរត់ទៅទីណាមួយ; តែកាលបុគ្គលដទៃនៅខាងក្នុងកំពែង និងជញ្ជាំងផ្ទះជាដើម វេលានោះ ក៏ជាវេលា

ដែលរូបមិនប្រាកដ, ក្នុងខណៈនោះ រូបមិនប្រាកដដល់គេ ក៏ពិតមែនហើយ; ក៏ប៉ុន្តែថា ឈ្មោះថា វិញ្ញត្តិនោះឯង ព្រោះជាធម្មជាតិ ប្រាកដដល់អ្នកនៅចំពោះមុខ ។

**សួរថា** កាយកាលដែលមានចិត្តជាសមុដ្ឋានកំពុងកម្រើក,ចុះកាយដែលមានសមុដ្ឋាន ៣ កម្រើក ឬក៏មិនកម្រើក?

**ឆ្លើយថា** សូម្បីកាយមានសមុដ្ឋាន ៣ នោះ ក៏កម្រើកដូចគ្នាដែរ ។

កាយដែលមានសមុដ្ឋាន ៣ នោះ មានគតិដូចកាយដែលមានចិត្តជាសមុដ្ឋាន គឺស្របតាមកាយដែលមានចិត្តជាសមុដ្ឋានដោយពិត ។ ដូចយ៉ាងថា កាលទឹកកំពុងហូរទៅ សូម្បីកម្ទេចឈើស្ងួត ស្មៅស្ងួត ស្លឹកឈើស្ងួតជាដើម ដែលធ្លាក់ទៅក្នុងទឹក ក៏រមែងហូរទៅតាមទឹក មានគតិដូចទឹកតែម្តង, គឺកាលទឹកហូរទៅ កម្ទេចឈើស្ងួតជាដើម ក៏រមែងហូរទៅ, កាលទឹកឈប់ កម្ទេចឈើស្ងួតជាដើមនោះក៏ឈប់ យ៉ាងណា; ពាក្យឧបមាជាគ្រឿងញុំាងឧបមេយ្យឱ្យដល់ព្រមនេះបណ្ឌិតគប្បីជ្រាបយ៉ាងនោះ; វិញ្ញត្តិក្នុងរូបទាំងឡាយ ដែលមានចិត្តជាស-មុដ្ឋាននេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **ទ្វារនៃកាយកម្ម** ដោយប្រការដូច្នេះ។ ក៏ចេតនាណា ដែលនាំឱ្យសម្រេចក្នុងទ្វារនោះ ជាហេតុឱ្យបុគ្គល**សម្លាប់សត្វ,** កាន់យកវត្ថុដែលគេមិនបានឱ្យ, ប្រព្រឹត្តមិច្ឆាចារ, វៀរចាកបាណាតិបាតជាដើម;

ចេតនានេះ ឈ្មោះថា **កាយកម្ម** ។ កាលបរវាទីមានយ៉ាងនេះ បណ្ឌិតក៏គប្បីស្ថិតនៅដោយន័យនៃពាក្យថា “**កាយជាទ្វារ**, ចេតនាដែលសម្រេចក្នុងទ្វារនោះជាកាយកម្ម គឺជាកុសល ឬជាអកុសល” ។ តែបើបរវាទីមិនមាន ក៏គប្បីតាំងតិកៈថា “កាយកម្មជាកុសល ឬអកុសល ឬអព្យាកតៈ” ឱ្យបរិបូរណ៍; ក្នុងខនោះ ប្រៀបដូចជាទ្វារនគរ រមែងតាំងទុកក្នុងទីដែលគេសាងទុកហើយ, រមែងមិនខិតទៅខិតមក សូម្បីត្រឹមតែមួយធ្នាប់, ក៏មហាជនរមែងសញ្ចរទៅផ្លូវទ្វារនោះៗ យ៉ាងណា, ទ្វារក៏យ៉ាងនោះដែរ មិនត្រាច់ទៅបានក្នុងទ្វារទេ, ចំណែកកម្មរមែងត្រាច់ទៅដោយការកើតឡើងក្នុងទ្វារនោះៗ; ដោយហេតុនោះ ទើបព្រះបោរាណាចារ្យទាំងឡាយពោលទុកថា ៖-

**“ទ្វារេ ចរន្តិ កម្មានិ ន ទ្វារា ទ្វារចារិនោ**
**តស្មា ទ្វារេហិ កម្មានិ អញ្ញមញ្ញំ វវដ្ឋិតា ។**

**កម្មទាំងឡាយរមែងត្រាច់ទៅក្នុងទ្វារ ទ្វារទាំងឡាយមិនត្រាច់ទៅក្នុងទ្វារទាំងឡាយទេ ព្រោះហេតុនោះ ទើបលោកកំណត់កម្មទាំងឡាយជាមួយនឹងទ្វារទាំងឡាយទៅវិញ ទៅមក” ។**

ក៏គាថានោះ អធិប្បាយថា ទ្វាររមែងបានឈ្មោះតាមកម្ម, សូម្បីកម្ម ក៏បានឈ្មោះតាមទ្វារ ។ ដូចយ៉ាងថា ទីជាទីកើតឡើងនៃវិញ្ញាណជាដើម បាន

ឈ្មោះថា **ទ្វារនៃវិញ្ញាណ**, **ទ្វារនៃសម្ផស្ស**, **ទ្វារនៃការមិនសង្រួម**, **ទ្វារនៃការសង្រួម** ដូច្នេះយ៉ាងណា, ទីជាទីកើតឡើងនៃកាយកម្ម ក៏បានឈ្មោះថា **ទ្វារនៃកាយកម្ម** យ៉ាងនោះដែរ ។ សូម្បីក្នុងទ្វារនៃវចីកម្ម និងមនោកម្ម ក៏ន័យនេះដែរ ។

ម្យ៉ាងទៀត ទេវតាដែលអាស្រ័យនៅលើដើមឈើនោះៗ បានឈ្មោះតាមដើមឈើនោះៗ ថា ទេវតាដើមរកា (**សិម្ពលីទេវតា**), ទេវតាដើមចារ (**បលាសទេវតា**), ទេវតាដើមស្ដៅ (**បុចិមន្ទទេវតា**), ទេវតាដើមពង្រ (**ផន្ទនទេវតា**) យ៉ាងណា, សូម្បីកម្មដែលបុគ្គលធ្វើហើយដោយកាយទ្វារបានឈ្មោះតាមទ្វារថា **កាយកម្ម** យ៉ាងនោះដូចគ្នា ។ សូម្បីក្នុងវចីកម្ម និងមនោកម្មក៏ន័យនេះដែរ ។ បណ្ដាកាយ និងកម្ម កាយក៏ជាម្យ៉ាង, កម្មក៏ជាម្យ៉ាង, តែលោកហៅកាយ និងកម្មនោះថា **កាយកម្ម** ព្រោះការដែលកម្មនោះធ្វើដោយកាយ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយទើបពោលថា ៖-

**“បើកម្មធ្វើដោយកាយ ហៅថាកាយកម្ម, កាយ និងកាយកម្ម លោកក៏កំណត់ទុកទៅវិញទៅមក ។ បើកម្មធ្វើដោយម្ឆុល ហៅថា សុចិកម្ម, ម្ឆុល និងសុចិកម្ម លោកក៏កំណត់ទុកទៅវិញទៅមក ។ បើកម្មធ្វើដោយកាំបិត ហៅថា វាសិកម្ម កាំបិត និងវាសិកម្ម លោកក៏កំណត់ទុក**

**ទៅវិញទៅមក ។ បើកម្មធ្វើដោយបុរសហៅថា បុរិសកម្ម បុរស និង បុរិសកម្ម លោកក៏កំណត់ទុកទៅវិញទៅមក យ៉ាងណា; បើកម្មធ្វើដោយ កាយកម្ម ហៅថាកាយកម្ម ។ កាយ និងកាយកម្ម លោកក៏កំណត់ទុក ទៅវិញទៅមកយ៉ាងនោះដែរ”។**

កាលបើហេតុយ៉ាងនោះ ការកំណត់ចំពោះទ្វារ ក៏មិនត្រឹមត្រូវ, ការ កំណត់ចំពោះកម្មក៏មិនត្រឹមត្រូវ; **សួរថា** មិនត្រឹមត្រូវដូចម្ដេច? **ឆ្លើយថា** ព្រោះ បាលីថា **“ទ្វារេ ចរន្តិ កម្មានិ** = កម្មទាំងឡាយត្រាច់ទៅក្នុងទ្វារ” សូម្បី វចីកម្ម ក៏ប្រព្រឹត្តទៅក្នុងកាយវិញ្ញត្តិ, ព្រោះហេតុនោះ ការកំណត់វចីវិញ្ញត្តិនោះ ថា ទ្វារនៃកាយកម្មដូចនេះ ក៏មិនត្រូវ; ទាំងកាយកម្ម ក៏ប្រព្រឹត្តទៅ សូម្បីក្នុង វចីវិញ្ញត្តិ, ព្រោះហេតុនោះ ការកំណត់វចីវិញ្ញត្តិនោះថា កាយកម្មក៏មិនត្រឹមត្រូវ ឡើយ ។ ការកំណត់យ៉ាងនោះ មិនមែនមិនត្រឹមត្រូវទេ, ព្រោះហេតុអ្វី? ព្រោះ ការប្រព្រឹត្តទៅដោយច្រើន និងព្រោះការប្រព្រឹត្តទៅ ដោយច្រើនក្នុងទ្វារនោះ ។ ពិតណាស់ កាយកម្មប៉ុណ្ណោះ ប្រព្រឹត្តិទៅដោយច្រើនក្នុងកាយវិញ្ញត្តិ, វចីកម្មមិន ប្រព្រឹត្តទៅដោយច្រើនទេ; ព្រោះហេតុដូច្នោះ កាលដែលកាយវិញ្ញត្តិនេះ ជាទ្វារ នៃកាយកម្មសម្រេចហើយ ប្រព្រឹត្តទៅដោយច្រើននៃកាយកម្ម, ប្រៀបដូច ស្រុកព្រាហ្មណ៍ ចំការស្វាយ និងព្រៃខ្ទឹងជាដើម ឈ្មោះថា **ព្រាហ្មណគ្រាម**

ជាដើម ព្រោះហេតុនោះ ការកំណត់ទ្វារទើបត្រឹមត្រូវ; ក៏កាយកម្មប្រព្រឹត្តទៅច្រើនក្នុងកាយទ្វារប៉ុណ្ណោះ, ចំណែកក្នុងវចីទ្វារប្រព្រឹត្តិទៅតិច ព្រោះហេតុដូច្នោះ ការដែលទ្វារនេះជាកាយកម្ម សម្រេចហើយប្រព្រឹត្តទៅដោយច្រើនក្នុងកាយទ្វារ, ប្រៀបដូចគោចររបស់នាយព្រានព្រៃ និងថូលកុមារិកា (កុមារីធាត់) ជាដើម ឈ្មោះថា **ព្រានព្រៃ**ជាដើម ព្រោះហេតុដូច្នោះ សូម្បីការកំណត់កម្មទើបត្រឹមត្រូវ ដោយប្រការដូច្នេះ ៕

**ចប់កថាសម្តែងអំពីទ្វារនៃកាយកម្ម**

## សម្តែងអំពីទ្វារនៃវចីកម្ម

ក៏ក្នុងកថាពោលដោយទ្វារនៃវចីកម្ម ឈ្មោះថា **វាចា** មាន ៣ យ៉ាងគឺ ចេតនា, វិរតិ និងសទ្ទៈ (សំឡេង) ។ បណ្តាវាចាទាំង ៣ យ៉ាងនោះ វាចានេះថា "ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ នេះ ជាវាចាសុភាសិត, មិនមែនវាចាទុព្ភាសិតទេ, ជាវាចាមិនមានទោស ជាវាចាដែលវិញ្ញូជនមិនតិះដៀល" [៤] ហៅថា **ចេតនាវាចា** ។ វាចានេះថា "ការឈប់ ការវៀរវចីទុច្ចរិត

[៤] សំ. ស. ។

៤ ណា ។ល ។ នេះហៅថា **សម្មាវាចា**" [៥] ឈ្មោះថា **វិរតិវាចា** ។ វាចានេះថា "វាចាដែលបន្លឺ គន្លងនៃពាក្យ ការបន្លឺឡើង សំឡេងគឹកកង ធ្វើសំឡេងឱ្យគឹកកង វាចា ការថ្លែងវាចា" [៦] ដូច្នេះ ឈ្មោះថា **សទ្ទវាចា** ។

បណ្តាវាចាទាំង ៣ នោះ ពាក្យថា **"វចីកម្មទ្វារ"** មិនមែនជាឈ្មោះរបស់ចេតនា, មិនមែនជាឈ្មោះវិរតិ; តែថា វិញ្ញត្តិម្យ៉ាង ដែលមានសំឡេងរួមផង នេះឈ្មោះថា **ទ្វារនៃវចីកម្ម** ។ វចីទ្វារដែលព្រះមានព្រះភាគទ្រង់ប៉ងយកត្រាស់ទុកថា "រូបដែលមានវចីវិញ្ញត្តិនោះ តើដូចម្តេច? ការនិយាយ ការថ្លែងចេញ គន្លងនៃពាក្យ ការបន្លឺឡើង សំឡេងគឹកកង ការធ្វើឱ្យសំឡេង គឹកកងវាចា ការថ្លែងវាចានៃបុគ្គលអ្នកមានចិត្តជាកុសល ឬមានចិត្តជាអកុសល ឬក៏មានចិត្តជាអព្យាក្រិតណា, នេះហៅថា **វាចា** ។ វិញ្ញត្តិ ការសម្តែងឱ្យដឹង សេចក្តីកិរិយាសម្តែងឱ្យដឹងសេចក្តីវាចានោះណា, រូបនេះ ហៅថា **វចីវិញ្ញត្តិ**" [៧] ។ ពិតមែន កាលតថាគតត្រិះរិះថា "អញនឹងពោលពាក្យនេះ, អញនឹងពោលពាក្យនោះ" ឈ្មោះថា សំឡេងដែលផ្សាយទៅដោយវិតក្កៈ រមែងកើតឡើង ។

---

[៥] អភិ. ។

[៦] អភិ. ។

[៧] អភិ. ។

វាទៈនេះមកហើយ ក្នុង**មហាអដ្ឋកថាដូច្នេះ**ថា “សំឡេងនេះ មិនបានដឹងដោយសោតៈ, ដឹងបានដោយចិត្ត” ; តែក្នុងអដ្ឋកថាដែលមានមកទាំងឡាយអធិប្បាយពាក្យថា “**វិតក្កវិប្ផារសទ្ទំ** = សំឡេងដែលផ្សាយទៅដោយវិតក្កៈ” ជាសំឡេងរបស់មនុស្ស ដេកលក់ និងប្រមាទហើយជាដើម កំពុងរវើរវាយកើតឡើងដោយអំណាចនៃ ការផ្សាយទៅរបស់វិតក្កៈ ។ ពាក្យថា “**សុត្វា**” សេចក្ដីថា កាលមនុស្សនោះស្ដាប់ហើយ ត្រិះរិះនូវរឿងណា សំឡេងដែលផ្សាយទៅនៃវិតក្កៈនោះ កើតឡើងហើយ, ដោយអំណាចនៃរឿងនោះ ក៏សន្និដ្ឋានបានថា “ចិត្តរបស់អ្នកជាយ៉ាងនេះខ្លះ, ចិត្តរបស់អ្នកជាយ៉ាងនោះខ្លះ” លុះពោលដោយប្រការដូច្នោះហើយ ក៏ពោលរឿងទាំងឡាយ ។ សូម្បីក្នុងបដ្ឋាន ក៏មានព្រះបាលីមកហើយថា “**សទ្ទាយតនៈ** មានចិត្តជាសមុដ្ឋាន ជាបច្ច័យដល់សោតវិញ្ញាណ ដោយអារម្មណប្បច្ច័យ” ។ ព្រោះហេតុដូច្នោះ ឈ្មោះថា សំឡេងដែលផ្សាយទៅនៃវិតក្កៈ មិនដឹងបានដោយសោតៈដែលកើតឡើង វៀរចាកការប៉ះខ្ទប់នឹងវិញ្ញត្តិ រមែងមិនមាន ។ ក៏ចិត្តកាលកើតឡើងថា “អញនឹងពោលពាក្យនេះ, អញនឹងពោលពាក្យនោះ” រមែងញុំាងរូប ៨ ឱ្យកើតឡើង គឺ **បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ, វណ្ណៈ, គន្ធៈ, រសៈ និងឱជៈ** ។ បឋវីធាតុ ដែលមានចិត្តជាសមុដ្ឋានក្នុងខាងក្នុងនៃរូប ៨ នោះ

ប៉ះខ្ទប់ ឧបាទិន្នករូបមុនហើយ ទើបកើតឡើង, សំឡេងរមែងកើតឡើងដោយការប៉ះខ្ទប់នឹងបឋវីធាតុនោះ នេះឈ្មោះថា សំឡេងដែលមានចិត្តជាសមុដ្ឋាន, នេះមិនមែនវិញ្ញត្តិទេ; តែថា វិការនៃអាការម្យ៉ាងដែលជាបច្ច័យដល់ការប៉ះខ្ទប់នឹងឧបាទិន្នក កាយរបស់បឋវីធាតុដែលមានចិត្តជាសមុដ្ឋាននោះ, នេះឈ្មោះថា **វចីវិញ្ញត្តិ**; ក្រៅអំពីនេះ ពាក្យទាំងពួងមានជាអាទិ៍ថា “**សា អដ្ឋ រូបានិ វិយ ន ចិត្តសមុដ្ឋានា** = វចីវិញ្ញត្តិនោះ មិនមានចិត្តជាសមុដ្ឋាន ដូចរូបទាំង ៨ទេ” បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងខាងក្រោយនោះឯង ។

ពិតណាស់ ក្នុងទីនេះ បុគ្គលឮសំឡេងរបស់អ្នកហៅថា “**តិស្ស ទត្ត មិត្ត**” ហើយក៏គិតដល់វិញ្ញត្តិ ដោយមនោទ្វារ ចិត្តរមែងដឹងថា “អ្នកនេះទំនងឱ្យអញធ្វើវត្ថុនេះ និងវត្ថុនោះ” ។ សូម្បីវចីវិញ្ញត្តិនេះ ក៏រមែងប្រាកដដល់សត្វតិរច្ឆាន ដូចកាយវិញ្ញត្តិដែរ ។ ពិតណាស់ សូម្បីសត្វតិរច្ឆានទាំងឡាយ ស្តាប់សំឡេងថា “ឯងចូរមក, ចូរទៅ” ក៏ដឹងថា “បុគ្គលនេះ ប្រហែលប្រើឱ្យអញធ្វើវត្ថុនេះ” ទើបដើរមក និងដើរទៅ ។

ក៏វារៈនេះថា “សំឡេងរមែងញុំាងកាយដែលមានសមុដ្ឋាន ៣ យ៉ាងឱ្យកម្រើក ឬមិនឱ្យកម្រើក” មិនមានក្នុងវចីវិញ្ញត្តិនេះ, សូម្បីកិច្ច គឺការឧបត្ថម្ភ

នៃសំឡេងដែលមានចិត្តជាសមុដ្ឋានដូងមុន ក៏មិនមាន; តែថា ចេតនាណា ដែលឱ្យសម្រេច សូម្បីក្នុងវចីទ្វារនោះ, ចេតនាដែលជាហេតុ និយាយកុហក, និយាយស៊កសៀត, ពោលពាក្យអាក្រក់, ពោលពាក្យឡេះឡោះ និងចេតនា វៀរចាកមុសាវាទជាដើមណា; ចេតនានេះ ឈ្មោះថា **វចីកម្ម** ។ ខាងមុខពីនេះ បណ្ឌិតគប្បីជ្រាបការកំណត់កម្ម ការកំណត់ទ្វារទាំងអស់ ដោយន័យដែល ពោលទុកក្នុងខាងក្រោយនោះឯង ៕

ចប់កថាពោលដោយទ្វារនៃវចីកម្ម

## កថាសម្តែងអំពីទ្វារនៃមនោកម្ម

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងកថាពោលដោយទ្វារនៃមនោកម្មតទៅ ៖-

ចិត្ត ៤ យ៉ាង ដោយអំណាចនៃចិត្តដែលជាកាមាវចរចិត្តជាដើម ឈ្មោះ ថា **មនោ** (ចិត្ត) ។ ក្នុងមនោកម្ម ដែលជាកាមាវចរជាដើមនោះ មនោទាំង អស់មាន ៨៩ ដួង ចិត្តដែលជាកាមាវចរ ៥៤ ដួង, ចិត្តដែលជារូបាវចរ ១៥ ដួង, ចិត្តដែលជាអរូបាវចរ ១២ ដួង និងចិត្តដែលជាលោកុត្តរ ៨ ដួង ។ ក្នុងចិត្ត ទាំងនោះ ធម្មតាមនោនេះ មិនគួរពោលថា មិនជាមនោទ្វារទេ ដូចយ៉ាងថា ធម្មតាចេតនានេះ មិនគួរពោលថា មិនជាកម្ម ដោយហោចទៅ សូម្បីចេតនា

ដែលសម្បយុត្តដោយបញ្ចវិញ្ញាណ (វិញ្ញាណ ៥) **ក្នុងមហាបករណ៍** ក៏ទ្រង់សម្ដែងទុកថា ជាកម្មនោះឯង យ៉ាងណា, ធម្មតាថា **មនោ** នេះ មិនគួរពោលថា មិនមែនជាមនោទ្វារ ក៏យ៉ាងនោះដែរ ។

ក្នុងអធិការដែលពោលដោយមនោទ្វារនេះ មានអ្នកតាំងពាក្យសួរថា ធម្មតាកម្មនេះ តើដូចម្ដេច? ឆ្លើយថា រមែងប្រមូលមក, រមែងតាក់តែង, រមែងរួបរួម, រមែងតាំងចិត្ត, រមែងត្រិះរិះ និងរមែងឱ្យសម្រេច ។ **សួរថា** បើហេតុយ៉ាងនេះមាន ចេតនាបញ្ចវិញ្ញាណ រមែងប្រមូលមក, តាក់តែង, រួបរួម, តាំងចិត្ត ត្រិះរិះ និងឱ្យសម្រេចនូវអ្វី? **ឆ្លើយថា** ប្រមូលមក, តាក់តែង, រួបរួម, តាំងចិត្ត, ត្រិះរិះ និងឱ្យសម្រេចនូវសហជាតធម៌ទាំងឡាយ ។ ពិតណាស់ សូម្បីចេតនាក្នុងបញ្ចវិញ្ញាណនោះ រមែងប្រមូលមក, តាក់តែង, រួបរួម, តាំងចិត្ត ត្រិះរិះ ឱ្យសម្រេចសម្បយុត្តក្ខន្ធ ដែលកើតព្រមគ្នា ។ ម្យ៉ាងទៀត មានប្រយោជន៍អ្វីដោយការពោលដល់ខនេះ, ព្រោះលោកបានពោលពាក្យ នេះទុកដោយអំណាចនៃការរួបរួមមនោ (ចិត្ត) ទុកទាំងអស់ ។ ក៏ក្នុងអធិការពោលដោយមនោទ្វារនេះ មានពាក្យសន្និដ្ឋានដូច្នេះ ៖-

ចិត្ត ២៩ ដួង ដោយអំណាចនៃកុសល និងអកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា ទ្វារនៃមនោកម្ម ។ តែចេតនាណា ដែលឱ្យសម្រេចក្នុងមនោ

ទ្វារនោះ, រមែងកាន់យកនូវអភិជ្ឈា, ព្យាបាទ, និងមិច្ឆាទស្សនៈ និងមិនមាន អភិជ្ឈា, មិនមានព្យាបាទ និងសម្មាទស្សនៈ ដោយចេតនាណា; នេះឈ្មោះថា **មនោកម្ម** ។ ខាងមុខពីនេះ បណ្ឌិតគប្បីជ្រាបការកំណត់កម្ម និងការកំណត់ ទ្វារទាំងអស់ ដោយន័យដែលពោលទុកក្នុងខាងក្រោយនេះឯង ៕

ចប់កថាពោលដោយទ្វារនៃមនោកម្ម

## កថាសម្តែងអំពីកម្ម ៣* យ៉ាង

ឈ្មោះថា ទ្វារនៃកម្ម ៣ នេះ ឥឡូវនេះ នឹងពោលពាក្យពិស្តារ ការ តាំងមាតិកាក្នុងកថា ពោលដោយទ្វារដែលសេសសល់ តាំងផ្តើមពីកម្ម ៣ តាម ដែលបានសម្តែងទ្វារនៃកម្មទាំងនេះហើយ វៀរកម្ម ៣ ទាំងនេះទុក ។ មែនពិត កម្ម ៣ គឺកាយកម្ម, វចីកម្ម និងមនោកម្ម ។ ***សួរថា*** ឈ្មោះថា **កម្ម**នេះ បាន ដល់អ្វីខ្លះ? **ឆ្លើយថា** បានដល់ចេតនា និងធម៌ដែលសម្បយុត្តដោយចេតនាពួក ខ្លះ ។ បណ្តាធម៌ទាំង ២ នោះ ការដែលចេតនាជាកម្ម មានព្រះសូត្រលោកពោល ទុកថា ៖-

**“ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចេតនាថាជាកម្ម, បុគ្គលគិត**

---

* កថានេះ ជាលំដាប់ដំបូងពីទានសម្តែងទុកទី ២ ។

**ហើយធ្វើកម្មដោយកាយ ដោយវាចា និងដោយចិត្ត”** [៨] ; (និងពាក្យថា) “ម្នាលអានន្ទ ពិតណាស់ កាលបើកាយមាន សុខ និងទុក្ខខាងក្នុង រមែងកើតឡើង ព្រោះកាយសញ្ចេតនាជាហេតុ (ព្រោះការគិតផ្លូវកាយជាហេតុ); ម្នាលអានន្ទ ឬកាលបើវាចាមាន សុខ និងទុក្ខខាងក្នុងរមែងកើតឡើង ព្រោះវចីសញ្ចេតនាជាហេតុ; ម្នាលអានន្ទ ឬថាកាលបើចិត្តមាន សុខ និងទុក្ខខាងក្នុងរមែងកើតឡើង ព្រោះមនោសញ្ចេតនាជាហេតុ” [៩] ; (និងពាក្យថា) “ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ៣ យ៉ាង ជាកាយកម្មខាងអកុសល មានទុក្ខជាកម្រៃ មានទុក្ខជាវិបាក, វចីសញ្ចេតនា ៤ យ៉ាង ជាវចីកម្មខាងអកុសល ។ល។ ម្នាលភិក្ខុទាំងឡាយ មនោសញ្ចេតនា ៣ យ៉ាង ជាមនោកម្មខាងកុសល មានសុខជាកម្រៃ មានសុខជាវិបាក” [១០] ; (និងពាក្យថា) “ម្នាលអានន្ទ បើមោឃបុរស ឈ្មោះថា **សមិទ្ធិនេះ** ត្រូវបាដលិបុត្តបរិព្វាជក សួរយ៉ាងនេះ គប្បីព្យាករយ៉ាងនេះថា ‘ម្នាលបាដលិបុត្ត លោកធ្វើកម្មជាប់ដោយសញ្ចេតនា រមែងសោយសុខ ជាប់ដោយសុខវេទនា ដោយកាយ ដោយវាចា និងដោយចិត្ត ។ល។

---

[៨] អំ. ឆក្ក. និព្វេធិកសុត្ត, អភិ. ។

[៩] សំ. និ. , អំ. ចតុក្ក. ។

[១០] អំ. ចតុក្ក. ។

លោករមែងសោយអទុក្ខមសុខ ជាប់ដោយអទុក្ខមសុខវេទនា’ ម្នាលអានន្ទ កាលសមិទ្ធិមោឃបុរសព្យាករយ៉ាងនេះ ឈ្មោះថា ព្យាករណ៍ដោយប្រពៃដល់បាដលិបុត្តបរិព្វាជក”[១០] ។ ការដែលចេតនាជាកម្មមានព្រះសូត្រប៉ុណ្ណេះសិន ។

ចំណែកការដែលសម្បយុត្តធម៌ដោយចេតនាជាកម្ម លោកសម្តែងទុកដោយកម្មចតុក្កៈ (ពួក ៤ នៃកម្ម) សមដូចដែលទ្រង់ត្រាស់ទុកថា ៖-

“ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ នេះ តថាគតធ្វើឱ្យជាក់ច្បាស់ដោយបញ្ញាជាគ្រឿងដឹងចំពោះដោយព្រះអង្គឯង ប្រកាសហើយ ។ កម្ម ៤ យ៉ាងតើដូចម្តេចខ្លះ? កម្ម ៤ យ៉ាងនោះ គឺកម្មខ្មៅមានវិបាកខ្មៅ ១, កម្មស មានវិបាកស ១, កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ១ និងកម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅមិនស ១ រមែងប្រព្រឹត្តទៅដើម្បីការអស់ទៅនៃកម្ម[១១] ។ ម្នាលភិក្ខុទាំងឡាយ ក៏កម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅ មិនស រមែងប្រព្រឹត្តទៅដើម្បីការអស់ទៅនៃកម្មតើដូម្តេច? ពោជ្ឈង្គ ៧ នេះណា គឺសតិសម្ពោជ្ឈង្គ ។ល។ ឧបេក្ខាសម្ពោជ្ឈង្គ, នេះតថាគតហៅថា កម្មមិនខ្មៅមិនស

[១០] អំ. ចតុក្ក. ។

[១១] អំ. ចតុក្ក. ។

មានវិបាកមិនខ្មៅមិនស រមែងប្រព្រឹត្តទៅដើម្បីការអស់ទៅនៃកម្ម [១២] ។ ម្នាលភិក្ខុទាំងឡាយ ក៏កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅ មិនស រមែងប្រព្រឹត្តទៅដើម្បីការអស់ទៅនៃកម្មតើដូចម្ដេច? ម្នាលភិក្ខុទាំង ឡាយអរិយមគ្គមានអង្គ ៨ នេះឯង តើដូចម្ដេច? គឺសម្មាទិដ្ឋិ ។ ល ។ សម្មាសមាធិ, នេះតថាគតហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស រមែងប្រព្រឹត្តទៅដើម្បីការអស់ទៅនៃកម្ម” [១៣] ។ ធម៌ ១៥ យ៉ាង ផ្សេងដោយពោជ្ឈង្គ និងអង្គមគ្គទាំងនេះ ទ្រង់សម្ដែងទុកដោយកម្មចតុក្កៈ មានប្រការដូច្នេះ ។

ក៏គប្បីជ្រាបធម៌ដែលសម្បយុត្តដោយចេតនា ២១ យ៉ាង និងធម៌ ៦ ប្រការនេះ គឺអភិជ្ឈា, ព្យាបាទ, មិច្ឆាទិដ្ឋិ, អនភិជ្ឈា, អព្យាបាទ និងសម្មាទិដ្ឋិ ។

បណ្ដាធម៌ទាំងឡាយនេះ លោកុត្តរមគ្គកាលនឹងរួមជាពួក ក៏រមែងរួមកម្ម ៣ យ៉ាង មានកាយកម្មជាដើម ។ ពិតណាស់ បុគ្គលប្រព្រឹត្តទ្រុស្តសីលដោយកាយណា, ការសង្រួមចាកការប្រព្រឹត្តទ្រុស្តសីលដោយកាយនោះ គប្បីជ្រាបថា កាយិក; បុគ្គលប្រព្រឹត្តទ្រុស្តសីលដោយវាចាណា, ការសង្រួមចាកការប្រព្រឹត្តិកន្លងការទ្រុស្តសីលផ្លូវវាចានុ៎ះ គប្បីជ្រាបថា ជាវាចសិក; សម្មាកម្មន្តជាកាយ

---

[១២] ម. អ., អភិ. ។

[១៣] អំ. ចតុក្ក. ។

កម្ម, សម្មាវាចាជាវចីកម្ម; កាលបើកាន់យកកម្មទាំង ២ ពួកនេះ សម្មាអាជីវៈ រមែងឈ្មោះថា កាន់យកហើយ ព្រោះជាពួកនៃកម្មទាំង ២ នោះតែម្ដង; ចំណែកបុគ្គលប្រព្រឹត្តទ្រុស្តសីលដោយចិត្តណា, ការសង្រួមចាកគន្លង ការទ្រុស្តសីលផ្លូវចិត្តនោះ គប្បីជ្រាបថាជាមានសិក; មានសិក (ការសង្រួមផ្លូវចិត្ត) នោះមាន ៥ យ៉ាង ដោយអំណាចនៃទិដ្ឋិ សង្កប្បៈ វាយាម សតិ និងសមាធិ, មានសិកទាំង ៥ យ៉ាងនេះ ឈ្មោះថា **មនោកម្ម** ។ លោកុត្តរមគ្គ ការរួមជាពួកក៏រមែងរួមកម្ម ៣ យ៉ាង ដោយប្រការដូច្នេះ ។

ក្នុងទីនេះ ឈ្មោះថា **ការប្រៀបធៀបនឹងទ្វារ**, ពិតណាស់ កម្មដែលដល់ការកម្រើកក្នុងកាយទ្វារ និងវចីទ្វារ តែមិនដល់កម្មបថក៏មាន, កម្មដែលដល់ការប្រាកដប្រព្រឹត្តទៅក្នុងមនោទ្វារ តែមិនដល់កម្មបថក៏មាន, ទើបលោកកាន់យកកម្មនោះៗ (ដែលមិនជាកម្មបថ) ធ្វើឱ្យជាពួករបស់ទ្វារនោះៗ តែម្យ៉ាង ។ ក្នុងរឿងនោះមានន័យដូច្នេះ ៖-

បុគ្គលណាគិតថា “អញនឹងទៅបរបាញ់សត្វ” ទើបរៀបចំធ្នូ, មូរខ្សែបន្លោះ, សំលៀងលំពែង, បរិភោគអាហារ រួចស្លៀកពាក់សម្លៀកបំពាក់; ដោយហេតុត្រឹមតែប៉ុណ្ណេះ កម្មក៏ដល់ការកម្រើកហើយក្នុងកាយទ្វារ ។ គេដើរទៅក្នុងព្រៃអស់ ១ ថ្ងៃ មិនបានអ្វីសោះ ដោយហោចទៅ សូម្បីទន្សាយ និងឆ្មា ។

**សួរថា** អកុសលនេះ ឈ្មោះថា ជាកាយកម្ម ឬមិនមែនជាកាយកម្ម? ឆ្លើយថា **មិនជាកាយកម្មទេ** ។ **សួរថា** ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះមិនមែនជាកម្មបថ, តែគប្បីជ្រាបថា អកុសលចិត្តនេះ ឈ្មោះថា **កាយទុច្ចរិត** តែម្យ៉ាង ។ សូម្បីក្នុងប្រយោគទាំងឡាយ មានការចាប់ត្រីជាដើម ក៏ន័យនេះដែរ ។ សូម្បីក្នុងវចីទ្វារ បុគ្គលបញ្ជាថា "អញនឹងទៅបរបាញ់សត្វ, អ្នកទាំងឡាយចូររៀបចំធ្នូទាំងឡាយ ដោយលឿនចុះ" កាលមិនបានអ្វីក្នុងព្រៃ ដោយន័យមុននោះឯងកម្មនោះ ក៏ដល់ការកម្រើកក្នុងវចីទ្វារ ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា ក៏មិនជាវចីកម្ម ព្រោះមិនទាន់ដល់កម្មបថ, តែគប្បីជ្រាបថា ឈ្មោះថាជាវចីទុច្ចរិតដោយពិត ។ ចំណែកក្នុងមនោទ្វារ កាលវធកចេតនាត្រឹមតែកើត ឡើងប៉ុណ្ណោះ ក៏ទម្លាយកម្មបថមែនពិត ។ **ក៏ប្រភេទនៃកម្មបថនោះ រមែងមានដោយអំណាចនៃការព្យាបាទ មិនមែនដោយអំណាចនៃបាណាតិបាតទេ**; ពិតមែនហើយ កាយកម្មដែលជាអកុសល រមែងតាំងឡើងក្នុងកាយទ្វារ និងវចីទ្វារ, មិនតាំងឡើងក្នុងមនោទ្វារ ។ វចីកម្មដែលជាអកុសល ក៏ដូចគ្នាដែរ ។ តែមនោកម្មដែលជាអកុសល ក៏រមែងតាំងឡើងក្នុងទ្វារទាំង ៣ ។ កាយកម្ម វចីកម្ម និងមនោកម្មដែលជាកុសល ក៏ដូចគ្នាដែរ ។

**សួរថា** តើដូចម្ដេច? ឆ្លើយថា កាលបុគ្គលសម្លាប់សត្វដោយដៃខ្លួនឯង

កាន់យកវត្ថុដែលគេមិនបានឱ្យ ហើយប្រព្រឹត្តមិច្ឆាចារ កម្មរមែងជាកាយកម្ម ប៉ុណ្ណោះ, សូម្បីទ្វារ ក៏ជាកាយកម្មដូចគ្នា; កាយកម្មដែលជាអកុសល រមែងតាំងឡើងក្នុងកាយទ្វារ យ៉ាងនេះសិន, ចំណែកអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ដែលកើតព្រមនឹងចិត្តទាំងនោះ ប្រព្រឹត្តទៅក្នុងខាងក្នុងចេតនាខ្លះ ជា**អព្វោហារិក** (ពោលអាងមិនបានថា មាន ឬមិនមាន) ខ្លះ ។

តែកាលបុគ្គលបញ្ជាថា “ឯងចូរទៅសម្លាប់អ្នកនេះ, ចូរលួចវត្ថុនេះ” កម្មជាកាយកម្ម, ឯទ្វារជាវចីទ្វារ; កាយកម្មដែលជាអកុសល រមែងតាំងឡើងក្នុងវចីទ្វារយ៉ាងនេះ, ចំណែកអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ដែលកើតព្រមនឹងចិត្តទាំងនោះ ប្រព្រឹត្តទៅជាចេតនាខ្លះ ជាអព្វោហារិកខ្លះ, ឈ្មោះថា ពាក្យអធិប្បាយដែលដូចគ្នារបស់អាចារ្យទាំង ៣ មានប្រមាណប៉ុណ្ណោះ ។

ចំណែកអាចារ្យវិតណ្ឌវាទីពោលថា “កាយកម្មជាអកុសលតាំងឡើងក្នុងមនោទ្វារក៏មាន” , អាចារ្យវិតណ្ឌវាទី ត្រូវអាចារ្យដទៃរំលឹកថា “អ្នកចូរនាំព្រះសូត្រដែលលើកឡើងក្នុងការរួបរួម (សង្គាយនា) ទាំង ៣ លើកមកមើល” ទើបនាំ**កុលុម្ពសូត្រ**នេះមកថា ៖-

“ម្នាលភិក្ខុទាំងឡាយ ខម្យ៉ាងទៀត សមណៈ ឬព្រាហ្មណ៍ខ្លះ ក្នុងលោកនេះ មានឫទ្ធិដល់ការជំនាញផ្លូវចិត្ត សម្លឹងឃើញសត្វអ្នកកើតក្នុងគភ៌របស់ស្ត្រី

ដទៃ ដោយចិត្តដ៏លាមកថា 'ឱហ្ន៎! សត្វក្នុងគភ៌នេះ កុំគប្បីប្រសូតិដោយសួស្តីឡើយ' ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ ការសម្លាប់សត្វក្នុងគភ៌ រមែងមានដោយអាការយ៉ាងនេះ" ។ អាចារ្យវិតណ្ឌវាទី លុះនាំសូត្រនេះមកហើយ ទើបពោលថា "ក៏ត្រឹមតែការគិតប៉ុណ្ណោះ សត្វកើតក្នុងគភ៌នៃស្ត្រីនោះ រមែងរលាយដូចជាដុំពពុះទឹក, ក្នុងការរលាយនៃគភ៌នេះ ការកម្រើកអង្គនៃកាយ ឬអង្គនៃវាចា នឹងមានពីទីណា, ក៏កាយកម្មដែលជាអកុសលនេះ រមែងតាំងឡើងក្នុងមនោទ្វារតែម្យ៉ាង"។

អាចារ្យទាំងឡាយ ពោលនឹងអាចារ្យវិតណ្ឌវាទីនោះថា "ពួកយើងនឹងពិចាណាសេចក្តីនៃព្រះសូត្ររបស់អ្នក" ហើយនាំគ្នាពិចារណាដោយន័យដែលលោកអាចារ្យវិតណ្ឌវាទីនិយាយហើយយ៉ាងនេះថា លោកពោលដល់ការសម្លាប់សត្វដទៃដោយឫទ្ធិ, ក៏ធម្មតាថា ឫទ្ធិនោះមាន ១០ យ៉ាង * គឺអធិដ្ឋានឫទ្ធិ, វិកុព្វនឫទ្ធិ, មនោមយឫទ្ធិ, ញាណវិប្ផារឫទ្ធិ, សមាធិវិប្ផារឫទ្ធិ, អរិយឫទ្ធិ,

* **អធិដ្ឋានឫទ្ធិ** = សម្រេចដោយការអធិដ្ឋាន, **វិកុព្វនឫទ្ធិ** = សម្រេចដោយការធ្វើនិមិត្តផ្សេងៗ, **មនោមយឫទ្ធិ** = ឫទ្ធិសម្រេចអំពីចិត្ត, **ញាណវិប្ផារឫទ្ធិ** = ឫទ្ធិសម្រេចដោយការផ្សាយទៅនៃញាណ, **សមាធិវិប្ផារឫទ្ធិ** = ឫទ្ធិសម្រេចដោយការផ្សាយទៅនៃសមាធិ, **អរិយឫទ្ធិ** = ឫទ្ធិរបស់ព្រះអរិយៈ, **កម្មវិបាកជឫទ្ធិ** = ឫទ្ធិកើតពីកម្មវិបាក, **បុញ្ញវតោឫទ្ធិ** = ឫទ្ធិរបស់អ្នកមានបុណ្យ **វិជ្ជាមយឫទ្ធិ** =

កម្មវិបាកជឫទ្ធិ, បុញ្ញវតោវិប្ផារឫទ្ធិ, វិជ្ជាមយឫទ្ធិ និងភាវនាមយឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះការប្រកបដោយប្រពៃក្នុងគុណនោះៗ ជាបច្ច័យ ។ បណ្តាឫទ្ធិទាំងនោះលោកពោលដោយឫទ្ធិយ៉ាងណា? លោកវិតណ្ឌវាទីឆ្លើយថា ភាវនាមយឫទ្ធិ ។ សួរថា កម្មគឺការសម្លាប់សត្វដទៃ មានបានដោយ ភាវនាមយឫទ្ធិឬ? លោកវិតណ្ឌវាទីឆ្លើយថា មែន, អាចារ្យពួកខ្លះពោលថា កាលសម្លាប់សត្វដទៃដោយភាវនាមយឫទ្ធិនោះមានតែម្តង, ដូចឆ្នាំង ឬក្អម ទឹកពេញដោយទឹក បុគ្គលចង់ប្រហារអ្នកដទៃ ចោលទៅហើយ សូម្បីក្អម ឬឆ្នាំងបែកក្តី, ទឹកវិនាសទៅក្តីយ៉ាងណា, កម្ម គឺការសម្លាប់សត្វដទៃ ដោយភាវនាមយឫទ្ធិ មានតែម្តង ក៏យ៉ាងនោះដែរ; តអំពីនោះទៅ ឫទ្ធិនោះ ក៏បាត់អស់ (គឺវិនាស) អស់ទៅ ។

លំដាប់នោះ អាចារ្យទាំងឡាយបាននិយាយនឹងលោកវិតណ្ឌវាទីនោះថា "កម្ម គឺការប្រហារអ្នកដទៃដោយភាវនាមយឫទ្ធិ មិនមែនតែម្តង ពីរដងប៉ុណ្ណោះទេ" ហើយទើបសួរលោកវិតណ្ឌវាទី ដែលមិនស្របទៅតាមវាចាបញ្ញត្តិថា "ភាវនាមយឫទ្ធិជាកុសល, ឬអកុសល ឬក៏អព្យាកតៈ?; សម្បយុត្តដោយសុខវេទនា, ឬទុក្ខវេទនា, ឬក៏អទុក្ខមសុខវេទនា?; ជាសវិតក្កវិចារៈ,

---

ឫទ្ធិសម្រេចពីវិជ្ជា **ភាវនាមយឫទ្ធិ** = ឫទ្ធិសម្រេចពីការភាវនា; (ចំណែកសេចក្តីពិស្តារ អ្នកសិក្សាគប្បីអាននៅក្នុងអដ្ឋសាលិនី អត្ថយោជនាបាលីភាគ ១ ចាប់ពីទំព័រ ១៦៧ ដល់ ១៧០ ផងចុះ) ។

មិនមានវិតក្កៈ, មានតែវិចារៈ, មិនមានវិតក្កៈមិនមានវិចារៈ; ជាកាមាវចរ ជារូបាវចរ ជាអរូបាវចរ" ។ បុគ្គលណាដឹងបញ្ហានេះ, បុគ្គលនោះរមែងពោលយ៉ាងនេះថា "**ភាវនាមយឫទ្ធិ** ជាកុសលខ្លះ, ជាអព្យាកតៈខ្លះ, ជាអទុក្ខមសុខវេទនាខ្លះ, ជាអវិតក្កាវិចារៈ និងជារូបាវចរប៉ុណ្ណោះ" ។ អាចារ្យវិតណ្ឌវាទីនោះ ត្រូវអ្នកដទៃសួរថា "ចេតនាដែលញ៉ាំងជីវិតសត្វឱ្យធ្លាក់ចុះកន្លងទៅ រមែងរួមចូលគ្នាបាននឹងចំណែកណា បណ្តាចំណែកទាំងឡាយមានកុសលជាដើម" ។ កាលអាចារ្យវិតណ្ឌវាទីដឹងហើយ ឆ្លើយប្រាប់ថា "ចេតនាញ៉ាំងសត្វមានជីវិតឱ្យកន្លងទៅ ជាអកុសល ជាទីតាំងនៃទុក្ខវេទនា មានវិតក្កៈ និងវិចារៈ ជាកាមាវចរប៉ុណ្ណោះ" ។ កាលបើហេតុយ៉ាងនេះមាន ក៏គប្បីប្រាប់វិតណ្ឌវាទីថា បញ្ហារបស់លោក មិនសមនឹងកុសលត្តិកៈ, មិនសមនឹងវេទនាតិកៈ, មិនសមនឹងវិតក្កត្តិកៈ, មិនសមនឹងភុម្មន្តរៈ (គឺកាមាវចរជាដើម) ។ អាចារ្យវិតណ្ឌវាទីនិយាយថា ក៏សូត្រធំយ៉ាងនេះមិនមានប្រយោជន៍ឬ? ពួកអាចារ្យក៏ឆ្លើយថា មិនមែន មិនមានប្រយោជន៍ទេ, តែថា លោកមិនដឹងប្រយោជន៍នៃសូត្រនោះថា "សមណៈ ឬព្រាហ្មណ៍នោះ **មានឫទ្ធិដល់ការជំនាញផ្លូវចិត្ត**" ។ ពិតណាស់ក្នុងទីនេះ លោកមិនសំដៅយកភាវនាមយឫទ្ធិទេ, តែប្រាថ្នាយកអាថព្វនឫទ្ធិ ។

ពិតណាស់ កាលបានអាថព្វនឫទ្ធិនោះ តែងបានក្នុងពាក្យថា អ្នកមានឫទ្ធិ

ដល់ការជំនាញផ្លូវចិត្តនេះ, តែថា អាថព្វនឫទ្ធិនោះ ផុតចាកកាយទ្វារ និងវចីទ្វារ ហើយក៏មិនអាចធ្វើបាន; ព្រោះថា បុគ្គលអ្នកប្រកបអាថព្វនឫទ្ធិទាំងឡាយ ត្រូវបរិភោគរបស់មិនប្រែ ក្រាលស្មៅទព្វៈ[១៤] ដេកលើផែនដី ប្រព្រឹត្តតបៈអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ រៀបចំផែនទីព្រៃស្មសាន ហើយឈរក្នុងជំហានជើងទី ៧ ធ្វើឱ្យដៃវិលទៅមក រាយមន្ត (វិជ្ជា) ដោយមាត់ ។ បន្ទាប់មក ការធ្វើរបស់ពួកគេទើបសម្រេច; សូម្បីឫទ្ធិនេះ ផុតចាកកាយទ្វារ និងវចីទ្វារហើយ ក៏មិនអាចធ្វើបាន ព្រោះហេតុដូច្នោះ ក្នុងខនេះ គប្បីដល់ការធ្លាក់ (យល់) ចុះថា "កាយកម្ម រមែងមិនតាំងឡើងក្នុងមនោទ្វារ" ។

ក៏កាលបុគ្គលពោលមុសាវាទជាដើម ដោយសីសៈ និងដៃ កម្មជាវចីកម្ម, តែទ្វារជាកាយទ្វារ; សូម្បីវចីកម្មដែលជាអកុសល ក៏តាំងឡើងក្នុងកាយទ្វារ ដោយប្រការដូច្នេះ ។ ចំណែកអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ដែលកើតព្រមជាមួយចិត្តទាំងឡាយនោះ រមែងជាផ្នែកនៃចេតនាខ្លះ, ជាអព្វោហារិកខ្លះ; ក៏កាលបុគ្គលធ្វើការថ្លែងវាចាពោលមុសាវាទជាដើម សូម្បីកម្មក៏ជាវចីកម្ម, សូម្បីទ្វារក៏ជាវចីទ្វារដូចគ្នា; វចីកម្មដែលជាអកុសល រមែងតាំងឡើងដោយវចីទ្វារ មាន

---

[១៤] ឈ្មោះស្មៅមួយប្រភេទ ដែលក្មេងចូលចិត្តក្តិចយកមកវាយគ្នាលេងហៅថា ស្មៅជុលមាន់ ឬស្មៅចៃមាន់ ។

ប្រការដូច្នេះ ។ ចំណែកអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ដែលកើតព្រមនឹងចិត្ត ទាំងឡាយនោះ ជាផ្នែកនៃចេតនាខ្លះ, ជាអព្វោហារិកខ្លះ; ឈ្មោះថា ពាក្យ បង្ហាញ (អដ្ឋកថា) ដែលដូចគ្នារបស់អាចារ្យទាំងឡាយ មានត្រឹមតែប៉ុណ្ណេះ ។

ចំណែកអាចារ្យវិតណ្ឌវាទីនិយាយថា "វចីកម្មដែលជាអកុសលរមែង តាំងឡើងក្នុងមនោទ្វារក៏បាន" ។ អាចារ្យវិតណ្ឌវាទីនោះ ត្រូវអាចារ្យដទៃ ពោលថា "លោកចូរនាំសូត្រឡើងកាន់ការរួបរួមទាំង ៣ ដង មកមើល" ទើប នាំសូត្រនេះអំពីឧបោសថក្ខន្ធកៈមកថា "ក៏ភិក្ខុណា កាលត្រូវសូត្រប្រកាសដល់ ៣ ដង រលឹកបាន, តែមិនធ្វើឱ្យជាក់ច្បាស់នូវអាបត្តិដែលមានហើយ, ភិក្ខុនោះ រមែងត្រូវអាបត្តិព្រោះសម្បជានមុសាវាទ"[១៥] ។ លុះលោកនាំសូត្រនេះ មកហើយ ក៏ពោលថា ភិក្ខុនោះមិនធ្វើឱ្យជាក់ច្បាស់នូវអាបត្តិយ៉ាងនេះ ជាអ្នក នៅស្ងៀម រមែងត្រូវអាបត្តិដទៃទៀត តើការកម្រើកអង្គនៃកាយ ឬវាចានេះ មានពីណា?, ក៏វចីកម្មដែលជាអកុសល រមែងតាំងឡើងក្នុងមនោទ្វារនោះឯង"។

អាចារ្យទាំងឡាយគប្បីសួរវិតណ្ឌវាទីនោះថា "ក៏សូត្រដែលលោកពោល នេះ មានសេចក្ដីដែលគួរណែនាំឬ?, ឬថា មានសេចក្ដីអធិប្បាយមកហើយដូច ម្ដេច?" វិតណ្ឌវាទីពោលថា សូត្ររបស់ខ្ញុំនេះ មានសេចក្ដីអធិប្បាយទុកហើយ

[១៥] វិនយ. ។

ដូច្នេះ; ហើយត្រូវពួកអាចារ្យសួរតឿនថា “លោកកុំពោលយ៉ាងនេះ, ពួកយើងនឹងនាំគ្នាពិចារណាមើលសេចក្ដីរបស់សូត្រនោះ” ហើយគប្បីសួរយ៉ាងនេះថា “មានអាបត្តិអ្វីក្នុងសម្បជានមុសាវាទ”? កាលបើអាចារ្យវិតណ្ឌវាទីដឹងហើយក៏ប្រាប់ថា “ជាអាបត្តិទុក្កដព្រោះសម្បជានមុសាវាទ” បន្ទាប់អំពីនោះ ក៏គប្បីប្រាប់ថា “វិន័យមានមូលហេតុពីរយ៉ាងគឺ កាយ និងវាចា, ពិតមែនហើយ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តអាបត្តិទាំងអស់ក្នុងទ្វារទាំង ២ នេះប៉ុណ្ណោះ, ឈ្មោះថា **ការបញ្ញត្តិអាបត្តិ** ក្នុងមនោទ្វារមិនមាន, លោកហាក់ដូចជាដឹងវិនយប្បញ្ញត្តិពេក, បុគ្គលណាបញ្ញត្តអាបត្តិក្នុងឋានដែលព្រះសាស្ដាទ្រង់មិនបានបញ្ញត្តទុក, អ្នកនោះឈ្មោះថា រមែងពោលបង្កាច់ព្រះសម្មាសម្ពុទ្ធ, រមែងប្រហារព្រះជិនចក្រ” លុះត្រូវសង្កត់ដោយពាក្យជាដើមយ៉ាងនោះហើយ គប្បីសួរបញ្ហាឱ្យច្រើនឡើងថា “សម្បជានមុសាវាទ រមែងតាំងឡើងដោយការធ្វើឬ? ឬថាព្រោះការមិនធ្វើ?” កាលវិតណ្ឌវាទីជ្រាបហើយ ក៏នឹងប្រាប់ថា ព្រោះការមិនធ្វើ, បន្ទាប់ពីនោះ ក៏គប្បីប្រាប់លោកថា “ភិក្ខុអ្នកមិនធ្វើឱ្យជាក់ច្បាស់អាបត្តិ ធ្វើនូវកិរិយាយ៉ាងណា?” លោកវិតណ្ឌវាទី កាលមិនឃើញនូវកិរិយាមែន ក៏នឹងដល់ការលំបាកចិត្ត, លំដាប់នោះ អាចារ្យទាំងឡាយគប្បីឱ្យវិតណ្ឌវាទីនោះ ដឹងច្បាស់ដោយសេចក្ដីនៃសូត្រនេះ; ក៏ក្នុងសូត្រនេះមានសេចក្ដីដូចតទៅនេះ ៖-

**សួរថា** សម្បជានមុសាវាទ ដែលពោលថាជាអាបត្តិ តើជាអាបត្តិអ្វី? គឺអាបត្តិប្រភេទណា? **ឆ្លើយថា** ជាអាបត្តិទុក្កដ, ក៏អាបត្តិទុក្កដនុ៎ះឯង មិនពោលដោយលក្ខណៈនៃមុសាវាទឡើយ, បណ្ឌិតគប្បីជ្រាបថា ជាអាបត្តិដែលមានការមិនធ្វើក្នុងវចីទ្វារ តាមព្រះតម្រាស់នៃព្រះមានព្រះភាគជាសមុដ្ឋាន; សមដូចត្រាស់ទុកក្នុងបរិវារៈ ពោលដោយសេទមោចនគាថាដូច្នេះថា ៖-

**“អនាលបន្តោ មនុជេន កេនចិ**
**វាចា គិរំ នោ ច បរេ ភណេយ្យ**
**អាបជ្ជេយ្យ វាចសិកំ ន កាយិកំ**
**បញ្ហា មេសា កុសលេហិ ចិន្តិតា។**

ភិក្ខុមិនចចារនឹងអ្នកណាមួយ មិនថ្លែងវាចានិយាយនឹងអ្នកដទៃ តែត្រូវអាបត្តិផ្លូវវាចា មិនត្រូវអាបត្តិផ្លូវកាយ; បញ្ហានេះ លោកអ្នកប្រាជ្ញទាំងឡាយគិតគ្នាហើយ”[១៦]។

ក្នុងទីនេះ គប្បីដល់ការយល់ព្រមថា “វចីកម្មដែលជាអកុសល រមែងមិនតាំងឡើងក្នុងមនោទ្វារ ដោយប្រការដូច្នេះ”។

តែថា ក្នុងកាលណា បុគ្គលមានចិត្តប្រព្រឹត្តទៅជាមួយនឹងអភិជ្ឈា ញុំាង

---

[១៦] វិនយ. ។

អង្គនៃកាយ ឱ្យកម្រើក ធ្វើកិច្ចមានការកាន់យកដោយដៃជាដើម, មានចិត្តប្រព្រឹត្តទៅជាមួយនឹងព្យាបាទ មានការកាន់ដំបងជាដើម, មានចិត្តប្រព្រឹត្តទៅជាមួយនឹងមិច្ឆាទិដ្ឋិ រួចគិតថា "ព្រះខន្ធកុមារ ព្រះសិវៈ (ឥសូរ) ប្រសើរបំផុត" ទើបធ្វើកិច្ចមានអញ្ជលីកម្ម និងការតាក់តែងតាំងតូចសម្រាប់ភូត, ដើម្បីព្រះសិវៈនោះ; ក្នុងកាលនោះ កម្មជាមនោកម្ម, តែទ្វារជាកាយទ្វារដែលជាអកុសលរមែងតាំងឡើងក្នុងកាយទ្វារ ដោយប្រការដូច្នេះ; តែចេតនាក្នុងទីនេះ ជាអព្វោហារិក ។

ក្នុងកាលណា បុគ្គលមានចិត្តប្រព្រឹត្តទៅជាមួយនឹងអភិជ្ឈា ញ៉ាំងចំណែកនៃវាចាឱ្យកម្រើក សម្លឹងមើលឧបករណ៍ជាគ្រឿងរីករាយចិត្ត របស់អ្នកដទៃដោយនិយាយថា "ឱហ្ន៎ ! របស់អ្នកដទៃគប្បីជារបស់អញ" , មានចិត្តប្រព្រឹត្តទៅជាមួយនឹងព្យាបាទ ពោលថា "សូមសត្វទាំងនេះត្រូវគេ បៀតបៀនចូរងាប់, ចូរដាច់សូន្យ, ឬកុំបានមានឡើយ" , មានចិត្តប្រព្រឹត្តទៅជាមួយនឹងមិច្ឆាទិដ្ឋិពោលថា "ទានដែលបុគ្គលឱ្យហើយមិនមានផល, យញ្ញដែលបុគ្គលបូជាហើយមិនមានផល" ជាដើម, ក្នុងកាលនោះ កម្មជាមនោកម្ម, តែទ្វារជាវចីទ្វារ; មនោកម្មជាអកុសលតាំងឡើងក្នុងវចីទ្វារ ដោយប្រការដូច្នេះ, ចេតនាក្នុងទីនេះ ក៏ជាអព្វោហារិក ។

ក៏ក្នុងកាលណា បុគ្គលមិនញុំាងចំណែកនៃកាយ និងវាចាឱ្យកម្រើក អង្គុយនៅក្នុងទីកំបាំង (ទីស្ងាត់) ឱ្យចិត្តទាំងឡាយកើតឡើងប្រព្រឹត្តទៅដោយអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ, ក្នុងកាលនោះ កម្មជាមនោកម្ម, សូម្បីទ្វារ ក៏ជាមនោទ្វារដូចគ្នា; មនោកម្មដែលជាអកុសលតាំងឡើងក្នុងមនោទ្វារ ដោយប្រការដូច្នេះ ។ ក៏ក្នុងទីនេះ ចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី តាំងឡើងក្នុងមនោទ្វារប៉ុណ្ណោះ, មនោកម្មដែលជាអកុសល បណ្ឌិតគប្បីជ្រាបថា តាំងឡើងក្នុងទ្វារទាំង ៣ ដូចពណ៌នាមកនេះ ។

ក៏ពាក្យដែលលោកពោលថា "ជាកាយកម្ម វចីកម្ម និងមនោកម្ម ដែលជាកុសល ក៏ដូចគ្នានោះដែរ" មានន័យដូចតទៅនេះ ៖-

ពិតណាស់ ក្នុងកាលណា បុគ្គលណាមិនអាចពោលវាចាដោយហេតុយ៉ាងណាខ្លះ កាន់យកសិក្ខាបទទាំងនេះ ដោយដៃ និងសីសៈថា "ខ្ញុំព្រះករុណាវៀរចាកបាណាតិបាត ចាកអទិន្នាទាន ចាកកាមេសុមិច្ឆាចារ" , ក្នុងកាលនោះ កម្មជាកាយកម្ម, សូម្បីទ្វារ ក៏ជាកាយទ្វារដូចគ្នា; កាយកម្មដែលជាកុសល តែងតាំងឡើងក្នុងកាយទ្វារយ៉ាងនេះ, ធម៌មានអនភិជ្ឈាជាដើម ដែលកើតព្រមនឹងចិត្តទាំងនោះ រមែងជាបក្សពួករបស់ចេតនាខ្លះ ជាអព្វោហារិកខ្លះ។

តែក្នុងកាលណា បុគ្គលពោលវាចា ទទួលសិក្ខាបទទាំងនោះឯង, ក្នុងកាលនោះ កម្មជាកាយកម្ម, តែទ្វារជាវចីទ្វារ; កាយកម្មដែលជាកុសល តែងតាំងឡើងក្នុងវចីទ្វារយ៉ាងនេះ, ធម៌មានអនភិជ្ឈាជាដើម ដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ រមែងជាបក្សនៃចេតនាខ្លះ ជាអព្វោហារិកខ្លះ ។

តែក្នុងកាលណា ភិក្ខុឱ្យសិក្ខាបទទាំងនោះកម្រើកហើយ បុគ្គលមិនឱ្យចំណែកនៃកាយ និងវាចាកម្រើក ទទួលយកដោយចិត្តប៉ុណ្ណោះថា “ខ្ញុំព្រះករុណាវៀរចាកបាណាតិបាត ចាកអទិន្នាទាន ចាកកាមេសុមិច្ឆាចារ” , ក្នុងកាលនោះ កម្មជាកាយកម្ម, តែទ្វារជាមនោទ្វារ; កាយកម្មដែលជាកុសល តាំងឡើងក្នុងមនោទ្វារយ៉ាងនេះ, ធម៌មានអនភិជ្ឈាជាដើម ដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ ជាបក្សនៃចេតនាខ្លះ ជាអព្វោហារិកខ្លះ ។ ក៏កាលបុគ្គលទទួលសិក្ខាបទទាំង ៤ មានចេតនាជាគ្រឿងវៀរចាកមុសាវាទជាដើម ដោយកាយជាដើម ដោយន័យដែលពោលហើយនុ៎ះឯង វចីកម្មដែលជាកុសល បណ្ឌិតគប្បីជ្រាបថា “តាំងឡើងក្នុងទ្វារទាំង ៣” , សូម្បីក្នុងទីនេះ ធម៌មានអភិជ្ឈាជាដើម ក៏ជាបក្សនៃចេតនាខ្លះ ជាអព្វោហារិកខ្លះ ។

តែបុគ្គលញ៉ាំងចំណែកនៃកាយឱ្យកម្រើកទៅដោយចិត្ត ដែលកើតព្រមដោយអនភិជ្ឈាជាដើម ធ្វើការបោសលានព្រះចេតិយ ធ្វើការបូជាដោយគ្រឿង

គ្រឿងរបស់ជាទីពេញចិត្តនៃអ្នកដទៃ គប្បីជារបស់អញ” មានចិត្តសហគតៈដោយអព្យាបាទ ពោលថា “**សព្វេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ** = សត្វទាំងឡាយទាំងពួង សូមកុំមានពៀរនឹងគ្នា កុំព្យាបាទគ្នា កុំមានសេចក្តីចង្អៀតចង្អល់នឹងគ្នា ចូររក្សានូវខ្លួនឱ្យជាសុខចុះ” មានចិត្តសហគតៈដោយសម្មាទិដ្ឋិ ពោលថា “ទានដែលបុគ្គលឱ្យហើយ មានផល” ជាដើម កម្មជាមនោកម្ម, តែទ្វារជាវចីទ្វារ; មនោកម្មដែលជាកុសលតាំងឡើងក្នុងវចីទ្វារយ៉ាងនេះ, តែចេតនាក្នុងទីនេះ ជាអព្វោហារិក; តែបុគ្គលមិនញ៉ាំងកាយ និងវាចាឱ្យកម្រើក អង្គុយក្នុងទីកំបាំង (ស្ងាត់) ឱ្យចិត្តសហគតៈដោយអនភិជ្ឈាជាដើម កើតឡើងដោយចិត្តប៉ុណ្ណោះ កម្មជាមនោកម្ម, សូម្បីទ្វារក៏ជាមនោទ្វារដូចគ្នា; មនោកម្មដែលជាកុសលតាំងឡើងក្នុងមនោទ្វារយ៉ាងនេះ, តែក្នុងទីនេះ ចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី រមែងតាំងឡើងក្នុងមនោទ្វារប៉ុណ្ណោះ ។

បណ្ដាកម្ម និងទ្វារទាំងនោះ បុគ្គលកាលនិយាយថា កាលបាណាតិបាត និងអទិន្នាទានទាំងឡាយ ដែលតាំងឡើងដោយអាណត្តិ សូម្បីកម្មក៏ជាកាយកម្ម, ឯទ្វារជាកាយទ្វារ ដោយអំណាចនៃកម្មនុ៎ះឯង, រមែងរក្សាកម្ម ឈ្មោះថា **ទម្លាយទ្វារ**; កាលពោលថា បណ្ដាមុសាវាទជាដើម ដែលតាំងឡើងដោយដៃ និងក្បាល សូម្បីទ្វារក៏ជាកាយទ្វារ ចំណែកកម្មជាកាយកម្ម ដោយអំណាចនៃទ្វារនុ៎ះឯង រមែងរក្សាទ្វារ ឈ្មោះថា **ទម្លាយកម្ម**; ព្រោះហេតុដូច្នោះ មិនគួរទម្លាយទ្វារដោយគិតថា "អញនឹងរក្សាកម្ម" , មិនគប្បីទម្លាយកម្មដោយគិតថា "អញនឹងរក្សាទ្វារ" , ក៏បណ្ឌិតគប្បីជ្រាបកម្ម និងទ្វារដោយន័យតាមដែលពោលហើយនោះឯង, ព្រោះថា កាលបុគ្គលពោលហើយយ៉ាងនេះ រមែងមិនទម្លាយនូវកម្ម និងទ្វារដូច្នេះឯង ៕

**ចប់កថាសម្ដែងអំពីកម្ម**

## អធិប្បាយអំពីវិញ្ញាណ ៥ ជាដើម

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យវិញ្ញាណ ៥ និងទ្វារនៃវិញ្ញាណ ៥ តទៅ ៖-

**ឈ្មោះថាវិញ្ញាណមាន ៥ គឺ**

**១~ចក្ខុវិញ្ញាណ** វិញ្ញាណ គឺភ្នែក

**២-សោតវិញ្ញាណ** វិញ្ញាណ គឺត្រចៀក

**៣-ឃានវិញ្ញាណ** វិញ្ញាណ គឺច្រមុះ

**៤-ជីវ្ហាវិញ្ញាណ** វិញ្ញាណ គឺអណ្តាត

**៥-កាយវិញ្ញាណ** វិញ្ញាណ គឺកាយ ។

## ឈ្មោះថាទ្វារនៃវិញ្ញាណ ៥ គឺ

**១-ចក្ខុវិញ្ញាណទ្វារ** ទ្វារនៃចក្ខុវិញ្ញាណ

**២-សោតវិញ្ញាណទ្វារ** ទ្វារនៃសោតវិញ្ញាណ

**៣-ឃានវិញ្ញាណទ្វារ** ទ្វារនៃឃានវិញ្ញាណ

**៤-ជីវ្ហាវិញ្ញាណទ្វារ** ទ្វារនៃជិវ្ហាវិញ្ញាណ

**៥-កាយវិញ្ញាណទ្វារ** ទ្វារនៃកាយវិញ្ញាណ ។

ចេតនាដែលកើតឡើងដោយអំណាចនៃទ្វារទាំង ៥ នេះ បណ្ឌិតគប្បីជ្រាបថា មិនជាកាយកម្ម និងមិនជាវចីកម្មទេ, តែជាមនោកម្មប៉ុណ្ណោះ ។ ក៏ឈ្មោះថា **សម្ផស្ស**ទាំងនេះ មាន ៦ គឺ ចក្ខុ, សោត, ឃាន, ជិវ្ហា, កាយ និងមនោសម្ផស្ស ។ ឈ្មោះថា**ទ្វារនៃសម្ផស្ស** ទាំងនេះមាន ៦ គឺ ទ្វារនៃចក្ខុ, សោត, ឃាន, ជិវ្ហា, កាយ និងទ្វារនៃមនោសម្ផស្ស ។ ឈ្មោះថា **អសំវរៈ**

ទាំង ៨ នេះ គឺ ចក្ខុ, សោត, ឃាន, ជិវ្ហា, បសាទកាយ, ចោបនកាយ, វាចា និងមនោអសំវរៈ ។ អសំវរៈទាំង ៨ នោះ ពោលដោយអត្ថ បានដល់ ធមិទាំង ៥ នេះ គឺ

១-ភាពជាអ្នកទ្រុស្តសីល = **ទុស្សីល្យំ**

២-ភាពជាអ្នកភ្លេចសតិ = **មុដ្ឋស្សច្ចំ**

៣-ការមិនដឹង = **អញ្ញាណំ**

៤-ការមិនអត់ធន់ = **អក្ខន្តិ**

៥-ភាពជាអ្នកខ្ជិល = **កោសជ្ជំ** ។

បណ្ដាធមិទាំង ៥ នោះ សូម្បីធមិតែមួយ៉ាង ក៏មិនកើតក្នុងចិត្តទាំងឡាយ មានវោដ្ឋព្វនចិត្តជាទីបំផុតក្នុងបញ្ចទ្វារ, តែរមែងកើតក្នុងខណៈជវនចិត្តប៉ុណ្ណោះ; សូម្បីធមិទាំងនោះ កើតឡើងក្នុងជវនចិត្ត លោកហៅថា “អសំវរៈ = ការមិនសង្រួម” ក្នុងទ្វារ ៥ ។

ពិតមែន ផស្សៈកើតជាមួយនឹងចក្ខុវិញ្ញាណ ឈ្មោះថា **ចក្ខុសម្ផស្ស**, ចេតនា ឈ្មោះថា **មនោកម្ម**, ចិត្តនោះ ឈ្មោះថា **ទ្វារនៃមនោកម្ម**; ក្នុងចក្ខុវិញ្ញាណនេះ អសំវរៈ ៥ យ៉ាង នៅមិនមាន ។ ផស្សៈដែលកើតជាមួយនឹងសម្បដិច្ឆន្នចិត្ត ឈ្មោះថា **មនោសម្ផស្ស**, ចេតនា ឈ្មោះថា **មនោកម្ម**, ចិត្តនោះ

ឈ្មោះថា **ទ្វារនៃមនោកម្ម**; សូម្បីក្នុងសម្បដិច្ឆន្នចិត្តនេះ អសំវរធម៌ ក៏នៅមិនមាន ។ សូម្បីក្នុងសន្តីរណចិត្ត និងវោដ្ឋព្វនចិត្ត ក៏ន័យនេះដែរ. តែថា សម្ផស្សដែលកើតជាមួយនឹងជវនចិត្ត ឈ្មោះថា **មនោសម្ផស្ស**, ចេតនា ឈ្មោះថា **មនោកម្ម**, ចិត្តនោះ ឈ្មោះថា **ទ្វារនៃមនោកម្ម**; ការមិនសង្រួមក្នុងជវនចិត្តនោះ ឈ្មោះថា **ចក្ខុអសំវរៈ** (ការមិនសង្រួមផ្លូវចក្ខុ) ។ សូម្បីក្នុងសោតៈ ឃានៈ ជិវ្ហា និងបសាទកាយទ្វារ ក៏ន័យនេះដែរ ។

ក៏ក្នុងកាលណា ជវនចិត្តផ្លូវមនោទ្វារ មានអារម្មណ៍ណាមួយ មានរូបជាដើមជាអារម្មណ៍ វៀរវចីទ្វារ តាំងឡើងញ៉ាំងការកម្រើកកាយទ្វារសុទ្ធ ឱ្យប្រព្រឹត្តទៅ, ក្នុងកាលនោះ ផស្សៈដែលកើតឡើងជាមួយនឹងចិត្តនោះ ឈ្មោះថា **មនោសម្ផស្ស**, ចេតនា ឈ្មោះថា **កាយកម្ម**, តែចិត្តនោះ ជាអព្វោហារិក; មិនដល់ការរាប់ថាជាមនោទ្វារ ព្រោះមានការកម្រើកកើតហើយ ។ ក៏ការមិនសង្រួមក្នុងជវននេះ ឈ្មោះថា **ការមិនសង្រួមផ្លូវកាយ** (កាយអសំវរៈ) ។

ក្នុងកាលណា ជវនចិត្តនោះៗ ឯង វៀរចាកកាយទ្វារ ហើយកើតឡើងញ៉ាំងការកម្រើកវចីទ្វារសុទ្ធៗ ឱ្យប្រព្រឹត្តទៅ, ក្នុងកាលនោះ ផស្សៈដែលកើតជាមួយនឹងចិត្តនោះ ឈ្មោះថា **មនោសម្ផស្ស**, ចេតនា ឈ្មោះថា **វចីកម្ម**, តែចិត្តនោះ ជាអព្វោហារិក, មិនដល់ការរាប់ថាជាមនោទ្វារឡើយ ព្រោះមាន

ការកម្រើកកើតហើយ; ការមិនសង្រួមក្នុងជវនចិត្តនេះ ឈ្មោះថា **ការមិនសង្រួមវាចា** (វចីអសំវរៈ) ។

ក៏ក្នុងកាលណា ជវនចិត្តដូចនោះ វៀរចាកកាយទ្វារ និងវចីទ្វារ ជាមនោទ្វារសុទ្ធតែប៉ុណ្ណោះកើតឡើង, ក្នុងកាលនោះ ផស្សៈដែលកើតព្រមនឹងចិត្ត នោះ ឈ្មោះថា **មនោសម្ផស្ស**, ចេតនា ឈ្មោះថា **មនោកម្ម**, ចិត្តនោះ ឈ្មោះថា **ទ្វារនៃមនោកម្ម**; ការមិនសង្រួមក្នុងជវនចិត្តនេះ ឈ្មោះថា **ការមិនសង្រួមផ្លូវចិត្ត** (មនោអសំវរៈ) ។ បណ្ឌិតគប្បីជ្រាបទ្វារនៃអសំវរៈ ទាំង ៨ នេះ គឺទ្វារនៃអសំវរៈផ្លូវភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, បសាទកាយ, ចោបនកាយ, វាចា និងទ្វារនៃអសំវរៈផ្លូវមនោដោយអំណាចនៃអសំវរៈទាំង ៨ នេះ មានប្រការដូច្នេះ ។

ចំណែកឈ្មោះថា **សំវរៈ ៨** ទាំងនេះ គឺចក្ខុសំវរៈ (សង្រួមផ្លូវភ្នែក), សោតសំវរៈ, ឃានសំវរៈ, ជិវ្ហាសំវរៈ, បសាទកាយសំវរៈ, ចោបនកាយសំវរៈ, វាចាសំវរៈ និងមនោសំវរៈ ។ សំវរធម៌ទាំងនោះ ពោលដោយអត្ថ បានដល់ធម៌ទាំង ៥ នេះ គឺ **សីល**, **សតិ**, **ញាណ**, **ខន្តី** និង**វីរិយៈ** ។ បណ្ដាធម៌ទាំង ៥ នោះ សូម្បីធម៌ណាមួយ រមែងមិនកើតក្នុងចិត្តទាំងឡាយ មានវោដ្ឋព្វនចិត្តជាទីបំផុតក្នុងបញ្ចទ្វារាវជ្ជនៈ, ធម៌នោះ រមែងកើតក្នុងខណៈជវនចិត្តប៉ុណ្ណោះ;

សូម្បីកើតក្នុងជវនចិត្ត លោកហៅថា “សំវរៈ” ក្នុងបញ្ចទ្វារ ។

បណ្ឌិតគប្បីជ្រាប ការកើតឡើងនៃផស្សៈនោះ សូម្បីទាំងអស់ ដោយន័យ ដែលពោលហើយក្នុងអសំវរៈ ដែលមានពាក្យថា **“ចក្ខុវិញ្ញាណសហជាតោ ហិ ផស្សោ ចក្ខុសម្ផស្សោ** = ពិតមែន ផស្សៈដែលកើតជាមួយនឹងចក្ខុវិញ្ញាណ ឈ្មោះថា **ចក្ខុសម្ផស្ស”** ជាដើម; ដោយអំណាចនៃសំវរៈទាំង ៨ យ៉ាងនេះ បណ្ឌិតគប្បីជ្រាប **សំវរទ្វារ (ទ្វារនៃការសង្រួម) ទាំង** ៨ នេះ គឺទ្វារនៃការសង្រួមផ្លូវភ្នែក ។ល។ ទ្វារនៃការសង្រួមផ្លូវចិត្ត តាមដែលពោលហើយ ។

## សម្តែងអំពីអកុសលកម្មបថ

ក៏ឈ្មោះថា អកុសលកម្មបថទាំងនេះ មាន ១០ ប្រការគឺ

**១_បាណាតិបាត** ការសម្លាប់សត្វ

**២_អទិន្នាទាន** ការលួចទ្រព្យគេ

**៣_កាមេសុមិច្ឆាចារ** ការប្រព្រឹត្តខុសក្នុងកាម

**៤_មុសាវាទ** ការពោលពាក្យកុហក

៥.**បិសុណាវាចា** ការនិយាយស៊កសៀត

៦.**ផរុសវាចា** ការនិយាយគ្រោតគ្រាត

៧.**សម្ផប្បលាប** ការនិយាយឥតប្រយោជន៍

៨.**អភិជ្ឈា** ការសម្លឹងរំពៃចង់បាន

៩.**ព្យាបាទ** ការចង្អៀតចង្អល់

១០.**មិច្ឆាទិដ្ឋិ** ការយល់ឃើញខុស ។

បណ្ដាអកុសលកម្មបថទាំងនោះ ការញុំាងសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង ឈ្មោះថា **បាណាតិបាត**, លោកអធិប្បាយថា ការទម្លាយជីវិត គឺការសម្លាប់សត្វ ។ ក៏ក្នុងពាក្យថា **បាណ** នេះ ដោយវោហារបានដល់សត្វ, ដោយបរមត្ថបានដល់ជីវិតិន្ទ្រិយ ២ យ៉ាង; វធកចេតនា (ចេតនាសម្លាប់) របស់បុគ្គលអ្នកមានការសម្គាល់ក្នុងសត្វនោះថា មានជីវិត ហើយប្រព្រឹត្តផ្លូវទ្វារណាមួយ នៃកាយទ្វារ ឬវចីទ្វារដែលតាំងឡើងដោយការព្យាយាម ចូលទៅផ្ដាច់ជីវិតិន្ទ្រិយ ឈ្មោះថា **បាណាតិបាត** ។ បណ្ដាសត្វទាំងឡាយ មានសត្វតិរច្ឆានជាដើម ដែលមិនមានគុណ, បាណាតិបាតនោះ ឈ្មោះថា មានទោសតិច ព្រោះសត្វតូច, ឈ្មោះថា មានទោសច្រើន ព្រោះមានរាងកាយធំ ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមានព្យាយាមខ្លាំង ។ សូម្បីមានព្យាយាមស្មើគ្នា ក៏មានទោសច្រើន ព្រោះ

វត្ថុធំ ។

បណ្តាសត្វដែលមានគុណមានមនុស្សជាដើម បាណាតិបាត ឈ្មោះថា មានទោសតិច ព្រោះសត្វ (មនុស្ស) មានគុណតិច, ឈ្មោះថា មានទោសច្រើន ព្រោះសត្វ (មនុស្ស) មានគុណច្រើន ។ បើសត្វនោះ មានសរីរៈ និងគុណប៉ុនគ្នា ក៏គប្បីជ្រាបថា បាណាតិបាតមានទោសតិច ព្រោះកិលេសទាំងឡាយ និងព្យាយាមខ្សោយ ឈ្មោះថា មានទោសច្រើន ព្រោះកិលេស និងព្យាយាមខ្លាំង ។

អង្គ (ចំណែកប្រកប) នៃបាណាតិបាតនោះ មាន ៥ គឺ

**១-បាណោ** សត្វមានជីវិត

**២-បាណសញ្ញិតា** ដឹងថាសត្វមានជីវិត

**៣-វធកចិត្តំ** មានចិត្តគិតនឹងសម្លាប់

**៤-ឧបក្កមោ** ព្យាយាមសម្លាប់

**៥-តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

## បាណាតិបាតនោះមានប្រយោគ ៦ គឺ

**១-សាហត្ថិកប្បយោគ** ធ្វើដោយខ្លួនឯង

**២-អាណត្តិកប្បយោគ** ប្រើគេឱ្យធ្វើ

**៣.និស្សគ្គិយប្បយោគ** ធ្វើដោយការបោះ ឬចោល

**៤.ថាវរប្បយោគ** ប្រយោគមាំទាំ

**៥.វិជ្ជាមយប្បយោគ** ប្រយោគសម្រេចអំពីវិជ្ជា

**៦.ឥទ្ធិមយប្បយោគ** ប្រយោគសម្រេចអំពីឫទ្ធិ ។

ក៏ក្នុងអត្ថនេះ កាលបើខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) ពង្រីកឱ្យពិស្តារពេកទៅ រមែង(នាំឱ្យ)យឺតយូរពេក ព្រោះហេតុនេះ ខ្ញុំមិនញុំាងអត្ថនោះ និងអត្ថដទៃដូចគ្នា ឱ្យពិស្តារទេ, តែអ្នកត្រូវការអត្ថពិស្តារ គប្បីពិនិត្យមើលអដ្ឋកថាព្រះវិន័យឈ្មោះ **សមន្តប្បាសាទិកា** ហើយកាន់យកចុះ [១៧] ៕

## សម្តែងអំពីអទិន្នាទាន

ការកាន់យកវត្ថុដែលគេមិនបានឱ្យ ឈ្មោះថា **អទិន្នាទាន,** លោកអធិប្បាយថា ការនាំភណ្ឌៈ (ទ្រព្យ) របស់អ្នកដទៃ គឺការលួច ការលួច (កម្មរបស់ចោរ) ។ បណ្តាបទទាំងនោះ បទថា **"អទិន្នំ"** បានដល់ ទ្រព្យរបស់ដែលបុគ្គលដទៃហួងហែង ។ អធិប្បាយថា បុគ្គលដទៃប្រើរបស់ដែលធ្វើហើយតាមពេញចិត្តក្នុងវត្ថុណា មិនមានកំហុស មិនមានទោស ថេយ្យចេតនា របស់

---

[១៧] វិនយ. អ. ២ ។

បុគ្គលអ្នកមានសេចក្ដីសម្គាល់ក្នុងវត្ថុដែលបុគ្គលដទៃហួងហែងរក្សានោះ ក៏ដឹងថា បុគ្គលដទៃហួងហែង ហើយឱ្យតាំងឡើងដោយការព្យាយាមកាន់យកវត្ថុនោះ ទើបឈ្មោះថា **អទិន្នាទាន** ។ អទិន្នាទាននោះ ឈ្មោះថា **មានទោសតិច** ព្រោះវត្ថុដែលជារបស់អ្នកដទៃថោកថយ, ឈ្មោះថា **ទោសច្រើន** ព្រោះវត្ថុប្រណីត; ព្រោះហេតុអ្វី ទើបមានទោសច្រើន? ព្រោះវត្ថុដែលលួចទៅនោះ ជារបស់ប្រណីត, កាលវត្ថុស្មើគ្នា អទិន្នាទាននោះ ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុរបស់បុគ្គល (នោះ) មានគុណដ៏ក្រៃលែង; ឈ្មោះថា មានទោសតិច ព្រោះវត្ថុរបស់បុគ្គលនោះ អ្នកមានគុណថោកថយ ដោយធៀបនឹងអ្នកមានគុណនោះៗ ៕

## អទិន្នាទាននោះមានអង្គ ៥ គឺ

**១-បរបរិគ្គហិតំ** របស់ដែលគេថែរក្សា

**២-បរបរិគ្គហិតសញ្ញិតា** ដឹងថារបស់ដែលគេថែរក្សា

**៣-ថេយ្យចិត្តំ** ចិត្តគិតនឹងលួច

**៤-ឧបក្កមោ** ព្យាយាមនឹងលួច

**៥-តេន ហរណំ** លួចបានមកដោយព្យាយាមនោះ ។

អទិន្នាទាននោះ មានប្រយោគ ៦ មានសាហត្ថិកប្បយោគជាដើម ប្រយោគទាំងនេះឯង ប្រព្រឹត្តទៅដោយអំណាចនៃអវហារ (ការលួច) ទាំង ៥ នេះ គឺ

**១. ថេយ្យាវហារ** លួចដោយលបលាក់

**២. បសយ្ហាវហារ** លួចដោយសង្កត់សង្កិន (ប្លន់)

**៣. បដិច្ឆន្នាវហារ** លួចដោយបិទបាំង

**៤. បរិកប្បាវហារ** លួចដោយកំណត់ទុកជាមុន

**៥. កុសាវហារ** លួចដោយប្តូរស្លាក ។

នេះជាសេចក្តីសង្ខេបក្នុងទីនេះ, ឯសេចក្តីពិស្តារលោកពោលទុកក្នុង**សមន្តប្បាសាទិកា** ឯណោះហើយ[១៨] ៕

## សម្តែងអំពីកាមេសុមិច្ឆាចារ

ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **កាមេសុមិច្ឆាចារ** ដូចតទៅ ៖-

ពាក្យថា **"កាមេសុ"** បានដល់ សេពមេថុន ។ ការប្រព្រឹត្តលាមកដែលបណ្ឌិតតិះដៀលដោយចំណែកមួយ ឈ្មោះថា **មិច្ឆាចារ** ។ តែការពោលដោយលក្ខណៈ បានដល់ ចេតនាជាហេតុល្មើសគន្លងឋានដែលមិនគួរដល់ (ការ

---

[១៨] វិនយ. អ. ២ ។

សេព) ដែលប្រព្រឹត្តទៅតាមផ្លូវកាយទ្វារ ដោយប្រាថ្នាអសទ្ធម្ម ឈ្មោះថា **កា-មេសុមិច្ឆាចារ** ៕

## អគមនីយដ្ឋាន ២០

ក្នុងកាមេសុមិច្ឆាចារនោះ មានស្ត្រី ២០ ជំពូក បានដល់ ស្ត្រីដែលមាតារក្សាជាដើម ១០ ជំពូកដំបូង គឺ

**១-មាតុរក្ខិតា** ស្ត្រីដែលមាតារក្សា

**២-បិតុរក្ខិតា** ស្ត្រីដែលបិតារក្សា

**៣-មាតាបិតុរក្ខិតា** ស្ត្រីដែលមាតាបិតារក្សា

**៤-ភាតុរក្ខិតា** ស្ត្រីដែលបងប្រុស ប្អូនប្រុសរក្សា

**៥-ភគិនីរក្ខិតា** ស្ត្រីដែលបងស្រី ប្អូនស្រីរក្សា

**៦-ញាតិរក្ខិតា** ស្ត្រីដែលញាតិរក្សា

**៧-គោត្តរក្ខិតា** ស្ត្រីដែលត្រកូលរក្សា

**៨.ធម្មរក្ខិតា** ស្ត្រីដែលមានធម៌រក្សា*

**៩.សារក្ខា** ស្ត្រីដែលប្រកបដោយការរក្សា (ស្ត្រីដែលគេស្ដីដណ្ដឹងទុក)

**១០.សបរិទណ្ឌា** ស្ត្រីដែលព្រះរាជាដាក់អាជ្ញា

និងស្ត្រីជាភរិយាមានការទិញដោយទ្រព្យជាដើមទាំងនេះគឺ

**១.ធនក្កីតា** ភរិយាដែលទិញមកដោយទ្រព្យ

**២.ឆន្ទវាសិនី** ភរិយាដែលនៅដោយការពេញចិត្ត

**៣.ភោគវាសិនី** ភរិយាដែលនៅដោយសារបានភោគៈ

**៤.បដវាសិនី** ភរិយាដែលមកនៅដោយសារបានសំពត់

**៥.ឱទបត្តកិនី** ភរិយាដែលគេធ្វើវិធីស្រោចទឹក ដើម្បីឱ្យបានគ្នាជាប្ដីប្រពន្ធ ។

**៦.ឱភដចុម្ពដា** ភរិយាដែលបុរសជួយដាក់ទ្រនូលអំពីសីសៈ

**៧.ទាសី ច ភរិយា** ភរិយាដែលជាទាសីក្នុងផ្ទះ

**៨.កម្មការី ច ភរិយា** ភរិយាដែលជួលមកធ្វើការ

---

* មូលដីកា. ស្ត្រីដែលសហធម្មិកទាំងឡាយរក្សា ឈ្មោះថា ធម្មរក្ខិតា ។ អដ្ឋ. យោជនា. ជនមានធម៌ក្នុងត្រកូលស្មើគ្នាក្ដី បព្វជិតក្ដី រក្សាហើយ ព្រោះឧទ្ទិសសាស្ដាមួយៗ មានបរិព្វាជិកាស្លៀកពាក់សជាដើម ឈ្មោះថា ធម្មរក្ខិតា ។

**៩.ធជាហដា** ភរិយាដែលជាឈ្លើយសឹក*

**១០.មុហុត្តិកា** ភរិយាដែលនៅរួមប្រសព្វគ្នាមួយស្របក់ (ស្រីបន) ។

ស្ត្រី ២០ ជំពូកនេះ ហៅថា **អគមនីយដ្ឋាន** គឺឋានដែលមិនគួរទាក់ទង «សេព» ។ ក៏បណ្ដាស្ត្រីទាំងឡាយ ស្ត្រី ១២ ជំពូកដែលបុរសមិនគួរកន្លងល្មើស គឺស្ត្រីដែលទទួលស្ដីដណ្ដឹង និងស្ត្រីដែលព្រះរាជាដាក់អាជ្ញា រួមជាពីរជំពូក និងស្ត្រីជាភរិយា ១០ ជំពូក មានស្ត្រីដែលជាភរិយាទិញមកដោយទ្រព្យជាដើម នេះឈ្មោះថា **អគមនីយដ្ឋាន** ។

ក៏មិច្ឆាចារនេះឯង ឈ្មោះថា **មានទោសតិច** ក៏ព្រោះអគមនីយដ្ឋានវៀរចាកគុណមានសីលគុណជាដើម, ឈ្មោះថា **មានទោសច្រើន** ក៏ព្រោះអគមនីយដ្ឋានដល់ព្រមដោយគុណមានសីលជាដើម ។

## មិច្ឆាចារនោះមានអង្គ ៤ គឺ

**១.អគមនីយវត្ថុ** វត្ថុដែលមិនគួរទាក់ទង

**២.តស្មឹ សេវនចិត្តំ** ចិត្តគិតនឹងសេពក្នុងអគមនីយវត្ថុនោះ

---

* អដ្ឋ. យោ. ស្ត្រីដែលគេនាំមកហើយដោយទង់ជ័យ (សង្គ្រាម) ។

**៣-សេវនប្បយោគោ** ព្យាយាមសេព

**៤-មគ្គេន មគ្គប្បដិបាទនំ** ការញ៉ាំងមគ្គឱ្យដល់មគ្គ ។

ប្រយោគរបស់មិច្ឆាចារនោះមានតែមួយគឺ**សហត្ថិកប្បយោគ**ប៉ុណ្ណោះ ៕

## សម្ដែងអំពីមុសាវាទ

ការព្យាយាមផ្លូវវាចា (វចីបយោគ) ឬការព្យាយាមផ្លូវកាយ ដែលទម្លាយប្រយោជន៍របស់បុគ្គលអ្នកចង់ពោលឱ្យខុស ឈ្មោះថា **មុសា** ។ ក៏ចេតនាដែលតាំងឡើងដោយការព្យាយាមផ្លូវកាយ និងផ្លូវវាចា ដែលចង់ពោលឱ្យខុសជាយ៉ាងដទៃ ដល់បុគ្គលដទៃដោយបំណង នឹងពោលឱ្យឃ្លៀងឃ្លាត ឈ្មោះថា **មុសាវាទ** ។

ន័យមួយទៀត រឿងមិនពិត គឺមិនមែនរបស់ពិត ឈ្មោះថា **មុសា** ។ ការឱ្យបុគ្គលដឹងរឿងមិនពិតនោះ ដោយភាវៈថាពិត ថាមែន ឈ្មោះថា **វាទៈ**; ក៏ពោលដោយលក្ខណៈ ចេតនាដែលឱ្យតាំងឡើងដោយឃ្លាតយ៉ាងនោះ របស់បុគ្គលអ្នកប៉ងឱ្យអ្នកដទៃដឹង ដល់រឿងមិនពិត ដោយរឿងពិត (ឬរឿងពិតដោយរឿងមិនពិត) ហៅថា **មុសាវាទ** ។

មុសាវាទនោះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ណាដែលអ្នក

និយាយទម្លាយប្រយោជន៍នោះតិច, ឈ្មោះថា **មានទោសច្រើន** ព្រោះទម្លាយប្រយោជន៍ច្រើន ។ ម្យ៉ាងទៀត មុសាវាទរបស់គ្រហស្ថទាំងឡាយ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា “មិនមាន” ព្រោះប្រាថ្នានឹងមិនឱ្យវត្ថុរបស់ខ្លួន ឈ្មោះថា **មានទោសតិច** ។ មុសាវាទដែលខ្លួនជាសាក្សី ហើយពោលដើម្បីទម្លាយប្រយោជន៍ ឈ្មោះថា **មានទោសច្រើន** ។ មុសាវាទរបស់បព្វជិតទាំងឡាយដែលប្រព្រឹត្តទៅដោយន័យនៃបូរណកថាជាដើមថា “ថ្ងៃនេះ ប្រេងក្នុងស្រុកប្រហែលហូរទៅដូចជាស្ទឹង” ដោយបំណងនឹងសើចលេង ព្រោះបានប្រេង ឬទឹកដោះថ្លាត្រឹមតែតិចតួច ឈ្មោះថា **មានទោសតិច** ។ តែមុសាវាទរបស់បព្វជិត អ្នកពោលដោយន័យជាដើមថា “មិនឃើញ ថាឃើញ” ឈ្មោះថា **មានទោសច្រើន** ។

## អង្គនៃមុសាវាទនោះមាន ៤ យ៉ាងគឺ

**១-អតថំ វត្ថុ** វត្ថុមិនពិត

**២-វិសំវាទនចិត្តំ** ចិត្តគិតនឹងពោលឱ្យខុស

**៣-តជ្ជោ វាយាមោ** ព្យាយាមកើតអំពីការគិតនោះ

**៤-បរស្ស តទត្ថវិជាននំ** ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ។

ប្រយោគមុសាវាទមានតែម្យ៉ាង គឺ**សាហត្ថិកប្រយោគ**ប៉ុណ្ណោះ ។ មុសាវាទនោះ គប្បីជ្រាបដោយការធ្វើកិរិយារបស់អ្នកពោលឱ្យខុសដោយកាយ ឬដោយរបស់ជាប់ដោយកាយ ឬក៏ដោយវាចា ។ បើបុគ្គលដទៃដឹងសេចក្ដីនោះដោយកិរិយានោះ ចេតនាដែលតាំងឡើងដោយកិរិយានេះ រមែងចងព័ន្ធដោយកម្មដែលជាមុសាវាទក្នុងខណៈនោះតែម្ដង ។ ក៏កាលបុគ្គលបង្គាប់ថា "ចូរអ្នកប្រាប់ដល់បុគ្គលនេះ" ដូច្នេះក្ដី កាលសរសេរសៀវភៅបោះទៅខាងមុខក្ដី កាលសរសេរទុកជាប់នឹងជញ្ជាំងផ្ទះជាដើម ដោយប៉ងថា "សេចក្ដីនេះ គឺបុគ្គលគប្បីជ្រាបយ៉ាងនេះ" ដូច្នេះក្ដី ដោយប្រការដែលឱ្យបុគ្គលដទៃប្រាប់ឱ្យឃ្លាតចាកកាយ ឬវត្ថុជាប់ដោយកាយ ឬថាដោយវាចា ព្រោះហេតុដូច្នោះ សូម្បីប្រយោគទាំងឡាយ គឺអាណត្តិកប្រយោគ, និស្សគ្គិយប្រយោគ និងថាវរប្រយោគ ក៏រមែងសមគួរក្នុងមុសាវាទនេះ, តែព្រោះមិនមានមកក្នុង **អដ្ឋកថាទាំងឡាយ** ទើបគួរពិចារណាមុន ហើយទើបកាន់យក ៕

## សម្ដែងអំពីបិសុណាវាចាជាដើម

គប្បីជ្រាបក្នុង **បិសុណាវាចា** ជាដើមដូចតទៅ ៖-

បុគ្គលរមែងពោលវាចាដល់បុគ្គលណា, រមែងធ្វើសេចក្ដីស្រឡាញ់របស់

ខ្លួនក្នុងបេះដូង (ចិត្ត) របស់បុគ្គលនោះ ឱ្យកើតការញុះញង់ដល់បុគ្គលដទៃ, វាចានោះ ឈ្មោះថា **បិសុណាវាចា** ។ ក៏វាចាណាធ្វើសេចក្ដីគ្រោតគ្រាតឱ្យខ្លួនឯងខ្លះ ឱ្យអ្នកដទៃខ្លះ, វាចានោះ ឈ្មោះថា ផរុសវាចា ។ មួយ៉ាងទៀត វាចាណាធ្វើការនិយាយអាក្រក់ដោយខ្លួនឯង គឺជាវាចាមិនពីរោះត្រចៀក មិនជាប់ចិត្ត (មិនដក់នៅក្នុងចិត្ត), វាចានេះ ឈ្មោះថា **ផរុសវាចា** ។ បុគ្គលនិយាយឡេះឡោះ គឺឥតប្រយោជន៍ដោយភាវៈណា, ភាវៈនោះ ឈ្មោះថា **សម្ផប្បលាបៈ**, សូម្បីចេតនា ក៏បានឈ្មោះថា **បិសុណាវាចាជាដើមនុ៎ះឯង** ព្រោះជាហេតុរបស់វាចាទាំងនោះ, ក៏ចេតនានោះឯង ដែលលោកសំដៅយកហើយក្នុងទីនេះ ។

បណ្ដាវាចាទាំងនោះ ចេតនានៃបុគ្គលអ្នកមានចិត្តសៅហ្មងហើយ តាំងឡើងដោយការព្យាយាមផ្លូវកាយ និងវាចាដើម្បីបំបែកជនទាំងឡាយដទៃ ឬធ្វើការស្រឡាញ់ឱ្យដល់ខ្លួន ឈ្មោះថា **បិសុណាវាចា**, ចេតនាដែលជាបិសុណាវាចានោះ ឈ្មោះថា **មានទោសតិច** ព្រោះធ្វើការបំបែកបុគ្គលអ្នកមានគុណតិច, ឈ្មោះថា **មានទោសច្រើន** ព្រោះបុគ្គលនោះមានគុណច្រើន ។

ចំណែកការប្រកប (អង្គ) របស់បិសុណាវាចា មាន ៤ គឺ

**១. ភិន្ទិតព្វោ បរោ** អ្នកដទៃដែលខ្លួនគប្បីធ្វើការបំបែក

**២. ភេទបុរេក្ខារតា** គិតនឹងញុះញង់បំបែកអ្នកដទៃដោយប្រាថ្នាថា

"ជនទាំងនេះនឹងប្រព្រឹត្តទៅផ្សេងៗ គ្នា ដោយឧបាយ (ហេតុ) យ៉ាងនេះ" , ឬជាអ្នកចង់ធ្វើខ្លួនឱ្យជាទីស្រឡាញ់ថា "អញនឹងជាទីស្រឡាញ់ នឹងជាទីទុកចិត្ត (ស្និទ្ធស្នាល) ដោយឧបាយយ៉ាងនេះ" ។

**៣-តជ្ជោ វាយាមោ** មានសេចក្តីព្យាយាមកើតឡើងដោយចិត្តនេះ

**៤-តស្ស តទត្ថវិជាននំ** បុគ្គលនោះដឹងច្បាស់នូវសេចក្តីនោះ ។

ក៏កាលបុគ្គលដទៃមិនបែកគ្នា កម្មបថ ក៏មិនបែក, កាលបុគ្គលបែកគ្នា នុ៎ះឯង កម្មបថ ទើបបែកមែនពិត ។

ចេតនានិយាយអាក្រក់ដោយចំណែកដែលតាំងឡើងដោយនិយាយអា-ក្រក់ផ្លូវកាយ និងវាចាដែលកាត់សេចក្តីស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា **ផរុសវាចា** ។ ដើម្បីការជាក់ច្បាស់នៃផរុសវាចានោះ មានរឿងនេះជាឧទាហរណ៍ ៖-

បានឮថា ក្មេងប្រុសម្នាក់មិនជឿស្តាប់ពាក្យរបស់មាតា ហើយទើបទៅព្រៃ, មាតាមិនអាចឱ្យគេត្រឡប់បាន ទើបបានជេរថា "សូមឱ្យមេក្របីកាចជាប់តាមវាចុះ" ; គ្រានោះ មេក្របីក្នុងព្រៃបានប្រាកដដល់គេ ដូចមាតាពោលនោះឯង, ក្មេងប្រុសបានធ្វើសច្ចកិរិយាថា "ម៉ែរបស់ខ្ញុំនិយាយពាក្យណា ដោយមាត់ (មិនគិតអាក្រក់ទេ), សូមពាក្យនោះកុំមានឡើយ, បើម៉ែគិតពាក្យណា ដោយការតាំងចិត្ត សូមពាក្យនោះមានចុះ" ។ មេក្របីបានឈរស្ងៀម ដូចបុគ្គល

ចងទុកក្នុងទីនោះៗឯង ។

ការព្យាយាមដែលកាត់ចេញនូវសេចក្ដីស្រឡាញ់យ៉ាងនេះ មិនឈ្មោះថា **ផរុសវាចា** ព្រោះចិត្តទន់ភ្លន់ ។ ពិតណាស់ ក្នុងកាលខ្លះ មាតា និងបិតានិយាយនឹងកូនតូចយ៉ាងនេះថា “សូមឱ្យពួកចោរកាត់ពួកឯងជាកំណាត់តូចៗ នឹងកំណាត់ធំចុះ” , តែអ្នកទាំង ២ នោះមិនប្រាថ្នាអ្វីៗ សូម្បីតែឱ្យត្របកផ្កាឧប្បលធ្លាក់ត្រូវកូនទាំងនោះ; ក៏ក្នុងកាលខ្លះ អាចារ្យ និងឧបជ្ឈាយ៍ ពោលនឹងសិស្សអ្នកអាស្រ័យយ៉ាងនេះថា “ពួកឯងនេះ មិនមានហិរិ មិនមានឱត្តប្បៈ និយាយអ្វី, ពួកអ្នកចូរបណ្ដេញគេចេញទៅ” , តែតាមពិត លោកទាំងនោះ ប្រាថ្នាការដល់ព្រមនៃការរៀន និងការសម្រេចមគ្គផលរបស់សិស្សទាំងនោះ; មិនឈ្មោះថា **ផរុសវាចា** ព្រោះចិត្តទន់ យ៉ាងណា, មិនឈ្មោះថាជា**ផរុសវាចា** ព្រោះជាវាចាផ្អែមល្ហែម យ៉ាងនោះដែរ ក៏មិនមែន; ដោយពោលពាក្យនិយាយរបស់បុគ្គលអ្នកចង់ដឹងឱ្យអ្នកដទៃស្លាប់ថា “ពួកអ្នកចូរឱ្យអ្នកនេះដេកជាសុខ” មិនមែនជាផរុសវាចា ក៏មិនមែន, ក៏វាចានោះ ជាផរុសវាចាពិត ព្រោះជាវាចាមានចិត្តអាក្រក់ ។ វាចានោះ ដែលបុគ្គលប្រព្រឹត្តហើយ ព្រោះសំដៅយកបុគ្គលណា ឈ្មោះថា **មានទោសតិច**, ព្រោះភាពនៃបុគ្គលនោះ មានគុណតិច, ឈ្មោះថា **មានទោសច្រើន** ព្រោះបុគ្គលនោះមានគុណច្រើន ។

**ផរុសវាចានោះមានអង្គ ៣ គឺ**

**១-អក្កោសិតព្វោ បរោ** អ្នកដទៃដែលខ្លួនគប្បីជេរ

**២-កុបិតចិត្តំ** ចិត្តខឹងក្រោធ

**៣-អក្កោសនា** បានជេរ * ។

អកុសលចេតនាដែលញុំាងបុគ្គលដទៃឱ្យដឹងវត្ថុ ដែលមិនជាប្រយោជន៍ ដែលតាំងឡើងដោយការព្យាយាមផ្លូវកាយ និងវាចា ឈ្មោះថា **សម្ផប្បលាបៈ**។ សម្ផប្បលាបៈនោះ ឈ្មោះថា **មានទោសតិច** ព្រោះមានការសេពគប់តិច, ឈ្មោះថា **មានទោសច្រើន** ព្រោះមានការសេពគប់ច្រើន ។ អង្គរបស់សម្ផប្បលាបៈនេះមាន ២ គឺ

**១-ភារតយុទ្ធសីតាហរណាទិនិរត្ថកកថាបុរេក្ខារតា** ភាពជាអ្នកមានចេតនានឹងចង់និយាយរឿងឥតប្រយោជន៍ មានរឿងភារតយុទ្ធ និងការលួចនាំនាងសីតាជាដើម ។

**២-តថារូបីកថាកថនំ** ការពោលវាចាមានសភាពដូច្នោះ ។

ក៏បុគ្គលដទៃមិនកាន់យកពាក្យនោះ កម្មបថក៏មិនបែកធ្លាយ, កាលមាន

---

* ច្បាប់ខ្លះថា អក្កោសនំ ។

អ្នកដទៃកាន់យកសម្ពប្បលាបៈនោះៗ ឯង កម្មបថទើបបែកធ្លាយ ។

ធម្មជាតិសម្លឹងរំពៃ ឈ្មោះថា **អភិជ្ឈា** ។ អធិប្បាយថា ជាអ្នកមានមុខឆ្ពោះទៅរកទ្រព្យនៃអ្នកដទៃ ប្រព្រឹត្តទៅដោយភាពជាអ្នកបង្អោនទៅកាន់សម្បត្តិអ្នកដទៃនោះ ។ អភិជ្ឈានោះ មានការសម្លឹងមើលភណ្ឌៈរបស់អ្នកដទៃជាលក្ខណៈយ៉ាងនេះថា "ឱហ្ន៎! វត្ថុនេះគប្បីជារបស់អញ" ។ ឈ្មោះថា **មានទោសតិច និងទោសច្រើន** ដូចអទិន្នាទានដែរ ។ អភិជ្ឈានេះមានអង្គ ២ គឺ

**១~បរភណ្ឌំ** ទ្រព្យរបស់អ្នកដទៃ

**២~អត្តនោ បរិណាមនញ្ច** បង្អោនមកដើម្បីខ្លួន ។

ពិតមែន ការកើតសេចក្ដីលោភក្នុងវត្ថុអ្នកដទៃ កម្មបថមិនដាច់មុនទេ រហូតដល់គេបង្អោនមកដើម្បីខ្លួនដោយពាក្យថា "ឱហ្ន៎! វត្ថុនេះគប្បីជារបស់យើង"។ សភាវធម៌ដែលញ៉ាំងប្រយោជន៍ និងសេចក្ដីសុខឱ្យវិនាសទៅ ឈ្មោះថា **ព្យាបាទ**។ ព្យាបាទនោះ មានការប៉ងអាក្រក់ដើម្បីឱ្យអ្នកដទៃវិនាសជាលក្ខណៈ មានទោសតិច ឬទោសច្រើនដូចផរុសវាចា ។

ព្យាបាទនេះ មាន អង្គ ២ គឺ

**១~បរសត្តោ** សត្វដទៃ

**២~តស្ស ច វិនាសចិន្តា** គិតឱ្យសត្វនោះវិនាសទៅ ។

ពិតណាស់ កាលសេចក្ដីក្រោធមានសត្វដទៃជាទីតាំងកើតហើយ កម្មបថនៅមិនទាន់ដាច់ទេ ដរាបដល់គិតញុំាងសត្វឱ្យវិនាសថា "ម្ដេចហ្ន៎! សត្វនេះគប្បីដាច់សូន្យ, គប្បីវិនាស"។

ធម្មជាតិនេះ ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ឃើញខុសដោយការមិនកាន់យកតាមសភាវៈពិត ។ មិច្ឆាទិដ្ឋិនោះ មានការឃើញវិបរិត (ខុស) ជាលក្ខណៈ ដោយន័យជាអាទិ៍ថា "ទានដែលបុគ្គលឱ្យហើយ មិនមានផល" ឈ្មោះថា **មានទោសតិច និងទោសច្រើន** ដូចសម្ផប្បលាបៈដែរ, ម្យ៉ាងទៀតអនិយតមិច្ឆាទិដ្ឋិមានទោសតិច ឯនិយតមិច្ឆាទិដ្ឋិមានទោសច្រើន ។

អង្គរបស់មិច្ឆាទិដ្ឋិនេះមាន ២ យ៉ាងគឺ

**១.វត្ថុនោ ច គហិតាការវិបរីតតា** រឿងទាំងឡាយវិបរិតចាកអាការដែលកាន់យក ។

**២.យថា ច តំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ** ការប្រាកដឡើងនៃរឿងនោះ ដោយប្រការមិនពិត តាមដែលកាន់យក ។

បណ្ដាមិច្ឆាទិដ្ឋិទាំងនោះ កម្មបថដាច់ទៅ ព្រោះនត្ថិកទិដ្ឋិ អហេតុកទិដ្ឋិ និងអកិរិយទិដ្ឋិប៉ុណ្ណោះ, កម្មបថមិនដាច់ទៅ ព្រោះទិដ្ឋិដទៃៗ ៕

## សម្តែងអំពីអកុសលកម្មបថ ៥ ប្រភេទ

គប្បីជ្រាបអកុសលកម្មបថទាំង ១០ នេះ ដោយអាការ ៥ គឺ

**១-ធម្មតោ** ដោយធម្មៈ

**២-កោដ្ឋាសតោ** ដោយកោដ្ឋាសៈ

**៣-អារម្មណតោ** ដោយអារម្មណ៍

**៤-វេទនាតោ** ដោយវេទនា

**៥-មូលតោ** ដោយមូល ។

បណ្តាអាការទាំង ៥ នោះ ពាក្យថា “ដោយធម៌” សេចក្តីថា ក៏បណ្តាអកុសលកម្មបថទាំង ១០ នោះ អកុសលកម្មបថ ៧ ដោយលំដាប់ (កាយទុច្ចរិត ៣ វចីទុច្ចរិត ៤) ជាធម៌ គឺជាចេតនាប៉ុណ្ណោះ, អកុសលកម្មបថ ៣ មានអភិជ្ឈាជាដើម ជាធម៌សម្បយុត្តដោយចេតនា ។

ពាក្យថា “**ដោយកោដ្ឋាសៈ**” បានដល់ អកុសលកម្មបថ ៨ មិនជាមូល គឺអកុសលកម្មបថ ៧ ដោយលំដាប់ និងមិច្ឆាទិដ្ឋិ ។ អភិជ្ឈា និងព្យាបាទ ជាកម្មបថផង ជាមូលផង ។ ពិតណាស់ អភិជ្ឈា គឺលោភៈ ព្រោះសម្លឹងដល់មូលចាត់ជាអកុសលមូល, ព្យាបាទ គឺតួទោសៈ ជាអកុសលមូល ។

ពាក្យថា “ដោយអារម្មណ៍” បានដល់ **បាណាតិបាត** មានសង្ខារជាអារម្មណ៍ ព្រោះមានជីវិតិន្ទ្រិយជាអារម្មណ៍ ។ **អទិន្នាទាន** មានសត្វជាអារម្មណ៍ ឬ មានសង្ខារជាអារម្មណ៍ ។ **មិច្ឆាចារ** មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃផោដ្ឋព្វៈ, អាចារ្យពួកខ្លះពោលថា មិច្ឆាចារ មានសត្វជាអារម្មណ៍ដូច្នេះខ្លះ ។ **មុសាវាទ** មានសត្វជាអារម្មណ៍ ឬមានសង្ខារ ជាអារម្មណ៍ ។ **បិសុណាវាចា** មានអារម្មណ៍ដូចមុសាវាទ ។ **ផរុសវាចា** មានសត្វជាអារម្មណ៍ប៉ុណ្ណោះ ។ **សម្ផប្បលាបៈ** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ គឺទិដ្ឋ, សុតៈ, មុត្តៈ, វិញ្ញាតៈ ។ **អភិជ្ឈា** ក៏ដូចគ្នា ។ **ព្យាបាទ** មានសត្វជាអារម្មណ៍តែប៉ុណ្ណោះ ។ **មិច្ឆាទិដ្ឋិ** មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

ពាក្យថា **“ដោយវេទនា”** បានដល់**បាណាតិបាត** ជាទុក្ខវេទនា ។ ពិតណាស់ ព្រះរាជាទាំងឡាយ ទ្រង់ឃើញចោរហើយ សូម្បីសើចក៏ទ្រង់ត្រាស់ថា “អ្នកទាំងឡាយចូរទៅសម្លាប់វាចេញ” ក៏ពិតមែនហើយ, ប៉ុន្តែថា ចេតនាដែលដល់ការព្រមព្រះទ័យរបស់ព្រះរាជាទាំងនោះ ក៏ជាចេតនាដែលសម្បយុត្តដោយទុក្ខវេទនាពិត ។ **អទិន្នាទាន** មានវេទនា ៣, ជាការពិតណាស់ អទិន្នាទាននោះកាលបុគ្គលឃើញភណ្ឌៈរបស់អ្នកដទៃ ហើយរីករាយត្រេកអរកាន់យក ក៏ជាសុខ

វេទនា, កាលភ័យខ្លាច តក់ស្លុតហើយកាន់យក ក៏ជាទុក្ខវេទនា, ឬការពិចារណាផលដែលហូរចេញពីអទិន្នាទាន ក៏ជាទុក្ខវេទនាដូចគ្នា, តែក្នុងវេលាដែលលួចតាំងនៅក្នុងភាពជាកណ្ដាល អទុក្ខមសុខវេទនា ក៏កើតឡើង ។ **មិច្ឆាចារ** មានវេទនា ២ ដោយអំណាចនៃសុខវេទនា និងអទុក្ខមសុខវេទនា; តែក្នុងចិត្តដែលធ្លាក់ចុះ ចិត្តមិនជាឧបេក្ខាវេទនាទេ ។ **មុសាវាទ** មានវេទនា ៣ ដូចន័យដែលពោលហើយក្នុងអទិន្នាទាននោះឯង ។ **បិសុណាវាចា** ក៏មានវេទនា ៣ ដូចគ្នា។ **ផរុសវាចា** ជាទុក្ខវេទនា ។ សម្ផប្បលាបៈ មានវេទនា ៣ ។ ពិតណាស់ កាលបុគ្គលមានចិត្តត្រេកអរពោលរឿង មានរឿងលួចនាំនាងសីតា និងភារតយុទ្ធជាដើម កាលបុគ្គលដទៃកំពុងឱ្យសាធុការ មានការលើកឡើងនូវសំពត់ជាដើម សម្ផប្បលាបៈនោះ ជាសុខវេទនា ។ គ្រាកាលបុគ្គលម្នាក់ឱ្យថ្លៃឈ្នួលមុន តែខាងក្រោយមក អ្នកដទៃនិយាយថា “សូមលោកពោលរឿងតាំងពីដើម” ; ក្នុងពេលកំពុងប្រាប់ ទោមនស្សកើតឡើងដោយគិតថា “អញនឹងពោលកថាតិចតួចដែលជាប់តគ្នា ឬមិនហ្ន៎?” ជាទុក្ខវេទនា, កាលគេនិយាយកថាព្រងើយៗ ជាអទុក្ខមសុខវេទនា ។ **អភិជ្ឈា** មានវេទនា ២ ដោយអំណាចនៃសុខវេទនា និងឧបេក្ខាវេទនា ។ **មិច្ឆាទិដ្ឋិ** មានវេទនា ២ ដូចអភិជ្ឈាដែរ ។ **ព្យាបាទ** ជាទុក្ខវេទនា ។

ពាក្យថា **“ដោយមូល”** គឺបាណាតិបាត មានមូល ២ ដោយអំណាចនៃទោសមូល និងមោហមូល ។ **អទិន្នាទាន** ក៏មានមូល ២ គឺដោយអំណាចនៃទោសៈ និងមោហៈ ឬដោយអំណាចនៃលោភៈ និងមោហៈ ។ **មិច្ឆាចារ** ក៏មានមូល ២ គឺដោយអំណាចនៃលោភៈ និងមោហៈនោះឯង; **មុសាវាទ**មានមូល ២ គឺដោយអំណាចនៃទោសៈ និងមោហៈ ឬដោយអំណាចនៃលោភៈ និងមោហៈ។ **បិសុណាវាចា** និង**សម្ផប្បលាបៈ** ក៏មានមូលពីរដូចគ្នាដែរ; **ផរុសវាចា** មានមូលពីរដោយអំណាចនៃទោសៈ និងមោហៈ; **អភិជ្ឈា** មានមូលតែមួយដោយអំណាចនៃមោហៈ; **ព្យាបាទ** មានមូល ១ ដូចគ្នា; **មិច្ឆាទិដ្ឋិ** មានមូលពីរដោយអំណាចនៃលោភមូល និងមោហមូល ។

**ចប់កថាសម្តែងអំពីអកុសលកម្មបថ**

# កថាសម្ដែងអំពីកុសលកម្មបថ ១០

ធម៌ទាំង ១០ យ៉ាងនេះ គឺការវៀរចាកបាណាតិបាតជាដើម ( មាន ៧ យ៉ាង), អនភិជ្ឈា, អព្យាបាទ និងសម្មាទិដ្ឋិ ឈ្មោះថា **កុសលកម្មបថ** ។ បណ្ដាកុសលកម្មបថទាំង ១០ នោះ បាណាតិបាតជាដើម មានសេចក្ដីអធិប្បាយទុករួចហើយ ។ ធម៌ដែលឈ្មោះថា **វិរតិ** ព្រោះអត្ថថា ជាគ្រឿងវៀរចាកបាណាតិបាតជាដើម ដោយធម៌នេះ ឬវៀរដោយខ្លួនឯង, ឬថា ធម៌នេះគ្រាន់តែវៀរប៉ុណ្ណោះ ។ ការវៀររបស់បុគ្គលអ្នកវៀរចាក បាណាតិបាតសម្បយុត្តដោយកុសលចិត្តតាមដែលត្រាស់ទុកយ៉ាងនេះថា "ការឈប់ ការវៀរចាកបាណាតិបាតណា មានក្នុងសម័យនោះ"*, វិរតិ (ការវៀរ) មាន ៣ ប្រភេទ គឺ

**១-សម្បត្តវិរតិ** ការវៀរចាកដោយការដល់ចំពោះ(វត្ថុដែលគួរវៀរ)

**២-សមាទានវិរតិ** ការវៀរចាកព្រោះសមាទានសិក្ខាបទហើយ

**៣-សមុច្ឆេទវិរតិ** ការវៀរចាកដោយដាច់ស្រឡះ ។

---

* អភិ. ។

អដ្ឋសាលិនី

បណ្ដាវិរតិទាំង ៣ ប្រភេទនោះ វិរតិណាដែលកើតឡើងដល់បុគ្គលអ្នកមិនបានសមាទានសិក្ខាបទទាំងឡាយ ដែលពិចារណាដល់ការកើត (ជាតិ) ការសូន្យ (វ័យ) និងពហុសច្ច (ភាពជាអ្នកចេះដឹងច្រើន) ជាដើមរបស់ខ្លួន ហើយមិនកន្លងវត្ថុដែលដល់ព្រម ដោយគិតថា "ការធ្វើបាបមានសភាពដូចនេះ មិនសមគួរដល់អញទេ" ដូច្នេះ គប្បីជ្រាបថាជា**សម្បត្តវិរតិ** ។ **សម្បត្តវិរតិ**នោះ មានរឿងជាឧទាហរណ៍ ដូចវិរតិរបស់ឧបាសកឈ្មោះ **ចក្កនៈ** * អ្នកនៅក្នុងកោះសីហឡ: ដូចតទៅនេះ ៖-

បានឮថា រោគកើតដល់មាតារបស់នាយចក្កនៈនោះ ក្នុងវេលាដែលគាត់នៅក្មេង ។ ពេទ្យប្រាប់ថា "គួរបានសាច់ទន្សាយស្រស់" ។ លំដាប់នោះ បងប្រុសរបស់នាយចក្កនៈ បានប្រើចក្កនៈទៅដោយពាក្យថា "ម្នាលប្អូនប្រុស អ្នកចូរទៅ, ចូរដើរទៅកាន់ស្រែ" នាយចក្កនៈនោះ ក៏ទៅក្នុងទីនោះ ។ ក៏សម័យនោះ មានទន្សាយមួយ មកដើម្បីទំពាស៊ីសន្ទូងខ្ចី, វាឃើញចក្កនៈនោះ ក៏ស្ទុះទៅដោយរហ័ស រួចក៏ជំពាក់ជើងនឹងវល្លិ៍ចងជាប់ ទើបធ្វើសំឡេងថា "**កិរិ កិរិ**" ។ ឯនាយចក្កនៈ ក៏ដើរទៅតាមសំឡេងនោះ រួចចាប់ទន្សាយនោះ

---

* ច្បាប់ខ្លះថា ជក្កនឧបាសក ។

ហើយគិតថា "អញនឹងផ្សំថ្នាំឱ្យមាតា" ទើបគិតទៀតថា "អញនឹងសម្លាប់សត្វដទៃ ព្រោះហេតុតែជីវិតរបស់មាតា កម្មនេះមិនគួរសោះឡើយ" ; លំដាប់នោះ ទើបព្រលែងទៅដោយពាក្យថា "ឯងចូរទៅស៊ីស្មៅ និងផឹកទឹកជាមួយនឹងទន្សាយទាំងឡាយក្នុងព្រៃនេះចុះ" ។ ពេលមកដល់ផ្ទះ បងសួរថា "ម្នាលប្អូន ឯងបានទន្សាយហើយឬ?" ចក្កនៈក៏បានប្រាប់រឿងនោះទាំងអស់; លំដាប់នោះ បងប្រុសបានជេរចក្កនៈ, ឯចក្កនៈនោះក៏ដើរទៅកាន់សំណាក់មាតា ហើយពោលអធិដ្ឋានសច្ចវាចាថា "តាំងពីកើតមក ខ្ញុំមិនដែលក្លែងសម្លាប់សត្វមានជីវិតសោះឡើយ" , ពេលនោះឯង មាតារបស់គាត់ក៏ជាចាករោគភ្លាម ។

ក៏វិរតិណាវមែងកើតឡើងដល់បុគ្គលអ្នកសមាទានសិក្ខាបទទាំងឡាយក្នុងកាលសមាទានសិក្ខាបទទាំងឡាយនុ៎ះឯង និងក្នុងការដែលហ៊ានលះបង់ជីវិតរបស់ខ្លួន មិនសម្លាប់ជីវិតសត្វដទៃ គប្បីជ្រាបថាជា**សមាទានវិរតិ** ។ ដូចវិរតិរបស់ឧបាសក អ្នកអាស្រ័យនៅទៀបភ្នំឈ្មោះ **ទន្តរវឌ្ឍមានៈ** មានសេចក្តីដូចតទៅនេះ ៖-

## ៦៦
### អដ្ឋសាលិនី

បានឮថា ឧបាសកនោះសមាទានសិក្ខាបទទាំងឡាយ ក្នុងសំណាក់ព្រះថេរៈឈ្មោះ **បិង្គលពុទ្ធរក្ខិត** អ្នកនៅក្នុងអម្ពរិយវិហារ * រួចក៏ទៅភ្ជួរស្រែ ។ គ្រានោះ គោរបស់គាត់បានបាត់ទៅ គាត់ដើរតាមគោនោះ ក៏បានឡើងទៅកាន់ភ្នំឈ្មោះ **ទន្តរវឌ្ឍមានៈ** ពេលនោះពស់ដ៏ធំបានរឹបគាត់ក្នុងទីនោះ គាត់គិតថា "អញនឹងកាត់ក្បាលពស់នេះ ដោយកាំបិតដ៏មុតនេះ" , ហើយគិតទៀតថា "អាត្មាអញបានទទួលសិក្ខាបទទាំងឡាយ ក្នុងសំណាក់គ្រូដែលគួរដល់ការសរសើរ ហើយទម្លាយសិក្ខាបទ ហេតុនេះ មិនសមគួរដល់អាត្មាអញឡើយ" ។ គាត់គិតយ៉ាងនេះរហូតអស់វារៈ ៣ ដង ទើបកាត់ចិត្តថា "អាត្មាអញស៊ូលះបង់ជីវិត មិនលះបង់សិក្ខាបទ" ទើបបោះចោលកាំបិតដ៏មុតដែលនៅលើស្មានោះឯងទៅក្នុងព្រៃ, ខណៈនោះឯង ពស់ធំនោះក៏ពន្លែងគាត់ ហើយបានជៀសចេញបាត់ទៅ ។

ក៏វិរតិណាដែលសម្បយុត្តដោយអរិយមគ្គ គប្បីជ្រាបថាជា **សមុច្ឆេទវិរតិ**, ចាប់ផ្ដើមអំពីសមុច្ឆេទវិរតិកើតឡើងហើយ ចិត្តរបស់អរិយបុគ្គលទាំងឡាយ ក៏មិនកើតឡើងថា "អញនឹងសម្លាប់សត្វ" ដូច្នេះទេ ៕

---

* ច្បាប់ខ្លះថា អម្ពតិស្សវិហារ ។

# សម្តែងអំពីកុសលកម្មបថ ៥ ប្រភេទ

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងកុសលកម្មបថទាំងនេះ ដោយអាការ ៥ យ៉ាង ដូចអកុសលកម្មបថ គឺដោយធម៌, ដោយកោដ្ឋាសៈ, ដោយអារម្មណ៍, ដោយវេទនា និងដោយមូល ។

បណ្តាកុសលកម្មបថ ៥ ប្រភេទនោះ ពាក្យថា **ដោយធម៌** បានដល់កុសលកម្មបថ ៧ (កាយសុចរិត ៣ វចីសុចរិត ៤) ក្នុងកុសលកកម្មបថ ១០ នោះ ជាចេតនា និងវិរតិ, ឯកម្មបថ ៣ ខាងចុង ជាធម៌សម្បយុត្តដោយចេតនាប៉ុណ្ណោះ ។

ពាក្យថា **ដោយកោដ្ឋាសៈ** សេចក្តីថា កម្មបថ ៧ ដោយលំដាប់ជាកម្មបថតែម្យ៉ាង, មិនជាមូល, កម្មបថ ៣ ខាងចុង ជាកម្មបថផងជាមូលផង ។ ពិតណាស់ អនភិជ្ឈា គឺអលោភៈ សំឡឹងដល់មូលហើយ ជាកុសលមូល, អព្យាបាទ គឺអទោសៈ ជាកុសលមូល, សម្មាទិដ្ឋិ គឺអមោហៈជាកុសលមូល ។

ពាក្យថា **ដោយអារម្មណ៍** សេចក្តីថា អារម្មណ៍ទាំងឡាយរបស់បាណាតិបាតជាដើមនោះឯង ក៏ជាអារម្មណ៍របស់កុសលកម្មទាំងនោះ ។ ពិតណាស់

ការវៀរចាកវត្ថុដែលគប្បីកន្លងនោះឯង ឈ្មោះថា **វេរមណី** ។ ដូចយ៉ាងថា អរិយមគ្គមាននិព្វានជាអារម្មណ៍ តែងលះកិលេសទាំងឡាយ យ៉ាងណា, កម្មបថទាំងនេះមានជីវិតិន្ទ្រិយ៍ជាដើមជាអារម្មណ៍ គប្បីជ្រាបថា តែងលះភាពជាអ្នកទ្រុស្តសីលទាំងឡាយ មានបាណាតិបាតជាដើម ក៏យ៉ាងនោះដែរ ។

ពាក្យថា **ដោយវេទនា** សេចក្តីថា កុសលកម្មបថទាំងឡាយទាំងអស់ជាសុខវេទនា ឬជាឧបេក្ខាវេទនា ។ ពិតមែនហើយ សំឡឹងដល់កុសលឈ្មោះថា **ទុក្ខវេទនារមែងមិនមាន** ។

ពាក្យថា **ដោយមូល** សេចក្តីថា កម្មបថ ៧ ដោយលំដាប់ មានមូល ៣ គឺ**អលោភៈ, អទោសៈ** និង**អមោហៈ** របស់បុគ្គលអ្នកវៀរដោយចិត្ត ដែលសម្បយុត្តដោយញាណ, មានមូល ២ របស់បុគ្គលអ្នកវៀរដោយចិត្ត មិនប្រកបដោយញាណ, (ញាណវិប្បយុត្ត); និងមានមូល ២ របស់បុគ្គលអ្នកវៀរដោយចិត្តដែលសម្បយុត្តដោយអនភិជ្ឈា និងញាណ, មានមូលតែ ១ របស់បុគ្គលអ្នកវៀរដោយចិត្ត មិនប្រកបដោយញាណ; តែអលោភៈមិនជាមូលរបស់ខ្លួននឹងខ្លួនទេ ។ សូម្បីក្នុងអព្យាបាទ ក៏មានន័យដូចគ្នានេះដែរ ។ **សម្មាទិដ្ឋិ** មានមូល ២ ដោយអំណាចនៃទោសៈ និងអលោភៈ ឈ្មោះថា

កុសលកម្មបថ មាន ១០ ទាំងនេះ ដោយប្រការដូច្នេះ ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបការប្រៀបធៀបកម្មបថ ក្នុងទីនេះ ៖-

ពិតមែនហើយ អសំវរៈដែលកើតតាមទ្វារនៃសម្ផស្ស ៥ ជាមនោកម្មខាងអកុសលប៉ុណ្ណោះ ។ អសំវរៈដែលកើតឡើងតាមទ្វារនៃមនោសម្ផស្ស ជាកម្មសូម្បីទាំង ៣ យ៉ាង; ព្រោះថា អសំវរៈនោះ ដល់ការកម្រើកក្នុងកាយទ្វារហើយ ជាកាយកម្មខាងអកុសល, ដល់ការកម្រើកក្នុងវចីទ្វារ ក៏ជាវចីកម្មខាងអកុសល, មិនដល់ការកម្រើកក្នុងទ្វារទាំង ២ នេះ ក៏ជាមនោកម្មខាងអកុសល ។ អសំវរៈដែលកើតឡើងដោយអំណាចនៃអសំវរៈ ៥ ជាមនោកម្មខាងអកុសលប៉ុណ្ណោះ។ អសំវរៈដែលកើតឡើងដោយអំណាចទ្វារនៃអសំវរៈដែលកាយកម្រើក ជាកាយកម្មខាងអកុសលប៉ុណ្ណោះ ។ អសំវរៈដែលកើតឡើង ដោយអំណាចទ្វារនៃអសំវរៈ ដោយឱ្យវាចាកម្រើក ជាវចីកម្ម ខាងអកុសលប៉ុណ្ណោះ ។ អសំវរៈដែលកើតឡើងដោយអំណាចទ្វារនៃអសំវរៈដោយឱ្យមនោកម្រើកទៅ ជាមនោកម្មខាងអកុសលប៉ុណ្ណោះ ។ កាយទុច្ចរិត ៣ ប្រការ ជាកាយកម្មខាងអកុសលប៉ុណ្ណោះ ។ វចីទុច្ចរិត ៤ ប្រការ ជាវចី

កម្មខាងអកុសលប៉ុណ្ណោះ មនោទុច្ចរិត ៣ ប្រការ ក៏ជាមនោកម្ម ខាងអកុសលប៉ុណ្ណោះ ។

សូម្បីសំវរៈដែលកើតដោយអំណាចទ្វារនៃសម្ផស្ស ៥ ក៏ជាមនោកម្មខាងកុសលប៉ុណ្ណោះ។ សូម្បីសំវរៈនេះ ដែលកើតដោយអំណាចនៃមនោសម្ផស្ស ក៏ជាកម្មទាំង ៣ ប្រការដូចអសំវរៈដែរ ។ ក៏សំវរៈដែលកើតហើយ ដោយអំណាចទ្វារនៃសម្ផស្ស ៥ ក៏ជាមនោកម្មខាងកុសលប៉ុណ្ណោះ ។ សំវរៈដែលកើត ឡើងដោយអំណាចទ្វារនៃការកម្រើកកាយ ក៏ជាកាយកម្មខាងកុសលប៉ុណ្ណោះ, សំវរៈដែលកើតឡើងដោយអំណាចទ្វារនៃសំវរៈ ឱ្យកម្រើកវាចា ក៏ជាវចីកម្មខាងកុសលប៉ុណ្ណោះ ។ សំវរៈដែលកើតឡើងដោយអំណាចទ្វារនៃសំវរៈផ្លូវចិត្ត ក៏ជាមនោកម្មខាងកុសលដូចគ្នា ។ កាយសុចរិត ៣ ប្រការ ជាកាយកម្មខាងកុសលប៉ុណ្ណោះ ។ វចីសុចរិត ៤ ប្រការជាវចីកម្ម ខាងកុសលប៉ុណ្ណោះ, មនោសុចរិត ៣ ប្រការ ក៏ជាមនោកម្មខាងកុសល ដូចគ្នា ។

កាយកម្មដែលជាអកុសល មិនកើតឡើងដោយអំណាចទ្វារនៃសម្ផស្ស ៥ តែរមែងកើតឡើងដោយអំណាចទ្វារនៃមនោសម្ផស្សប៉ុណ្ណោះ ។ វចីកម្មខាងអកុសលក៏ដូចគ្នា, ឯមនោកម្មខាងអកុសលកើតឡើងដោយអំណាចទ្វារនៃ

សម្ផស្ស ៦; មនោកម្មនោះ ដល់ការកម្រើកក្នុងកាយទ្វារ និងវចីទ្វារហើយ ក៏ជាកាយកម្ម និងវចីកម្មខាងអកុសល; មនោកម្មមិនដល់ការកម្រើក ក្នុងកាយទ្វារ និងវចីទ្វារ ក៏ជាមនោកម្មខាងអកុសលប៉ុណ្ណោះ ។ ដូចយ៉ាងថា កាយកម្មខាងអកុសល មិនកើតឡើងដោយអំណាចទ្វារនៃសម្ផស្ស ៥ យ៉ាងណា, កាយកម្មខាងអកុសល ក៏មិនកើតឡើងដោយអំណាចទ្វារនៃអសំវរៈ ៥ យ៉ាងនោះដែរ; តែកើតឡើងដោយអំណាចទ្វារនៃអសំវរៈ ដែលញ៉ាំងកាយឱ្យកម្រើក និងដោយអំណាចទ្វារនៃអសំវរៈផ្លូវវាចា មិនកើតឡើងដោយអំណាចទ្វារនៃអសំវរៈផ្លូវមនោ ។ សូម្បីវចីកម្មដែលជាអកុសល មិនកើតឡើងដោយអំណាចទ្វារ នៃអសំវរៈ ៥ ទេ, កើតឡើងដោយទ្វារនៃអសំវរៈដែលញ៉ាំងកាយ និងវាចាឱ្យកម្រើក, មិនកើតឡើងដោយអំណាចទ្វារនៃអសំវរៈផ្លូវមនោឡើយ ។ មនោកម្មខាងអកុសល រមែងកើតសូម្បីដោយអំណាចទ្វារនៃអសំវរៈ ៨ នោះឯង, សូម្បីកាយកម្មខាងកុសលជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ចំណែកសេចក្ដីផ្សេងគ្នាមានដូច្នេះ ៖-

កាយកម្ម និងវចីកម្មដែលជាអកុសល មិនកើតឡើងដោយអំណាចទ្វារនៃអសំវរៈផ្លូវមនោ យ៉ាងណា, កាយកម្ម និងវចីកម្មដែលជាកុសល មិន

កើតឡើងដោយអំណាចទ្វារនៃអសំវរៈ ខាងមនោយ៉ាងនោះដែរ ។ តែថា កាយកម្ម និងវចីកម្មខាងកុសលទាំងនេះ កើតឡើងដល់បុគ្គលអ្នកមិនញ៉ាំងចំណែកកាយ និងវាចា ឱ្យកម្រើកទទួលនូវសិក្ខាបទទាំងឡាយសូម្បីក្នុងទ្វារនៃមនោសំវរៈ ។

ដោយប្រការដូចពោលមកហើយ កុសលចិត្តដែលជាកាមាវចរ ឈ្មោះថាកើតឡើងក្នុងមនោទ្វារនោះ ដោយអំណាចនៃកម្ម និងទ្វារ ៣ យ៉ាង, មិនកើតឡើងដោយអំណាចនៃទ្វារ និងវិញ្ញាណ ៥ ។ ការសោយអារម្មណ៍ ជាសុខ ឬជាទុក្ខ ជាអទុក្ខមសុខនេះណា រមែងកើតឡើងព្រោះចក្ខុសម្ផស្ស ជាបច្ច័យ ។ ក៏ដោយន័យនេះ កុសលចិត្តជាកាមាវចរៈ រមែងកើតឡើង ដោយអំណាចទ្វារនៃសម្ផស្ស ៦, មិនកើតឡើងដោយអំណាចទ្វារនៃអសំវរៈ ៨; កើតឡើងដោយអំណាចទ្វារនៃសំវរៈ ៨; មិនកើតឡើងដោយអំណាចនៃអកុសលកម្មបថ ១០, កើតឡើងដោយអំណាចនៃកុសលកម្មបថ ១០; ព្រោះហេតុដូច្នោះ កុសលចិត្តនេះ ទើបកើតឡើងដោយអំណាចទ្វារនៃកម្ម ៣ យ៉ាង ឬដោយអំណាចទ្វារនៃផស្សៈ ៦ ឬក៏ដោយអំណាចទ្វារនៃសំវរៈ ៨ ឬថាដោយអំណាចនៃកុសលកម្មបថ ១០ ។ ពាក្យថា "កាមាវចកុសលចិត្ត

កើតឡើងប្រារព្ធរូបាអារម្មណ៍ ។ល។ ឬធម្មារម្មណ៍" ត្រាស់ទុកហើយ, កាមាវចរកុសលចិត្តទាំងអស់ ក៏ត្រាស់ទុកហើយដែរ ។

**ចប់កថាពោលអំពីទ្វារ**

---

គប្បីជ្រាបការប្រកបសេចក្តីក្នុងព្រះបាលីនេះថា **"យំ យំ វា បនារព្ភ"** ដូចតទៅនេះ ៈ-

បណ្តារូបារម្មណ៍ជាដើម តាមដែលពោលហើយខាងដើម ប្រារព្ធរូបជាអារម្មណ៍, គឺធ្វើរូបឱ្យជាអារម្មណ៍ក្តី; ឬប្រារព្ធសំឡេងជាអារម្មណ៍ក្តី ។ល។ ឬក៏ប្រារព្ធនូវធម្មារម្មណ៍ក្តី ហើយទើបកើតឡើង; ដោយពាក្យមានប្រមាណប៉ុណ្ណេះ ដូចគ្នានឹងការទទួលរងអារម្មណ៍មួយប៉ុណ្ណោះ ក្នុងអារម្មណ៍ទាំងនេះ អារម្មណ៍ណាមួយរបស់ចិត្តនេះ។ ក៏ចិត្តនេះរបស់បុគ្គលម្នាក់ ក្នុងសម័យមួយ ប្រារព្ធរូបារម្មណ៍ ហើយកើតឡើង ឬសូម្បីប្រារព្ធអារម្មណ៍ណាមួយ មានសំឡេងជាដើមរបស់បុគ្គលដទៃ ក្នុងសម័យដទៃ ទើបកើតឡើងម្តងទៀត ។ ក៏ចិត្តនេះមានអារម្មណ៍កើតឡើងយ៉ាងនេះ ក៏មិនមានលំដាប់នេះថា ចិត្តមួយដួងប្រារព្ធនូវអារម្មណ៍មុន ក្នុងភពមួយប្រព្រឹត្តទៅហើយ, ទើបប្រារព្ធសទ្ទា

រម្មណ៍ខាងក្រោយដូច្នេះ ។ សូម្បីលំដាប់នេះថា បណ្តាអារម្មណ៍មានរូបជាដើម មានពណ៌ខៀវជាអារម្មណ៍មុនហើយ មានពណ៌លឿងជាអារម្មណ៍ ក្នុងខាងក្រោយដូច្នេះ ក៏មិនកំណត់ទុកដើម្បីសម្តែងចិត្តនោះៗឯង មានអារម្មណ៍គ្រប់យ៉ាងនេះ និងការមិនមានលំដាប់ និងសូម្បីក្នុងការមិនមានលំដាប់ ក៏នៅមិនមានការកំណត់អារម្មណ៍ មានពណ៌ខៀវ និងពណ៌លឿងជាដើម ទើបត្រាស់ពាក្យថា **"យំ យំ វា បនារព្ភ"** ។ ពាក្យនេះ លោកអធិប្បាយទុកថា ៖-

បណ្តាអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមនេះ មិនមែនមានអារម្មណ៍ណាមួយជាអារម្មណ៍ទេ, តាមពិត ប្រារព្ធអារម្មណ៍ណាក៏បាន ហើយទើបកើតឡើង, ឯចិត្តនោះសូម្បីកាលកើតឡើងយ៉ាងនេះ ក៏មិនកើតឡើងសូម្បីដោយលំដាប់យ៉ាងនេះថា "មានរូបជាអារម្មណ៍មុន ខាងក្រោយទើបមានសំឡេងជាអារម្មណ៍" , តែថា ប្រារព្ធអារម្មណ៍ណាៗ ក៏បាន ហើយទើបកើតឡើង ។ អធិប្បាយថា ធ្វើអារម្មណ៍យ៉ាងណាក៏ដោយ ក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ហើយទើបកើតឡើងដោយបដិលោម ឬដោយអនុលោម ឬក៏ដោយន័យមានអារម្មណ៍មួយជាចន្លោះ ឬថាពីរជាចន្លោះជាដើម ។ សូម្បីរូបារម្មណ៍ទាំងឡាយ ក៏មិនកើតដោយការកំណត់នេះថា ចិត្ត

នេះ មានពណ៌ខៀវជាអារម្មណ៍មុន, ខាងក្រោយទើបមានពណ៌លឿងជាអារម្មណ៍, តែប្រារព្ធអារម្មណ៍ណា១ ក៏បានអធិប្បាយថា ចិត្តប្រារព្ធរូបារម្មណ៍ណាមួយ បណ្តារូបារម្មណ៍ទាំងឡាយ មានពណ៌ខៀវ និងពណ៌លឿងជាដើម ហើយទើបកើតឡើង ។ សូម្បីសទ្ទារម្មណ៍ជាដើម ក៏ន័យនេះដែរ; នេះជាការប្រកបសេចក្តីអធិប្បាយទុកយ៉ាងនេះមុន នៅមានសេចក្តីដែលគួរណែនាំដទៃទៀត ដូចតទៅនេះ ៖-

រូបជាអារម្មណ៍របស់ចិត្តនេះមាន ព្រោះហេតុនោះ ទើបចិត្តនេះ ឈ្មោះថា **មានរូបជាអារម្មណ៍** ។ល។ ធម៌ជាអារម្មណ៍របស់ចិត្តនេះមាន ព្រោះហេតុនោះ ទើបចិត្តនេះ ឈ្មោះថា **មានធម៌ជាអារម្មណ៍** ។ ព្រះមានព្រះភាគត្រាស់ថា "ចិត្តមានរូបារម្មណ៍ ។ល។ ឬមានធម្មារម្មណ៍កើតឡើង" ដោយប្រការដូច្នេះហើយ ទើបត្រាស់ទៀតថា "ឬក៏ចិត្តប្រារព្ធនូវអារម្មណ៍ណា១ ហើយទើបកើតឡើង" ។

សេចក្តីនៃព្រះតម្រាស់ដែលត្រាស់ថា "ចិត្តប្រារព្ធអារម្មណ៍ណា១ ទើបកើតឡើង" ដូច្នេះនោះ គប្បីជ្រាបន័យដែលពោលហើយ ក្នុងរូបជាដើមទាំងនេះចុះ ។

ចំណែកក្នុង**មហាអដ្ឋកថា** មានខសេចក្ដីពោលទុកត្រឹមនេះថា ព្រះភគវាទ្រង់ត្រាស់ទុកក្នុងយេវាបនកន័យថា "មិនមានអ្វីថ្មីសោះ, គឺគ្រាន់តែជាអារម្មណ៍ដែលកាន់យកហើយ ក្នុងគ្រាក្រោយនុ៎ះឯង" ដូច្នេះ ទើបត្រាស់ព្រះតម្រាស់នេះ ដើម្បីពោលថា "ប្រារព្ធរូប ។ល។ ឬប្រារព្ធធម៌ ឬប្រារព្ធអារម្មណ៍នេះ ឬប្រារព្ធអារម្មណ៍នោះ" ៕

## អធិប្បាយពាក្យថាធម៌មានផស្សៈជាដើម

ពាក្យថា "**តស្មឹ សមយេ**" នេះ ជាពាក្យបដិនិទ្ទេស (គឺការវិលត្រឡប់មកអធិប្បាយទៀត) ដោយកំណត់សម័យ ទ្រង់លើកឡើងសម្ដែងដោយមិនទៀងទាត់ ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្ដីនៃពាក្យថា **តស្មឹ សមយេ** នោះថា "កាមាវចកុសលចិត្ត កើតឡើងក្នុងសម័យណា, ផស្សៈ ។ល។ អវិក្ខេបៈ ក៏កើតឡើងក្នុងសម័យនោះៗ ឯង" ។

ក្នុងសេចក្ដីទាំងនោះ ពាក្យជាមតិរបស់អាចារ្យទាំងឡាយ ក្រៅអំពីអដ្ឋកថា ពោលទុកដូច្នេះថា "គប្បីធ្វើការប្រកបអធិប្បាយធម៌ទាំងឡាយមានផស្សៈជាដើមដូចចិត្តនេះឯង ដោយអំណាចនៃបទដែលគិតបាន" ដោយ

ន័យមានជាអាទិ៍ថា “ផស្សៈរមែងកើតឡើង, សួរថា ផស្សៈកើតជាអ្វី? ឆ្លើយថា កើតជាកាមាវចរកុសល, ជាសោមនស្សសហគតៈ” ; ព្រោះថា វេទនាមិនបានក្នុងពាក្យថា “សោមនស្សហគតៈ” , និងក្នុងបញ្ចិន្ទ្រិយ ក៏មិនបានក្នុងពាក្យថា “ញាណសម្បយុត្ត” , ព្រោះហេតុដូច្នោះ ទើបពោលថា “ដោយអំណាចនៃបទដែលគិតបាន” ; តែពាក្យដែលអាចារ្យពោលហើយនេះ មិនគួរយល់ឃើញថាជាសារៈទេ ។

សួរថា ក៏ព្រោះហេតុអ្វីក្នុងពាក្យថា “**ផស្សោ ហោតិ**” ជាដើមនេះ ព្រះភគវន្តមុនី ត្រាស់ផស្សៈទុកមុន?

ឆ្លើយថា ព្រោះផស្សៈញុំាងចិត្តឱ្យធ្លាក់ចុះទៅមុន* ។

ពិតណាស់ ផស្សៈជាធម៌ញុំាងចិត្តឱ្យធ្លាក់ចុះទៅមុនក្នុងអារម្មណ៍ ប៉ះពាល់អារម្មណ៍ ហើយទើបកើតឡើង, ព្រោះហេតុដូច្នោះ ទើបត្រាស់ផស្សៈមុន; ក៏ចិត្តប៉ះត្រូវអារម្មណ៍ដោយផស្សៈ ហើយទើបសោយអារម្មណ៍ ដោយវេទនា, ចាំអារម្មណ៍បានដោយសញ្ញា, គិតដោយចេតនា, ដោយហេតុនោះ ព្រះភគវាទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលផស្សៈពាល់ត្រូវ

---

* បាលីកន្លែងខ្លះថា **ចិត្តស្ស បឋមាភិនិបាតត្តា** ប្រែថា ព្រោះជាការប្រជុំរួមគ្នានៃចិត្តជាគ្រាដំបូង ។

ហើយ រមែងសោយអារម្មណ៍, អ្នកដែលផស្សៈពាល់ត្រូវហើយ រមែងចាំអារម្មណ៍, អ្នកដែលផស្សៈពាល់ត្រូវហើយ រមែងគិតអារម្មណ៍” [១៩] ។

ម្យ៉ាងទៀត ផស្សៈដែលបច្ច័យដ៏មានកម្លាំងរបស់សម្បយុត្តធម៌ ដែលកើតព្រមគ្នា ដូចប្រាសាទ ឈ្មោះថា សសរជាបច្ច័យសំខាន់របស់ទព្វសម្ភារៈដ៏សេស គឺធ្នឹម, ដៃរណែង, ជើងជញ្ជាំង, កំពូល, ផ្លាន, ហោជាង, ក្ដោង និងផ្ទោង ជាវត្ថុដែលជាប់ដោយសសរ តាំងនៅលើសសរដូច្នោះ; ផស្សៈនេះក៏ដូចនឹងសសរ, សម្បយុត្តធម៌ដែលកើតព្រមគ្នា ដូចទព្វសម្ភារៈដ៏សេស; ព្រោះហេតុដូច្នោះ ទើបត្រាស់ផស្សៈមុន; តែសេចក្ដីដែលពោលហើយនេះមិនមែនជាហេតុ (ការណ៍) ទេ, ព្រោះថា ធម៌ខនេះមិនគ្រាន់តែថា “ផស្សៈនេះកើតឡើងមុនធម៌ ដែលកើតឡើងក្នុងចិត្តមួយដួងទេ, តែសម្បយុត្តធម៌នេះ កើតខាងក្រោយ” ដូច្នេះ ទាំងហេតុ (ការណ៍) របស់ផស្សៈ សូម្បីក្នុងភាពនៃបច្ច័យដែលមានកម្លាំង ក៏មិនប្រាកដ, ព្រះមានព្រះភាគទ្រង់ត្រាស់ផស្សៈមុន ដោយវារៈនៃទេសនាប៉ុណ្ណោះ ។ ការពិតសូម្បីនាំមកពោលថា “វេទនាកើត, ផស្សៈកើត; សញ្ញាកើត, ផស្សៈកើត; ចេតនាកើត, ផស្សៈ

---

[១៩] សំ. សឡា.។

កើត; ចិត្តកើត, ផស្សៈកើត; វេទនាកើត, សញ្ញាកើត, ចេតនាកើត, វិតក្កៈកើត” ក៏គួរ ។ ក៏ផស្សៈនោះឯង គប្បីជ្រាបថា ត្រាស់ទុកមុនដោយវារៈនៃទេសនាដូច្នេះ ។ ក៏ផស្សៈនេះ យ៉ាងណា, សូម្បីធម៌ដែលសេសក្រៅពីនេះ ក៏គប្បីជ្រាបយ៉ាងនោះ ឈ្មោះថា លំដាប់នៃធម៌ដែលកើតមុន និងកើតក្រោយបណ្ឌិតមិនគប្បីស្វែងរកទេ; តែគប្បីស្វែងរកធម៌ទាំងឡាយ ដោយអត្ថនៃពាក្យ (វចនត្ថៈ) លក្ខណៈ និងរសជាដើមប៉ុណ្ណោះ; តើដូចម្ដេច? គឺ ៖-

## អត្ថនៃពាក្យថាផស្សៈ

**ផុសតីតិ ផស្សោ** ធម៌ដែលឈ្មោះថា ផស្សៈ ព្រោះអត្ថថា ពាល់ត្រូវអារម្មណ៍, ផស្សៈនោះ មានលក្ខណាទិចតុក្កៈដូច្នេះ ៖-

-**ផុសនលក្ខណោ** មានការពាល់ត្រូវអារម្មណ៍ជាលក្ខណៈ

-**សំឃដ្ដនរសោ** មានការតភ្ជាប់ជាកិច្ច

-**សន្និបាតបច្ចុប្បដ្ឋានោ** មានការប្រជុំព្រមគ្នាជាផល

-**អាបាថគតវិសយបទដ្ឋានោ** មានអារម្មណ៍មកកាន់គន្លង ជាហេតុជិត ។

ពិតណាស់ ផស្សៈនេះសូម្បីមិនមែនជារូបធម៌ តែក៏ប្រព្រឹត្តទៅដោយអាការការពាល់ត្រូវអារម្មណ៍តែប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **មានការពាល់ត្រូវអារម្មណ៍ជាលក្ខណៈ**, ផស្សៈនេះសូម្បីមិនជាប់នឹងអ្វីត្រឹមតែម្យ៉ាង, តែក៏តភ្ជាប់ចិត្ត និងអារម្មណ៍ ដូចរូប និងចក្ខុ, សំឡេង និងសោតៈ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា មានការតភ្ជាប់ជាកិច្ចរស ម្យ៉ាងទៀតគប្បីជ្រាបថា មានការតភ្ជាប់ជារស ដោយ (ពាក្យថា) រស គឺមានអត្ថថាសម្បត្តិ ព្រោះការកើតតភ្ជាប់វត្ថុនិងអារម្មណ៍; សមដូចពាក្យអដ្ឋកថាពោលទុកថា "ផស្សៈដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានការប៉ះខ្ទប់អារម្មណ៍ ជាលក្ខណៈមិនមែន ក៏មិនមានដែរ (គឺមាន), តែផស្សៈប្រព្រឹត្តទៅតាមផ្លូវបញ្ចទ្វារប៉ុណ្ណោះ មានការតភ្ជាប់ជាកិច្ច ពិតមែនហើយ ពាក្យថា មានការប៉ះខ្ទប់អារម្មណ៍ ជាលក្ខណៈក្តី មានការតភ្ជាប់ជាកិច្ចក្តី ជាឈ្មោះរបស់ផស្សៈ ដែលប្រព្រឹត្តទៅក្នុងផ្លូវបញ្ចទ្វារ, ពាក្យថា មានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ ជាឈ្មោះរបស់ផស្សៈ ដែលប្រព្រឹត្តទៅក្នុងផ្លូវមនោទ្វារ, តែពាក្យថា មានការតភ្ជាប់ជាកិច្ច មិនជាឈ្មោះរបស់ផស្សៈ ដែលប្រព្រឹត្តទៅតាមផ្លូវមនោទ្វារទេ" ដូច្នេះ លុះលោកពោលពាក្យនេះហើយ បាននាំ

សូត្រនេះមកថា “បពិត្រមហារាជ ពពែ ២ ក្បាលជល់គ្នា គប្បីឃើញភ្នែកដូចពពែមួយក្បាល, គប្បីឃើញរូបដូចពពែទី ២, គប្បីឃើញផស្សៈ ដូចការជល់គ្នារបស់ពពែទាំងពីរនោះ, ផស្សៈមានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ និងមានការតភ្ជាប់ជាកិច្ច ដោយអាការយ៉ាងនេះ ។ បពិត្រមហារាជ ក៏ដូចបាតដៃទាំងពីរខ្ទប់គ្នា គឺគប្បីយល់ចក្ខុ ដូចបាតដៃម្ខាង គប្បីយល់រូប ដូចបាតដៃទី ២ នោះ [*], ផស្សៈ មានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ និងមានការតភ្ជាប់គ្នាជាកិច្ច ដោយអាការដូច្នេះ” [២០] សេចក្ដីពិស្ដារមានត្រឹមប៉ុណ្ណេះ ។

ម្យ៉ាងទៀត ព្រះអង្គត្រាស់ចក្ខុវិញ្ញាណជាដើម ដោយឈ្មោះថា ចក្ខុជាដើម ក្នុងប្រយោគថា **“ចក្ខុនា រូបំ ទិស្វា = ឃើញរូបដោយភ្នែក”** ជាដើមយ៉ាងណា [២១], សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបថា ចក្ខុវិញ្ញាណជាដើមទាំងនោះ ត្រាស់ទុកដោយឈ្មោះថា ចក្ខុជាដើម ក៏យ៉ាងនោះដែរ ។ ព្រោះហេតុដូច្នោះ គប្បីជ្រាបសេចក្ដីនៃពាក្យមានជាអាទិ៍ថា **“ឯវំ ចក្ខុ ឧដ្ឋព្វំ”** ដោយ

---

[*] បាតដៃម្ខាងតាងឱ្យចក្ខុ, បាតដៃម្ខាងទៀត តាងឱ្យរូបារម្មណ៍ (សម្រួលតាមច្បាប់អង់គ្លេស) ។

[២០] មិលិន្ទ. ។

[២១] អភិ. ។

ន័យនេះថា គប្បីឃើញចក្ខុវិញ្ញាណដូច្នោះ ។ កាលបើហេតុយ៉ាងនេះមាន ព្រោះការតភ្ជាប់ចិត្ត និងអារម្មណ៍ ក្នុងសូត្រនេះ ផស្សៈទើបសម្រេចជាការ តភ្ជាប់កិច្ច ដោយកិច្ច ដោយរសជាអត្ថ ។

ក៏ផស្សៈនោះ មានការប្រជុំព្រមគ្នាជាបច្ចុប្បដ្ឋាន ព្រោះសម្ដែងឱ្យ ជ្រាប ដោយអំណាចនៃការធ្វើរបស់ខ្លួន ពោលគឺការប្រជុំព្រមគ្នារបស់ធម៌ ៣ គឺ (អារម្មណ៍, វត្ថុ និងវិញ្ញាណ) ។ ពិតមែនហើយ ផស្សៈនេះ ប្រកាស ឱ្យដឹងដោយអំណាចនៃការធ្វើក្នុងទីនោះៗ យ៉ាងនេះ "ឈ្មោះថា ផស្សៈ ព្រោះមានការប្រជុំសភាវធម៌ ៣ យ៉ាង"។ ព្រោះហេតុដូច្នោះ គប្បីជ្រាប សេចក្ដីនៃបទព្រះសូត្រនេះថា "ឈ្មោះថា ផស្សៈ ព្រោះមានការប្រជុំ នៃ សភាវៈធម៌ ៣" , មិនមែនផស្សៈត្រឹមតែការប្រជុំប៉ុណ្ណោះទេ, តែផស្សៈ រមែងប្រាកដដោយអាការនោះៗ ឯង ព្រោះការប្រកាសហើយយ៉ាងនេះ ព្រោះហេតុដូច្នោះ ទើបពោលថា "**មានការប្រជុំជាអាការប្រាកដ**" ។

ក៏ផស្សៈនោះ មានវេទនាជាបច្ចុប្បដ្ឋាន ព្រោះបច្ចុប្បដ្ឋានមានវេទនា ជាអត្ថ ។ ពិតមែនហើយ ផស្សៈនេះ រមែងញ៉ាំងវេទនាឱ្យប្រាកដ, គឺឱ្យកើត ឡើង; ក៏ផស្សៈនេះ កាលឱ្យវេទនាកើតឡើង សូម្បីនឹងមានបច្ច័យដទៃ

ពោលគឺវត្ថុ និងអារម្មណ៍ ។ តែក៏នាំឱ្យវេទនាកើតឡើងចំពោះចិត្ត ដែលជាទីអាស្រ័យរបស់ខ្លួនប៉ុណ្ណោះ, ព្រោះខ្លួនអាស្រ័យចិត្តគប្បីជ្រាបថា មិនធ្វើឱ្យវេទនាកើតឡើងក្នុងវត្ថុ ឬអារម្មណ៍ សូម្បីនឹងជាបច្ច័យរបស់ខ្លួន ដូចចំហាយក្តៅដែលអាស្រ័យនៅក្នុងធាតុ គឺអាចម៍ល័ក្ត រមែងធ្វើឱ្យកើតសេចក្តីទន់ក្នុងគ្រាដែលជាទីអាស្រ័យរបស់ខ្លួន សូម្បីព្រោះការក្តៅខាងក្រៅ ជាបច្ច័យ, តែមិនធ្វើឱ្យកើតការទន់ក្នុងការក្តៅ ពោលគឺស្ថានទីដែលប្រាសចាកអណ្តាតភ្លើងខាងក្រៅ សូម្បីជាបច្ច័យរបស់ខ្លួន ផស្សៈនេះលោកហៅថា “**មានអារម្មណ៍មកកាន់គន្លងជាបទដ្ឋាន គឺហេតុជិតឱ្យកើតឡើង**” ព្រោះការកើតឡើងនៃផស្សៈ មិនមានការរារាំងក្នុងអារម្មណ៍ ដែលប្រមូលមកនូវធម៌ទាំងនោះ និងឥន្ទ្រិយដែលតាក់តែងល្អហើយ ៕

## អត្ថនៃពាក្យថាវេទនា

**វេទយតីតិ វេទនា** ធម៌ដែលឈ្មោះថា **វេទនា** ព្រោះអត្ថថា ដឹងច្បាស់នូវអារម្មណ៍, វេទនានោះមានលក្ខណាទិចតុក្កៈដូច្នេះ

**-វេទយិតលក្ខណា** មានការដឹងច្បាស់នូវអារម្មណ៍ជាលក្ខណៈ

**អនុភវនរសា** មានការសោយនូវអារម្មណ៍ជាកិច្ច

**ឥដ្ឋាការសម្ភោគរសា** ឬមានការសោយអារម្មណ៍ដែលគួរប្រាថ្នាជាកិច្ច ។

**ចេតសិកអស្សាទបច្ចុប្បដ្ឋានា** មានការពេញចិត្តជាផល

**បស្សទ្ធិបទដ្ឋានា** មានបស្សទ្ធិជាបទដ្ឋាន ។

ពិតណាស់ វេទនាប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា **មិនមានការដឹងច្បាស់នូវអារម្មណ៍** ជាលក្ខណៈក៏ទេ (គឺមាន) តែលោកពោលថា “វេទនាមានការសោយអារម្មណ៍ជាកិច្ច បានចំពោះតែសុខវេទនាប៉ុណ្ណោះ” ដូច្នេះហើយ ត្រឡប់បដិសេធវាទៈនោះទៀត ទើបសម្តែងសេចក្តីនេះថា “សុខវេទនាក៏ដោយ ទុក្ខវេទនាក៏ដោយ អទុក្ខមសុខវេទនាក៏ដោយ ទាំងអស់មានការសោយអារម្មណ៍ជាកិច្ច” ; ពិតមែនហើយ សំដៅដល់ឋាន ការសោយអារម្មណ៍ជាកិច្ចហើយ សម្បយុត្តធម៌ដែលសេស សោយអារម្មណ៍ត្រឹមតែចំណែកខ្លះ គឺផស្សៈ ក៏មានត្រឹមតែការខ្ទប់អារម្មណ៍ប៉ុណ្ណោះ, សញ្ញា មានត្រឹមតែការចាំអារម្មណ៍ប៉ុណ្ណោះ, ចេតនា មានត្រឹមតែការតាំងចិត្តប៉ុណ្ណោះ, វិញ្ញាណ មានការដឹងច្បាស់នូវអារម្មណ៍តែប៉ុណ្ណោះ តែវេទនាប៉ុណ្ណោះ រមែង

សោយរសនៃអារម្មណ៍ដោយចំណែកមួយ ព្រោះភាពជាម្ចាស់របស់ ដោយភាពជាធំ ជាអ្នកសមគួរ, ពិតណាស់ វេទនាប្រៀបដូចព្រះរាជា, ធម៌ដែលសេស ប្រៀបដូចអ្នកគ្រូ; អ្នកគ្រូញ៉ាំងភោជនមានរសដ៏ល្អផ្សេងៗ ឱ្យរៀបរយហើយ ដាក់ក្នុងស្នុគប្រថាប់ត្រា លើកទៅដាក់ទុកក្នុងសំណាក់ព្រះរាជា ទម្លាយត្រាហើយបើកស្នុគ ភ្នាក់ងារក៏កាន់យកចំណែកខាងលើអំពីសម្ល និងម្ហូបទាំងអស់ដាក់ក្នុងភាជនៈ ដើម្បីសាកភ្លក្សមើលថា មានទោស ឬមិនមានទោស, បន្ទាប់អំពីនោះ បង្អោនភោជនមានរស់ផ្សេងៗ ទៅថ្វាយព្រះរាជា; ព្រះរាជាប៉ុណ្ណោះជាម្ចាស់របស់ សោយបានតាមប្រាថ្នា; ព្រោះទ្រង់ជាធំ និងទ្រង់មានអំណាចធម៌ក្រៅនោះ សោយរសអារម្មណ៍ចំណែកខ្លះ ដូចអ្នកគ្រូបានត្រឹមតែភ្លក្ស និងសាកភ្លក្សព្រះក្រយាហារត្រឹមចំណែកខ្លះប៉ុណ្ណោះ យ៉ាងណា, សូម្បីធម៌ដ៏សេសក៏យ៉ាងនោះដែរ រមែងសោយអារម្មណ៍ដោយចំណែកខ្លះប៉ុណ្ណោះ ដូចយ៉ាងថា ព្រះរាជាជាម្ចាស់របស់ ព្រោះព្រះអង្គជាធំ ជាអ្នកសមគួរ រមែងសោយតាមការពេញព្រះទ័យ យ៉ាងណា, សូម្បីវេទនា ក៏យ៉ាងនោះ រមែងសោយរសនៃអារម្មណ៍ ដោយភាវៈនៃខ្លួនជាម្ចាស់របស់ ព្រោះ

ភាពជាធំ ជាអ្នកសមគួរ, ព្រោះហេតុដូច្នោះ ទើបលោកពោលថា **"វេទនាមានការសោយអារម្មណ៍ជាកិច្ច"**។

ក្នុងការកំណត់សេចក្ដីទី ២ វេទនាដែលលោកប្រាថ្នាយកក្នុងទីនេះ លោកពោលថា **"វេទនា (សុខវេទនា) ថាមានការសោយអាការ ដែលគួរប្រាថ្នាជារស"** , ព្រោះអត្ថថា សោយរសនៃអារម្មណ៍ មានអាការដែលគួរប្រាថ្នាតាមដែលប្រសព្វ ក៏វេទនានេះ បើពោលដោយសេចក្ដីពេញចិត្ត លោកពោលថា **"មានសេចក្ដីពេញចិត្តជាបទដ្ឋាន"** សំដៅដល់ការប្រាកដដោយសភាវៈរបស់ខ្លួន; ក៏ព្រោះបុគ្គលអ្នកមានកាយស្ងប់ហើយ ទើបសោយសេចក្ដីសុខ, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា **វេទនានេះមានការស្ងប់ជាបទដ្ឋាន** ៕

## អត្ថនៃពាក្យថាសញ្ញា

***នីលាទិភេទំ អារម្មណំ សញ្ជានាតីតិ សញ្ញា*** ធម៌ដែលឈ្មោះថា ***សញ្ញា*** ព្រោះអត្ថថា ចាំអារម្មណ៍មានពណ៌ខៀវជាដើម, សញ្ញានោះមានលក្ខណាទិចតុក្កៈដូច្នេះ ៖-

***សញ្ជាននលក្ខណា*** មានការចាំអារម្មណ៍បាន ជាលក្ខណៈ

**_បច្ចាភិញ្ញាណរសា_** មានការធ្វើគ្រឿងកំណត់ ជាកិច្ច ។

ពិតណាស់ សញ្ញាប្រព្រឹត្តទៅក្នុងភូមិ ៤ មិនឈ្មោះថា មានការចាំបាន មិនមែនទេ (គឺចាំបាន), សញ្ញាទាំងអស់ សុទ្ធតែមានការចាំជាលក្ខណៈមែនពិត ។ ក៏ក្នុងទីនេះ សញ្ញាណា ចាំបានដោយគ្រឿងកំណត់, សញ្ញានោះឈ្មោះថា **មានការធ្វើគ្រឿងកំណត់ជារស** (កិច្ច) ។ គប្បីជ្រាបការប្រព្រឹត្តទៅនៃសញ្ញានោះ ក្នុងគ្រឿងកំណត់នោះទៀត និងក្នុងវេលាដែលបុរសកំណត់គ្រឿងកំណត់ ដោយប្រជ្រុយខ្មៅជាដើម ហើយចាំគ្រឿងកំណត់របស់បុគ្គលនោះទៀតថា "បុគ្គលនេះ ឈ្មោះឯណោះ" ដូច្នេះ ដោយគ្រឿងកំណត់នោះ និងវេលាដែលនាយឃ្លាំងអ្នករក្សាគ្រឿងប្រដាប់របស់ព្រះរាជាចងសៀវភៅទុកត្រង់គ្រឿងប្រដាប់នោះ កាលព្រះរាជាត្រាស់ថា "អ្នកចូរនាំគ្រឿងប្រដាប់ឯណោះមក" អ្នកឃ្លាំង ក៏អុចប្រទីប ហើយចូលទៅក្នុងបន្ទប់ ដោយប្រទីបនោះ អានសៀវភៅហើយ ក៏នាំគ្រឿងប្រដាប់នោះៗចេញមកបាន ។

ន័យមួយទៀត ក៏កាលថាដោយរួបរួមធមិទាំងអស់សញ្ញាមានការចាំ

បានជាលក្ខណៈ, មានការធ្វើនិមិត្តដោយបច្ច័យ ឱ្យចាំបានទៀតជារស ដូចជាងចាំងជាដើម ធ្វើគ្រឿងកំណត់ត្រង់ឈើជាដើម, ដោយអំណាចនៃនិមិត្តតាមដែលខ្លួនធ្វើទុក ឈ្មោះថា ធ្វើការទោរទន់ទុកជាបច្ចុប្បដ្ឋាន ដូចមនុស្សខ្វាក់ភ្នែកដែលជួបដំរី*, ឬថា មានការតាំងនៅក្នុងអារម្មណ៍មិនយូរ ជាផលព្រោះមិនចុះកាន់ក្នុងអារម្មណ៍ដូចផ្លេកបន្ទោរ, ឬការដែលមានអារម្មណ៍តាមដែលប្រាកដជាបទដ្ឋាន, ដូចសញ្ញាដែលកើតឡើងដល់កូនម្រឹគទាំងឡាយក្នុងតិណបុរិសកៈ (រូបបុរសដែលធ្វើដោយស្មៅ) ថាជាប្រុស ។ ក៏ក្នុងទីនេះសញ្ញាណា ជាញាណសម្បយុត្ត, សញ្ញានោះ ក៏ប្រព្រឹត្តទៅតាមញាណនោះឯង ធមិដែលនៅសល់ទាំងឡាយ គប្បីជ្រាបដូចបឋវីធាតុជាដើម ក្នុងសសម្ភារៈ ក្នុងបឋវីជាដើម ៕

---

* ប្រៀបដូចមនុស្សខ្វាក់ដែលនឹកគិតដល់ដំរីទៅតាមលក្ខណៈជាចំណែក១ ក្នុងការបានស្ទាបត្រូវចំណែកណាមួយ, ឧ. ពេលបានស្ទាបចំកន្ទុយ ក៏និយាយថា ដំរីមានរាងដូចអំបោស, ពេលបានស្ទាបចំជើង ក៏និយាយថា ដំរីមានរាងដូចអង្រែ ។ល។ (ចាកអរិយាលង្ការត្រង់ឧទាន) ។

## អត្ថនៃពាក្យថាចេតនា

**ចេតយតីតិ ចេតនា** ធម៌ដែលឈ្មោះថា **ចេតនា** ព្រោះអត្ថថា តាំងចិត្ត, អធិប្បាយថា ញុំាងសម្បយុត្តធម៌ និងខ្លួនឱ្យប្រព្រឹត្តទៅក្នុងអារម្មណ៍; ចេតនានោះ មានលក្ខណាទិចតុក្កៈដូច្នេះ ៖-

**-ចេតយិតលក្ខណា** មានការតាំងចិត្តជាលក្ខណៈ, គឺមានការចូលចិត្តជាលក្ខណៈ ។

**-អាយូហនរសា** មានការប្រមូលមកជារស ។

ពិតណាស់ ចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា **មិនមានការចូលចិត្ត ក៏មិនមែនទេ** (គឺមាន) ។ ចេតនាទាំងអស់ មានការតាំងចិត្តជាលក្ខណៈមែនពិត, ក៏ចេតនាដែលមានការប្រមូលមកជារសៈ ជាកុសល និងអកុសលទាំងនោះ សំឡឹងដល់ឋាននៃការប្រមូលមកនូវកុសលកម្ម និងអកុសលកម្ម ហើយសម្បយុត្តដែលសល់ ក៏មានកិច្ចត្រឹមតែចំណែកខ្លះប៉ុណ្ណោះ, តែថា ចេតនាមានឧស្សាហ៍ក្រៃលែងណាស់ មានព្យាយាមក្រៃលែងណាស់ គឺមានឧស្សាហ៍ទ្វេគុណ មានព្យាយាមទ្វេគុណ; ដោយហេតុនោះ បោរាណាចារ្យទើបពោលថា "ក៏ឯចេតនានេះ តាំងនៅក្នុងសភាពជាម្ចាស់

របស់ពិត" ដូច្នេះ ម្ចាស់របស់ស្រែ ហៅថា **ម្ចាស់របស់ពិត** ដូចយ៉ាងថា បុរសម្ចាស់របស់ស្រែ បបួលបុរសរួមកម្លាំងគ្នា ៥៥ នាក់ចុះមកស្រែព្រមគ្នា ដោយប្រាប់ថា "យើងនឹងច្រូតស្រូវ" ម្ចាស់ស្រែមានឧស្សាហ៍ណាស់ មានព្យាយាមណាស់ គឺមានឧស្សាហ៍ទ្វេគុណ មានព្យាយាមទ្វេគុណ, ប្រាប់ហើយដល់អ្នកខេត្ត (ស្រែ) ដោយពាក្យថា "ពួកអ្នកចូរច្រូតជាប់តគ្នាទៅ" , ហើយចាត់ចែងសុរា អាហារ និងគ្រឿងក្រអូបជាដើម, នាំទៅឱ្យពួកជននោះ បង្ហាញផ្លូវឱ្យប៉ុនៗគ្នា យ៉ាងណា ខឧបមេយ្យនេះ បណ្ឌិតគប្បីជ្រាបដូច្នោះចុះ។ ពិតណាស់ ចេតនាដូចបុរសម្ចាស់ស្រែ, ធម៌ទាំងឡាយដែលជាកុសល ៥៥ ដែលកើតឡើង ដោយអំណាចនៃអង្គរបស់ចិត្ត ដូចបុរសរួមកម្លាំងគ្នា ៥៥ នាក់, ព្រោះសំឡឹងដល់ឋាននៃការប្រមូលមកនូវកុសលកម្ម និងអកុសលកម្ម ចេតនាក៏មានឧស្សាហ៍ទ្វេគុណ, មានព្យាយាមទ្វេគុណ, ដូចបុរសម្ចាស់ស្រែ មានឧស្សាហ៍ទ្វេគុណ, មានព្យាយាមទ្វេគុណ; បណ្ឌិតគប្បីជ្រាបចេតនានោះ **មានការប្រមូលមកជារស** ដោយប្រការដូច្នេះ ។

ក៏ចេតនានោះ មានការចាត់ចែងជាបច្ចុប្បដ្ឋាន (**សំវិទហនបច្ចុប្បដ្ឋានា**) ; តាមពិត ចេតនានេះកាលចាត់ចែង រមែងប្រាកដដូចជេដ្ឋសិស្ស (សិស្ស

ច្បង) និងជាងឈើធំជាដើម អ្នកអាចធ្វើកិច្ចរបស់ខ្លួន និងរបស់អ្នកដទៃឱ្យសម្រេច។ ដូចយ៉ាងថាសិស្សច្បង ឃើញព្រះឧបជ្ឈាយ៍មកពីចម្ងាយ កាលខ្លួនឯងសាធ្យាយហើយ ក៏តឿនសិស្សអ្នកប្អូនក្រៅនេះ ឱ្យសាធ្យាយតាមអធ្យាស្រ័យរបស់ខ្លួនៗ, កាលសិស្សច្បងនោះផ្ដើមសាធ្យាយ សិស្សប្អូនទាំងនោះក៏សាធ្យាយ ព្រោះស្របតាមសិស្សច្បងនោះ យ៉ាងណា; និងប្រៀបដូចជាងឈើធំ កាលខ្លួនឯងចាំង ក៏ញុំាងជាងក្រៅនេះឱ្យប្រព្រឹត្តទៅក្នុងកម្មគឺការចាំងរបស់ខ្លួនៗ, ព្រោះថា កាលមេជាងនោះផ្ដើមចាំង ជាងចាំងទាំងនោះ ក៏រមែងចាំងតាមមេជាងនោះ យ៉ាងណា, និងប្រៀបដូចមេទ័ព កាលខ្លួនឯងច្បាំង ក៏តឿនអ្នកច្បាំងក្រៅនេះឱ្យធ្វើការច្បាំង, ព្រោះថា សូម្បីមេទ័ពផ្ដើមធ្វើការច្បាំង អ្នកច្បាំងទាំងនោះ ក៏ធ្វើការច្បាំងតាមមេទ័ពនោះ យ៉ាងណា, សូម្បីចេតនានេះ ក៏យ៉ាងនោះដែរ សូម្បីប្រព្រឹត្តទៅក្នុងអារម្មណ៍របស់ខ្លួនហើយ ក៏ញុំាងសម្បយុត្តធម៌ដទៃៗ ឱ្យប្រព្រឹត្តទៅក្នុងការធ្វើរបស់ខ្លួនៗ, ព្រោះថា កាលចេតនានោះ ផ្ដើមកិច្ចរបស់ខ្លួនសូម្បីសម្បយុត្តធម៌ និងចេតនានោះ ក៏ផ្ដើម; ព្រោះហេតុដូច្នោះ ខ្ញុំទើបពោលថា “ចេតនានោះ ធ្វើរបស់ខ្លួន និងរបស់អ្នកដទៃឱ្យសម្រេច ដូចសិស្សច្បង និងមេជាងជាដើម” ។ ក៏ចេតនា

នេះ គប្បីជ្រាបថា ប្រាកដជាប្រព្រឹត្តទៅដោយការញ៉ាំងសម្បយុត្តធម៌ ឱ្យឧស្សាហ៍ក្នុងការរព្វកដល់ការងារទាំងឡាយ ដែលប្រញាប់បន្ទាន់ជាដើម ៕

## អត្ថនៃពាក្យថាចិត្ត

អត្ថនៃពាក្យថា ចិត្ត ខ្ញុំពោលទុកដោយន័យជាដើមថា “**អារម្មណំ ចិន្តេតីតិ ចិត្តំ** = ធម៌ដែលឈ្មោះថា ចិត្ត ព្រោះអត្ថថា គិតនូវអារម្មណ៍” ដូច្នេះនោះឯង; ក៏កាលពោលដោយលក្ខណៈជាដើម ៖-

-**វិជាននលក្ខណំ** មានការដឹងច្បាស់នូវអារម្មណ៍ជាលក្ខណៈ

-**បុព្វង្គមរសំ** មានការជាប្រធានជាកិច្ច

-**សន្ធានបច្ចុប្បដ្ឋានំ** មានការកើតជាប់តគ្នាជាផល

-**នាមរូបបទដ្ឋានំ** មាននាមរូបជាបទដ្ឋាន ។

តាមពិត ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា **មិនមានការដឹងច្បាស់នូវអារម្មណ៍** ជាលក្ខណៈ ក៏មិនមែនទេ (គឺមាន), ចិត្តទាំងអស់មានការដឹងច្បាស់នូវអារម្មណ៍មែនពិត ។

ក៏សំឡឹងដល់ទ្វារហើយ ចិត្តក៏ជាប្រធាន គឺមានការត្រាច់ទៅមុន ក្នុងទីជាទីធ្វើឱ្យដឹងច្បាស់នូវអារម្មណ៍ ។ តាមពិត បុគ្គលរមែងដឹងច្បាស់នូវរូបារម្មណ៍ដែលឃើញដោយភ្នែក ដោយចិត្តនោះឯង ។ល។ រមែងដឹងច្បាស់នូវធម្មារម្មណ៍ដែលដឹងដោយចិត្ត ដោយចិត្តនោះឯង ដូចយ៉ាងថា បុរសអ្នករក្សានគរ អង្គុយនៅត្រង់ផ្លូវបែកជា ៤ ក្នុងកណ្ដាលនគរ រមែងត្រួតពិនិត្យកំណត់ជនអ្នកមកហើយៗ ថា "អ្នកនេះជាម្ចាស់អាវាស, អ្នកនេះជាអ្នកមកថ្មី" យ៉ាងណា, គប្បីជ្រាបសេចក្ដីឧបមេយ្យយ៉ាងនោះចុះ ។ ខនេះដូចព្រះថេរៈព្រះនាមនាគសេន ពោលទុកថា ៖-

"បពិត្រមហារាជ ធម្មតាបុគ្គលអ្នករក្សានគរ អង្គុយនៅត្រង់ផ្លូវបែកជា ៤ នៃកណ្ដាលនគរ គប្បីឃើញបុគ្គលអ្នកមកអំពីទិសខាងកើត, គប្បីឃើញបុគ្គលអ្នកមកអំពីទិសខាងលិច, អំពីទិសខាងត្បូង, អំពីទិសខាងជើង យ៉ាងណា, បពិត្រមហារាជ យ៉ាងនោះឯង បុគ្គលឃើញនូវរូបណាដោយភ្នែក, រមែងដឹងច្បាស់នូវរូបនោះ ដោយវិញ្ញាណ; ឮសំឡេងណាដោយត្រចៀក, ធំក្លិនណាដោយច្រមុះ, លិទ្ធជញ្ជក់ជញ្ជាប់រសណា ដោយអណ្ដាត, ប៉ះត្រូវផោដ្ឋព្វណា ដោយកាយ, ដឹងច្បាស់ធម៌ណា ដោយចិត្ត,

រមែងដឹងច្បាស់វត្ថុនោះៗ ដោយវិញ្ញាណ”[២២] ។ ព្រោះសំឡឹងដល់ទ្វារហើយ ចិត្តប៉ុណ្ណោះ ជាប្រធាន ជាធម្មជាត ត្រាច់ទៅខាងមុខ ក្នុងឋានដែលធ្វើអារម្មណ៍ឱ្យច្បាស់លាស់យ៉ាងនេះ, ព្រោះហេតុដូច្នោះ ទើបពោលថា **“មានការជាប្រធានជារស”** ។

ចិត្តនេះឯង ដួងក្រោយៗ កើតឡើងរមែងប្រាកដជាប់តគ្នាតែម្តង ព្រោះធ្វើដួងដើមៗ ឱ្យតគ្នានោះឯង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **មានការជាប់បន្តគ្នាជាផល**; តែថា ក្នុងបញ្ចវោហាការភព (ភពមានខន្ធ ៥) ចិត្តមាននាមរូប ជាបទដ្ឋាន, ក្នុងចតុវោការភព មាននាមប៉ុណ្ណោះជាបទដ្ឋានដោយទៀងទាត់; ព្រោះហេតុដូច្នោះ លោកទើបពោលថា **“ចិត្តមាននាមនិងរូបជាបទដ្ឋាន”**។

សួរថា ក៏ចិត្តនេះ ជាចិត្តដួងដូចគ្នានឹងចិត្ត ដែលសម្តែងខាងដើមឬ?, ឬថាជាចិត្តដួងដទៃ?

ឆ្លើយថា ជាដួងដូចគ្នានោះឯង។

---

[២២] មិលិន្ទ.។

សួរថា កាលបើហេតុយ៉ាងនេះមាន ហេតុអ្វី ចិត្តដែលសម្ដែងហើយមុន ទើបយកមកពោលទៀត?

ឆ្លើយថា ពាក្យនេះ អដ្ឋកថា និងអាចារ្យទាំងឡាយ នៅមិនបានពិចារណាក្នុងពាក្យនៃចិត្តនេះទេ។

ក៏ក្នុងពាក្យនៃចិត្តនេះ មានការប្រាកដដូច្នេះ ដូចយ៉ាងថា ព្រះអាទិត្យជាដើម ដែលបញ្ញត្តិព្រោះអាស្រ័យរូបជាដើម ពោលដោយអត្ថ ក៏មិនមែនវត្ថុដទៃក្រៅអំពីរូបជាដើមឡើយ; ដោយហេតុនោះឯង សូម្បីពោលថា "សម័យណា ព្រះអាទិត្យរះឡើង, សម័យនោះ រូប គឺពន្លឺព្រះអាទិត្យដទៃរមែងប្រាកដ" ដូច្នេះ ឈ្មោះថា ព្រះអាទិត្យក្រៅអំពីរូបជាដើម រមែងមិនមាន យ៉ាងណា, ចិត្តនេះរមែងមិនមានដូច្នេះទេ, ព្រះអង្គទ្រង់បញ្ញត្តិ ព្រោះអាស្រ័យធម៌ទាំងឡាយ មានផស្សៈជាដើម, តែការពោលដោយសេចក្ដីចិត្តនោះ ក៏ជាចិត្តមួយដួងទៀត ក្រៅអំពីធម៌ទាំងឡាយមានផស្សៈជាដើមនោះដោយពិត; ព្រោះហេតុនោះ ដើម្បីសម្ដែងសេចក្ដីនេះថា "សម័យណា ចិត្តកើតឡើង, សម័យនោះ ចិត្តដួងដទៃក្រៅអំពីធម៌ទាំងឡាយ មានផស្សៈ

ជាដើម រមែងកើតឡើង” ចិត្តនេះ បណ្ឌិតគប្បីជ្រាបថា ព្រះអង្គទ្រង់យកមកត្រាស់ទុកទៀត ។

ដូចយ៉ាងថា កាលព្រះអង្គទ្រង់កំណត់សម័យ ដោយបុគ្គលអ្នកចម្រើនក្នុងព្រះបាលីមានពាក្យជាដើមថា “សម័យណា បុគ្គលចម្រើនមគ្គ ។ល។ មានបឋវីកសិណជាអារម្មណ៍ដើម្បីការកើតឡើងក្នុងរូបភព; សម័យនោះ វេទនារមែងមាន ផស្សៈរមែងមាន”[២៣] អ្នកណាចម្រើនមគ្គក្នុងសម័យ, ពោលដោយអត្ថ អ្នកនោះ ឈ្មោះថា **កើតឡើងមិនបាន**; ព្រោះហេតុនោះៗឯង ក្នុងខដែលពោលហើយនោះ ទើបត្រាស់ថា “ផស្សៈរមែងមាន វេទនារមែងមាន” យ៉ាងណា, តែមិនបានត្រាស់ថា “បុគ្គលណាចម្រើនមគ្គ បុគ្គលនោះរមែងមាន” យ៉ាងនោះ; តែកាលទ្រង់កំណត់សម័យដោយចិត្ត ក្នុងព្រះបាលីមានពាក្យជាដើមថា “សម័យណា កាមាវចកុសលចិត្តកើតឡើង” ចិត្តទ្រង់កំណត់ដោយសម័យ ពោលដោយអត្ថហើយរមែងមិនកើតឡើងយ៉ាងនោះ មិនមានទេ; តែត្រាស់ថា ផស្សៈរមែងមាន, វេទនារមែងមាន, ក្នុងសម័យនោះ យ៉ាងណា; សូម្បីចិត្ត ក៏រមែងកើតមាន

---

[២៣] អភិ. ។

យ៉ាងនោះ ។ ដូច្នេះដើម្បីសម្ដែងសេចក្ដីនេះ គប្បីជ្រាបថា ទ្រង់ត្រាស់ចិត្តនេះទៀត; ក៏ក្នុងខនេះ មានខសន្និដ្ឋានដូចតទៅនេះ ៖-

ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងចិត្ត ដើម្បីប្រមូលមកទុកក្នុងឧទ្ទេសវារៈ និងដើម្បីទ្រង់ចែកក្នុងនិទ្ទេសវារៈ; តាមពិត ព្រះអង្គទ្រង់កំណត់សម័យទុកដោយចិត្តសព្ទ ដែលជាសព្ទដើមតែម្ដង; ដើម្បីទ្រង់សម្ដែងធម៌ក្នុងសម័យដែលមានការកំណត់ដោយចិត្ត; ទើបផ្ដើមត្រាស់ថា "**ផស្សោ ហោតិ**" ជាដើម សូម្បីចិត្តនោះ ក៏រមែងមានក្នុងសម័យនោះដូចគ្នា ព្រោះហេតុដូច្នោះ ដើម្បីប្រមូលមកនូវចិត្តនោះ ទើបត្រាស់ថា "ចិត្តនេះ" ទៀត ។ ក៏កាលមិនត្រាស់ពាក្យថា "ចិត្តនេះ" ក្នុងទីនេះ ក៏មិនអាចដើម្បីចែកក្នុងនិទ្ទេសវារៈបានថា "ចិត្តក្នុងសម័យនោះ តើដូចម្ដេច?" ដោយហេតុនោះ ការចែកចិត្តនោះៗឯង ក៏បាត់ទៅ; ព្រោះហេតុនោះឯង គប្បីជ្រាបថា ដើម្បីសម្ដែងចែកចិត្តនោះ ក្នុងនិទ្ទេសវារៈ ទើបត្រាស់ចិត្តនេះទៀត ។

ម្យ៉ាងទៀត ក្នុងអដ្ឋកថាលោកពិចារណាថា "ពាក្យថា ចិត្តកើតឡើង ក្នុងពាក្យថា **ឧប្បន្នំ ហោតិ** នេះ ពោលត្រឹមតែទេសនាសីសៈប៉ុណ្ណោះ, តែមិនមែនចិត្តនេះ កើតឡើងបានត្រឹមតែមួយដួងប៉ុណ្ណោះទេ" ; ព្រោះ

ហេតុដូច្នោះ សូម្បីក្នុងពាក្យថា **“ចិត្តំ ឧប្បន្នំ”** នេះ ក៏មិនបានកាន់យកចិត្តតែម្យ៉ាងទេ, តែកាន់យកចិត្ត និងកុសលធម៌លើស ៥០ តែម្តង ដោយប្រការដូច្នេះ ទើបផ្តើមត្រាស់ពាក្យថា **“ផស្សោ ហោតិ”** ជាដើម ដើម្បីសម្តែងចិត្តនោះ ក្នុងទីនោះដោយសង្ខេប និងសម្តែងដោយប្រភេទ ដោយកាន់យកចិត្ត និងចេតសិកធម៌ទាំងនោះ និងដោយសង្ខេបក្នុងទីនេះ ដោយប្រការដូច្នេះ គប្បីជ្រាបថា សូម្បីចិត្ត ក៏គប្បីត្រាស់ទុកដូចធម៌ មានផស្សៈជាដើមដូច្នោះ ៕

## អត្ថនៃពាក្យថាវិតក្កៈ

**វិតក្កេតីតិ វិតក្កោ វិតក្កនំ វា វិតក្កោ** ធម៌ដែលមានឈ្មោះថា **វិតក្កៈ** ព្រោះអត្ថថា ត្រិះរិះ ។ ម្យ៉ាងទៀត ការត្រិះរិះ គឺការកត់ត្រាអារម្មណ៍ឈ្មោះថា **វិតក្កៈ** ។ វិតក្កៈនេះឯង មានការលើកចិត្តឡើងក្នុងអារម្មណ៍ ជាលក្ខណៈ = **អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ** ។ ពិតណាស់ វិតក្កៈនោះ លើកចិត្តឡើងក្នុងអារម្មណ៍ ។ ដូចយ៉ាងថា អ្នកខ្លះអាស្រ័យញាតិ ឬមិត្រជាទីស្រឡាញ់របស់ស្តេច ទើបចូលទៅកាន់រាជវាំងបាន យ៉ាងណា, ចិត្ត

ក៏អាស្រ័យវិតក្កៈហើយ ឡើងកាន់អារម្មណ៍បាន យ៉ាងនោះដែរ; ព្រោះហេតុដូច្នោះ វិតក្កៈនោះ ទើបលោកពោលថា **មានការលើកចិត្តឡើងក្នុងអារម្មណ៍ជាលក្ខណៈ**។

ក៏ប៉ុន្តែ ព្រះនាគសេនត្ថេរពោលថា "វិតក្កៈមានការគោះអារម្មណ៍ជាលក្ខណៈ; សូមថ្វាយព្រះពរមហាបពិត្រ ប្រៀបដូចបុគ្គលវាយស្គរ ក្រោយអំពីនោះ ក៏មានសំឡេងស្គរឮគ្រហឹមផ្សាយទៅ យ៉ាងណា, មហារាជ គប្បីយល់ព្រះទ័យ វិតក្កៈដូចបុគ្គលវាយស្គរ គប្បីយល់ព្រះទ័យវិចារៈ ដូចសំឡេងស្គរឮគ្រហឹម យ៉ាងនោះ"[២៤] ។

វិតក្កៈនោះ មានការធ្វើឱ្យចិត្តប៉ះខ្ទប់អារម្មណ៍រឿយៗ ជាកិច្ច = **អាហននបរិយាហននរសោ** ។ ពិតដូច្នោះ លោកទើបពោលថា ព្រះយោគាវចរតែងធ្វើចិត្តនោះ ដែលវិតក្កៈឱ្យប៉ះខ្ទប់ហើយៗ ។ វិតក្កៈនោះ មានការនាំចិត្តមកក្នុងអារម្មណ៍ជាបច្ចុប្បដ្ឋាន = **អារម្មណេ ចិត្តស្ស អានយបច្ចុប្ប**

---

[២៤] មិលិន្ទ.។

ដ្ឋានោ; មាននាមក្ខន្ធ ៣ ដែលសល់ ( វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធ ) ជាបទដ្ឋាន = **សេសក្ខន្ធត្តយបទដ្ឋានោ** * ៕

## អត្ថនៃពាក្យថាវិចារៈ

**អារម្មណេ តេន ចិត្តំ វិចរតីតិ វិចារោ** ធម៌ដែលឈ្មោះថា **វិចារៈ** ព្រោះជាហេតុឱ្យចិត្តត្រាច់ទៅក្នុងអារម្មណ៍ ។ ម្យ៉ាងទៀត ការត្រាច់ទៅ គឺការសញ្ចរទៅតាមអារម្មណ៍ ឈ្មោះថា **វិចារៈ** ។ វិចារៈនោះ មានការពិចារណាក្នុងអារម្មណ៍រឿយៗ ជាលក្ខណៈ = **អារម្មណានុមជ្ជនលក្ខណោ**; មានការប្រកបសហជាតធម៌ក្នុងអារម្មណ៍នោះជាកិច្ច = **តត្ថ សហជាតានុយោជនរសោ**; មានការចងចិត្តទុកក្នុងអារម្មណ៍ ជាផល = **ចិត្តអនុប្បពន្ធបច្ចុប្បដ្ឋានោ** ។

ក៏កាលការមិនញែកគ្នានៃវិតក្កៈ និងវិចារៈ ក្នុងចិត្តប្បាទកន្លែងខ្លះ សូម្បីមានដោយប្រការយ៉ាងនេះ ការដែលចិត្តធ្លាក់ទៅក្នុងគ្រាដំបូង ឈ្មោះថា វិតក្កៈ ព្រោះអត្ថថា ជាធម៌គ្រោតគ្រាត, ព្រោះអត្ថថា ជាធម៌ដែល

---

* បាលីថា សេសខន្ធត្តយបទដ្ឋានោ មិនមានក្នុងទីនេះទេ ។

ដល់មុន, ព្រោះអត្ថថា លើកចិត្តឡើងកាន់អារម្មណ៍ ដូចការគោះជង់ ។ ការចងពន្ធក្នុងអារម្មណ៍ ឈ្មោះថា **វិចារៈ** ព្រោះអត្ថថា ជាធម៌ល្អិត និងព្រោះអត្ថថា ពិចារណាក្នុងអារម្មណ៍ ដូចសំឡេងដ៏ពីរោះរបស់រគាំង ។ ក៏ក្នុងធម៌ទាំង ២ យ៉ាងនោះ វិតក្កៈមានការផ្សាយទៅ គឺជាការផ្សាយទៅដោយជុំវិញ ក្នុងការកើតឡើងនៃចិត្តចាប់អារម្មណ៍គ្រាដំបូង ដូចការលាតសន្ទឹងស្លាបនៃបក្សីដែលត្រូវហើរឡើងឰដ៏អាកាស និងដូចភមរជាតិ មានចិត្តចងពន្ធក្នុងក្លិន មានមុខឆ្ពោះហើរចុះកាន់ផ្កាបទុមដូច្នោះ ។ វិចារៈមានការប្រព្រឹត្តិទៅស្ងប់ មិនមានការផ្សាយទៅនៃចិត្តលើស ដូចការលាតសន្ទឹងស្លាបនៃបក្សីដែលត្រូវការហើរទៅឰដ៏អាកាស និងដូចភមរជាតិ ដែលហើរចុះត្រង់ផ្កាបទុមហើយហើរពិចារណាខាងលើដូច្នោះ ។ តែ**អដ្ឋកថាទុកនិបាត** លោកពោលទុកថា "វិតក្កៈប្រព្រឹត្តិទៅដោយការលើកចិត្តឡើងក្នុងអារម្មណ៍ ដូចបក្សីធំហើរទៅឰដ៏អាកាស ទទះស្លាបទាំងពីរឱ្យចាប់ខ្យល់ ហើយឱ្យស្លាបទាំងពីរជក់ខ្យល់ហើរទៅ; ព្រោះថា វិតក្កៈនោះ មានអារម្មណ៍តែមួយយ៉ាងប៉ុណ្ណោះ។ ចំណែកវិចារៈប្រព្រឹត្តទៅ ដោយការពិចារណាអារម្មណ៍ ដូចបក្សីធំត្រដាងស្លាប ដើម្បីឱ្យចាប់ខ្យល់ ហើយប្រព្រឹត្តទៅ; ព្រោះថា វិចារៈនោះ

មានការពិចារណាក្នុងអារម្មណ៍” ។ ពាក្យនៃអដ្ឋកថាទុកនិបាតនោះ ហាក់ដូចជាសមណាស់ ក្នុងការដែលចិត្តចងពន្ធក្នុងអារម្មណ៍ ហើយប្រព្រឹត្តទៅ ។ ប៉ុន្តែថា ការប្លែកគ្នានៃវិតក្កៈ និងវិចារៈនោះ ប្រាកដច្បាស់ក្នុងឈានទី ១ និងឈានទី ២ ។

ម្យ៉ាងទៀត កាលបុគ្គលយកដៃម្ខាងកាន់ភាជនៈសំរឹទ្ធ ដែលជាប់ស្នឹមទុកឱ្យមាំ ហើយយកដៃម្ខាងទៀតដុសខាត់ដោយលំអិត និងប្រេង (ឬអាចម៍សត្វដែលសមគួរ)* វិតក្កៈដូចកាលដែលដៃចាប់ទុកមាំ, វិចារៈដូចដៃដែលដុសខាត់ ។ ក៏កាលស្មូនឆ្នាំង ប្រើឱ្យក្រឡឹងចក្រធ្វើភាជនៈ វិតក្កៈដូចដៃដែលសង្កត់ វិចារៈដូចដៃដែលបង្វិលទៅខាងនោះ និងខាងនេះ ។ ក៏កាលបុគ្គលធ្វើវង្វង់មូល វិតក្កៈ គឺការរៀបចំនូវអារម្មណ៍ ដូចដែកស្រួច ដែលដោតទប់ទុកត្រង់កណ្ដាល, វិចារៈពិចារណាអារម្មណ៍ ដូចដែកស្រួចវិលទៅរឿយៗខាងក្រៅដូច្នោះ ៕

---

* ពាក្យនៅក្នុងវង់ក្រចកនេះ ខ្ញុំពិនិត្យមើលនៅក្នុងអដ្ឋកថាបាលី, មូលដីកា និងអនុដីកា, ព្រមទាំងអត្ថយោជនា ដូចជាមិនឃើញ, សូមអ្នកសិក្សាពិចារណាមើលចុះ ។

## អត្ថនៃពាក្យថាបីតិ

**បីនយតីតិ បីតិ** = ធម៌ដែលឈ្មោះថា **បីតិ** ព្រោះអត្ថថា ត្រេកអរ, បីតិនោះមានការរីករាយត្រេកអរជាលក្ខណៈ = **សម្បិយាយនលក្ខណា**, មានការធ្វើកាយ និងចិត្ត ឱ្យឆ្អែតជាកិច្ច ឬថា មានការផ្សាយទៅជាកិច្ច = **កាយចិត្តបីនន‌រសាផរណរសា វា**, មានការអណ្ដែតឡើងនូវកាយ និងចិត្ត ជាបច្ចុប្បដ្ឋាន = **ឱទគ្យបច្ចុប្បដ្ឋានា** ។

ក៏បីតិនោះមាន ៥ យ៉ាងគឺ

**១-ខុទ្ទកាបីតិ** បីតិតូច

**២-ខណិកាបីតិ** បីតិមួយខណៈ

**៣-ឱក្កន្តិកាបីតិ** បីតិឈានចុះកាន់កាយហើយបាត់ទៅ

**៤-ឧព្វេង្គាបីតិ** បីតិមានកម្លាំងអាចហោះឡើងបាន

**៥-ផរណាបីតិ** បីតិដែលផ្សាយទៅកាន់សរីរៈទាំងមូល ។

បណ្ដាបីតិទាំងនោះ **ខុទ្ទកាបីតិ** អាចដើម្បីធ្វើត្រឹមតែរោមក្នុងរាងកាយឱ្យព្រឺប៉ុណ្ណោះ ។ **ខណិកាបីតិ** ដូចនឹងការកើតឡើងនៃផ្លេកបន្ទោរមួយ

ខណៈៗ ។ **ឱក្កន្តិកាបីតិ** ឈានចុះកាន់កាយ, លុះឈានចុះហើយ ក៏បែកទៅដូចរលកត្រង់ឆ្នេរសមុទ្រ ។ **ឧព្វេង្គាបីតិ** ជាបីតិមានកម្លាំង, ធ្វើកាយឱ្យអណ្តែតឡើងដល់ការរសាត់ទៅក្នុងអាកាសបាន ។

ពិតយ៉ាងនោះមែន ព្រះមហាតិស្សត្ថេរអ្នកនៅក្នុង**បុណ្ណវល្លិកវិហារ** (លង្កាទ្វីប) ក្នុងថ្ងៃបុណ្ណមី វេលាល្ងាចទៅកាន់ព្រះលាននៃចេតិយ ឃើញពន្លឺដួងចន្ទ ទើបបែរមុខឆ្ពោះទៅព្រះមហាចេតិយ ហើយរំពឹងថា "ពេលនេះពួកបរិស័ទទាំង ៤ កំពុងថ្វាយបង្គំព្រះមហាចេតិយហ្ន៎!" ដូច្នេះ ហើយញ៉ាំងឧព្វេង្គាបីតិ មានព្រះពុទ្ធជាអារម្មណ៍ឱ្យកើតឡើង ដោយអំណាចនៃអារម្មណ៍ដែលឃើញតាមប្រក្រតី អណ្តែតឡើងទៅក្នុងអាកាស ហើយទៅឈរចំពោះទីលាននៃព្រះមហាចេតិយនោះឯង ដូចកូនឃ្លីដ៏វិចិត្រដែលគេគ្រវែងទៅលើផ្ទៃ ដែលបូកលាបទុកដោយកំបោរ ។

ក៏សូម្បីកុលធីតាម្នាក់ក្នុង**វត្តកាលកគ្រាម** ដែលអាស្រ័យនៅជិតគិរិ-កណ្ឌកវិហារ អណ្តែតទៅក្នុងអាកាសដោយឧព្វេង្គាបីតិ មានព្រះពុទ្ធគុណដ៏មានកម្លាំងជាអារម្មណ៍ ។ បានឮថា មាតាបិតារបស់កុលធីតានោះ ទៅវិហារដើម្បីត្រូវការស្តាប់ធម៌ ក្នុងពេលល្ងាចបានប្រាប់ថា "នែកូន នាងមាន

ភារៈធ្ងន់, មិនអាចដើម្បីត្រាច់ទៅក្នុងកាលមិនគួរជាមួយនឹងពួកយើងបានទេ, ពួកយើងស្តាប់ធម៌នោះហើយ ឱ្យចំណែកបុណ្យនោះដល់កូន” ដូច្នេះ ហើយនាំគ្នាទៅ ។ កុលធីតានោះសូម្បីចង់ទៅ, តែមិនអាចរឹងទទឹងនឹងពាក្យរបស់មាតាបិតាបាន ទើបឈប់នៅខាងក្រោយ ឈរទៀបទ្វារផ្ទះ ប្រមើលមើលទីលានព្រះចេតិយ ទៀបគិរិគណ្ឌកវិហារ ផ្លូវអាកាសដោយពន្លឺព្រះចន្ទ បានឃើញការបូជាដួងប្រទីបនៃព្រះចេតិយ និងបានឃើញបរិស័ទទាំង ៤ ធ្វើការបូជាព្រះចេតិយដោយមាលា និងគ្រឿងក្រអូបជាដើម ហើយធ្វើប្រទក្សិណ; បានស្តាប់សំឡេងស្វាធ្យាយជាគណៈនៃពួកភិក្ខុសង្ឃ ។ គ្រានោះ នាងគិតថា “ឱ! មនុស្សអ្នកមានបុណ្យទាំងនេះ នាំគ្នាទៅវត្ត, បានដើម្បីការដើរក្រឡឹង (ប្រទក្សិណ) ទូលព្រះចេតិយ និងបានដើម្បីស្តាប់ព្រះធម្មកថាដ៏ពិរោះ មានសភាពបែបនេះ” ដូច្នេះហើយ កំពុងប្រមើលមើល ព្រះចេតិយប្រាកដដូចគំនរកែវមុក្តានោះឯង **ឧព្វេង្គាបីតិ** ក៏កើតឡើង ។ នាងអណ្តែតទៅក្នុងអាកាស ចុះលើទីលានព្រះចេតិយតាមផ្លូវអាកាស មុនជាងមាតា និងបិតា ហើយថ្វាយបង្គំព្រះចេតិយ ឈរស្តាប់ព្រះធម៌ ។ គ្រានោះ មាតា និងបិតាមកដល់ហើយសួរនាងកុលធីតានោះថា “នៃកូន នាងមកតាមផ្លូវណា?”; នាង

ឆ្លើយថា “ខ្ញុំមកតាមផ្លូវអាកាស, មិនមែនមកតាមផ្លូវទេ”។ មាតាបិតានិយាយថា “ធម្មតាព្រះខីណាស្រពទាំងឡាយ ទើបត្រាច់ទៅតាមផ្លូវអាកាសបាន, នាងមកបានដូចម្ដេច?” ដូច្នេះ នាងឆ្លើយថា “កាលកូនឈរមើលព្រះចេតិយដោយពន្លឺព្រះចន្ទ បីតិដ៏មានកម្លាំង មានពុទ្ធគុណជាអារម្មណ៍ ក៏កើតឡើង, គ្រានោះ ខ្ញុំមិនជ្រាបថា ខ្លួនឈរ ឬអង្គុយ, ស្រាប់តែអណ្ដែតទៅកាន់អាកាសដោយនិមិត្តដែលកាន់យកនោះឯង ហើយឈរត្រង់ទីលានព្រះចេតិយ” ; **ឧព្វេង្គាបីតិ** មានការអណ្ដែតទៅក្នុងអាកាស ដោយប្រការដូច្នេះ ។

ចំណែកផរណាបីតិកើតឡើងហើយ ក៏ផ្សាយទៅកាន់សរីរៈទាំងអស់ដូចថង់ ដែលពេញដោយខ្យល់ និងដូចផ្ទៃភ្នំដែលអន្លង់ទឹកធំហូរចូលទៅជ្រួតជ្រាបហើយ ។

ក៏បីតិ ៥ យ៉ាងនេះ កាលកាន់យកគភិដល់ការចាស់ជុំវិញ ញ៉ាំងបស្សទ្ធិ ២ យ៉ាង គឺកាយបស្សទ្ធិ និងចិត្តបស្សទ្ធី ឱ្យបរិបូណ៌ បស្សទ្ធិកាលកាន់យកគភិដល់ការចាស់ជុំវិញញ៉ាំងសុខ ២ យ៉ាង គឺកាយិកសុខ និងចេតសិកសុខឱ្យបរិបូណ៌, សុខកាលកាន់យកគភិដល់ការចាស់ជុំវិញ ញ៉ាំងសមាធិ ៣ គឺ

ខណិកសមាធិ, ឧបចារសមាធិ និងអប្បនាសមាធិឱ្យបរិបូណ៌ ។ បណ្ដាបីតិទាំងនោះ បីតិ ២ យ៉ាង វៀរបីតិដែលដល់ការសម្បូណ៌ដោយអប្បនា គួរក្នុងកាមាវចរនេះ ៕

## អត្ថនៃពាក្យថាសុខ

**សុខយតីតិ សុខំ** = ធម៌ដែលមានឈ្មោះថា **សុខ** ព្រោះអត្ថថាសប្បាយ, អធិប្បាយថា សេចក្ដីសុខកើតឡើងដល់អ្នកណា, ក៏ធ្វើបុគ្គលនោះឱ្យដល់សេចក្ដីសប្បាយ ។ ម្យ៉ាងទៀត ធម្មជាតិណាទំពាស៊ីដោយល្អ, និង ជីក (ទម្លាយ) អាពាធផ្លូវកាយផ្លូវចិត្ត ព្រោះហេតុនោះ ធម្មជាតនោះ ទើបឈ្មោះថា **សុខ** ។ សុខនេះជាឈ្មោះរបស់សោមនស្សវេទនា ។ បណ្ឌិតគប្បីជ្រាបលក្ខណៈជាដើមរបស់សុខនោះ ដោយន័យដែលពោលហើយក្នុងបទនៃវេទនានោះឯង; ន័យមួយទៀត ៖-

សុខ មានវេទនាដែលឆ្ងាញ់ពិសាជាលក្ខណៈ = **សាតលក្ខណំ**, មានការញ៉ាំងសម្បយុត្តធម៌ ទាំងឡាយឱ្យចម្រើនជាកិច្ច = **សម្បយុត្តានំ ឧបព្រូហនរសំ**, មានការអនុគ្រោះជាផល = **អនុគ្គហនបច្ចុប្បដ្ឋានំ**; ក៏កាលបើបីតិ

និងសុខទាំងនោះ មិនញែកគ្នាមាននៅក្នុងទីខ្លះ សេចក្ដីត្រេកអរក្នុងការបាន ឥដ្ឋារម្មណ៍ជាបីតិ, ការសោយនូវរសនៃអារម្មណ៍ដែលបានហើយជាសុខ; បីតិ មានក្នុងទីណា, សុខក៏មានក្នុងទីនោះ, សុខមានក្នុងទីណា, ក្នុងទីនោះ មិន ទៀងថា មានបីតិទេ; បីតិលោកសង្គ្រោះចូលក្នុងសង្ខារក្ខន្ធ, សុខលោក សង្គ្រោះចូលក្នុងវេទនាខន្ធ ។ បីតិរមែងមានក្នុងករណីដែលបុគ្គលនឿយហត់ ក្នុងផ្លូវកន្តារ (ផ្លូវដាច់ស្រយាល) បានឃើញព្រៃ ឬបានឮសំឡេងទឹក, សុខ មានក្នុងវេលាដែលបុគ្គលនោះ ចូលទៅកាន់ម្លប់ក្នុងព្រៃ និងប្រើប្រាស់ទឹក ដូច្នោះ ។

ដូចយ៉ាងថា បុរសដើរផ្លូវកន្តារច្រើន មានញើសជោគខ្លួន មានការ ស្រេកឃ្លាន ឃើញបុរសដើរផ្លូវជួសមក ក៏គប្បីសួរថា "ទឹកផឹកមាន ក្នុង ទីណា?" , បុរសនោះប្រាប់ថា "ឆ្លងផុតដងព្រៃទៅ មានស្រះធម្មជាតិ (ជាតស្រះ) និងព្រៃសណ្ឌ (ព្រៃស្ដុក), អ្នកទៅក្នុងទីនោះ នឹងបាន"; គេ ស្ដាប់ពាក្យប្រាប់ បុរសនោះហើយ ក៏គប្បីមានចិត្តត្រេកអររីករាយ, កាលគេ ទៅអំពីនោះ ឃើញស្រទាប់ធាងស្លឹក ផ្កាឧប្បលជាដើមធ្លាក់ចុះលើផែនដី ក៏ជាអ្នកមានចិត្តត្រេកអររីករាយច្រើនឡើង កាលដើរទៅ ឃើញបុរសមាន

សំពត់សើម សក់សើម, ឮសំឡេងមាន់ព្រៃ និងក្ងោកជាដើម, គប្បីឃើញព្រៃសណ្ឋះដែលខៀវ ដូចសំណាញ់កែវមណី ដែលកើតនៅមាត់ជាតស្រះ; គប្បីឃើញផ្កាឧប្បល បទុម និងផ្កាកោមុទៈជាដើម ដែលកើតឡើងក្នុងស្រះ, គប្បីឃើញទឹកថ្លាស្អាត; គេក៏មានសេចក្ដីត្រេកអររីករាយក្រៃលែង ទើបឈានចុះកាន់ជាតស្រះ ងូតទឹក និងផឹកទឹកតាមពេញចិត្ត រំងាប់ការក្រវល់ក្រវាយ ហើយទំពាស៊ីក្រឱឈូក និងស្លឹកឈូកជាដើម ប្រដាប់ផ្កាឧប្បលខៀវជាដើម យកក្រឱឈូកសដាក់លើស្មា ឡើងអំពីស្រះហើយ ស្លៀកសំពត់សាដក ហាលសំពត់សាដក សើមត្រង់កំដៅថ្ងៃ ដេកនៅក្រោមម្លប់ ដ៏ត្រជាក់កាលខ្យល់តិចៗ បក់មក ទើបពោលថា “សុខហ្ន៎ៗ” ; ពាក្យឧបមាជាគ្រឿងឧបមេយ្យ គប្បីជ្រាបយ៉ាងនេះ ។

ក៏បីតិមានអាការរីករាយត្រេកអរក្នុងអារម្មណ៍ជាចំណែកខាងដើម គប្បីឃើញដូចវេលាដែលរីករាយត្រេកអរ រាប់តាំងពីពេលដែលបុរសនោះបានឮថា មានជាតស្រះ និងព្រៃសណ្ឋះ ដរាបដល់បានឃើញទឹក ។ សុខឋិតនៅដោយអាការសោយរសអារម្មណ៍ ដែលដល់ការមានកម្លាំង គប្បីឃើញដូចបុគ្គលងូតទឹក ។ ផឹកហើយដេកនិយាយថា “សុខហ្ន៎ សុខហ្ន៎!” ក្រោមម្លប់ឈើដ៏ត្រជាក់ ដែលមានខ្យល់ល្ហើយៗ បក់មកប៉ះ។ ក៏សុខនេះគប្បីជ្រាបថា

ព្រះមានជោគទ្រង់ត្រាស់ហើយ ព្រោះការប្រាកដក្នុងសម័យនោះៗ ដូច្នេះ, ពាក្យនេះលោកពោលអធិប្បាយថា ក៏ក្នុងទីណា មានបីតិ, សូម្បីសុខក៏មានក្នុងទីនោះៗឯង ៕

## អធិប្បាយអំពីឯកគ្គតានៃចិត្ត

ភាវៈនៃចិត្តដែលមានអារម្មណ៍តែមួយ ឈ្មោះថា **ចិត្តស្សេកគ្គតា**, ពាក្យថា ចិត្តស្សេកគ្គតានេះ ជាឈ្មោះរបស់សមាធិ ។ ក៏ក្នុងធម៌មានលក្ខណៈជាដើមនៃសមាធិនោះ អដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាមុនថា ៖-

"សមាធិនោះ មានភាវៈជាប្រធានជាលក្ខណៈ = **បាមោក្ខលក្ខណោ** និងមានការមិនរវើរវាយជាលក្ខណៈ = **អវិក្ខេបលក្ខណោ** ។

ពិតមែន សមាធិឈ្មោះថា ជាប្រធាននៃធម៌នោះទាំងអស់ ព្រោះកុសលទាំងពួងសម្រេចដោយសមាធិ ដូចហោជាងនៃផ្ទះមានកំពូល ឈ្មោះថាជាប្រធានរបស់ទព្វសម្ភារៈនៃផ្ទះដ៏សេស ព្រោះជាគ្រឿងរឹបទុក; ព្រោះហេតុដូច្នោះ ព្រះនាគសេនត្ថេរទើបថ្វាយព្រះពរថា ៖-

"បពិត្រមហារាជ ឈើផ្ទោងទាំងឡាយ មិនថាចំណែកណានៃកូដាគារ (ផ្ទះកំពូល) ឈើផ្ទោងទាំងអស់នោះ ទៅរួមត្រង់កំពូលផ្ទះ បង្អោនទៅ

ត្រង់កំពូល ទៅប្រជុំគ្នាត្រង់កំពូល លយទៅត្រង់កំពូល, កំពូលផ្ទះ បណ្ឌិតពោលថា ជាកំពូលជាងឈើផ្ទោងទាំងនោះ យ៉ាងណា, សូមថ្វាយព្រះពរមហារាជ កុសលធម៌ មិនថាប្រភេទណា, កុសលធម៌ទាំងអស់នោះ បង្អោនទៅកាន់សមាធិ ប្រជុំចុះត្រង់សមាធិ លយទៅត្រង់សមាធិ, សមាធិ បណ្ឌិតពោលថា ជាកំពូលនៃកុសលធម៌ទាំងនោះ យ៉ាងនោះ”[២៥] ។ សមាធិឈ្មោះថា មានការមិនរវើរវាយជាលក្ខណៈ ព្រោះមិនឱ្យសហជាតធម៌ទាំងឡាយ រាយមាយ ខ្ចាត់ខ្ចាយ ដូចព្រះរាជាជាកំពូលទ័ព ស្ដេចយាងទៅកាន់ទីទាហាន ប្រជុំគ្នាកកកុញ ក្នុងទីដែលព្រះអង្គស្ដេចយាងទៅៗ, ទាហានរមែងព្រមព្រៀងគ្នាទម្លាយទាហានសត្រូវ ស្របតាមព្រះរាជានោះឯង” ។

ន័យម្យ៉ាងទៀត ឈ្មោះថា **សមាធិ** ពោលគឺឯកគ្គតានៃចិត្តនេះ មានការមិនផ្សាយជាលក្ខណៈ ឬមានការមិនរវើរវាយជាលក្ខណៈ, មានការប្រមូលមកនូវសហជាតធម៌ទាំងឡាយ ចូលរួមគ្នាជាកិច្ច ដូចទឹកប្រមូលលម្អិតសម្រាប់ងូតទឹក (ធ្វើលម្អិតឱ្យជាដុំ); មានការស្ងប់ជាផល ឬមានញាណជាផល, អធិប្បាយថា “បុគ្គលមានចិត្តតាំងមាំហើយ រមែងជ្រាបច្បាស់ គឺ

---

[២៥] មិលិន្ទ. ។

រមែងឃើញតាមការពិត”[២៦] ; ពោលដោយពិសេស សមាធិ មានសុខជាបទដ្ឋាន, បណ្ឌិតគប្បីជ្រាបការតាំងនៅនៃចិត្ត ដូចការតាំងនៅនៃអណ្ដាតប្រទីបប្រាសចាកខ្យល់ដូច្នោះដែរ ៕

## អត្ថនៃពាក្យថាសទ្ធិន្ទ្រិយ

ធម៌ដែលឈ្មោះ សទ្ធា ព្រោះអត្ថថា ជាហេតុឱ្យជឿ, ឬជឿឯង, ឬត្រឹមតែការជឿប៉ុណ្ណោះ ក៏ឈ្មោះថា សទ្ធា ។ សទ្ធានោះ ឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា អធិបតី ព្រោះការគ្របសង្កត់ការមិនជឿ ។ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រងភាពជាធំជាងធម៌ដទៃ ក្នុងការបង្អោនចិត្តជឿជាលក្ខណៈ, សទ្ធានោះឯង ជាឥន្ទ្រិយ ឈ្មោះថា សទ្ធិន្ទ្រិយ ។ ក៏សទ្ធានោះមានការជ្រះថ្លា ជាលក្ខណៈ = **សម្បសាទនលក្ខណា** និងមានការស្ទុះទៅជាលក្ខណៈ = **បក្ខន្ទនលក្ខណា** ។ សទ្ធាកាលកើតឡើង រមែងសង្កត់នីវរណៈទាំងឡាយ, ញ៉ាំងកិលេសឱ្យស្ងប់, ធ្វើចិត្តឱ្យផូរផង់, ធ្វើចិត្តមិនឱ្យល្អក់, ដូចកែវមណីនៃព្រះបាទចក្រពត្តិ ដែលធ្វើទឹកឱ្យថ្លាស្អាត ដាក់ក្នុងទឹកហើយ

---

[២៦] សំ. សឡា., សំ. ម. ។

ធ្វើឱ្យកករ, សារាយ, ចក និងភក់ ស្ងប់ (ធ្លាក់ចុះ), ឱ្យទឹកថ្លាស្អាត, មិនល្អក់ដូច្នោះ ។ កុលបុត្រយោគាវចរឱ្យទានក្ដី, សមាទានសីលក្ដី, ធ្វើឧបោសថកម្មក្ដី, ប្រារព្ធភាវនាក្ដី ដោយចិត្តដ៏ផូរផង់ គប្បីជ្រាបសទ្ធានោះ យ៉ាងនេះថា **មានការជ្រះថ្លាជាលក្ខណៈ; ព្រោះហេតុនោះ ព្រះនាគសេនត្ថេរមានអាយុ** ទើបថ្វាយព្រះពរ ព្រះបាទមិលិន្ទថា ៖-

"បពិត្រមហារាជ ស្ដេចចក្រពត្តិឆ្លងស្ទឹងតូច ជាមួយនឹងចតុរង្គិនីសេនា, ទឹកនោះគប្បីរលកដោយដំរី សេះ រថ និងពលថ្មើរជើងទាំងឡាយ ក៏ល្អក់ ល្អក់កករជាភក់, ព្រះរាជាទ្រង់ឆ្លងទៅហើយ ទើបបញ្ជាមនុស្សទាំងឡាយថា "នែប្រស្ដែង ពួកអ្នកចូរនាំទឹកផឹកមក, យើងនឹងសោយទឹកនោះ"; ក៏ព្រះរាជាមានកែវមណីសម្រាប់ធ្វើទឹក ឱ្យថ្លាស្អាត, ពួកមនុស្សទើបក្រាបទូលថា "ព្រះករុណាថ្លៃវិសេស" ហើយយកកែវមណីដែលធ្វើទឹកឱ្យថ្លានោះដាក់ចុះក្នុងទឹក; ព្រមនឹងការធ្លាក់ចុះទៅក្នុងទឹក កករ សារាយ ចក ភក់ ក៏ស្ងប់ (លិចចុះ), ទឹកគប្បីជាទឹកថ្លាស្អាត មិនល្អក់, លំដាប់នោះ ពួកមនុស្សក៏បង្អោនទឹកសោយ ថ្វាយព្រះរាជា ដោយក្រាបទូលថា "សូមព្រះសម្មតិទេព ទ្រង់សោយទឹកចុះព្រះអង្គ" ។

## អដ្ឋសាលិនី

សូមថ្វាយព្រះពរមហាបពិត្រ ព្រះអង្គគប្បីឃើញចិត្តដូចទឹក, គប្បីឃើញកុលបុត្រយោគាវចរ ដូចមនុស្សទាំងនោះ, គប្បីឃើញកិលេស ដូចកករ សារាយ ចក ភក់, គប្បីឃើញសទ្ធាដូចកែវមណីធ្វើទឹកឱ្យថ្លាស្អាត, សូមថ្វាយព្រះពរ មហាបពិត្រ សទ្ធាកាលកើតរមែងសង្កត់នីវរណៈទាំងឡាយ, ចិត្តប្រាសចាកនីវរណៈ ក៏ថ្លាស្អាតមិនល្អក់ ដូចកាលដាក់កែវមណី ដែលញុំាងទឹកឱ្យថ្លាស្អាត ហើយកករ សារាយ ចក ភក់ រមែងស្ងប់ ទឹកថ្លាស្អាតមិនល្អក់" ។

ដូចយ៉ាងថា ពួកជនអ្នកខ្លាច អាស្រ័យមហានទីដែលច្រើនទៅដោយក្រពើ ឆ្លាម មករ និងអារក្សទឹកកាចជាដើម ក៏ឈរទ្បៀបឆ្នេរ ស្ទឹងទាំងពីរ, ចំណែកមេទាហាន អ្នកក្លាហានក្នុងសង្គ្រាមមកដល់ ទើបសួរថា "ព្រោះហេតុអ្វី ពួកអ្នកទើបឈរ?" កាលគេប្រាប់ថា "ពួកយើងមិនអាចឆ្លង ព្រោះមានភ័យចំពោះមុខ" ទើបចាប់ដាវដែលខ្លួនស្ទាត់ជំនាញមកនោះ ហើយប្រាប់ថា "ពួកអ្នកចូរមកខាងក្រោយយើង, កុំខ្លាចឡើយ" ហើយឈានចុះកាន់ស្ទឹង ការពារក្រពើជាដើមដែលមកហើយៗ ធ្វើសេចក្តីសួស្តីដល់ពួកមនុស្សទាំងឡាយ នាំអំពីត្រើយអាយទៅត្រើយនាយយ៉ាងណា, កាលបុគ្គល

ឱ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ប្រារព្ធភាវនា សទ្ធារមែងជាប្រធាន ជាភារៈនាំមុខទៅ; ព្រោះហេតុដូច្នោះ ទើបពោលថា “**សទ្ធា** មានការស្ទុះទៅជាលក្ខណៈ” ។

ន័យមួយទៀត សទ្ធាមានការជឿជាលក្ខណៈ = **សទ្ទហនលក្ខណា** ឬមានការជឿមាំជាលក្ខណៈ = **ឱកប្បនលក្ខណា វា**, មានការជ្រះថ្លាជាកិច្ច = **បសាទនរសា**, ដូចកែវមណីធ្វើទឹកឱ្យថ្លាឆ្វេង, ឬថា មានការស្ទុះទៅជាកិច្ច = **បក្ខន្ទនរសា** ដូចការឆ្លងអន្លង់ទឹក; មានការមិនកករជាផល = **អកាលុស្សិយប្បច្ចុបដ្ឋានា** ឬមានការបង្អោនចិត្តជឿជាផល = **អធិមុត្តិបច្ចុប្បដ្ឋានា**, មានវត្ថុជាទីតាំងនៃសទ្ធា ជាហេតុជិត = **សទ្ធេយ្យវត្ថុបទដ្ឋានា** ឬមានសោតាបត្តិយង្គ (អង្គជាហេតុនៃសោតាបត្តិមគ្គ) ជាហេតុជិត, បណ្ឌិតគប្បីឃើញដូចដៃ ទ្រព្យ សម្បត្តិ និងពូជ ៕

## អត្ថនៃពាក្យថាវីរិយិន្ទ្រិយ

ភាពនៃបុគ្គលជាអ្នកក្លាហាន ឈ្មោះថា **វីរិយៈ**, ឬការងារនៃបុគ្គលអ្នកក្លាហាន ឈ្មោះថា **វីរិយៈ**, ឬថា ឈ្មោះថា **វីរិយៈ** ព្រោះអត្ថថា គប្បីដើរទៅ គឺឱ្យប្រព្រឹត្តទៅដោយវិធី ដោយន័យ ដោយឧបាយ ។ វីរិយៈនោះ

ឯង ឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ជាអធិបតី ព្រោះសង្កត់កោសជ្ជៈ (ការខ្ជិលច្រអូស) ។ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះភាពជាធំជាងធម៌ដទៃក្នុងលក្ខណៈនៃសេចក្ដីព្យាយាម ។ សេចក្ដីព្យាយនោះឯងជាឥន្ទ្រិយ ឈ្មោះថា វីរិយិន្ទ្រិយ ។ ក៏វីរិយៈនេះនោះ មានការឧបត្ថម្ភ គឺកល់ទ្រទុកជាលក្ខណៈ = **ឧបត្ថម្ភនលក្ខណំ** និងមានការផ្គងទុកជាលក្ខណៈ = **បគ្គហណលក្ខណំ**, ដូចយ៉ាងថា ផ្ទះចាស់តាំងនៅបានដោយសសរដទៃ មកទ្រកល់ទុកយ៉ាងណា, ព្រះយោគាវចរ ក៏យ៉ាងនោះឯង ជាអ្នកបានឧបត្ថម្ភហើយដោយឧបត្ថម្ភរបស់វីរិយៈ កុសលធម៌ទាំងពួង ទើបមិនសូន្យទៅ គឺមិនវិនាសទៅ; គប្បីជ្រាបវីរិយិន្ទ្រិយនោះ មានការជ្រោមជ្រែង គឺទ្រទុកជាលក្ខណៈ យ៉ាងនេះសិន; ដោយហេតុនោះ ព្រះនាគសេនត្ថេរ ទើបថ្វាយព្រះពរព្រះបាទមិលិន្ទ្រថា ៖-

"មហាបពិត្រ វីរិយៈ មានការឧបត្ថម្ភ គឺគាំទ្រជាលក្ខណៈ, កុសលធម៌ទាំងអស់ មានវីរិយៈឧបត្ថម្ភគាំទ្រហើយ មិនសូន្យទៅ គឺមិនវិនាសទៅ ដូចកាលផ្ទះចាស់ទ្រេតទៅ បានឈើដទៃមកទល់ទ្រផ្ទះដែលមានសសរឧបត្ថម្ភជ្រោមជ្រែងហើយនុ៎ះឯង ក៏មិនគប្បីរលំ"[២៧] ។

---

[២៧] មិលិន្ទ.។

ដូចយ៉ាងថា កងទ័ពតូចនិងកងទ័ពធំ ធ្វើសង្គ្រាមគ្នា កងទ័ពតូចថយបន្តិចមក, គ្រានោះគេគប្បីក្រាបទូលព្រះរាជា, ព្រះរាជាគប្បីបញ្ជូនពលនិងពាហនៈទៅ, កងទ័ពរបស់ព្រះអង្គដែលពល និងពាហនៈជួយគាំទ្រហើយគប្បីញុាំងកងទ័ពសត្រូវឱ្យបរាជ័យយ៉ាងណា, វិរិយៈក៏យ៉ាងនោះដែរ រមែងមិនធ្វើឱ្យសម្បយុត្តធម៌ដែលកើតព្រមគ្នា ឱ្យរួញរា ឱ្យថយ លើកគឺផ្គងទុក; ដោយហេតុនោះ ទើបលោកពោលទុកថា "មានការផ្គងទុកជាលក្ខណៈ"។

ន័យម្យ៉ាងទៀត វិរិយៈមានការឧស្សាហ៍ជាលក្ខណៈ = **ឧស្សាហនលក្ខណំ**, មានការជួយឧបត្ថម្ភសហជាតធម៌ទាំងឡាយជាកិច្ច = **សហជាតធម្មានំ ឧបត្ថម្ភនរសំ**, មានការមិនរាថយជាផល = **សំសីទនភាវបច្ចុបដ្ឋានំ**, មានការសង្វេគជាហេតុជិត = **សំវេគបទដ្ឋានំ** ព្រោះព្រះបាលីថា **សំវេគ្គោ យោនិសោ បទហតិ** = ការស្លុត តែងផ្តើមតាំងសេចក្តីព្យាយាម ដោយឧបាយ [២៨] ឬមានវត្ថុនៃវិរិយារម្ភជាហេតុជិត = **វត្ថុវីរិយារម្ភបទដ្ឋានំ វា**; បណ្ឌិតគប្បីជ្រាបថា សេចក្តីព្យាយាមដែលតាំងផ្តើមដោយត្រឹមត្រូវ ជាមូលហេតុនៃសម្បត្តិទាំងពួង ៕

---

[២៨] អំ. ចតុក្ក.។

## អត្ថនៃពាក្យថាសតិន្ទ្រិយ

ធម៌ដែលឈ្មោះថា **សតិ** ព្រោះជាហេតុរលឹក, ឬថា រលឹកឯង, ឬថា ត្រឹមតែការរលឹកប៉ុណ្ណោះ ។ ក៏សតិនោះឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ជាអធិបតី ព្រោះការគ្របសង្កត់ភាពជាអ្នកភ្លេចសតិ, ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះភាពជាធំក្នុងលក្ខណៈនៃការឧបដ្ឋាន (ការតាំងមាំ), សតិនោះឯង ជាឥន្ទ្រិយ ឈ្មោះថា **សតិន្ទ្រិយ** ។ ក៏សតិនេះនោះ មានការមិនង៉ើមង៉ាម(មិនភាន់ច្រឡំ)ជាលក្ខណៈ និងមានការផ្គងយ៉ាងមាំជាលក្ខណៈ; សតិរមែងឱ្យកំណត់ រមែងឱ្យរលឹកកុសលកម្មដោយត្រឹមត្រូវ ដូចនាយឃ្លាំងរបស់ព្រះរាជា រក្សារតនៈ ១០ យ៉ាង ញ៉ាំងព្រះរាជាឱ្យកំណត់ ឱ្យរលឹកដល់ឥស្សរិយសម្បត្តិក្នុងពេលល្ងាច ពេលព្រឹកដូច្នោះ ។ ព្រោះហេតុនោះ **ព្រះនាគសេនត្ថេរ** ទើបថ្វាយព្រះពរព្រះរាជាថា ៖-

“មហាបពិត្រ នាយឃ្លាំងរបស់ស្តេចចក្រពត្តិ រមែងញ៉ាំងស្តេចចក្រពត្តិឱ្យរលឹកដល់ឥស្សរិយសម្បត្តិក្នុងពេលល្ងាច និងពេលព្រឹកថា ‘បពិត្រព្រះសម្មតិទេព ដំរីមានប្រមាណប៉ុណ្ណេះ, សេះមានប្រមាណប៉ុណ្ណេះ, រថមានប្រមាណប៉ុណ្ណេះ, ពលថ្មើរជើងមានប្រមាណប៉ុណ្ណេះ, ប្រាក់មានប្រមាណប៉ុណ្ណេះ, មាសមានប្រមាណប៉ុណ្ណេះ, សម្បត្តិទាំងពួងមានប្រមាណប៉ុណ្ណេះ, សូមព្រះសម្មតិទេព រលឹកដល់ឥស្សរិយសម្បត្តិទាំងពួង’ យ៉ាងណា, សូមថ្វាយ

ព្រះពរមហាបពិត្រ សតិក៏យ៉ាងនោះដែរ ឱ្យរលឹកដល់កុសលធម៌ទាំងឡាយ គឺ ‘សតិប្បដ្ឋាន ៤ នេះ, សម្មប្បធាន ៤ នេះ, ឥទ្ធិបាទ ៤ នេះ, ពលៈ ៥ នេះ, ឥន្ទ្រិយ ៥ នេះ, ពោជ្ឈង្គ ៧ នេះ, នេះអរិយមគ្គប្រកបដោយអង្គ ៨, នេះសមថៈ, នេះវិបស្សនា, ទាំងនេះជាអរិយសច្ច, នេះជាវិជ្ជា, នេះជាវិមុត្តិ, ទាំងនេះជាលោកុត្តរធម៌’ ដូច្នេះ; មហាបពិត្រ សតិមានការរលឹកជាលក្ខណៈយ៉ាងនេះឯង”[២៩] ។

ក៏សតិពិចារណាគតិទាំងឡាយនៃធម៌ដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ដឹងថា “ធម៌ទាំងឡាយមានកាយទុច្ចរិតជាដើមនេះ ថាមិនជាប្រយោជន៍” ដូច្នេះ រមែងច្រានចេញធម៌ដែលមិនជាប្រយោជន៍, ដឹងថា “ធម៌ទាំងឡាយមានកាយសុចរិតជាដើមនេះ ជាប្រយោជន៍” រមែងរក្សាធម៌ដែលជាប្រយោជន៍ ដូចបរិនាយកកែវរបស់ស្តេចចក្រពត្តិ ដឹងវត្ថុដែលមិនជាប្រយោជន៍ និងវត្ថុដែលមានប្រយោជន៍របស់ស្តេចចក្រពត្តិ នាំយកវត្ថុដែលមិនជាប្រយោជន៍ចេញទៅ បង្អោនមកនូវវត្ថុដែលជាប្រយោជន៍ដូច្នោះ។ ព្រោះហេតុនោះ ព្រះនាគសេនត្ថេរទើបថ្វាយព្រះពរព្រះរាជាថា “បពិត្រមហារាជ បរិនាយកកែវនៃស្តេចចក្រពត្តិ ដឹងវត្ថុដែលជាប្រយោជន៍ និងវត្ថុដែលមិនជាប្រយោជន៍ ដល់ព្រះបាទចក្រពត្តិថា ‘វត្ថុទាំងឡាយនេះ ជា

[២៩] មិលិន្ទ.។

ប្រយោជន៍ដល់ព្រះរាជា, វត្ថុទាំងនេះ មិនជាប្រយោជន៍, វត្ថុទាំងនេះជាឧបការៈ, វត្ថុទាំងនេះ មិនជាឧបការៈ' ; បន្ទាប់អំពីនោះ ក៏នាំចេញ (កម្ចាត់) វត្ថុមិនជាប្រយោជន៍, ថែរក្សាវត្ថុដែលមានប្រយោជន៍ យ៉ាងណា, សូមថ្វាយព្រះពរមហាបពិត្រ សតិក៏យ៉ាងនោះដែរ កាលកើតឡើង រមែងពិចារណាគតិទាំងឡាយ នៃធម៌ដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ថា 'ធម៌ទាំងនេះ ជាប្រយោជន៍, ធម៌ទាំងនេះមិនជាប្រយោជន៍, ធម៌ទាំងនេះ មានឧបការៈ, ធម៌ទាំងនេះមិនមានឧបការៈ' ; លំដាប់នោះ ក៏នាំចេញ(កម្ចាត់) ធម៌ដែលមិនជាប្រយោជន៍, រក្សាធម៌ដែលមិនជាប្រយោជន៍, មហាបពិត្រ សតិមានការរក្សាជាលក្ខណៈយ៉ាងនេះឯង" ។

ក៏ន័យម្យ៉ាងទៀត សតិមានការមិនភ្លេចភ្លាំងជាលក្ខណៈ, មានការមិនវង្វេងជាកិច្ច, មានការរក្សា (អារម្មណ៍) ខ្ជាប់ជាផល, ឬមានមុខឆ្ពោះទៅកាន់អារម្មណ៍ជាហេតុជិត, មានការចាំបានដ៏មាំទាំជាហេតុជិត ឬមានកាយគតាសតិប្បដ្ឋានជាដើម ជាហេតុជិត; ក៏បណ្ឌិតគប្បីយល់ឃើញសតិ ដូចសសរខឿន ព្រោះតាំងនៅមាំក្នុងអារម្មណ៍ និងដូចឆ្មាំទ្វារ អ្នករក្សាទ្វារ ព្រោះរក្សាទ្វារទាំងឡាយមានចក្ខុទ្វារជាដើម ៕

## អត្ថនៃពាក្យថាសមាធិន្ទ្រិយ

ធម៌ដែលឈ្មោះថា **សមាធិ** ព្រោះតាំងមាំ គឺដាក់ចិត្តទុកក្នុងអារម្មណ៍ដោយល្អ, ក៏សមាធិនោះឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ជាអធិបតី ព្រោះគ្របសង្កត់ការរវើរវាយ, ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រងរក្សាភាពជាធំជាងធម៌ដទៃក្នុងលក្ខណៈនៃការមិនរវើរវាយ ។ សមាធិនោះឯង ជាឥន្ទ្រិយ ឈ្មោះថា សមាធិន្ទ្រិយៈ; ក៏ធម៌មានលក្ខណៈជាដើមរបស់សមាធិនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលមកហើយ ក្នុងខាងក្រោយនោះឯង ៕

## អត្ថនៃពាក្យថាបញ្ញិន្ទ្រិយ

**បជានាតីតិ បញ្ញា** ធម៌ដែលឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ដឹងច្បាស់ ។ សួរថា ដឹងច្បាស់នូវអ្វី? ឆ្លើយថា ដឹងច្បាស់នូវអរិយសច្ចទាំងឡាយ ដោយន័យមានពាក្យថា “នេះជាទុក្ខ” ជាដើម; **តែក្នុងអដ្ឋកថា** លោកពោលទុកថា “ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា រមែងឱ្យដឹងច្បាស់” ។ សួរថា រមែងឱ្យដឹងច្បាស់នូវអ្វី? ឆ្លើយថា រមែងឱ្យដឹងច្បាស់ថា “**អនិច្ចំ ទុក្ខំ អនត្តា**” ។

ក៏បញ្ញានោះឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ជាអធិបតី ព្រោះគ្រប

សង្កត់អវិជ្ជា, ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះភាពជាធំជាងធម៌ដទៃក្នុងលក្ខណៈនៃការឃើញ។ បញ្ញានោះឯង ជាឥន្ទ្រិយ ឈ្មោះថា **បញ្ញិន្ទ្រិយ**។ បញ្ញានេះឯង មានការបំភ្លឺជាលក្ខណៈ = **ឱភាសនលក្ខណា** និងមានការដឹងច្បាស់ជាលក្ខណៈ = **បជាននលក្ខណា**; ដូចយ៉ាងថា កាលបុគ្គលអុជប្រទីបឱ្យភ្លឺក្នុងពេលយប់ ក្នុងផ្ទះដែលមានជញ្ជាំង ៤ ខាង សេចក្ដីងងឹតរមែងអស់ទៅ, ពន្លឺរមែងប្រាកដ យ៉ាងណា; បញ្ញាក៏ភ្លឺយ៉ាងនោះដែរ ។ ធម្មតាពន្លឺ ស្មើដោយពន្លឺនៃបញ្ញាមិនមាន = **បញ្ញាភាសសមោ ឱភាសោ នាម នត្ថិ** ។ ពិតណាស់ កាលមហាបុរស អ្នកមានបញ្ញាអង្គុយដោយបល្ល័ង្កមួយ មុឺនលោកធាតុ ក៏មានពន្លឺដូចគ្នា ។ ដោយហេតុនោះ **ព្រះនាគសេនត្ថេរ** ទើបថ្វាយព្រះពរព្រះរាជាថា "មហាបពិត្រ ក្នុងពេលដែលងងឹតសុងហើយ បុរសគប្បីយកប្រទីបនាំចូលទៅក្នុងផ្ទះ ប្រទីបដែលនាំចូលទៅហើយ រមែងកម្ចាត់សេចក្ដីងងឹត រមែងញុំាងពន្លឺឱ្យកើតឡើង, ញុំាងពន្លឺឱ្យរុងរឿង, ធ្វើរូបឱ្យប្រាកដ យ៉ាងណា; មហាបពិត្រ បញ្ញាក៏យ៉ាងនោះដែរ កាលកើតឡើងតែងកម្ចាត់ការងងឹត គឺអវិជ្ជា ញុំាងឱភាស គឺវិជ្ជាឱ្យកើតឡើង ញុំាងពន្លឺ គឺបញ្ញាឱ្យរុងរឿង និងធ្វើអរិយសច្ចទាំងឡាយ ឱ្យប្រាកដ; មហាបពិត្រ បញ្ញាក៏មានការភ្លឺស្វាងជាលក្ខណៈ ដោយប្រការដូច្នេះឯង"[៣០] ។

---
[៣០] មិលិន្ទ. ១។

ម្យ៉ាងទៀត បញ្ញាកាលកើតឡើង រមែងដឹងច្បាស់នូវធមិទាំងឡាយ ដែលជាកុសល និងអកុសល, ដែលគួរសេព និងមិនគួរសេព អាក្រក់ និង ប្រណិត, ខ្មៅ និងសរ, ចូលគ្នាបាន និងមិនចូលគ្នាបាន ដូចពេទ្យអ្នកឆ្លាតដឹង ថ្នាំជាដើម ដែលជាទីសប្បាយ និងមិនជាទីសប្បាយដល់អ្នកឈឺដូច្នោះ ។ សមដូចពាក្យ **ព្រះធម្មសេនាបតី** ពោលថា “ម្នាលអាវុសោ ធម្មជាតណា ដឹងច្បាស់ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **បញ្ញា** ។ សួរថា ដឹងច្បាស់នូវអ្វី? ឆ្លើយថា ដឹងច្បាស់ថា ‘នេះជាទុក្ខ’ ជាដើម”[៣១] ខ សេចក្ដីនេះ បណ្ឌិតគប្បីឱ្យពិស្ដារ ។ គប្បីជ្រាបថា បញ្ញានោះ មានការដឹង ច្បាស់ជាលក្ខណៈ ដោយប្រការដូច្នេះ ។ ន័យម្យ៉ាងទៀត ៖-

## លក្ខណាទិចតុក្កៈនៃបញ្ញា

បញ្ញាមានការចាក់ធ្លុះសភាវៈតាមការពិតជាលក្ខណៈ = **យថាសភាវ បដិវេធលក្ខណា** ។

ឬមានការចាក់ធ្លុះមិនខុសភ្លាត់ជាលក្ខណៈ = **អក្ខលិតបដិវេធ លក្ខណា**, ដូចជាការចាក់របស់ព្រួញដែលនាយខ្មាន់ធ្នូអ្នកឆ្លាតបាញ់ទៅដូច្នោះ ។

[៣១] ម. មូ. ។

មានការបំភ្លឺឱ្យឃើញអារម្មណ៍ជាកិច្ច = **ទិសយោភាសនរសា** ដូចប្រទីប ។

មានការមិនវង្វេងជាផល = **អសម្មោហបច្ចុប្បដ្ឋានោ** ដូចអ្នកចង្អុលផ្លូវដល់បុគ្គលអ្នកទៅក្នុងព្រៃដូច្នោះ ៕

## អត្ថនៃពាក្យថាមនិន្ទ្រិយ

ធម៌ដែលឈ្មោះថា **មនះ** ព្រោះរមែងដឹង គឺរមែងដឹងជាក់ ។ ប៉ុន្តែ **ព្រះអដ្ឋកថាចារ្យ** ទាំងឡាយពោលថា “ឈ្មោះថា **មនះ** ព្រោះដឹងអារម្មណ៍ដូចបុគ្គលរាប់ដោយនាឡិ និងដូចថ្លឹងដោយជញ្ជីងធំដូច្នោះ” ។ **មនះ**នោះឯងឈ្មោះថា **ឥន្ទ្រិយ** ព្រោះភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណៈនៃការដឹង ។ មនះនោះឯង ជាឥន្ទ្រិយ ទើបឈ្មោះថា **មនិន្ទ្រិយ** ។ មនះនេះជាពាក្យវេវចនៈរបស់ចិត្ត តាមដែលពោលហើយ ក្នុងខាងក្រោយ (ខាងដើម) ៕

## អត្ថនៃពាក្យថាសោមនស្សិន្ទ្រិយ

បុគ្គលឈ្មោះថា **សុមនះ** ព្រោះមានចិត្តល្អ ព្រោះសម្បយោគដោយបីតិ និងសោមនស្ស ។ ភាវៈនៃបុគ្គលអ្នកមានចិត្តល្អ ឈ្មោះថា **សោមនស្ស** ។ សោមនស្សនោះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណៈ

នៃការត្រេកអរ ។ សោមនស្សនោះឯង ជាឥន្ទ្រិយ ទើបឈ្មោះថា **សោមនស្សិន្ទ្រិយ**, សោមនស្សិន្ទ្រិយនេះ ជាពាក្យវេវចនៈរបស់វេទនា តាមដែលពោលហើយក្នុងខាងក្រោយ ៕

## អត្ថនៃពាក្យថាជីវិតិន្ទ្រិយ

ធម៌ដែលឈ្មោះថា **ជីវិត** ព្រោះជាហេតុឱ្យធម៌ដែលសម្បយុត្តដោយជីវិតិន្ទ្រិយនោះរស់នៅ, ជីវិតនេះឈ្មោះថា **ឥន្ទ្រិយ** ព្រោះភាពជាធំជាងធម៌ដទៃក្នុងលក្ខណៈនៃការតាមរក្សា, ជីវិតនេះជាឥន្ទ្រិយ ទើបឈ្មោះថា **ជីវិតិន្ទ្រិយ** ព្រោះភាពជាធំជាងធម៌ដទៃក្នុងលក្ខណៈនៃការតាមរក្សា, ជីវិតឯងនោះជាឥន្ទ្រិយ ទើបឈ្មោះថា **ជីវិតិន្ទ្រិយ** ។ ជីវិតិន្ទ្រិយនោះជាអធិបតីក្នុងការប្រព្រឹត្តទៅ និងបន្តទៅ ។ ក៏កាលពោលដោយលក្ខណៈជាដើម ជីវិតិន្ទ្រិយមានការតាមរក្សាធម៌ដែលកើតហើយ មិនវៀរខ្លួន ជាលក្ខណៈ, មានការប្រព្រឹត្តទៅនៃធម៌ដែលសម្បយុត្តទាំងឡាយនោះ ជាកិច្ច, មានការតាំងនៅនៃសម្បយុត្តធម៌ទាំងឡាយនោះឯង ជាផល, មានធម៌ (គឺវេទនា សញ្ញា និងវិញ្ញាណ) ដែលរស់នៅជាហេតុជិត ។ កាលបើវិធីមានការតាមរក្សាជាលក្ខណៈជាដើមមាន ជីវិតិន្ទ្រិយនោះ ក៏រមែងតាមរក្សាធម៌ទាំងឡាយនោះ ក្នុងខណៈសូម្បីដែលមានហើយប៉ុណ្ណោះ, ដូចទឹកតាមរក្សាហើយនូវផ្កា

ឧប្បលជាដើម តាមរក្សាធម៌ទាំងឡាយដែលកើតឡើង ព្រោះបច្ច័យតាមភាពរបស់ខ្លួន ដូចមេនំចិញ្ចឹមមើលកុមារ; និងប្រព្រឹត្តទៅដោយសម្ពន្ធនឹងធម៌ដែលខ្លួនឱ្យប្រព្រឹត្តទៅ ដូចអ្នកចែវទូក ញុំាងទូកឱ្យស្ទុះទៅ, ជីវិតិន្ទ្រិយនោះឱ្យប្រព្រឹត្តទៅលើភង្គខណៈមិនបាន ព្រោះមិនមានខ្លួន និងធម៌ដែលខ្លួនឱ្យប្រព្រឹត្តទៅ; មិនតាំងនៅក្នុងភង្គខណៈ ព្រោះខ្លួនឯង ក៏ត្រូវរលត់ ដូចប្រឆេះប្រេងអស់ទៅ អណ្ដាតប្រទីប ក៏រលត់ទៅ; បណ្ឌិតមិនគប្បីឃើញជីវិតិន្ទ្រិយថា វៀរចាកអានុភាពនៃការថែរក្សា ការឱ្យប្រព្រឹត្តទៅ ការស្ថិតនៅព្រោះជីវិតិន្ទ្រិយ ញុំាងអានុភាពនោះ៧ ឱ្យសម្រេច” ៕

## អធិប្បាយអំពីសម្មាទិដ្ឋិជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សម្មាទិដ្ឋិ** ជាដើម, អង្គមគ្គដែលឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា ការឃើញ = **ទស្សនដ្ឋេន**, ឈ្មោះថា **សម្មាសង្កប្បៈ** ព្រោះអត្ថថា ការលើកឡើង = **អភិនិរោបនដ្ឋេន**, ឈ្មោះថា **សម្មាវាយាមៈ** ព្រោះអត្ថថា ការផ្គង = **បគ្គហនដ្ឋេន**, ឈ្មោះថា **សម្មាសតិ** ព្រោះអត្ថថា ការតាំងមាំ = **ឧបដ្ឋានដ្ឋេន**, ឈ្មោះថា **សម្មាសមាធិ** ព្រោះអត្ថថា ការមិនរាយមាយ = **អវិក្ខេបនដ្ឋេន** ។ **ក៏ពោលដោយវចនត្ថ** គឺអត្ថនៃព្រះបាលីឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះឃើញប្រពៃ, ឬជាហេតុនាំឱ្យ

ឃើញត្រូវ; ឈ្មោះថា **សម្មាសង្កប្បៈ** ព្រោះត្រិះរិះត្រូវ, ឬជាហេតុនាំឱ្យត្រិះរិះត្រូវ; ឈ្មោះថា **សម្មាវាយាមៈ** ព្រោះព្យាយាមត្រូវ, ឬជាហេតុនាំឱ្យព្យាយាមត្រូវ; ឈ្មោះថា **សម្មាសតិ** ព្រោះរលឹកត្រូវ, ឬជាហេតុនាំឱ្យរលឹកត្រូវ; ឈ្មោះថា **សម្មាសមាធិ** ព្រោះតាំងមាំដោយប្រពៃ, ឬជាហេតុឱ្យតាំងមាំដោយប្រពៃ ។ មួយទៀត គប្បីជ្រាបវចនត្ថនៃអង្គមគ្គដោយន័យនេះថា ទិដ្ឋិដែលបណ្ឌិតសរសើរហើយ ជាទិដ្ឋិត្រូវ ឈ្មោះថា **សម្មាទិដ្ឋិ** ។ ចំណែកធមិមានលក្ខណៈជាដើម ខ្ញុំពោលទុកហើយ ក្នុងខាងក្រោយនោះឯង ៕

## អធិប្បាយអំពីសទ្ធាពលៈជាដើម

ធមិមានសទ្ធាពលៈជាដើម មានសេចក្ដីដូចបានពោលមកហើយ ក្នុងសទ្ធាពលៈនោះឯង, ប៉ុន្តែ គប្បីជ្រាបពាក្យថា **ពលៈ** ព្រោះអត្ថថា មិនញ៉ូរកក្រើក ។ បណ្ដាធមិទាំងនោះ ធមិដែលឈ្មោះថា **សទ្ធាពលៈ** ព្រោះមិនញាប់ញ៉ូរទៅក្នុងភាពជាអ្នកមិនមានសទ្ធា; ឈ្មោះថា **វីរិយពលៈ** ព្រោះមិនញាប់ញ៉ូរទៅក្នុងការខ្ជិល; ឈ្មោះថា **សតិពលៈ** ព្រោះមិនញាប់ញ៉ូរទៅក្នុងការវង្វេងភ្លេចសតិ; ឈ្មោះថា **សមាធិពលៈ** ព្រោះមិនញាប់ញ៉ូរ ទៅក្នុងការរាយមាយ; ឈ្មោះថា **បញ្ញាពលៈ** ព្រោះមិនញាប់ញ៉ូរទៅក្នុងអវិជ្ជា; ឈ្មោះ

ថា **ហិរិពលះ** ព្រោះមិនញាប់ញ័រទៅក្នុងអហិរិកៈ; ឈ្មោះថា **ឱត្តប្បពលះ** ព្រោះមិនញាប់ញ័រទៅក្នុងអនោត្តប្បៈ; នេះជាការពណ៌នាសេចក្ដីដោយអំណាចនៃបទទាំងពីរ ដោយប្រការដូច្នេះ ។

បណ្ដាពលៈទាំង ៧ នោះ ពលៈ ៥ ខាងដើម ខ្ញុំប្រកាសហើយ ដោយលក្ខណៈជាដើមនោះឯង ក្នុងខាងក្រោយ ។ ពលៈ ២ ខាងក្រោយ មានពាក្យអធិប្បាយថា ធម៌ដែលឈ្មោះថា **ហិរិ** ព្រោះខ្មាសកាយទុច្ចរិតជាដើម = **កាយទុច្ចរិតាទីហិ ហិរិយតីតិ ហិរិ** ។

ពាក្យថា **ហិរិ** នេះ ជាឈ្មោះនៃការខ្មាស; ឈ្មោះថា **ឱត្តប្បៈ** ព្រោះខ្លាចក្រែងកាយទុច្ចរិតជាដើមនោះដូចគ្នា = **តេហិយេវ ឱត្តប្បតីតិ ឱត្តប្បំ** ។ ពាក្យថា ឱត្តប្បៈនេះ ជាឈ្មោះនៃការខ្លាចក្រែងបាប ។ ដើម្បីសម្ដែងសេចក្ដីផ្សេងគ្នានៃហិរិ និងឱត្តប្បៈទាំងពីរនោះ ទើបលោកផ្ដើមតាំងមាតិកា (មេបទ) នេះថា “**សមុដ្ឋានំ អធិបតីលជ្ជាភយលក្ខណេន ច** = សមុដ្ឋាន អធិបតី លជ្ជាភយៈ និងលក្ខណៈ” ។

**ពោលដោយសមុដ្ឋានជាដើម** ឈ្មោះថា **ហិរិ** ព្រោះមានហេតុខាងក្នុងជាសមុដ្ឋាន, ឈ្មោះថា **ឱត្តប្បៈ** ព្រោះមានហេតុខាងក្រៅជាសមុដ្ឋាន; ឈ្មោះថា **ហិរិ** ព្រោះមានអត្តាជាអធិបតី, ឈ្មោះថា **ឱត្តប្បៈ** ព្រោះមានលោកជាអធិបតី; ឈ្មោះថា **ហិរិ** ព្រោះតាំងនៅក្នុងសភាពនៃការខ្មាស,

ឈ្មោះថា **ឱត្តប្បៈ** ព្រោះតាំងនៅក្នុងសភាពនៃការខ្លាច ។ ឈ្មោះថា **ហិរិ** ព្រោះមានការគោរពជឿស្តាប់ (កោតក្រែង) ជាលក្ខណៈ, ឈ្មោះថា **ឱត្តប្បៈ** ព្រោះមានការខ្លាចទោស និងឃើញភ័យជាលក្ខណៈ ។ បណ្តាហិរិ និងឱត្តប្បៈទាំងនោះ បុគ្គលឱ្យហិរិដែលមានហេតុខាងក្នុងជាសមុដ្ឋាន ដោយហេតុ ៤ យ៉ាងគឺ

**១_ជាតឹ បច្ចវេក្ខិត្វា** ពិចារណាដល់ជាតិ

**២_វយំ បច្ចវេក្ខិត្វា** ពិចារណាដល់វ័យ

**៣_សូរភាវំ បច្ចវេក្ខិត្វា** ពិចារណាដល់ភាពជាអ្នកក្លាហាន

**៤_ពាហុសច្ចំ បច្ចវេក្ខិត្វា** ពិចារណាដល់ភាពជាពហុស្សូត្រ ។

**សួរថា** ពិចារណាយ៉ាងណា? **ឆ្លើយថា** ខាងដើមបុគ្គលពិចារណាដល់ជាតិយ៉ាងនេះថា "ធម្មតាការធ្វើអាក្រក់នេះ មិនមែនជាការងាររបស់បុគ្គលអ្នកដល់ព្រមដោយជាតិទេ, ការងារនេះ ជារបស់បុគ្គលអ្នកមានជាតិថោកទាបមានពួកប្រមង់ជាដើម, ការងារនេះ មិនសមគួរដល់បុគ្គលអ្នកដល់ព្រមដោយជាតិដូចអាត្មាអញទេ" ដូច្នេះ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា **ញុំាងហិរិឱ្យកើតឡើង** ។

ក៏បុគ្គលអ្នកពិចារណាដល់វ័យ យ៉ាងនេះថា "ធម្មតាការធ្វើបាបនេះ ជាការងារ គឺមនុស្សក្មេងទាំងឡាយគប្បីធ្វើ, ការធ្វើនេះមិនសមគួរដល់អ្នក

តាំងនៅក្នុងវ័យដូចអាត្មាអញទេ” ដូច្នេះ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា **ញ៉ាំងហិរិឱ្យកើតឡើង** ។

ក៏បុគ្គលអ្នកពិចារណាដល់ភាពជាអ្នកក្លាហាន យ៉ាងនេះថា “ធម្មតាការធ្វើបាបនេះ ជាការងាររបស់បុគ្គលអ្នកមានជាតិទន់ខ្សោយ*, កម្មនេះ មិនសមគួរដល់អ្នកសម្បូណ៌ដោយកម្លាំង (ក្លាហាន) ដូចអាត្មាអញទេ” ដូច្នេះ ហើយមិនធ្វើបាបមានបាណាតិបាតជាដើមឈ្មោះថា **ញ៉ាំងហិរិឱ្យកើតឡើង** ។

ក៏បុគ្គលអ្នកពិចារណាដល់ភាពជាពហុស្សូត្រ យ៉ាងនេះថា “ធម្មតាការធ្វើបាបនេះ ជាការងាររបស់បុគ្គលអន្ធពាល, មិនមែនជារបស់បណ្ឌិតទេ; កម្មនេះ មិនសមគួរដល់បុគ្គលអ្នកជាពហុស្សូត្រ អ្នកជាបណ្ឌិតដូចអាត្មាអញទេ” ដូច្នេះ ហើយមិនធ្វើបាបមានបាណាតិបាតជាដើម ឈ្មោះថា **ញ៉ាំងហិរិឱ្យកើតឡើង** ដោយអាការយ៉ាងនេះ; បុគ្គលឈ្មោះថា ញ៉ាំងហិរិដែលមានហេតុខាងក្នុងជាសមុដ្ឋានឱ្យកើតឡើងដោយហេតុ ៤ យ៉ាង ដោយប្រការដូច្នេះ ។ ក៏ពេលឱ្យតាំងឡើង គឺឱ្យហិរិចូលទៅតាំងទុកក្នុងចិត្តរបស់ខ្លួនហើយ ទើបមិនធ្វើបាបកម្ម, ឈ្មោះថា **ហិរិ** មានហេតុខាងក្នុងជាសមុដ្ឋាន ដោយប្រការដូច្នេះ ។

---

* ត្រង់ចន្លោះនេះ ច្បាប់ខ្លះមានពាក្យប្រាកដមកថា កម្មនេះ មិនមែនជាកម្ម របស់អ្នកក្លាហានទាំងឡាយទេ។

សួរថា ឈ្មោះថា **ឱត្តប្បៈ** មានហេតុខាងក្រៅ ជាសមុដ្ឋានយ៉ាងណា? ឆ្លើយថា បើអ្នកនឹងធ្វើបាបកម្ម, អ្នកក៏ត្រូវបរិស័ទទាំង ៤ តិះដៀល ។ ពិតណាស់ កាលបុគ្គលពិចារណាយ៉ាងនេះថា ៖-

**“គរហិស្សន្តិ តំ វិញ្ញូ អសុចឹ នាគរិកោ យថា**
**វិវជ្ជិតោ សីលវន្តេហិ កថំ ភិក្ខុ ករិស្សសិ។**

**វិញ្ញូជនទាំងឡាយនឹងតិះដៀលអ្នក, អ្នកនឹងត្រូវបុគ្គល អ្នកមានសីលទាំងឡាយ វៀរចេញហើយ, ដូចអ្នកគ្រូ វៀរចេញនូវរបស់មិនស្អាត; ម្នាលភិក្ខុ អ្នកនឹងធ្វើដូចម្ដេច?”។**

បុគ្គលនោះមិនធ្វើបាបកម្ម ព្រោះឱត្តប្បៈដែលមានហេតុខាងក្រៅជាសមុដ្ឋាន, ឈ្មោះថា **ឱត្តប្បៈ** មានហេតុខាងក្រៅជាសមុដ្ឋាន ដោយប្រការដូច្នេះ ។ **សួរថា** ឈ្មោះថា **ហិរិ** មានអត្តាជាអធិបតី យ៉ាងណា? **ឆ្លើយថា** កុលបុត្រខ្លះក្នុងលោកនេះ ធ្វើខ្លួនឱ្យជាធំ ឱ្យជាប្រធាន (អធិបតី) ហើយគិតថា “ការធ្វើសេចក្ដីអាក្រក់មិនសមគួរដល់អ្នកបួសដោយសទ្ធា ជាពហុស្សូត្រ ជាអ្នកបដិបត្តិធុតង្គប្រាកដដូចអញទេ” ដូច្នេះ ហើយមិនធ្វើបាបកម្ម ឈ្មោះថា **ហិរិ** មានអត្តាជាអធិបតីយ៉ាងនេះឯង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “បុគ្គលនោះធ្វើខ្លួនប៉ុណ្ណោះ ឱ្យជាធំ ឱ្យជាប្រធាន ហើយលះអកុសល, ចម្រើនកុសល លះធម៌ដែលមានទោស ចម្រើនធម៌ដែលគ្មាន

ទោស, បរិហារខ្លួនឱ្យបរិសុទ្ធ” [៣២] ។

**សួរថា** ឈ្មោះថា **ឱក្តប្បៈ** មានលោកជាអធិបតីយ៉ាងណា?

ឆ្លើយថា កុលបុត្រខ្លះក្នុងលោកនេះ ធ្វើលោកឱ្យជាធំ ឱ្យជាប្រធាន ហើយមិនធ្វើបាបកម្ម; ដូចយ៉ាងដែលត្រាស់ទុកថា “ក៏លោកសន្និវាសនេះ ធំពិត, ម្យ៉ាង ក្នុងលោកសន្និវាសនេះធំពិត មានសមណព្រាហ្មណ៍ទាំងឡាយអ្នកមានឫទ្ធិ, មានទិព្វចក្ខុ, ដឹងចិត្តរបស់អ្នកដទៃ, សមណព្រាហ្មណ៍ទាំងឡាយនោះ រមែងមើលឃើញបានសូម្បីពីទីឆ្ងាយ, សូម្បីនៅជិតអញ ក៏មិនប្រាកដ សមណព្រាហ្មណ៍ទាំងនោះតែងដឹងច្បាស់នូវចិត្ត (របស់អញ) ដោយចិត្ត សូម្បីលោកទាំងនោះ នឹងដឹងអញយ៉ាងនេះថា ‘ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកអ្នកចូរមើលកុលបុត្រនេះ, គេជាអ្នកមានសទ្ធាចេញចាកផ្ទះ បួសជាបព្វជិត អ្នកមិនមានផ្ទះ តែពាសពេញទៅដោយពួកអកុសលធម៌ដ៏លាមក’ ។ ទេវតាទាំងឡាយ អ្នកមានឫទ្ធិ, មានទិព្វចក្ខុ ដឹងចិត្តអ្នកដទៃ, ទេវតាទាំងឡាយនោះ មើលឃើញសូម្បីពីទីឆ្ងាយ សូម្បីលោកនៅជិត ក៏យើងមើលមិនឃើញ, ទេវតាទាំងឡាយក៏ដឹងច្បាស់នូវចិត្ត (របស់អញ) ដោយចិត្តដែរ, សូម្បីពួកទេវតានោះ ក៏នឹងដឹងអញយ៉ាងនេះថា ‘អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលកុលបុត្រនេះ ជាអ្នកមានសទ្ធាចេញចាកផ្ទះ បួសជាបព្វជិត

---

[៣២] អំ. តិក. ។

អ្នកមិនមានផ្ទះ, តែពាសពេញទៅដោយអកុសលធម៌ដ៏លាមកទាំងឡាយ' ។ បុគ្គលនោះ ធ្វើលោកប៉ុណ្ណោះឱ្យជាធំ ឱ្យជាប្រធានហើយលះអកុសលធម៌, ចម្រើនកុសលធម៌, លះធម៌ដែលមានទោស, ចម្រើនធម៌ដែលគ្មានទោស បរិហារខ្លួនឱ្យបរិសុទ្ធ"[៣៣] ដូច្នេះ ឈ្មោះថា ឱត្តប្បៈ មានលោកជាអធិបតី ដោយប្រការដូច្នេះ ។

ក៏បណ្ឌិតគប្បីជ្រាបសេចក្ដីនៃពាក្យថា **ហិរិ ដែលកើតឡើងដោយសភាវៈ គឺការអៀនខ្មាស, និង ឱត្តប្បៈ ដែលកើតឡើងដោយសភាវៈ គឺការខ្លាចក្រែង** ដូចតទៅ ៖-

ពាក្យថា **"អៀនខ្មាស"** បានដល់ អាការអៀនខ្មាស, អធិប្បាយថា ហិរិតាំងនៅដោយការខ្មាសនោះ ។ ពាក្យថា **"ខ្លាចក្រែង"** បានដល់ ខ្លាចអបាយ, អធិប្បាថា ឱត្តប្បៈតាំងនៅដោយសភាវៈដែលគួរខ្លាចនោះ។ ក៏ហិរិ និងឱត្តប្បៈទាំងពីរនោះ រមែងប្រាកដដោយការវៀរចាកសេចក្ដីអាក្រក់ ។ ពិតណាស់ មនុស្សខ្លះ ឈានចុះកាន់ធម៌ គឺសេចក្ដីខ្មាសខាងក្នុង រមែងមិនធ្វើបាប ដូចកុលបុត្រខ្លះ អ្នកធ្វើការបន្ទោបង់ឧច្ចារៈ និងបស្សាវៈជាដើម ឃើញបុគ្គលសូម្បីម្នាក់ដែលខ្លួនគួរខ្មាស ក៏គប្បីដល់អាការខ្មាស គប្បីពួនហើយ ជាអ្នកខ្មាសហើយ មិនធ្វើការបន្ទោបង់ឧច្ចារៈបស្សាវៈដូច្នោះ ។ មនុស្សខ្លះ ជា

[៣៣] អំ. តិក. ។

អ្នកខ្លាចចំពោះភ័យក្នុងអបាយហើយ ក៏មិនធ្វើបាបកម្ម ។ ក្នុងអធិការនៃហិរិ និងឱត្តប្បៈនោះ មានឧឧបមាដូចនេះ ៖-

ប្រៀបដូចដុំដែក ២ ដុំ មួយដុំត្រជាក់ តែប្រឡាក់លាមក, មួយដុំក្តៅគគុក, បណ្តាដុំដែកទាំងពីរនោះ បណ្ឌិតរង្កៀសដុំដែកត្រជាក់ ទើបមិនចាប់, ព្រោះវាប្រឡាក់លាមក, រង្កៀសដុំដែកក្រៅនេះ ព្រោះខ្លាចក្តៅ, ក្នុងការឧបមានោះ គប្បីជ្រាបការដែលបុគ្គលឈានចុះកាន់ធម៌ គឺសេចក្តីអៀនខ្មាសខាងក្នុង ហើយមិនធ្វើបាប ដូចបណ្ឌិតមិនចាប់កាន់ដុំដែកត្រជាក់ ប្រឡាក់លាមក ព្រោះការរង្កៀស, គប្បីជ្រាបការមិនធ្វើបាប ព្រោះខ្លាចអបាយ ដូចបុគ្គលមិនចាប់កាន់ដុំដែកក្តៅ ព្រោះខ្លាចក្តៅដូច្នោះ ។

**ហិរិមានការគោរពជឿស្តាប់ជាលក្ខណៈ = សប្បតិស្សវលក្ខណា, ឱត្តប្បៈមានការខ្លាចទោស និងឃើញភ័យ ជាលក្ខណៈ = វជ្ជភីរុកភយទស្សាវិលក្ខណំ**, ព្រោះហេតុដូច្នោះ ធម៌ទាំងពីរនេះ ទើបប្រាកដក្នុងការវៀរចាកបាបដូចគ្នា ។ ពិតណាស់ អ្នកខ្លះញ៉ាំងហិរិដែលមានការគោរពជឿស្តាប់ជាលក្ខណៈ ឱ្យតាំងឡើង ហើយមិនធ្វើបាប ដោយហេតុ ៤ គឺ

**១-ជាតិមហន្តបច្ចវេក្ខណា** ពិចារណាដល់ជាតិដែលជាធំ

**២-សត្ថុមហត្តបច្ចវេក្ខណា** ពិចារណាដល់សាស្តាដែលជាធំ

**៣. ទាយជ្ជមហត្តបច្ចវេក្ខណា** ពិចារណាដល់ទាយាទដែលជាធំ *

**៤. សព្រហ្មចារិមហត្តបច្ចវេក្ខណា** ពិចារណាដល់សព្រហ្មចារីជាធំ ។

អ្នកខ្លះញុំាងឱត្តប្បៈ ដែលមានការខ្លាចទោស និងឃើញភ័យ ជាលក្ខណៈ ឱ្យតាំងឡើងហើយ មិនធ្វើបាបដោយហេតុ ៤ គឺ

**១. អត្តានុវាទភយំ** ភ័យកើតអំពីការតិះដៀលខ្លួនឯង

**២. បរានុវាទភយំ** ភ័យកើតអំពីការតិះដៀលអំពីអ្នកដទៃ

**៣. ទណ្ឌភយំ** ភ័យកើតអំពីអាជ្ញា

**៤. ទុគ្គតិភយំ** ភ័យកើតអំពីទុគ្គតិ ។

បណ្ដាហេតុទាំង ៨ នោះ បណ្ឌិតគប្បីពោលដល់ការពិចារណាជាតិដែលជាធំជាដើម និងភ័យមានការតិះដៀលខ្លួនឯងជាដើម ឱ្យពិស្ដារ ៕

## អត្ថនៃពាក្យថាអលោភៈ

ធម៌ដែលឈ្មោះថា **អលោភៈ** ព្រោះជាហេតុមិនឱ្យលោភ, ឬថាខ្លួនឯង មិនលោភ, ឬក៏គ្រាន់តែមិនលោភ ។ សូម្បីក្នុងអទោសៈ និងអមោហៈ ក៏មានន័យដូចគ្នាដែរ ។ បណ្ដាធម៌ទាំង ៣ នោះ អលោភៈ មាន

---

* មូលដីកា ពាក្យថា ទាយាទ បានដល់ លោកុត្តរធម៌ ៩ ជាដើម ។

ចិត្តមិនត្រេកអរក្នុងអារម្មណ៍ជាលក្ខណៈ = **អារម្មណេ ចិត្តស្ស អគេ្គធលក្ខណោ**, ឬមានចិត្តមិនជាប់ក្នុងអារម្មណ៍ជាលក្ខណៈ = **អលគ្គភាវលក្ខណោ**, ដូចតំណក់ទឹកមិនជាប់លើស្លឹកឈូក; មានការមិនហួងហែងជាកិច្ច = **អបរិគ្គហណរសោ**, ដូចភិក្ខុរួចផុតហើយ ( ព្រះខីណាស្រព) និងមានការមិនជាប់ចិត្តជាផល = **អនល្លីនភាវបច្ចុប្បដ្ឋានោ**, ដូចបុរសធ្លាក់ចុះទៅក្នុងរបស់មិនស្អាតដូច្នោះ ។

## លក្ខណាទិចតុក្កៈនៃអទោសៈ

អទោសៈមានការមិនកាចជាលក្ខណៈ = **អចណ្ឌិក្កលក្ខណោ**, ឬមានការមិនក្រោធជាលក្ខណៈ = **អវិរោធលក្ខណោ**, ដូចមិត្តជួយទំនុកបំរុង; មានការកម្ចាត់អាឃាត ជាកិច្ច = **អាឃាតវិនយរសោ**, ឬមានការកម្ចាត់ការក្តៅក្រហាយ ជាកិច្ច = **បរិឡាហវិនយរសោ**, ដូចចន្ទន៏ក្រហម; មានសេចក្តីត្រជាក់ជាអាការប្រាកដ = **សោម្មភាវបច្ចុប្បដ្ឋានោ**, ដូចព្រះចន្ទពេញវង្ស ។ ចំណែកអមោហៈ ព្រមទាំងលក្ខណៈជាដើម លោកតាំងបទអធិប្បាយដូចបញ្ញិន្ទ្រិយ តាមដែលពោលហើយក្នុងខាងដើមនោះឯង ។

ក៏ក្នុងធមិទាំង ៣ នេះ អលោភៈជាសត្រូវចំពោះមន្ទិល គឺការកំណាញ់

អទោសៈ ជាសត្រូវចំពោះមន្ទិល គឺភាពទ្រុស្តសីល*, អមោហៈ ជាសត្រូវចំពោះការមិនចម្រើន ក្នុងកុសលធម៌ទាំងឡាយ; ឯក្នុងគុណធម៌ទាំងនោះ អលោភៈជាហេតុនៃទាន, អទោសៈជាហេតុនៃសីល និងអមោហៈ ជាហេតុនៃភាវនា; បណ្ដាគុណធម៌ទាំងនោះ បុគ្គលមានការមិនល្មោភ រមែងកាន់យកមិនច្រើន ព្រោះអ្នកល្មោភទើបកាន់យកច្រើន ។ បុគ្គលមិនមានទោសៈ រមែងកាន់យកមិនខ្វះ ព្រោះអ្នកមានទោសៈប្រទូស្តហើយ ទើបកាន់យកមិនគ្រប់គ្រាន់, បុគ្គលមិនមានមោហៈ រមែងកាន់យកមិនវិបរិត ព្រោះអ្នកវង្វេងទើបកាន់យកវិបរិត ។

ក៏ក្នុងគុណធម៌ទាំងនេះ បុគ្គលទ្រង់ចាំទោសដែលមានហើយ ដោយភាពជាទោស រមែងបើកបង្ហាញទោសទាំងឡាយទៅ ព្រោះការមិនលោភ; ព្រោះថា បុគ្គលលោភហើយ រមែងបិទបាំងទោស ។ បុគ្គលចាំគុណដែលមានហើយ ដោយភាពជាគុណ ប្រកាសគុណទាំងឡាយ ឱ្យប្រព្រឹត្តទៅ ព្រោះការមិនមានទោសៈ, ព្រោះថា បុគ្គលមានទោសៈប្រទូស្តហើយ រមែងលុបគុណគេ ។ បុគ្គលទ្រង់ចាំទុកនូវសភាវៈតាមសេចក្ដីពិត, ដោយសភាវៈតាមសេចក្ដីពិត ប្រកាសការពិតឱ្យប្រព្រឹត្តទៅ ព្រោះការមិនវង្វេង, ព្រោះថា

---

* មូលដីកា ពាក្យនេះគឺលោកពោលហើយ ព្រោះសំដៅយកនូវភាពទ្រុស្តសីល ដែលមានទោសៈជាសមុដ្ឋាន និងមានទោសៈជាឧបនិស្ស័យ ។

បុគ្គលវង្វេង រមែងកាន់យកវត្ថុពិតថា ជាវត្ថុមិនពិត កាន់យកវត្ថុមិនពិតថា ជាវត្ថុពិត ។

ក៏ទុក្ខមានការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់មិនមាន ព្រោះការមិនលោភ, ព្រោះអ្នកលោភហើយ មានសភាវៈប្រកាន់មាំ សេចក្តីស្រឡាញ់ និងព្រោះមិនអត់ទ្រាំចំពោះការព្រាត់ប្រាស របស់ជាទីស្រឡាញ់បាន ។ ទុក្ខមានការប្រសព្វជួបនឹងរបស់មិនជាទីស្រឡាញ់មិនមាន ព្រោះការមិនមានទោសៈ, ព្រោះបុគ្គលមានទោសៈប្រទូស្តហើយ មានសភាវៈប្រកាន់មាំ វត្ថុដែលមិនជាទីស្រឡាញ់ និងព្រោះមិនអត់ធន់ចំពោះការជួបប្រសព្វ នឹងរបស់ដែលមិនជាទីស្រឡាញ់បាន ។ ទុក្ខមានការមិនបានវត្ថុដែលប្រាថ្នា រមែងមិនមាន ព្រោះមិនវង្វេង, ព្រោះបុគ្គលអ្នកមិនវង្វេង មានការចម្រើន ពិចារណាយ៉ាងនេះថា “ពួកអ្នកគប្បីបានវត្ថុនោះ ក្នុងទីនេះពីទីណា” ជាដើម [៣៤] ។

ក៏បណ្តាគុណធម៌ទាំងនេះ ជាតិទុក្ខរមែងមិនមាន ព្រោះអលោភៈ, ព្រោះអលោភៈជាបដិបក្ខចំពោះតណ្ហា និងជាតិទុក្ខមានតណ្ហាជាមូល ។ ជរាទុក្ខ រមែងមិនមានព្រោះអទោសៈ, ព្រោះបុគ្គលមានទោសៈខ្លាំង ជាអ្នកមានជរាលឿនរហ័ស ។ មរណទុក្ខ រមែងមិនមានព្រោះអមោហៈ, ព្រោះការស្លាប់របស់បុគ្គលអ្នកវង្វេងជាទុក្ខ, តែទុក្ខនោះ មិនមានដល់បុគ្គលអ្នកមិន

---

[៣៤] ទី. បា., អំ. នវក. ។

វង្វេង ។

ក៏ការនៅរួមគ្នាជាសុខរបស់គ្រហស្ថទាំងឡាយ ព្រោះអលោភៈ, ការនៅរួមគ្នាជាសុខរបស់បព្វជិតទាំងឡាយ ព្រោះអមោហៈ, ការនៅរួមគ្នា ជាសុខរបស់គ្រហស្ថ និងបព្វជិតទាំងឡាយ ព្រោះអទោសៈ ។

ក៏បណ្ដាធមិទាំងឡាយនោះ ពោលដោយពិសេស (ដោយច្រើន) ការកើតឡើងក្នុងបិត្តិវិស័យ(ប្រេត)មិនមាន ព្រោះអលោភៈ, ពិតណាស់ សត្វទាំងឡាយ ដោយច្រើនចូលទៅដល់បិត្តិវិស័យ ព្រោះតណ្ហា, ព្រោះថា អលោភៈជាបដិបក្ខចំពោះតណ្ហា ។ ការកើតឡើងក្នុងនរកមិនមាន ព្រោះអទោសៈ, ពិតណាស់ សត្វទាំងឡាយចូលទៅដល់នរកប្រាកដដូចនឹងទោសៈ ព្រោះជាអ្នកកាចដោយទោសៈ, ព្រោះថា អទោសៈ ជាបដិបក្ខចំពោះទោសៈ ។ ការកើតក្នុងកំណើតសត្វតិរច្ឆានមិនមាន ព្រោះអមោហៈ, ពិតណាស់ បុគ្គលទាំងឡាយអ្នកវង្វេងជានិច្ចដោយមោហៈ តែងចូលដល់កំណើតសត្វតិរច្ឆាន, ព្រោះថា អមោហៈ ជាបដិបក្ខចំពោះមោហៈ ។ បណ្ដាគុណធមិទាំងនោះ អលោភៈ មិនធ្វើការជាប់ជំពាក់ដោយអំណាចនៃរាគៈទេ, អទោសៈមិនធ្វើការថ្នាំងថ្នាក់បដិឃៈដោយអំណាចនៃទោសៈទេ, អមោហៈមិនធ្វើភាពជាកណ្ដាលដោយអំណាចនៃមោហៈឡើយ ។

មួយវិញទៀត ពោលដោយគុណធមិទាំងនេះសូម្បីទាំង ៣ រមែងបាន

សញ្ញាទាំង ៣ នេះ តាមលំដាប់ គឺ **នេក្ខម្មសញ្ញា**, **អព្យាបាទសញ្ញា**, **អវិហឹសាសញ្ញា** និងសញ្ញាទាំង ៣ នេះ គឺ **អសុភសញ្ញា**, **អប្បមាណសញ្ញា** និង **ធាតុសញ្ញា**; ក៏ការវៀរធម៌ទីបំផុត គឺកាមសុខល្លិកានុយោគ រមែងមានព្រោះអលោភៈ, ការវៀរអន្តធម៌ គឺអត្តកិលមថានុយោគ រមែងមាន ព្រោះអទោសៈ, ការដើរតាមផ្លូវមជ្ឈិមប្បដិបទា រមែងមាន ព្រោះអមោហៈ ។ មួយ៉ាងទៀត ការទម្លាយអភិជ្ឈាកាយគន្ថៈ រមែងមាន ព្រោះអលោភៈ, ការទម្លាយព្យាបាទកាយគន្ថៈ រមែងមាន ព្រោះអទោសៈ, ការទម្លាយកាយគន្ថៈទាំងពីរដ៏សេស រមែងមាន ព្រោះអមោហៈ, មួយ៉ាងវិញទៀត សតិប្បដ្ឋាន ២ ខាងដើម រមែងសម្រេចដោយអានុភាព (អំណាច) នៃគុណធម៌ពីរខាងដើម, សតិប្បដ្ឋាន ២ ខាងចុង រមែងសម្រេច ដោយអានុភាពនៃគុណធម៌ខាងក្រោយប៉ុណ្ណោះ ។

ក៏បណ្ដាធម៌ទាំង ៣ នេះ អលោភៈជាបច្ច័យដល់ការមិនមានរោគ, ព្រោះបុគ្គលមិនមានលោភៈហើយ មិនសេពអសប្បាយវត្ថុ សូម្បីជាអារម្មណ៍នៃលោភៈ, ព្រោះហេតុនោះ បុគ្គលអ្នកមិនមានលោភៈ ទើបមិនមានរោគ ។ អទោសៈជាបច្ច័យដល់ភាពពេញវ័យ, ព្រោះបុគ្គលមិនមានទោសៈ ប្រទូស្ត ហើយ ក៏មិនត្រូវភ្លើង គឺទោសៈដែលនាំមកនូវភាពជាអ្នកស្បែកជ្រីវជ្រួញ និងសក់ស្កូវរោលរាល គឺជាអ្នកនៅពេញវ័យបានយូរ ។ អមោហៈ ជាបច្ច័យ

ដល់ការមានអាយុវែង, ព្រោះបុគ្គលអ្នកមិនវង្វេង ដឹងវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ កាលវៀរវត្ថុដែលមិនជាប្រយោជន៍ និងសេពវត្ថុដែលជាប្រយោជន៍ ទើបជាអ្នកមានអាយុវែង ។

មួយទៀត បណ្ដាគុណធម៌ទាំងនោះ អលោភៈជាបច្ច័យដល់ភោគសម្បត្តិ, ព្រោះអ្នកមិនលោភហើយ ក៏ជាអ្នកបានចំពោះនូវភោគៈ ដោយចាគៈ; អទោសៈជាបច្ច័យដល់ការបាននូវមិត្តសម្បត្តិ, ព្រោះកាលបុគ្គលមិនត្រូវទោសៈប្រទូស្តហើយ ក៏បានមិត្ត និងការមិនបែកមិត្ត ព្រោះមានមេត្តា ។

អមោហៈជាបច្ច័យដល់អត្តសម្បត្តិ, ព្រោះថា បុគ្គលមិនល្ងង់ កាលធ្វើប្រយោជន៍របស់ខ្លួននោះឯង ឈ្មោះថា ញុំាងខ្លួនឱ្យដល់ព្រម ។ អលោភៈជាបច្ច័យដល់ទិព្វវិហារ ( ឈាន ៤), អទោសៈជាបច្ច័យដល់ព្រហ្មវិហារ, អមោហៈជាបច្ច័យដល់អរិយវិហារ ( ផលនៃសមាបត្តិ) ។

ក៏បណ្ដាគុណធម៌ទាំងនោះ បុគ្គលអ្នករលីកក្នុងសត្វ និងសង្ខារទាំងឡាយប៉ែកខាងខ្លួនបានដោយអលោភៈ, ព្រោះសត្វ និងសង្ខារទាំងឡាយនោះវិនាសទៅ ក៏មិនមានសេចក្ដីទុក្ខដែលមានការជាប់ជំពាក់ជាហេតុ; អ្នករលត់សត្វ និងសង្ខារទាំងឡាយប៉ែកខាងអ្នកដទៃ បានដោយអទោសៈ, ព្រោះបុគ្គលមិនមានទោសៈប្រទូស្តហើយ ក៏មិនមានការសម្គាល់ចងពៀរ សូម្បីក្នុងបុគ្គលទាំងឡាយដែលចងពៀរគ្នា ។ អ្នករលត់សត្វ និងសង្ខារទាំងឡាយ

ក្នុងប៉ែកខាងកណ្ដាលព្រងើយៗ បានដោយអមោហៈ, ព្រោះអ្នកមិនល្ងង់ ក៏មិនមានការជាប់ជំពាក់ទាំងអស់ ។

ការឃើញអនិច្ចំ រមែងមានដោយអលោភៈ, ព្រោះបុគ្គលលោភហើយ មិនឃើញសង្ខារថា មិនទៀង ដោយការមិនទៀង ដោយបំណងនឹងប្រើប្រាស់ ។ ការឃើញទុក្ខរមែងមានដោយទោសៈ ព្រោះអ្នកមានអធ្យាស្រ័យមិនមានទោសៈ កំណត់លះអាឃាតវត្ថុហើយ រមែងឃើញសង្ខារទាំងឡាយដោយសេចក្ដីជាទុក្ខ ។ ការឃើញអនត្តា រមែងមានដោយអមោហៈ, ព្រោះអ្នកមិនល្ងង់ជាអ្នកឆ្លាតក្នុងការកាន់យកសភាវៈតាមសេចក្ដីពិត ដឹងខន្ធ ៥ ដែលមិនមែនជាអ្នកធំ ដោយមិនមែនជាអ្នកធំ ។

ការឃើញអនិច្ចំជាដើម រមែងមានដោយគុណធម៌ទាំង ៣ យ៉ាងណា, សូម្បីគុណធម៌ទាំង ៣ នោះ ក៏មានការឃើញអនិច្ចំជាដើម យ៉ាងនោះដែរ ។ ពិតណាស់ ការមិនលោភ ព្រោះការឃើញអនិច្ចលក្ខណៈ, ការមិនក្រោធ ព្រោះការឃើញទុក្ខលក្ខណៈ, ការមិនវង្វេង ព្រោះការឃើញអនត្តលក្ខណៈ ។ ព្រោះថា តើអ្នកណាទៅដឹងដោយប្រពៃថា “វត្ថុនេះជារបស់មិនទៀង” ហើយគប្បីឱ្យសេចក្ដីស្រឡាញ់កើតឡើង ដើម្បីត្រូវការវត្ថុមិនទៀងនោះទៀត?, ឬដឹងថា “នេះជាទុក្ខ” ក្នុងសង្ខារដូច្នេះហើយ គប្បីញ៉ាំងសេចក្ដីទុក្ខដែលកើតអំពីការក្រោធ សូម្បីដទៃទៀត ឱ្យកើតឡើងទៀត? និងដឹង

ដល់ការសូន្យក្នុងអត្តាហើយ គប្បីដល់ការវង្វេងទៀត” ៕

## អត្ថនៃពាក្យថាអនភិជ្ឈា

ធម៌ដែលឈ្មោះថា **អនភិជ្ឈា** ព្រោះមិនសម្លឹងរំពៃ ។ ឈ្មោះថា **អព្យាបាទ** ព្រោះញ៉ាំងសុខផ្លូវកាយ សុខផ្លូវចិត្ត ប្រយោជន៏ក្នុងលោកនេះ ប្រយោជន៏ក្នុងលោកខាងមុខ និងកេរ្តិ៍ឈ្មោះដែលបានចំពោះហើយ ដោយអានុភាពនៃសេចក្តីល្អ មិនឱ្យវិនាស ។ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះឃើញត្រូវ ឬឃើញដោយល្អ ។ ពាក្យថា **អភិជ្ឈា** ជាដើមទាំងនោះ ជាឈ្មោះរបស់ធម៌មានអលោភៈជាដើមនោះឯង, ក៏ធម៌ទាំងឡាយនោះ គប្បីជ្រាបថា លោកកាន់យកហើយដោយអំណាចនៃមូលខាងក្រោយ, ក្នុងទីនេះកាន់យកដោយអំណាចនៃកម្មបថ ៕

## អធិប្បាយលោកបាលធម៌ ២ យ៉ាង

សូម្បី **ហិរិ** និង **ឱត្តប្បៈ** ក៏គប្បីជ្រាបថា (អធិប្បាយលោក បាលធម៌ ២ យ៉ាង) ខាងដើម លោកកាន់យកហើយដោយអំណាចនៃកម្លាំង, ក្នុងទីនេះ គប្បីជ្រាបថា លោកកាន់យកហើយដោយអំណាចនៃលោកបាល ។ ពិតណាស់ ធម៌ទាំងពីនេះ តែងរក្សាលោក; ដូចយ៉ាងដែលត្រាស់ទុកថា ៖-

“ម្នាលភិក្ខុទាំងឡាយ សុក្កធម៌ទាំងពីរនេះតែងរក្សាលោក, ធម៌ពីរប្រការ តើដូចម្ដេច? គឺ ហិរិ និងឱត្តប្បៈ, ម្នាលភិក្ខុទាំងឡាយ សុក្កធម៌ ២ នេះឯង រមែងរក្សាលោក ។ ម្នាលភិក្ខុទាំងឡាយ បើសុក្កធម៌ ២ នេះ មិនគប្បីគ្រប់គ្រងលោកសោត, ក្នុងលោកនេះ ក៏មិនគប្បីប្រាកដដោយពាក្យថា ម៉ែក្ដី ម្ដាយមីងក្ដី ម្ដាយធំក្ដី ភរិយារបស់អាចារ្យក្ដី ឬភរិយារបស់គ្រូ, សត្វលោកនឹងដល់សម្ភេទ (ការច្រឡូកច្រឡំ), ដូចយ៉ាងពួកពពែ ចៀម មាន់ ជ្រូក សុនខ ចចក; ម្នាលភិក្ខុទាំងឡាយ ក៏ព្រោះថា សុក្កធម៌ទាំង ២ នេះ តែងគ្រប់គ្រងលោក, ព្រោះហេតុដូច្នោះ ទើបនៅប្រាកដដោយពាក្យថា ម៉ែក្ដី ម្ដាយមីងក្ដី ម្ដាយធំក្ដី ភរិយារបស់អាចារ្យ ឬភរិយារបស់គ្រូក្ដី”[៣៥] ៕

## អត្ថនៃយុគលធម៌

ការស្ងប់កាយ ឈ្មោះថា **កាយបស្សទ្ធិ**; ការស្ងប់ចិត្ត ឈ្មោះថា **ចិត្តបស្សទ្ធិ** ។ ពាក្យថា **កាយ** ក្នុងពាក្យថា **កាយបស្សទ្ធិ** នេះ បានដល់ ខន្ធ ៣ មានវេទនាខន្ធជាដើម; មួយទៀត បស្សទ្ធិធម៌ទាំងពីរនេះរួមបញ្ចូលគ្នាហើយគប្បីឃើញថា **កាយបស្សទ្ធិ និងចិត្តបស្សទ្ធិ**; មានការរំងាប់ ការក្រវល់ក្រវាយផ្លូវកាយ និងផ្លូវចិត្តជាលក្ខណៈ, មានការកម្ចាត់ការក្រវល់ក្រវាយផ្លូវ

---

[៣៥] អំ. ទុក. ៤០ ។

កាយ និងផ្លូវចិត្តជាកិច្ច, មានភាពត្រជាក់ មិនក្តៅក្រហាយនៃកាយ និងចិត្តជាផល, មានកាយ (ចេតសិក) និងចិត្ត ជាហេតុជិត, ជាបដិបក្ខចំពោះកិលេសមានឧទ្ធច្ចៈដែលធ្វើការមិនស្ងប់ជាដើម នៃកាយ និងចិត្ត ។

ការស្រាលកាយ ឈ្មោះថា **កាយលហុតា**; ការស្រាលចិត្ត ឈ្មោះថា **ចិត្តលហុតា** ។ លហុតាទាំងពីរនោះ គប្បីឃើញថា មានការស្ងប់ភារៈធ្ងន់នៃកាយ និងចិត្តជាលក្ខណៈ, មានការកម្ចាត់ភាពធ្ងន់នៃកាយ និងចិត្តជាកិច្ច, មានការមិនយឺតយូរនៃកាយ និងចិត្តជាអាការប្រាកដ, មានកាយ និងចិត្តជាហេតុជិត, ជាបដិបក្ខចំពោះកិលេស មានថីនមិទ្ធៈជាដើម ដែលធ្វើនូវភារៈនៃកាយ និងចិត្ត ឱ្យធ្ងន់ ។

ការទន់នៃកាយ ឈ្មោះថា **កាយមុទុតា**; ការទន់នៃចិត្ត ឈ្មោះថា **ចិត្តមុទុតា** ។ កាយ និងចិត្តមុទុតាទាំងនោះ មានការចូលទៅស្ងប់ការរឹងត្អឹង នៃកាយ និងចិត្តជាលក្ខណៈ, មានការកម្ចាត់ការរឹងត្អឹងនៃកាយ និងចិត្ត ជាកិច្ច, មានការមិនថ្នាំងថ្នាក់ចិត្តជាផល, មានកាយ និងចិត្ត ជាបទដ្ឋាន. គប្បីឃើញថា ជាសត្រូវនឹងកិលេស មានទិដ្ឋិ និងមានះជាដើម ដែលធ្វើកាយ និងចិត្តឱ្យរឹងត្អឹង ។

កាគួរដល់ការងារនៃកាយ ឈ្មោះថា **កាយកម្មញ្ញតា**; ការគួរដល់ការងារនៃចិត្ត ឈ្មោះថា **ចិត្តកម្មញ្ញតា** ។ កម្មញ្ញតាទាំងពីរនោះ មានការ

ចូលទៅរំងាប់ការមិនគួរដល់ការងារនៃកាយ និងចិត្តជាលក្ខណៈ, មានការកម្ចាត់ការមិនគួរដល់ការងារនៃកាយ និងចិត្តជាកិច្ច, មានការដល់ព្រមដោយការធ្វើកាយ និងចិត្តសមគួរដល់អារម្មណ៍ជាបច្ចុប្បដ្ឋាន, មានកាយ និងចិត្តជាបទដ្ឋាន, គប្បីឃើញថា ជាសត្រូវនឹងនីវរណៈដ៏សេស ដែលធ្វើការមិនគួរដល់ការងារនៃកាយ និងចិត្ត ។ គប្បីឃើញកម្មញ្ញតាទាំងពីរនោះ ជាធម៌នាំមកនូវសេចក្តីជ្រះថ្លា ក្នុងវត្ថុដែលគួរជាទីជ្រះថ្លាទាំងឡាយ, ជាការនាំមកនូវសេចក្តីក្សេម សមគួរក្នុងការធ្វើប្រយោជន៍ ដូចការបរិសុទ្ធិនៃមាសដូច្នោះ ។

ភាវៈនៃការស្ទាត់ជំនាញនៃកាយ ឈ្មោះថា **កាយបាគុញ្ញតា**; ភាវៈនៃការស្ទាត់ជំនាញនៃចិត្ត ឈ្មោះថា **ចិត្តបាគុញ្ញតា** ។ **បាគុញ្ញតា** ទាំងពីរនោះ មានការមិនជំទាស់រារាំងនៃកាយ និងចិត្តជាលក្ខណៈ, មានការជំទាស់រារាំងនៃចិត្តជារស, មានការប្រាសចាកទោសជាបច្ចុប្បដ្ឋាន, មានកាយ និងចិត្តជាបទដ្ឋាន, គប្បីឃើញថា ជាសត្រូវនឹងកិលេស គឺភាពជាអ្នកមិនមានសទ្ធាជាដើម ដែលធ្វើការជំទាស់រារាំងដល់កាយ និងចិត្ត ។

ភាវៈនៃកាយត្រង់ ឈ្មោះថា **កាយុជុកតា**; ភាវៈនៃចិត្តត្រង់ ឈ្មោះថា **ចិត្តុជុកតា** ។ ឧជុកតាទាំងពីរនោះ មានការត្រង់កាយ និងចិត្តជាលក្ខណៈ, មានការកម្ចាត់ការវៀចនៃកាយ និងចិត្តជាកិច្ច, មានការស្មោះត្រង់នៃកាយ និងចិត្តជាផល, មានកាយ និងចិត្តជាបទដ្ឋាន, គប្បីឃើញថា ជាសត្រូវនឹង

កិលេសមានមាយា និងសាថេយ្យៈជាដើមដែលធ្វើការវៀចនៃកាយ និងចិត្ត ។

ធម៌ដែលឈ្មោះថា **សតិ** ព្រោះអត្ថថា រលឹក = **សរតីតិ សតិ**, ឈ្មោះថា **សម្បជញ្ញៈ** ព្រោះអត្ថថា ដឹងខ្លួន = **សម្បជានាតីតិ សម្បជញ្ញំ**; អធិប្បាយថា ដឹងខ្លួនមានប្រការផ្សេងៗ ដោយជុំវិញ; ក៏បណ្ដាធម៌ទាំងពីរនោះ គប្បីជ្រាបថា សម្បជញ្ញៈមាន ៤ ប្រការគឺ

**១.សាត្ថកសម្បជញ្ញៈ** ដឹងច្បាស់ថានឹងមានប្រយោជន៍

**២.សប្បាយសម្បជញ្ញៈ** ដឹងច្បាស់ថានឹងបានសប្បាយ

**៣.គោចរសម្បជញ្ញៈ** ដឹងច្បាស់ក្នុងការត្រាច់ទៅ

**៤.អសម្មោហសម្បជញ្ញៈ** ដឹងច្បាស់ គឺមិនវង្វេង ។

ចំណែកធម៌មានលក្ខណៈជាដើមនៃសតិ និងសម្បជញ្ញៈនោះ គប្បីជ្រាបដោយន័យដែលពោលក្នុងសតិន្ទ្រិយ និងបញ្ញិន្ទ្រិយនុ៎ះឯង ។ គូធម៌នេះត្រាស់ទុកក្នុងខាងដើមហើយ ក្នុងទីនេះត្រាស់ទុកទៀត ដោយអំណាចនៃធម៌មានឧបការៈ ដោយប្រការដូច្នេះ ។

ធម៌ដែលឈ្មោះថា **សមថៈ** ព្រោះស្ងប់ធម៌ដែលជាសត្រូវមានកាមច្ឆន្ទៈជាដើម = **កាមច្ឆន្ទាទយោ បច្ចនីកធម្មេ សមេតីតិ = សមថោ** ។

ឈ្មោះថា **វិបស្សនា** ព្រោះឃើញធម៌ទាំងឡាយ ដោយអាការ មានប្រការផ្សេងៗ ដោយអំណាចនៃការមិនទៀងជាដើម = **អនិច្ចាទិវសេន**

**វិវិធេហិ អាការេហិ ធម្មេ បស្សតីតិ = វិបស្សនា**, ដោយអត្ថ **វិបស្សនា** នេះ ក៏គឺបញ្ញានុ៎ះឯង ។ ធម៌មានលក្ខណៈជាដើមនៃសមថៈ និងវិបស្សនានេះ មានសេចក្តីតាមដែលពោលទុកហើយក្នុងខាងដើមនុ៎ះឯង, តែកាន់យកក្នុងទីនេះទៀត ដោយអំណាចនៃធម្មយុគនទ្ធធម៌ ( ធម៌ជាប់គ្នាដូចនឹម) ។

ធម៌ដែលឈ្មោះថា **បគ្គាហៈ** ព្រោះផ្គងសហជាតធម៌; ក៏ឈ្មោះថា **អវិក្ខេបៈ** ព្រោះអត្ថថា ការមិនរវើរវាយ ព្រោះជាបដិបក្ខចំពោះការរវើរវាយ គឺឧទ្ធច្ចៈ; ធម៌ទាំងឡាយមានលក្ខណៈជាដើម នៃធម៌ទាំងពីរនេះ ពោលទុកហើយក្នុងខាងដើមនុ៎ះឯង ។ ក៏ធម៌ទាំងពីរនេះ គប្បីជ្រាបថា កាន់យកហើយក្នុងទីនេះ ដើម្បីការប្រកបវិរិយៈ និងសមាធិ ៕

## អធិប្បាយពាក្យថាយេវាបនកន័យ

ពាក្យថា "**យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា, ឥមេ ធម្មា កុសលា** = ឬថា ក្នុងសម័យនោះសូម្បីធម៌ដទៃណា ដែលមិនមែនជារូប មានការអាស្រ័យនូវគ្នានឹងគ្នា ហើយកើតឡើង, ធម៌ទាំងនោះ ក៏ឈ្មោះថាជា **កុសលា**" គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖-

កុសលធម៌ច្រើនជាង ៥០ = **បរោបណ្ណាសធម្មា** នេះ ព្រះភគវាទ្រង់

លើកឡើងសម្ដែងដោយលំដាប់ថា "ផស្សៈរមែងមាន ។ល។ អវិក្ខេបៈរមែងមាន" ដូច្នេះ ក៏មិនមែន, តាមពិត ទ្រង់សម្ដែងថា "ក្នុងសម័យណា មហាចិត្តជាអសង្ខារិកដួងទី ១ សហគតដោយសោមនស្សតិហេតុកៈ ខាងកាមាវចរ រមែងកើតឡើង; ក្នុងសម័យនោះ សូម្បីធម៌ដទៃ ដែលជាយេវាបនកធម៌ដែលសម្បយុត្តដោយធម៌ទាំងឡាយនោះ មានផស្សៈជាដើម ដែលអាស្រ័យបច្ច័យដ៏សមគួរដល់ខ្លួនៗ ហើយ កើតឡើង ឈ្មោះថា **អរូបៈ** ព្រោះការមិនមានរូបដែលកំណត់ដោយសភាវៈ, សូម្បីធម៌ទាំងឡាយទាំងអស់ ក៏ជាកុសល"[៣៦] ។

ព្រះមានជោគព្រះអង្គទ្រង់ជាធម្មរាជ លុះសម្ដែងធម៌ច្រើនជាង ៥០ ដែលលើកឡើងទុកក្នុងបាលី ដោយអំណាចនៃចំណែកប្រកប (អវយវៈ) របស់ចិត្ត ដោយពុទ្ធវចនៈមានប្រមាណប៉ុណ្ណេះហើយ ទើបទ្រង់សម្ដែងធម៌ ៩ យ៉ាង សូម្បីដទៃទៀត ដោយអំណាចនៃយេវាបនកធម៌ ។ ពិតណាស់ បណ្ដាបទនៃព្រះសូត្រទាំងនោះៗ ធម៌ទាំង ៩ នេះ រមែងប្រាកដ គឺឆន្ទៈ ១ អធិមោក្ខ ១, មនសិការ ១, តត្រមជ្ឈត្តតា ១, ករុណា ១, មុទិតា ១ កាយទុច្ចរិតវិរតិ ១, វចីទុច្ចរិតវិរតិ ១ និងមិច្ឆាជីវវិរតិ ១ ។

ក៏ក្នុងមហាចិត្តដួងទី ១ នេះ ឆន្ទៈក្នុងកុសលធម៌របស់អ្នកប្រាថ្នាដើម្បី

---

[៣៦] អភិ. ៧៨ ។

នឹងធ្វើក៏មាន, តែមិនបានលើកឡើងទុកក្នុងព្រះបាលី ដោយអំណាចនៃអង្គប្រកបរបស់ចិត្ត, ក្នុងទីនេះ ឆន្ទៈនោះ ទើបលោកកាន់យកដោយអំណាចនៃ **យេវាបនកធម៌** ។ អធិមោក្ខក៏មាន, មនសិការ, តត្រមជ្ឈត្តតា និងបុព្វភាគនៃមេត្តាក៏មាន; កាលអទោសៈទ្រង់កាន់យកហើយ បុព្វភាគនៃមេត្តានោះក៏ជាចំណែកដែលកាន់យកហើយដូចគ្នា; សូម្បីបុព្វភាគនៃករុណា, បុព្វភាគនៃមុទិតា, បុព្វភាគនៃឧបេក្ខាក៏មាន; ប៉ុន្តែ កាលតត្រមជ្ឈត្តតាទ្រង់កាន់យកហើយ បុព្វភាគនៃឧបេក្ខានោះ ក៏កាន់យកហើយដែរ; សម្មាវាចាក៏មាន, សម្មាកម្មន្តៈក៏មាន, សម្មាអាជីវៈក៏មាន; ប៉ុន្តែ លោកមិនបានលើកឡើងទុកក្នុងបាលីដោយអំណាចនៃអង្គប្រកបរបស់ចិត្តទេ, ក្នុងទីនេះ ធម៌មានសម្មាវាចាជាដើមនោះ ក៏កាន់យកដោយអំណាចនៃយេវាបនកធម៌; ប៉ុន្តែក្នុងធម៌ ៩ យ៉ាងនេះ ធម៌ ៤ យ៉ាង ដែលបានក្នុងខណៈជាមួយគ្នា គឺឆន្ទៈ ១, អធិមោក្ខ ១, មនសិការ ១ និងតត្រមជ្ឈត្តតា ១; ដែលសល់ក្រៅពីនោះ បានក្នុងខណៈផ្សេងគ្នា ។

ដូចយ៉ាងថា បុគ្គលរមែងលះមិច្ឆាវាចាដោយចិត្តដូងនេះ, រមែងបំពេញសម្មាវាចាដោយអំណាចនៃវិរតិក្នុងកាលណា, ក្នុងកាលនោះ ធម៌ ៥ យ៉ាងនេះ គឺធម៌ ៤ យ៉ាង មានឆន្ទៈជាដើម និងសម្មាវាចា រមែងកើតក្នុងខណៈជាមួយគ្នា ។ កាលណាបុគ្គលលះមិច្ឆាកម្មន្តៈ, បំពេញសម្មាកម្មន្តៈ ដោយ

អំណាចនៃវិរតិ ។ល។ លះមិច្ឆាអាជីវៈ, បំពេញសម្មាអាជីវៈ ដោយអំណាចនៃវិរតិ ។ល។ កាលណាធ្វើបរិកម្មដោយករុណា ។ល។ ធ្វើបរិកម្មដោយមុទិតា, ក្នុងកាលនោះ ធម៌ទាំង ៥ នេះ រមែងកើតក្នុងខណៈជាមួយគ្នា គឺធម៌ ៤ មានឆន្ទៈជាដើម និងបុព្វភាគនៃមុទិតា ។ ក៏ក្រៅពីនេះហើយ កាលបុគ្គលឱ្យទាន, បំពេញសីល, ចម្រើនភាវនា និងរមែងបានធម៌ ៤ យ៉ាង (ឆន្ទៈ អធិមោក្ខ មនសិការ និងតត្រមជ្ឈត្តតា) ដែលជាចំណែកប្រកបដ៏ទៀងទាត់ ៕

## អធិប្បាយពាក្យថាឆន្ទៈជាដើម

បណ្ដាយេវាបនកធម៌ ៩ ពួកនេះ ដូចពណ៌នាមកនេះ ពាក្យថា ឆន្ទៈ ជាឈ្មោះរបស់**កត្តុកម្យតា**; ព្រោះហេតុដូច្នោះ ឆន្ទៈនោះទើបមានការប្រាថ្នាដើម្បីនឹងធ្វើជាលក្ខណៈ, មានការស្វែងរកអារម្មណ៍ជាកិច្ច, មានសេចក្ដីត្រូវការអារម្មណ៍ជាផល, អារម្មណ៍នៃឆន្ទៈនោះឯង ជាហេតុជិត, ក៏ឆន្ទៈនេះ ក្នុងការប្រកាន់អារម្មណ៍ បណ្ឌិតគប្បីឃើញចិត្តដូចលាដៃចេញទៅ ។

ការបង្អោនចិត្ត ឈ្មោះថា **អធិមោក្ខ**; អធិមោក្ខនោះ មានការចុះចិត្តស៊ប់ជាលក្ខណៈ; មានការមិនរំសាយទៅជាកិច្ច, មានការកាត់អស់ ជាអាការប្រាកដ, មានធម៌ដែលគប្បីចុះចិត្តស៊ប់ជាហេតុជិត, អធិមោក្ខនោះ គប្បី

ឃើញដូចសសរខឿន ព្រោះមិនញាប់ញ័រក្នុងអារម្មណ៍ ។

ការធ្វើ ឈ្មោះថា **ការៈ**, ការធ្វើទុកក្នុងចិត្ត ឈ្មោះថា **មនសិការ**, **មនសិ**, **មនស្មឹ** > **ការោ** > **មនសិការោ*** ធម៌ដែលឈ្មោះថា **មនសិការ** ព្រោះធ្វើចិត្តឱ្យឡើងកាន់វីថិពីភវង្គចិត្ត។ មនសិការនេះឯង មាន ៣ ប្រការគឺ

**១~អារម្មណបដិបាទកៈ** បានដល់សង្ខារក្ខន្ធ

**២~វីថិបដិបាទកៈ** បានដល់បញ្ចទ្វារាវជ្ជនចិត្ត

**៣~ជវនបដិបាទកៈ** បានដល់មនោទ្វារាវជ្ជនចិត្ត ។

បណ្ដាមនសិការទាំង ៣ នោះ មនសិការដែលធ្វើចិត្ត ឱ្យទទួលអារម្មណ៍ ឈ្មោះថា **មនសិការ** ព្រោះ**ធ្វើទុកក្នុងចិត្ត** ។ មនសិការធ្វើចិត្តឱ្យទទួលអារម្មណ៍នោះ មានការធ្វើសម្បយុត្តធម៌ឱ្យទទួលអារម្មណ៍ ជាលក្ខណៈ, មានការប្រកបសម្បយុត្តធម៌ទាំងឡាយ ដោយអារម្មណ៍ជាកិច្ច, មានការប្រាថ្នាចំពោះអារម្មណ៍ជាផល, រាប់បញ្ចូលដោយសង្ខារក្ខន្ធ (មានអារម្មណ៍ជាគ្រឿងទ្រ), គប្បីឃើញដូចសារថី ព្រោះញុំាងសម្បយុត្តធម៌ ឱ្យដំណើរទៅក្នុងអារម្មណ៍ ។ ចំណែកពាក្យថា **វីថិបដិបាទកៈ** នេះ ជាឈ្មោះនៃបញ្ចទ្វារាវជ្ជនចិត្ត ។ ពាក្យថា **ជវនបដិបាទកៈ** នេះ ជាឈ្មោះនៃមនោទ្វារាវជ្ជនចិត្ត ។ មនសិការទាំង ២ នោះ លោកមិន ប្រាថ្នាយកក្នុងទីនេះទេ ។

---

* អាចសរសេរជា មនសិ/មនស្មឹ >ការោ = មនសិការោ ដូច្នេះក៏បាន ។

ភាពជាកណ្តាលក្នុងធម៌ទាំងនោះ ឈ្មោះថា **តត្រមជ្ឈត្តតា** ។ តត្រមជ្ឈត្តតានោះ មានការទ្រទ្រង់ទុកនូវចិត្ត និងចេតសិកឱ្យស្មើគ្នាជាលក្ខណៈ, មានការហាមចិត្ត និងចេតសិកមិនឱ្យលើស ឬខ្វះជាកិច្ច ឬមានការកាត់ដាច់អំពីការធ្លាក់ទៅក្នុងផ្នែកណាមួយជាកិច្ច, មានភាពជាកណ្តាល ជាអាការប្រាកដ, ដោយអំណាចនៃការព្រងើយចំពោះចិត្ត និងចេតសិក (និងមានសម្បយុត្តធម៌ជាបទដ្ឋាន), តត្រមជ្ឈត្តតានេះ គប្បីឃើញដូចសារថី អ្នកតាំងចិត្តព្រងើយចំពោះសេះអាជានេយ្យទាំងឡាយ ដែលរត់ទៅរៀបរយដូច្នោះ ។

**ករុណា** និង **មុទិតា** នឹងមានជាក់ច្បាស់ ក្នុងនិទ្ទេសនៃព្រហ្មវិហារ [៣៧] ។ តាមពិត ករុណា និងមុទុតានោះ មានខដែលប្លែកគ្នាតែប៉ុណ្ណោះថា ដែលដល់អប្បនាជាកាមាវចរ ។

ការវៀរចាកកាយទុច្ចរិត ឈ្មោះថា **កាយទុច្ចរិតវិរតិ** ។ វិរតិ ២ នៅសល់ ក៏ន័យនេះដែរ ។ ក៏វិរតិទាំង ៣ នោះដោយលក្ខណៈជាដើម មានការមិនកន្លងល្មើសវត្ថុ មានកាយទុច្ចរិតជាដើម ជាលក្ខណៈ, អធិប្បាយថា មានការមិនញាំញីសត្វជាលក្ខណៈ; វិរតិ ៣ នោះ មានការបែរមុខចាកវត្ថុមានកាយទុច្ចរិតជាដើមជាកិច្ច, មានការមិនធ្វើកាយទុច្ចរិតជាដើម ជាអាការប្រាកដ, មានគុណ គឺសទ្ធា ហិរិ ឱត្តប្បៈ និងការប្រាថ្នាតិចជាដើម ជាគ្រឿង

[៣៧] វិសុទ្ធិ. ២ ។

ទ្រ, គប្បីឃើញវិរតិ ៣ នោះ ជាចិត្តដែលព្រងើយ (បែរមុខចេញ) ចំពោះការធ្វើបាប ។

វារៈនៃធម្មុទ្ទេស (ធម៌ដែលទ្រង់លើកឡើងសម្តែង) នេះ មានបទធម៌ទាំងអស់ ៦៥ បទ គឺធម៌ ៥៦ មានផស្សៈជាដើម និងធម៌ ៩ ដែលត្រាស់ទុកដោយអំណាចនៃ**យេវាបនកធម៌** ។

បណ្តាបទទាំងនោះ គ្រាខ្លះក្នុងខណៈដូចគ្នា ៦១ បទ, គ្រាខ្លះមាន ៦០ បទគត់; ព្រោះថា បទធម៌ទាំងឡាយនោះ ដែលត្រាស់ទុកហើយ ដោយអំណាចនៃការសម្បូណ៌ដោយសម្មាវាចាជាដើម ក៏មាន ៦១ បទ ដែលប្រព្រឹត្តទៅក្នុងឋាន ៥ (វិរតិ ៣ និងអប្បមញ្ញា ២) ។ ក្នុងឋានមួយផុតពីឋាន ៥ នេះ មានឋាន ៦០ គត់; តែបើវៀរយេវាបនកធម៌ បទធម៌ដែលលោកកាន់យកដោយអំណាចនៃរុឡ្ហីសព្ទ ក្នុងព្រះបាលីមាន ៥៦ បទ ។ តែបើមិនរាប់បទបន្ថែមក្នុងបាលីនេះទេ ក៏មានធម៌ ៣០ បទគត់ គឺពួក ៥ នៃផស្សៈ = **ផស្សបញ្ចកំ**, វិតក្កៈ ១ វិចារៈ ១, បីតិ ១, ចិត្តេកគ្គតា ១, ឥន្ទ្រិយ ៥ ពលៈ ២ គឺហិរិពលៈ ឱត្តប្បពលៈ; មូល ២ គឺអទោសៈ និងអលោភៈ; ធម៌ ១២ មានកាយបស្សទ្ធិ និងចិត្តបស្សទ្ធិជាដើម ។

បណ្តាធម៌ទាំង ៣០ នោះ ធម៌ ១៨ លោកមិនចែកទុកទេ, ធម៌ ១២ លោកចែកទុក ។ ធម៌ ១៨ ប្រការតើដូម្តេចខ្លះ? ធម៌ ១៨ ប្រការនេះ គឺ

ផស្សៈ ១, សញ្ញា ១, ចេតនា ១, វិចារៈ ១, បីតិ ១ និងជីវិតិន្ទ្រិយ ១; ធម៌ ១២ មានកាយបសទ្ធិជាដើម លោកមិនបានចែកទុកទេ ។ ធម៌ ១២ ប្រការនេះ គឺវេទនា ១, ចិត្ត ១, វិតក្កៈ ១, ចិត្តេកគ្គតា ១, សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១, សតិន្ទ្រិយ ១, បញ្ញិន្ទ្រិយ ១, ហិរិពលៈ ១, ឱត្តប្បពលៈ ១ អទោសៈ ១ និងអលោភៈ ១ លោកចែកទុក ។

បណ្ដាធម៌ទាំងនោះ ធម៌ ៧ ប្រការចែកទុកក្នុងឋានទាំងពីរ, ធម៌មួយចែកទុកក្នុងឋានទាំង ៣, ធម៌ ២ ចែកទុកក្នុងឋាន ៤, ធម៌ ១ ចែកទុកក្នុងឋាន ៦, ធម៌ ១ ចែកទុកក្នុងឋាន ៧ ។

សួរថា ធម៌ទាំង ៧ នេះគឺចិត្ត, វិតក្កៈ, សទ្ធា, ហិរិ, ឱត្តប្បៈ, អលោភៈ និងអទោសៈ ចែកទុកក្នុងឋាន ២ យ៉ាងណា? ឆ្លើយថា ពិតណាស់ បណ្ដាធម៌ទាំង ៧ នោះ **ចិត្ត** លោកសំដៅដល់ធម៌មានពួក ៥ នៃផស្សៈសិន លោកហៅថា “ចិត្ត” , សម្លឹងដល់ឥន្ទ្រិយលោកហៅថា “មនិន្ទ្រិយ” ។ **វិតក្កៈ** សំដៅដល់អង្គឈាន ក៏លោកហៅថា “វិតក្កៈ” , សម្លឹងដល់អង្គមគ្គ លោកហៅថា “សម្មាសង្កប្បៈ” ; **សទ្ធា** សម្លឹងដល់ឥន្ទ្រិយ លោកហៅថា “សទ្ធិន្ទ្រិយ” , សម្លឹងដល់ពលៈ លោកហៅថា “សទ្ធាពលៈ” ; **ហិរិ** សម្លឹងដល់ពលៈ លោកហៅថា “ហិរិពលៈ” , សម្លឹងដល់ធម៌ពួក ២ នៃលោកបាល លោកហៅថា “ហិរិ” ។ សូម្បីឱត្តប្បៈ ក៏មានន័យដូចគ្នានេះ

ដែរ ។ **អលោភៈ** សម្លឹងដល់មូល លោកហៅថា “អលោភៈ” ; សម្លឹងដល់កម្មបថ លោកហៅថា “អនភិជ្ឈា” ។ **អទោសៈ** សម្លឹងដល់មូល លោកហៅថា “អទោសៈ” , សម្លឹងដល់កម្មបថ ហៅថា “អព្យាបាទ” ។ ធម៌ ៧ នេះ ចែកទុកហើយក្នុងឋានទាំង ២ ។

ចំណែក **វេទនា** សម្លឹងដល់ធម៌ពួក ៥ នៃផស្សៈលោកហៅថា “វេទនា” , សម្លឹងដល់អង្គឈាន លោកហៅថា “សុខ” , សម្លឹងដល់ឥន្ទ្រិយ លោកហៅថា “សោមនស្សិន្ទ្រិយ” ។ ធម៌ ១ ចែកទុកក្នុងឋាន ៣ យ៉ាងនេះ ។

ចំណែក **វីរិយៈ** សម្លឹងដល់ឥន្ទ្រិយហៅថា “វីរិយិន្ទ្រិយ” , សម្លឹងដល់អង្គមគ្គហៅថា “សម្មាវាយាមៈ” , សម្លឹងដល់ពលៈ ហៅថា “វីរិយពលៈ” , សម្លឹងដល់បិដ្ឋិទុកៈ ហៅថា “**បគ្គាហៈ**” ។ សូម្បី **សតិ** សម្លឹងដល់ឥន្ទ្រិយ ក៏ហៅថា “សតិន្ទ្រិយ” , សម្លឹងដល់អង្គមគ្គ ហៅថា “សម្មាសតិ” , សម្លឹងដល់ពលៈ ហៅថា “សតិពលៈ” , សម្លឹងដល់បិដ្ឋិទុកៈ ហៅថា “សតិ” ។ ធម៌ ២ នេះ ចែកទុកក្នុងឋាន ៤ ដោយប្រការដូច្នេះ ។

ចំណែក **សមាធិ** សម្លឹងដល់អង្គឈានហៅថា “ចិត្តេកគ្គតា” , សម្លឹងដល់ឥន្ទ្រិយហៅថា “សមាធិន្ទ្រិយ” , សម្លឹងដល់អង្គមគ្គ ហៅថា “សម្មាសមាធិ” , សម្លឹងដល់ពលៈ ហៅថា “សមាធិពលៈ” សម្លឹងដល់

បិដ្ឋិទុកៈ ហៅថា “សមថៈ និងអវិក្ខេបៈ” , ធម៌មួយនេះ លោកចែកទុកក្នុងឋាន ៦ ដោយប្រការដូច្នេះ, ចំណែកខាង **បញ្ញា** សម្លឹងដល់ឥន្ទ្រិយ ហៅថា “បញ្ញិន្ទ្រិយ” , សម្លឹងដល់អង្គមគ្គ ហៅថា “សម្មាទិដ្ឋិ” , សម្លឹងដល់ពលៈ ហៅថា “បញ្ញាពលៈ” , សម្លឹងដល់មូល ហៅថា “អមោហៈ” , សម្លឹងដល់កម្មបថ ហៅថា “សម្មាទិដ្ឋិ” សម្លឹងដល់បិដ្ឋិទុកៈ ហៅថា “សម្បជញ្ញៈ និងវិបស្សនា” ; ធម៌ពួកមួយនេះ លោកចែកទុកក្នុងឋាន ៧ ដោយប្រការដូច្នេះ ។

ក៏បុគ្គលណា១ គប្បីទំនាស់ថា “ក្នុងព្រះបាលីនេះ ឡើងឈ្មោះថា បទដែលមិនធ្លាប់មាន មិនមានទេ, ព្រោះព្រះអង្គទ្រង់កំណត់ធម៌ដែលទ្រង់កាន់យកហើយក្នុងខាងដើមនោះឯង មកធ្វើបទឱ្យពេញក្នុងឋាននោះៗ, កថាដែលមិនមានអនុសន្ធិ ដូចវត្ថុដែលពួកចោរលួចមកបង្គរគ្នាទុក, ដូចនឹងស្មៅដែលហ្វូងគោជាន់ខ្ទេចត្រង់ផ្លូវដើរទៅ, ដែលព្រះពុទ្ធជាម្ចាស់ ទ្រង់មិនដឹងហើយទើបត្រាស់ទុក” ; បុគ្គលនោះ គប្បីត្រូវលោកពោលបដិសេធថា មិនគួរពោលយ៉ាងនោះទេ ព្រោះថា ទេសនារបស់ព្រះពុទ្ធទាំងឡាយ ដែលមិនមានអនុសន្ធិមិនមានឡើយ, គឺជាទេសនាដែលមានអនុសន្ធិ; សូម្បីពាក្យដែលមិនទ្រង់ជ្រាប ហើយត្រាស់ទុកក៏មិនមាន, រឿងទាំងអស់ព្រះអង្គ ទ្រង់ជ្រាបហើយ ទើបត្រាស់ទុកមែនពិត ។ ពិតណាស់ ព្រះសម្មាសម្ពុទ្ធទ្រង់

ជ្រាបនូវកិច្ច (នាទី) របស់ធម៌ទាំងនោះៗ, លុះទ្រង់ជ្រាបនូវកិច្ចនោះហើយ ទើបទ្រង់លើកឡើងចែកទៅតាមនាទី ទ្រង់ជ្រាបថា "ធម៌ទាំង ១៨ យ៉ាង មាននាទីតែម្យ៉ាង" ដូច្នេះ ទើបទ្រង់លើកឡើងចែកទុកក្នុងឋានមួយៗ; ទ្រង់ជ្រាបថា "ធម៌ ៧ យ៉ាងមាននាទីម្យ៉ាងៗ ២" ទើបទ្រង់លើកឡើងចែកទុកក្នុងឋាន ២ៗ; ទ្រង់ជ្រាបថា "វេទនាមាននាទី ៣" ទើបទ្រង់លើកឡើងចែកទុកក្នុងឋាន ៣; ទ្រង់ជ្រាបថា "វីរិយៈ និងសតិមាននាទី ៤ យ៉ាង" ដូច្នេះ ទើបលើកឡើងចែកទុកក្នុងឋាន ៤ៗ; ទ្រង់ជ្រាបថា "សមាធិមាននាទី ៦ យ៉ាង" ទើបលើកឡើងចែកទុកក្នុងឋាន ៦, ទ្រង់ជ្រាបថា "បញ្ញាមាននាទី ៧ យ៉ាង" ទើបលើកឡើងចែកទុកក្នុងឋាន ៧; ក្នុងសេចក្ដីនោះមានឧបមាដូច្នេះ ៖-

បានឮថា ព្រះរាជាមួយអង្គទ្រង់ជាបណ្ឌិត ស្ដេចប្រថាប់នៅក្នុងទីស្ងាត់ ហើយទ្រង់ព្រះតម្រិះថា "យើងនឹងបន្ថែមថ្លៃឈ្នួលដែលសមគួរដល់អ្នកចេះសិល្បសាស្ត្រ ដោយប្រការដែលមិនគប្បីឱ្យអស់ទ្រព្យក្នុងឃ្លាំងហ្លួងនេះ" ; ស្ដេចអង្គនោះ ទើបត្រាស់ឱ្យហៅអ្នកសិល្បសាស្ត្រទាំងអស់ ឱ្យមកប្រជុំគ្នាហើយត្រាស់ថា "ពួកអ្នកចូរអញ្ជើញមនុស្សដែលមានចំណេះដឹងខាងសិល្បៈមួយៗ មក" កាលព្រះអង្គត្រាស់ឱ្យហៅយ៉ាងនេះ ជនទាំង ១៨ នាក់ ក៏ក្រោកឡើងមកហើយ ព្រះអង្គក៏ព្រះរាជទានឱ្យជនទាំងនោះចំណែកមួយៗ។

កាលព្រះរាជាត្រាស់ថា "អ្នកដឹងសិល្បៈពីរ១ចូរមក" ដូច្នេះ មនុស្ស ៧ នាក់នាំគ្នាមកគាល់, ព្រះអង្គក៏ទ្រង់ព្រះរាជទាន ឱ្យមនុស្សទាំងនោះពីរ១ ចំណែក ។ កាលត្រាស់ថា "អ្នកដឹងសិល្បៈ ៣ យ៉ាង ចូរមក" មានមនុស្ស តែម្នាក់ចូលមកគាល់, ព្រះអង្គក៏ទ្រង់ព្រះរាជទានឱ្យអ្នកនោះ ៣ ចំណែក ។ កាលព្រះអង្គត្រាស់ថា "អ្នកដឹងសិល្បៈ ៤ យ៉ាងចូរមក" ក៏មានមនុស្ស ២ នាក់ចូលមកគាល់, ព្រះអង្គក៏ទ្រង់ព្រះរាជទានឱ្យមនុស្សទាំងនោះ ម្នាក់១ ៤១ ចំណែក ។ កាលព្រះអង្គត្រាស់ថា "អ្នកដឹងសិប្បៈ ៥ យ៉ាងចូរមក" ដូច្នេះ សូម្បីមនុស្សតែម្នាក់ ក៏មិនបានមក ។

កាលត្រាស់ថា "អ្នកចេះសិប្បៈ ៦ យ៉ាងចូរមក" ដូច្នេះ មានតែ មនុស្សម្នាក់ប៉ុណ្ណោះចូលមក, ព្រះអង្គក៏ទ្រង់ព្រះរាជទាន ៦ ចំណែកដល់គេ។ កាលព្រះអង្គត្រាស់ថា "អ្នកចេះសិប្បៈ ៧ យ៉ាងចូរមក" ដូច្នេះ មានតែ ម្នាក់ប៉ុណ្ណោះចូរមក, ព្រះអង្គទ្រង់ព្រះរាជទានឱ្យគេដល់ ៧ ចំណែក ។ ក្នុង រឿងនោះមានឧបមាដូច្នេះ ៖-

ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ជាធម្មរាជ រកអ្នកឯណាឱ្យក្រៃលែងជាង គ្មាន ប្រៀបដូចព្រះរាជាព្រះអង្គជាបណ្ឌិត, ធម៌ទាំងឡាយដែលកើតឡើង ដោយអំណាចនៃភាវៈជាអង្គរបស់ចិត្ត ប្រៀបដូចជនអ្នកចេះសិប្បៈ, ការ ដែលព្រះអង្គទ្រង់លើកធម៌ទាំងឡាយនោះ១ ឡើងចែកដោយអំណាចនៃនាទី

ប្រៀបដូចការបន្ថែមថ្លៃឈ្នួលឱ្យសមគួរដល់អ្នកចេះសិប្បៈ; ក៏សូម្បីធម៌ទាំងអស់នោះ ជាកងធម៌ ១៧ ពួក គឺធម៌ពួក ៥ មានផស្សៈជាដើម ១, អង្គឈាន ១, ឥន្ទ្រិយ ១, អង្គមគ្គ ១, ពលៈ ១, មូល ១, កម្មបថ ១, លោកបាលទុកៈ ១, បស្សទ្ធិ ១, លហុតា ១, មុទុតា ១, កម្មញ្ញតា ១, បាគុញ្ញតា ១, ឧជុកតា ១, សតិ និងសម្បជញ្ញៈ ១, សមថៈ និងវិបស្សនា ១, បគ្គាហាវិក្ខេប ១។

## ចប់កថាសម្តែងអំពីធម្មុទ្ទេសវារៈ

# អដ្ឋកថាចិត្តុប្បាទកណ្ឌ

ឥឡូវនេះ ទ្រង់បំណងនឹងចែកបទវារៈ ដែលពោលដោយធម្មុទ្ទេស (ប្រធានធម៌) ៥៦ ដែលលើកឡើងកាន់ព្រះបាលីនោះទាំងអស់ ទើបទ្រង់ផ្ដើមនិទ្ទេសវារៈដោយន័យជាដើមថា **“កតមោ តស្មឹ សមយេ ផស្សោ ហោតិ** = ផស្សៈកើតមានក្នុងសម័យនោះ តើដូចម្ដេច?” គួរជ្រាបសេចក្ដីនេះនៃពាក្យសួរក្នុងនិទ្ទេសនោះមុនហើយ គប្បីជ្រាបសេចក្ដីក្នុងពាក្យសួរទាំងអស់ ដោយន័យជាដើមថា “កាមាវចរមហាកុសលចិត្ត សហគតៈដោយសោមនស្ស ជាអសង្ខារិក កើតឡើងក្នុងសម័យណា, ផស្សៈក៏កើតមានក្នុងសម័យនោះដូច្នេះ, ទើបត្រាស់ថា **ផស្សៈ** មានក្នុងសម័យនោះ តើដូចម្ដេច? ។

ពាក្យថា **ផស្សៈណាក៏កើតមានក្នុងសម័យនោះ**, សេចក្ដីថា ផស្សៈណា ដែលកើតឡើងដោយអំណាចនៃធម៌ ដែលប៉ះពាល់ក្នុងសម័យនោះ, ពាក្យថា **“ផស្សៈនោះ”** នេះ ឈ្មោះថា ជាបទសភាវៈធម៌ ព្រោះសម្ដែងសភាវៈរបស់ផស្សៈ ។ ពាក្យថា **“ផុស្សនា”** បានដល់ អាការពាល់ត្រូវ ។ ពាក្យថា **“សម្ផុស្សនា”** គឺអាការដែលប៉ះពាល់ត្រូវព្រមគ្នានោះឯង ដែល

ទ្រង់បន្ថែមបទឧបសគ្គហើយត្រាស់ថា **សម្ផុស្សនា** ។ ពាក្យថា "**សម្ផុស្សិតត្តំ**" បានដល់ ភាវៈដែលត្រូវទង្គុកទង្គិចគ្នាហើយ ។ ក៏ក្នុងនិទ្ទេសវារៈនេះ មានពាក្យប្រកបសេចក្តីដូចតទៅនេះថា ៖-

ផស្សៈណា ដោយអំណាចនៃការពាល់ត្រូវ មានក្នុងសម័យនោះ, **ផុស្សនា** (កិរិយាដែលពាល់ត្រូវ) ណា មានក្នុងសម័យនោះ, **សម្ផុស្សនា** (អាការដែលប៉ះពាល់ព្រមគ្នា) ណា មានក្នុងសម័យនោះ, **សម្ផុស្សិតត្តំ** (ភាវៈដែលត្រូវទង្គុកទង្គិចព្រមគ្នា) ណា មានក្នុងសម័យនោះ ។ម្យ៉ាងទៀត ផស្សៈណា ដែលមានដោយអំណាចនៃធម៌ដែលប៉ះខ្ទប់គ្នា ក្នុងសម័យនោះ ដោយបរិយាយដទៃ លោកហៅថា **ផុស្សនា សម្ផុស្សនា សម្ផុស្សិតត្តា**, ភាវៈនេះ ឈ្មោះថា **ផស្សៈ** មានក្នុងសម័យនោះ ។ ក្នុងនិទ្ទេសទាំងឡាយ នៃធម៌ មានវេទនាជាដើម គប្បីជ្រាបយោជនាចំពោះបទដោយន័យនេះចុះ; ចំណែកខវិនិច្ឆ័យក្នុងការចែកបទដែលទូទៅក្នុងបទទាំងអស់ ក្នុងនិទ្ទេសវារៈ ដូចតទៅនេះ ៖-

ព្រះមានជោគលុះទ្រង់សម្តែងចែកមហាកុសលកាមាវចរចិត្តដួងទី ១ ហើយ កាលទ្រង់ចែកចេញទៅ ទើបដាក់ធម៌ទុកលើស ៥០ បទ ដោយអំណាចនៃមាតិកា ទើបទ្រង់លើកឡើងមួយបទៗ ចែកទៀត, បទធម៌ទាំងឡាយនោះ កាលដល់ការចែក តែងដល់ការចែកដោយហេតុ ៣ ប្រការ, បទធម៌ទាំងនោះ ដែលញែកផ្សេងគ្នា ក៏ញែកផ្សេងគ្នាដោយហេតុ ៤ ប្រការ ។ ក៏ក្នុងនិទ្ទេសវារៈនេះ ការសម្តែងដោយប្រការដទៃ តែងបានឋាន ២ ប្រការ ។ បានដូចម្តេច? ពិតមែនហើយ បទទាំងនោះរមែងដល់ការចែកដោយហេតុ ៣ ប្រការនេះ គឺដោយអំណាចនៃព្យញ្ជនៈ ១, ដោយអំណាចនៃឧបសគ្គ ១ និងដោយអំណាចនៃអត្ថ ១ ។

បណ្តាហេតុទាំង ៣ នោះ បណ្ឌិតគប្បីជ្រាបដល់ការចែកដោយអំណាចនៃ**ព្យញ្ជនៈ**យ៉ាងនេះថា “ការក្រោធ = **កោធោ**, កិរិយាដែលក្រោធ = **កុជ្ឈនា**, ភាពនៃអ្នកក្រោធ = **កុជ្ឈិតត្តំ**, ការប្រទូស្ត = **ទោសោ** កិរិយាដែលប្រទូស្ត = **ទុស្សនា**, ភាពជាអ្នកប្រទូស្ត = **ទុស្សិតត្តំ**” ។ ពិតណាស់ ក្នុងហេតុទាំងនេះ ការក្រោធតែម្យ៉ាងប៉ុណ្ណោះ ដល់ការចែកយ៉ាងនេះ

ដោយអំណាចនៃព្យញ្ជនៈ ។

ចំណែកការចែកដោយអំណាចនៃ **ឧបសគ្គ** គប្បីជ្រាបយ៉ាងនេះថា "**ចារោ** = ការត្រាច់ទៅ, **វិចារោ** = ការពិចារណា, **អនុវិចារោ** = ការតាម ពិចារណា, **ឧបវិចារោ** = ការចូលទៅពិចារណា" ។ គប្បីជ្រាបដល់ការចែកដោយអំណាចនៃ**អត្ថ** យ៉ាងនេះថា "**បណ្ឌិច្ចំ** = ភាពជាបណ្ឌិត, **កោសល្លំ** = ភាពជាអ្នកឆ្លាត, **នេបុញ្ញំ** = ភាពជាអ្នកឆ្លៀវឆ្លាត, **វេភព្យា** ភាពជាអ្នកដឹងច្បាស់, **ចិន្តា** = ការគិត, **ឧបបរិក្ខា** = ការពិចារណា" ។ បណ្ដាការចែកបទធម៌ទាំងនោះ ការចែកបទទាំង ៣ នេះ បានក្នុងនិទ្ទេសនៃបទផស្សៈជាមុន ។ ពិតណាស់ ពាក្យថា "**ផស្សោ ផុសនា**" បានដល់ ការចែកដោយព្យញ្ជនៈ ។ ពាក្យថា "**សម្ផុសនា**" បានដល់ ការចែកដោយឧបសគ្គ ។ ពាក្យថា "**សម្ផុសិតត្តំ**" បានដល់ ការចែកដោយអត្ថ ។ គប្បីជ្រាបការចែកក្នុងនិទ្ទេសនៃបទទាំងពួង ដោយន័យនេះចុះ ។

ចំណែកធម៌ទាំងឡាយ កាលមានបទផ្សេងគ្នា ឈ្មោះថា ផ្សេងគ្នា

ដោយហេតុ ៤ ប្រការនេះ គឺការផ្សេងគ្នាដោយឈ្មោះ ១, ការផ្សេងគ្នាដោយលក្ខណៈ ១, ការផ្សេងគ្នាដោយកិច្ច (នាទី) ១ និងការផ្សេងគ្នាដោយបដិសេធន៍ ១ ។ បណ្ដាការផ្សេងគ្នាទាំងនោះ គប្បីជ្រាប**ការផ្សេងគ្នាដោយឈ្មោះ** យ៉ាងនេះ ក្នុងទីនេះថា "ការព្យាបាទមានក្នុងសម័យនោះ តើដូចម្ដេច? ការប្រទូស្ត កិរិយាដែលប្រទូស្តណា មានក្នុងសម័យនោះ"[៣៨] ។ សូម្បីធម៌ទាំងពីរនេះ គឺការព្យាបាទ ឬទោសៈ ក៏គឺការក្រោធខឹងហ្នឹងឯង, គ្រាន់តែផ្សេងគ្នាដោយឈ្មោះតែប៉ុណ្ណោះ ។ ក៏ធម៌ ៥ យ៉ាង ឈ្មោះថា **ខន្ធ** ព្រោះអត្ថថា ជាកង = **រាសិដ្ឋេន**, ធម៌មួយប៉ុណ្ណោះ ក៏ហៅថា ខន្ធ; ក៏ខន្ធ ៥ **មានការផ្សេងគ្នាដោយលក្ខណៈ** យ៉ាងនេះ គឺបណ្ដាខន្ធទាំង ៥ នេះ

## លក្ខណាទិចតុក្កៈនៃខន្ធ ៥

រូប មានការវិនាសជាលក្ខណៈ **រុប្បនលក្ខណំ**

វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ **វេទយិតលក្ខណា**

---

[៣៨] អភិ. ។

សញ្ញា មានការចាំអារម្មណ៍ជាលក្ខណៈ **សញ្ជាននលក្ខណា**

ចេតនា មានការជំរុញតឿនសម្បយុត្តធម៌ ជាលក្ខណៈ **ចេតយិតលក្ខណា** ។

វិញ្ញាណ មានការដឹងអារម្មណ៍ជាលក្ខណៈ **វិជាននលក្ខណំ** ។

ពោលដោយ**សេចក្តីផ្សេងគ្នានៃកិច្ច** សេចក្តីព្យាយាមតែម្យ៉ាងប៉ុណ្ណោះមកហើយក្នុងឋានទាំង ៤ យ៉ាងនេះថា សម្មប្បធាន ៤ គឺភិក្ខុក្នុងសាសនានេះធ្វើឆន្ទៈឱ្យកើត ផ្គងចិត្តទុក ធ្វើសេចក្តីព្យាយាម ។ល។ ដើម្បីការពារបាបអកុសលធម៌ ដែលនៅមិនទាន់កើត មិនឱ្យកើតឡើង [៣៩] គប្បីជ្រាបសេចក្តីផ្សេងគ្នា ដោយអំណាចនៃ**ការផ្សេងគ្នាដោយកិច្ច** មានប្រការដូច្នេះ ។

ក៏គប្បីជ្រាបការផ្សេងគ្នា ដោយ**ការផ្សេងគ្នាដោយការបដិសេធន៍** ក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា “អធម៌ ៤ ប្រការ គឺភាពជាអ្នកធ្ងន់ក្នុងការក្រោធ, មិនមែនធ្ងន់ក្នុងព្រះសទ្ធម្ម១; ភាពជាអ្នកធ្ងន់ក្នុងការលុបគុណគេ,

---

[៣៩] ទី. ម., អភិ. ។

មិនមែនធ្ងន់ក្នុងព្រះសទ្ធម្ម ១; ភាពជាអ្នកធ្ងន់ក្នុងលាភមិនមែនធ្ងន់ក្នុងព្រះសទ្ធម្ម ១; ភាពជាអ្នកធ្ងន់ក្នុងសក្ការៈ, មិនមែនធ្ងន់ក្នុងព្រះសទ្ធម្ម១”[៤០] ។

ក៏ការផ្សេងគ្នាទាំង ៤ យ៉ាងនេះ រមែងបានក្នុងផស្សៈតែប៉ុណ្ណោះ ក៏មិនមែនទេ, បានក្នុងធម៌សូម្បីទាំងអស់ ដែលនៅមានធម៌ពួក ៥ មានផស្សៈជាដើម; ពិតណាស់ ពាក្យថា “**ផស្សោ**” ជាឈ្មោះនៃផស្សៈ ។ល។ ពាក្យថា “**ចិត្តំ**” ជាឈ្មោះនៃចិត្ត (នេះហៅថាការផ្សេងគ្នាដោយឈ្មោះ) ។ ក៏ផស្សៈមានការពាល់ត្រូវជាលក្ខណៈ = **ផុស្សនលក្ខណោ**, វេទនាមានការសោយអារម្មណ៍ជាលក្ខណៈ, សញ្ញាមានការចងចាំអារម្មណ៍ជាលក្ខណៈ, ចេតនាមានការជំរុញតឿន សម្បយុត្តធម៌ជាលក្ខណៈ, វិញ្ញាណមានការដឹងអារម្មណ៍ជាលក្ខណៈ (នេះហៅថាការផ្សេងគ្នាដោយលក្ខណៈ) ។

មួយ៉ាងទៀត ផស្សៈមានការពាល់ត្រូវប៉ុណ្ណោះជាកិច្ច **ផុស្សនកិច្ចោ**

---

[៤០] អំ. ចតុក្ក. ។

វេទនាមានការសោយអារម្មណ៍ជាកិច្ច **អនុភវនកិច្ចា**

សញ្ញាមានការចាំអារម្មណ៍ជាកិច្ច **សញ្ជាននកិច្ចា**

ចេតនាមានការជំរុញតឿនជាកិច្ច **ចេតនកិច្ចា**

វិញ្ញាណមានការដឹងអារម្មណ៍ជាកិច្ច **វិជាននកិច្ចំ** ។

គប្បីជ្រាបការផ្សេងគ្នានៃកិច្ចយ៉ាងនេះ ដោយប្រការដូច្នេះ ។

ការផ្សេងគ្នានៃការបដិសេធក្នុងធម៌ពួក ៥ នៃផស្សៈមិនមាន ។ ប៉ុន្តែក្នុងនិទ្ទេសនៃធម៌មានលោភៈជាដើម គប្បីជ្រាបការផ្សេងគ្នាដោយអំណាចនៃការបដិសេធយ៉ាងនេះថា បុគ្គលលោភដោយន័យជាដើមថា "ការមិនលោភ, កិរិយាដែលមិនលោភ, ភាពជាអ្នកមិនលោភ" ដូច្នេះ គប្បីជ្រាបការផ្សេងគ្នាទាំង ៤ យ៉ាង ដោយអំណាចនៃបទដែលមានក្នុងនិទ្ទេសនៃបទទាំងអស់ ដោយប្រកាដូច្នេះ។

ចំណែកឯ **ការសម្តែងដោយបរិយាយដទៃទៀត** បាន ២ ឋាន យ៉ាងនេះ គឺ **បទត្ថុតិ** = បទលើកសរសើរ, **ទឡ្ហីកម្មំ** = បទដែលបញ្ជាក់សេចក្តី ។ ពិតមែន កាលព្រះភគវន្តមុនីត្រាស់ពាក្យថា "ផស្សៈ" ត្រឹមតែម្តង ហាក់

ដូចការសង្កត់ដោយចុងឈើច្រត់ចុះ បទនោះនៅមិនឈ្មោះថា ប្រដាប់ហើយ, តាក់តែងហើយនូវបទសម្ផស្ស, កាលត្រាស់រឿយៗ ថា “**ផស្សោ ផុស្សនា សម្ផុស្សនា សម្ផុស្សិតត្តំ**” ដោយអំណាចនៃព្យញ្ជនៈ, ដោយអំណាចនៃឧបសគ្គ ដោយអំណាចនៃអត្ថ បទនោះ ទើបឈ្មោះថា ប្រដាប់ហើយ, តាក់តែងហើយនូវបទផស្សៈ ប្រៀបដូចភីលៀងភ្ញួតទឹកឱ្យព្រះរាជកុមារហើយ យកសំពត់ដែលពេញចិត្តដណ្ដប់ឱ្យ ហើយយកផ្កាឈើទាំងឡាយ ប្រដាប់ឱ្យ បន្ដក់ថ្នាំភ្នែកឱ្យ ។ តអំពីនោះ ក៏យកមនោសិលា (ពណ៌ក្រហម) ប្រោះមុខត្រង់ថ្ងាស់ត្រឹមមួយចំណុចប៉ុណ្ណោះ, ហេតុត្រឹមតែប៉ុណ្ណេះ នៅមិនទាន់ឈ្មោះថា មានស្នាមប្រោះល្អស្អាតដែរ, ប៉ុន្តែ កាលភីលៀងយកពណ៌ទាំងឡាយផ្សេងៗ មកប្រោះពទ្ធជុំវិញទើបឈ្មោះថា មានស្នាមប្រោះល្អស្អាត; កាលបើមានឧបមាជាគ្រឿងឧបមេយ្យនេះ គប្បីឃើញដូច្នោះចុះ ។ នេះឈ្មោះថា **បទត្ថុតិបទ** ។ ក៏ការពោលរឿយៗ ដោយអំណាចនៃព្យញ្ជនៈ អត្ថ និងឧបសគ្គ ឈ្មោះថា **ឧទ្ធារិកម្មបទ** ។ ប្រៀបដូចកាលពោលថា “អាវុសោ” ក្តី,

“ភន្តេ” ក្តី, “យក្ខ” ក្តី, “ពស់” ក្តី មិនឈ្មោះថា ពោលអះអាងសេចក្តីទេ ។ តែកាលពោលថា “អាវុសោ អាវុសោ, ភន្តេ ភន្តេ, យក្ស យក្ស, ពស់ ពស់” ដូច្នេះ ទើបឈ្មោះថា ពោលបញ្ជាក់អះអាងសេចក្តី យ៉ាងណា ។ កាលព្រះមានជោគត្រាស់បទថា “ផស្សៈ” ដូច្នេះ ក៏យ៉ាងនោះដែរ ដូចជាការសង្កត់ដោយចុងឈើច្រត់ មិនឈ្មោះថា ជាបទបញ្ជាក់សេចក្តីទេ, តែកាលបើត្រាស់រឿយៗ ថា **“ផស្សោ ផុស្សនា សម្ផុស្សនា សម្ផុសិតត្តំ ”** ដូច្នេះ ដោយអំណាចនៃព្យញ្ជនៈ ឧបសគ្គ និងអត្ថនោះឯង ទើបឈ្មោះថា **ជាការត្រាស់បញ្ជាក់សេចក្តី** ការសម្តែងដោយបរិយាយដទៃ បានឋាន ២ មានប្រការដូច្នេះ ។ បណ្ឌិតប្បីជ្រាបសេចក្តីក្នុងបទទាំងអស់ ក្នុងនិទ្ទេសនៃបទដែលមានដោយអំណាចនៃផស្សៈនេះសិនចុះ ។

ពាក្យថា **“អយំ តស្មឹ សមយេ ផស្សោ ហោតិ”** មានសេចក្តីថា ជាកាមាវចកុសលចិត្តដួងទី ១ កើតឡើងក្នុងសម័យណា, ឈ្មោះថា ផស្សៈនេះក៏មានក្នុងសម័យនោះ; ការពណ៌នានិទ្ទេសនៃបទផស្សៈត្រឹមតែប៉ុណ្ណេះសិនចុះ ៕

## **អធិប្បាយវេទនានិទ្ទេសជាដើម**

ក៏តអំពីនេះទៅ ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) នឹងពណ៌នានូវហេតុត្រឹមតែការផ្សេងគ្នាក្នុងនិទ្ទេសដទៃៗ នៃបទមានវេទនាជាដើម; ពាក្យដែលសល់គប្បីជ្រាបដោយន័យដែលពោលទុកក្នុងនិទ្ទេសនៃផស្សៈនេះតែម្តង ។

ក្នុងពាក្យថា **"យំ តស្មឹ សមយេ"** នេះ ព្រះភគវាទ្រង់ផ្តើមពាក្យមានពាក្យជាដើមថា "វេទនាក្នុងសម័យនោះ តើដូចម្តេច?" ក៏ពិតមែនហើយ, ប៉ុន្តែ ក៏ត្រាស់ពាក្យថា **"យំ"** ទុក ដោយអំណាចនៃបទ**សាតៈ** = សេចក្តីត្រេកអរ; វេទនាត្រាស់ហៅថា **តជ្ជា** ក្នុងពាក្យថា **"តជ្ជាមនោវិញ្ញាណធាតុសម្ផស្សជំ"** នេះ ព្រោះល្មមសមគួរដល់សេចក្តីសុខដែលជាទីត្រេកអរនោះ, ពិតណាស់ **តជ្ជា**សព្ទនេះ មានអត្ថថា សមគួរក៏មាន; ដូចយ៉ាងដែលត្រាស់ថា **"តជ្ជំ សារុប្បំ កថំ មន្តេតិ** = ជនប្រឹក្សាពាក្យសម្តីសមរម្យ សមគួរ[៤១]" ។

---

[៤១] តាមច្បាប់ខ្លះ ។

ម្យ៉ាងទៀត ធម៌ដែលឈ្មោះថា **តជ្ជា** ព្រោះកើតពីធម៌មានរូបារម្មណ៍ ជាដើមនោះ នឹងកើតពីបច្ច័យនៃសេចក្ដីសុខនេះក៏មាន ។ មនោវិញ្ញាណនោះ ឯង ឈ្មោះថា ធាតុ ព្រោះអត្ថថា មិនមែនសត្វ = **និស្សត្តត្ថេន** ព្រោះហេតុ ដូច្នោះ ទើបហៅថា **មនោវិញ្ញាណធាតុ** ធម៌ណាកើតអំពីសម្ផស្ស, ឬកើត ក្នុងសម្ផស្ស ព្រោះហេតុនោះ ធម៌នោះទើបឈ្មោះថា **សម្ផស្សជៈ** ឈ្មោះថា **ចេតសិក** ព្រោះអាស្រ័យចិត្ត = **ចិត្តនិស្សិតត្តា** ។ ឈ្មោះថា **សាតៈ** ព្រោះ អត្ថថា ពេញចិត្ត ។ ពាក្យនេះមានអធិប្បាយថា "ចេតសិកដែលកើតអំពី សម្ផស្សនៃមនោវិញ្ញាណធាតុ ឈ្មោះថា **តជ្ជា** ដោយអត្ថដូចដែលពោល ហើយដោយការត្រេកអរណា ក្នុងសម័យនោះ នេះឈ្មោះថា វេទនាក្នុង សម័យនោះ" ។ គប្បីជ្រាបការប្រកបបទទាំងពួង ដោយប្រការដូច្នេះ ។

ឥឡូវនេះ ក្នុងពាក្យថា "**ចេតសិកំ សុខំ**" ជាដើម ព្រះមានព្រះភាគ ទ្រង់បដិសេធសុខផ្លូវកាយ ដោយបទនៃចេតសិក; ទ្រង់បដិសេធទុក្ខផ្លូវចិត្ត ដោយបទនៃសុខ; បទថា **ចេតោសម្ផស្សជំ** បានដល់ ចិត្តកើតពីសម្ផស្ស ។

ច្រើនបទថា **“សាតំ សុខំ វេទយិតំ”** បានដល់ ការសោយអារម្មណ៍ដែលគួរពេញចិត្ត, មិនមែនសោយអារម្មណ៍ ដែលមិនគួរពេញចិត្តទេ; សោយអារម្មណ៍ជាសុខ, មិនមែនសោយអារម្មណ៍ជាទុក្ខទេ ។ ចំណែកឯ ៣ បទខាងមុខ ត្រាស់ទុកដោយឥត្ថីលិង្គ ។ ក៏សេចក្តីក្នុងបទទាំង ៣ នេះ មានត្រឹមតែប៉ុណ្ណេះថា វេទនាដែលពេញចិត្ត, មិនមែនវេទនាដែលមិនពេញចិត្តទេ; វេទនាដែលជាសុខ, មិនមែនវេទនាដែលជាទុក្ខទេ ។

ក្នុងនិទ្ទេសនៃសញ្ញា ពាក្យថា **“តជ្ជាមនោវិញ្ញាណធាតុសម្ផស្សជា”** បានដល់ សញ្ញាដែលកើតក្នុងសម្ផស្សនៃមនោវិញ្ញាណធាតុ ដែលសមគួរដល់កុសលសញ្ញានោះ ។ ពាក្យថា **“សញ្ញា”** ជាឈ្មោះនៃសភាវៈ ។ ពាក្យថា **“សញ្ជាននា”** បានដល់ អាការដែលចាំបាន ។ ពាក្យថា **“សញ្ជានិតត្តំ”** បានដល់ ភាវៈដែលចាំបាន ។ សូម្បីក្នុងនិទ្ទេសនៃចេតនា ក៏គប្បីជ្រាបដោយន័យនេះដែរ ។

ក្នុងនិទ្ទេសនៃចិត្ត ដែលឈ្មោះថា **ចិត្តំ** ព្រោះភាវៈនៃចិត្តជាធម្មជាតវិចិត្រ; ឈ្មោះថា **មនោ** ព្រោះកំណត់ដឹងអារម្មណ៍ មនោនោះឯង ឈ្មោះថា

**មានសៈ**។ ពិតណាស់ ក្នុងគាថាដែលថា “**អន្តលិក្ខចរោ បាសោ, ឃ្វាយំ ចរតិ មានសោ តេន តំ ពាធយិស្សាមិ ន មេ សមណ មោក្ខសិ** =

អន្ទាក់ គឺរាគៈណា មានការត្រាច់ទៅ, ខ្ញុំព្រះអង្គនឹងបំពាក់ព្រះអង្គទុកដោយអន្ទាក់នោះ, នៃសមណៈ លោកមិនកន្លងផុតនូវខ្ញុំទេ”[៤២] នេះ ត្រាស់ហៅថា ធម៌គឺរាគៈដែលសម្បយុត្តដោយចិត្តថា **មានសៈ**។ ព្រះអរហន្ត បានត្រាស់ថា “មានសៈ” ដូចក្នុងព្រះគាថានេះថា ៖-

“**កថញ្ហិ ភគវា តុយ្ហំ សាវកោ សាសនេ រតោ**
**អប្បត្តមានសោ សេខោ កាលំ កយិរា ជនេសុតា**

បពិត្រព្រះមានព្រះភាគ អ្នកប្រាកដក្នុងពពួកជន សាវ័ករបស់ព្រះអង្គ អ្នកត្រេកអរក្នុងព្រះសាសនា នៅមិនសម្រេចព្រះអរហត្ត ជាព្រះសេក្ខបុគ្គល ព្រោះហេតុអ្វី ទើបធ្វើកាលកិរិយា”។

តែក្នុងនិទ្ទេសនេះ **មនោ**នោះឯង ឈ្មោះថា **មានសៈ**, ព្រោះថា ធ្វើ

---

[៤២] ស. ស. ។

បទឱ្យច្រើនដោយព្យញ្ជនៈ ។ ពាក្យថា **ហទយះ** អធិប្បាយថា ទ្រូង, លោកហៅថា ហទយៈ ក្នុងពាក្យថា "យើងនឹងបោះចិត្តរបស់អ្នកទៅ, ឬយើងនឹងពុះហទយៈរបស់អ្នក"[៤៣] នេះ។ ចិត្តហៅថា **ហទយៈ** ក្នុងប្រយោគនេះថា "**ហទយា ហទយំ មញ្ញេ អញ្ញាយ តច្ឆតិ** = កូនជាងឈូសឈើប៉ុនធ្វើរថ តែជាងឈូសឈើដូចដឹងចិត្តដោយចិត្ត *"[៤៤] ; ហទយវត្ថុហៅថា **ហទយៈ** ក្នុងពាក្យនេះថា "**វក្កំ ហទយំ** = ទាច ឬលំពែង និងបេះដូង"[៤៥], តែក្នុងនិទ្ទេសនេះ ចិត្តប៉ុណ្ណោះ ហៅថា **ហទយៈ** ព្រោះអត្ថថា នៅខាងក្នុង ។ ចិត្តនោះឯង ឈ្មោះថា **បណ្ឌរះ** ព្រោះអត្ថថា បរិសុទ្ធ *, ពាក្យថា **បណ្ឌរះ** នេះ សំដៅយកភវង្គចិត្ត; ដូចយ៉ាងដែលត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ

---

[៤៣] ម. មូ.។

* តាមលំនាំច្បាប់ដើមថា កូនជាងធ្វើរថ រមែងឈូសឈើ ។

[៤៤] ទី. ម., ម. មូ. ។

[៤៥] សំ. ស., ខុ. សុ.។

* មូលដិកាថា សូម្បីអកុសល ក៏ឈ្មោះថា បណ្ឌរៈ ចាំបាច់ពោលទៅថ្វីដល់កុសល ។

ចិត្តនេះមានពន្លឺ, ប៉ុន្តែ ចិត្តនោះសៅហ្មងហើយ ដោយឧបក្កិលេសដែលចូលមកថ្មី”[៤៦]; ម្យ៉ាងទៀត សូម្បីអកុសលក៏ត្រាស់ទុកថា **“បណ្ឌរៈ”** ដូចគ្នា ព្រោះចេញចាកចិត្តនោះ ដូចស្ទឹងគង្គាហូរចេញអំពីស្ទឹងគង្គា និងស្ទឹងគោធាវរី ហូរចេញអំពីស្ទឹងគោធាវរីដូច្នោះដែរ ។

ចំណែកសព្ទ**មនោ** ក្នុងទីនេះថា **“មនោ មនាយតនំ”** ព្រះអង្គទ្រង់ត្រាស់ទុកហើយ ដើម្បីសម្ដែងមនោនោះឯងថាជាអាយតនៈ; ដោយពាក្យថា **មនោ មនាយតនំ** នោះ ទើបសម្ដែងបទ **មនោ** នោះថា “**មនោ** នេះឈ្មោះថា **មនាយនៈ** ព្រោះជាអាយតនៈនៃចិត្តនោះឯង ដូចពាក្យថា **ទេវាយតនំ** នេះមិនមែន, តាមពិត អាយតនៈ គឺមនោនោះឯង ឈ្មោះថា **មនាយតនៈ**” ។ ក្នុងពាក្យថា **មនាយតនៈ** នោះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថាអាយតនៈ ព្រោះអត្ថថា ជាទីអាស្រ័យ = **និវាសនដ្ឋានត្ថេន**, ព្រោះអត្ថថា ជាទីបង្កើត = **អាករត្ថេន**, ព្រោះអត្ថថា ជាទីប្រជុំ = **សមោសរណដ្ឋានត្ថេន**,

[៤៦] អំ. ឯក. ។

ព្រោះអត្ថថា កន្លែងកើត = **សញ្ជាតិទេសដ្ឋេន**, ព្រោះអត្ថថា ជាការណៈ (ហេតុ) = **ការណដ្ឋេន** ។

ពិតយ៉ាងនោះ ស្ថានទីនៅក្នុងលោកហៅថា "**អាយតនៈ**" ដូចក្នុងប្រយោគមានអាទិ៍ថា "ទីនៅរបស់ព្រះឥស្សរៈ = **ឥស្សរាយតនំ**, ទីនៅរបស់វាសុទេព = **វាសុទេវាយតនំ**" ទីកើតហៅថា "**អាយតនៈ**" ដូចក្នុងប្រយោគទាំងឡាយមានជាអាទិ៍ថា "អាយតនៈ គឺមាស = **សុវណ្ណាយតនំ**, អណ្តូងកើតរតនៈ = **រតនាយតនំ**" ; តែក្នុងសាសនា ស្ថានទីប្រជុំហៅថា "**អាយតនៈ**" ដូចក្នុងប្រយោគជាដើមថា "កាលស្ថានទីប្រជុំដែលជាទីរីករាយមាន, បក្សីទាំងឡាយនាំគ្នាសេពទីនោះ"[៤៧] ។ កន្លែងកើតហៅថា "អាយតនៈ" ដូចក្នុងប្រយោគមានអាទិ៍ថា "ទក្ខិណាបថ ជាកន្លែងកើតរបស់គោទាំងឡាយ" ។ ការណៈហៅថា "អាយតនៈ" ដូចក្នុងប្រយោគជាដើមថា "លោករមែងដល់អំណាចក្នុងធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់... ក្នុង

---

[៤៧] អំ. បញ្ចក. (សទ្ធសូត្រ) ។

ទីនោះៗមែន ក្នុងកាលបើហេតុនៃសតិមាន” [៤៨] ។ ក៏ប៉ុន្តែក្នុងទីនេះ គួរទាំង ៣ អត្ថ គឺឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាកន្លែងកើត, ព្រោះអត្ថថា ជាស្ថានទីប្រជុំ និងព្រោះអត្ថថា ជាការណៈ (ហេតុ) ។

ពិតមែន ធម៌មានផស្សៈជាដើម កើតព្រមគ្នាក្នុង**មនៈ**នេះ ព្រោះហេតុនោះ មនៈនេះទើបឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា ជាកន្លែងកើត ។ រូបសំឡេងក្លិនរសផោដ្ឋព្វៈខាងក្រៅ ប្រជុំចុះក្នុងមនៈនេះ ដោយភាវៈនៃអារម្មណ៍ ព្រោះហេតុនោះ **មនៈ**នេះ ទើបឈ្មោះថា **អាយតនៈ** សូម្បីដោយអត្ថថា ជាស្ថានទីប្រជុំ ។ ក៏**មនៈ**នេះ គប្បីជ្រាបថាជាអាយតនៈ ព្រោះអត្ថថា ជាបច្ច័យនៃផស្សៈជាដើម មានសហជាតប្បច្ច័យជាដើមខ្លះ, ដោយអត្ថថាជាហេតុ ព្រោះជាការណៈខ្លះ, មនិន្ទ្រិយមានអត្ថ តាមដែលពោលមកហើយនោះឯង ។

ធម្មជាតដែលឈ្មោះថា **វិញ្ញាណ** ព្រោះរមែងដឹងច្បាស់, ខន្ធ គឺវិញ្ញាណនោះឯង ហៅថា **វិញ្ញាណក្ខន្ធ**; គប្បីជ្រាបអត្ថនៃវិញ្ញាណក្ខន្ធនោះ

---

[៤៨] ទី. ម. ។

ដោយអំណាចនៃគំនរជាដើម ។

ពិតណាស់ ខន្ធដែលព្រះមានព្រះភាគត្រាស់ទុកដោយគំនរ ក្នុងព្រះបាលីនេះថា "ទឹកក្នុងមហាសមុទ្រ រាប់ថាជាគំនរ( ធារ)ទឹកធំ" [៤៩] ។ ខន្ធត្រាស់ដោយអត្ថថា គុណ ដូចក្នុងប្រយោគជាដើមថា "គុណ គឺសីលគុណ គឺសមាធិគុណ" [៥០] ។ ខន្ធត្រាស់ដោយអត្ថថា គ្រាន់តែបញ្ញត្តិ ដូចក្នុងប្រយោគនេះថា "ព្រះភគវាទ្រង់បានឃើញហើយនូវកំណាត់ឈើធំ" [៥១]។ តែក្នុងវិញ្ញាណក្ខន្ធនេះ ត្រាស់ខន្ធ**នេះ ដោយរុឡ្ហី**សព្ទ (គឺតាមដែលយល់); ព្រោះថា ចំណែកនៃវិញ្ញាណក្ខន្ធ ហៅថា វិញ្ញាណមួយដួង ព្រោះអត្ថថាជាកង; ព្រោះហេតុដូច្នោះ វិញ្ញាណមួយដួង ដែលជាចំណែកមួយនៃវិញ្ញាណក្ខន្ធលោកក៏ហៅថា វិញ្ញាណក្ខន្ធ តាមដែលដឹងគ្នា ដូចមនុស្សកាត់ចំណែកមួយនៃដើមឈើ លោកក៏ហៅថា កាត់ដើមឈើដូច្នោះ ។

---

[៤៩] អំ. ចតុក្ក. ។

[៥០] ទី. បា. ។

[៥១] ស. សឡា. ។

ពាក្យថា **“តជ្ជាមនោវិញ្ញាណធាតុ”** បានដល់ មនោវិញ្ញាណធាតុ ដែលសមគួរដល់ធមិ មានផស្សៈជាដើមនោះ ។ ពិតមែន ក្នុងបទនេះ ចិត្ត មួយដួងប៉ុណ្ណោះ លោកពោលឈ្មោះទុក ៣ យ៉ាង គឺឈ្មោះថា **មនោ** ព្រោះ អត្ថថា កំណត់អារម្មណ៏= **មននដ្ឋេន**, ឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា ដឹង ច្បាស់ = **វិជាននដ្ឋេន**, ឈ្មោះថា ធាតុ ព្រោះអត្ថថា ជាសភាវៈ = **សភាវដ្ឋេន**, ឬព្រោះអត្ថថា មិនមែនសត្វ = **និស្សត្តដ្ឋេន** ។

ក្នុងពួក ៥ នៃផស្សៈនេះ តាមដែលពោលមកហើយ ពោលផស្សៈមុន ព្រោះជាផស្សៈប៉ុណ្ណោះ, មិនមែនផស្សៈដែលកើតដោយសម្ផស្ស ដែលជា តជ្ជាមនោវិញ្ញាណធាតុ និងព្រោះចិត្តជាតជ្ជាវិញ្ញាណធាតុប៉ុណ្ណោះ, ព្រោះ ហេតុដូច្នោះ ព្រះអង្គទើបមិនទ្រង់លើកបញ្ញត្តិថា ជាតជ្ជាវិញ្ញាណធាតុ- សម្ផស្សជា ក្នុងពីរបទនេះទេ; ក៏ប៉ុន្តែប្រើក្នុងបទវិតក្កៈជាដើមបានខ្លះ មិន លើកឡើងប្រែក្នុងនិទ្ទេសនេះ ព្រោះមិនបានកំណត់ទុក ។

ម្យ៉ាងទៀត ព្រះមានព្រះភាគកាលទ្រង់ចែកធមិពួក ៥ នៃផស្សៈពួក នេះ ចែកជាមួយផ្នែក១ ហើយលើកឡើងកាន់បញ្ញត្តិ ឈ្មោះថា ធ្វើវត្ថុដែល

គេធ្វើដោយលំបាក ។ មែនហើយ កាលបុគ្គលដាក់ទឹកផ្សេងៗ ប្រេងផ្សេងៗ ចុះក្នុងភាជនៈមួយហើយកូរអស់មួយថ្ងៃ ការឃើញពណ៌ ឬការហិតក្លិន ឬថាការលិទ្ធរស ក៏អាចដឹងការផ្សេងគ្នាបាន ព្រោះការផ្សេងគ្នានៃពណ៌ ក្លិន និងរស, សូម្បីយ៉ាងនោះគេក៏និយាយគ្នាថា ការធ្វើនោះ ជាការធ្វើបានដោយកម្រ; តែព្រះសម្មាសម្ពុទ្ធ កាលចែកធម៌ គឺចិត្ត និងចេតសិក ដែលមិនមែនរូបនេះ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍មួយ ធ្វើឱ្យជាមួយផ្នែកៗ ហើយទ្រង់លើកឡើងកាន់បញ្ញត្តិ ឈ្មោះថា ទ្រង់ធ្វើបានដោយលំបាកក្រៃលែង ។ ព្រោះហេតុនោះ **ព្រះនាគសេនត្ថេរមានអាយុ** ទើបថ្វាយព្រះពរព្រះ**បាទមិលិន្ទ**ថា "បពិត្រមហារាជ ព្រះភគវាទ្រង់ធ្វើវត្ថុដែលគេធ្វើបានដោយលំបាក" ។

**ព្រះបាទមិលិន្ទ** : ព្រះនាគសេនដ៏ចម្រើន ព្រះភគវាធ្វើអ្វី ដែលគេធ្វើបានដោយលំបាក?

**ព្រះនាគសេន** : មហាបពិត្រ ព្រះភគវាទ្រង់ធ្វើ គឺប្រាប់ការកំណត់ធម៌ គឺចិត្ត និងចេតសិក ដែលមិនមែនរូបនេះ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ដូចគ្នាថា "នេះជាផស្សៈ, វេទនា, សញ្ញា, ចេតនា និងចិត្ត" ។

**ព្រះបាទមិលិន្ទ** ៖ សូមលោកម្ចាស់ឧបមាឱ្យស្តាប់មកមើល !

**ព្រះនាគសេន** ៖ មហាបពិត្រ ឧបមាដូចមនុស្សខ្លះ ឆ្លងសមុទ្រដោយនាវា ហើយយកដៃក្បង់ទឹក លិទ្ធមើលដោយអណ្តាត ក៏គប្បីជ្រាបឬទេថា "នេះទឹកស្ទឹងគង្គា, ទឹកស្ទឹងយមុនា, ទឹកស្ទឹងអចិរវតី, ទឹកស្ទឹងសរភូ, នេះទឹកស្ទឹងមហី"?

**ព្រះបាទមិលិន្ទ** ៖ បពិត្រលោកម្ចាស់នាគសេន ដឹងបានដោយលំបាក

**ព្រះនាគសេន** ៖ បពិត្រមហារាជ ការដែលព្រះមានជោគត្រាស់ប្រាប់ការកំណត់ធម៌ គឺចិត្ត និងចេតសិកដែលមិនមែនរូបប្រព្រឹត្តទៅក្នុងអារម្មណ៍ដូចគ្នាថា នេះជាផស្សៈ ។ល។ នេះជាចិត្ត ឈ្មោះថា ទ្រង់ធ្វើវត្ថុ ដែលគេធ្វើបានដោយលំបាកជាងនោះពេកណាស់ [៥២] ៕

---

[៥២] មិលិន្ទ. ។

## អធិប្បាយវិតក្កនិទ្ទេសជាដើម

ក្នុងនិទ្ទេសនៃវិតក្កៈ ធម៌ដែលឈ្មោះថា **តក្កៈ** ព្រោះត្រិះរិះ, បណ្ឌិតគប្បីជ្រាបការប្រព្រឹត្តទៅ នៃធម៌ដែលឈ្មោះថា **តក្កៈ** នោះ ដោយអំណាចនៃការត្រិះរិះយ៉ាងនេះថា "លោកត្រិះរិះដល់អ្វី? លោកត្រិះរិះដល់ក្អម, ត្រិះរិះដល់រទេះ, ត្រិះរិះដល់យោជន៍, ត្រិះរិះដល់កន្លះយោជន៍" ; នេះជាបទសម្ដែងសភាវៈនៃការត្រិះរិះ ។ ធម៌ដែលឈ្មោះថា **វិតក្កៈ** ព្រោះអំណាចនៃការត្រិះរិះវិសេស (ផ្សេងៗ); ពាក្យថា **វិតក្កៈ** នេះ ជាឈ្មោះនៃការត្រិះរិះមានកម្លាំងច្រើនជាង ។ ឈ្មោះថា **សង្កប្បៈ** ព្រោះការកំណត់យ៉ាងល្អ, ឯកគ្គតាចិត្ត ឈ្មោះថា **អប្បនា** ព្រោះនែបនិតក្នុងអារម្មណ៍ ។ បទទី ២ ទ្រង់បន្ថែមឡើងដោយអំណាចនៃឧបសគ្គ, ម្យ៉ាងទៀត អប្បនាមានកម្លាំងជាងឈ្មោះថា **ព្យប្បនា** ។ ធម្មជាតដែលឈ្មោះថា **ការលើកចិត្តឡើង** ព្រោះលើកចិត្ត គឺតាំងចិត្តទុកក្នុងអារម្មណ៍ ។ ធម៌ដែលឈ្មោះថា **សម្មាសង្កប្បៈ** ព្រោះជាសង្កប្បៈ (ត្រិះរិះ) ដែលព្រះមានព្រះភាគទ្រង់សរសើរដល់ភាវៈជាកុសល ព្រោះជាការត្រិះរិះ តាមសេចក្ដីពិត និងជាការត្រិះរិះនាំសត្វចេញ

ចាកវដ្តៈ ។

**ក្នុងនិទ្ទេសនៃវិចារៈ** ធម៌ដែលឈ្មោះថា **ចារៈ** ព្រោះត្រាច់ទៅក្នុងអារម្មណ៍; បទនេះជាបទសម្តែងរបស់សភាវៈនៃចារៈនោះ ។ ក៏ឈ្មោះថា **វិចារៈ** ព្រោះត្រាច់ទៅវិសេស (ផ្សេងៗ); ឈ្មោះថា **អនុវិចារៈ** ព្រោះតាមត្រាច់ទៅ, ឈ្មោះថា **ឧបវិចារៈ** ព្រោះត្រាច់ទៅជិត ។ បទទាំងឡាយនេះលោកបន្ថែមមកដោយអំណាចឧបសគ្គ ។ ធម៌ដែលឈ្មោះថា ការតចិត្តព្រោះការតតាំងចិត្តទុកក្នុងអារម្មណ៍ ដូចការបំពាក់ព្រួញត្រង់ខ្សែធ្នូ ។ ធម៌ដែលឈ្មោះថា **ការចូលទៅសំឡឹង** ព្រោះតាំងនៅ ដូចការសំឡឹងមើលអារម្មណ៍ ។

**ក្នុងនិទ្ទេសនៃបីតិ** បទថា **"បីតិ"** ជាបទសម្តែងភាវៈ, ភាវៈនៃបុគ្គលអ្នករីករាយហើយ ឈ្មោះថា **បាមោជ្ជៈ**; អាការនៃការសប្បាយ ឈ្មោះថា **អាមោទនា**; អាការដែលស្រួលឈ្មោះថា **បមោទនា**; ការរួមគ្នានៃថ្នាំ ឬប្រេង ឬក៏ទឹកក្តៅ និងទឹកត្រជាក់ចូលគ្នា លោកហៅថា **"មោទនា"** យ៉ាងណា, សូម្បីបីតិនេះ ក៏យ៉ាងនោះដែរ; ឈ្មោះថា **មោទនា** ព្រោះរួមធម៌ទាំង

ឡាយចូលគ្នា, តែព្រះមានព្រះភាគទ្រង់ប្រដាប់ពាក្យមោទនា ដោយឧបសគ្គ ហើយត្រាស់ថា **“អាមោទនា និងបមោទនា”** ; ធម៌ដែលឈ្មោះថា **ហាសះ** ព្រោះស្រស់ស្រាយ; ធម៌ដែលឈ្មោះថា **បហាសះ** ព្រោះរីករាយ, ពាក្យថា **ហាសះ** និង **បហាសះ** នេះ ជាឈ្មោះរបស់អាការដែលស្រស់ស្រាយ និងត្រេកអរ; ធម៌ដែលឈ្មោះថា **វិត្តះ** ព្រោះឆ្អែតចិត្ត, ពាក្យថា **“វិត្តះ”** នេះ ជាឈ្មោះនៃទ្រព្យ; ក៏សេចក្តីឆ្អែតចិត្តនេះ ឈ្មោះថា **វិត្តិ** ព្រោះជាបច្ច័យឱ្យកើតសោមនស្ស ព្រោះដូចនឹងសេចក្តីឆ្អែតចិត្តដែរ; ដូចយ៉ាងថា មនុស្សមានទ្រព្យ អាស្រ័យទ្រព្យ កើតសោមនស្ស យ៉ាងណា, អ្នកមានបីតិ ក៏អាស្រ័យបីតិ កើតសោមនស្ស ឡើងយ៉ាងនោះ ; ព្រោះហេតុដូច្នោះ ទើបហៅបីតិថា **“វិត្តិ”** , ពាក្យថា **វិត្តិ** នេះ ជាឈ្មោះនៃបីតិ ដែលស្ថិតនៅដោយសភាវៈនៃការត្រេកអរ ។ ក៏បុគ្គលមានបីតិ ត្រាស់ហៅថា **“ឱទគ្គះ”** ព្រោះការអណ្តែតឡើងនៃកាយ និងចិត្ត គឺការអណ្តែតឡើងខ្ពស់នៃកាយ និងចិត្ត ។ ភាវៈនៃអ្នកដែលមានកាយ និងចិត្តខ្ពស់ឡើង ហៅថា **ឱទគ្គះ** ភាពជាអ្នកមានចិត្តជារបស់ខ្លួន ឈ្មោះថា **អត្តមនតា**; ពិតមែន ចិត្តរបស់

បុគ្គលអ្នកមិនត្រេកអរ (ក្រោធ) មិនឈ្មោះថា ជាចិត្តរបស់ខ្លួនទេ ព្រោះជាហេតុនៃទុក្ខ ។ ម្យ៉ាង បុគ្គលត្រេកអរហើយ ក៏ឈ្មោះថា មានចិត្ត ជារបស់ខ្លួន ព្រោះជាហេតុឱ្យកើតសុខ ។ ដោយហេតុតាមដែលពោលមកនេះ ភាពជាអ្នកមានចិត្តជារបស់ខ្លួន ទើបឈ្មោះថា **អត្តមនតា** គឺចិត្តជារបស់ខ្លួន, អធិប្បាយថា បុគ្គលជាអ្នកមានចិត្តជារបស់ខ្លួន; ក៏ព្រោះសេចក្ដីត្រេកអរនោះមិនមែនជារបស់អ្នកដទៃទេ ព្រោះភាពជាអ្នកមានចិត្តជារបស់ខ្លួនឯង, គឺសភាវៈនោះជារបស់ចិត្តនោះឯង; ម្យ៉ាងទៀត អ្នកមានចិត្តជារបស់ខ្លួននោះមិនមែនជាធម៌ដទៃ គឺមិនមែនជាចេតសិកធម៌, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា **"ភាពជាអ្នកមានចិត្តជារបស់ខ្លួន គឺចិត្ត"** ។

**ក្នុងនិទ្ទេសនៃចិត្តស្សេកគ្គតា** ធម្មជាតិដែលឈ្មោះថា **ឋិតិ** ព្រោះតាំងមាំ ក្នុងអារម្មណ៍ដែលមិនញាប់ញ័រ ។ ពីរបទខាងមុខ លោកបន្ថែមឧបសគ្គចូលមក ។ ម្យ៉ាងទៀត ដែលឈ្មោះថា **សណ្ឋិតិ** ព្រោះប្រមូលសម្បយុត្តធម៌ទាំងឡាយតាំងទុកក្នុងអារម្មណ៍ ។ ដែលឈ្មោះថា **អវដ្ឋិតិ** ព្រោះចុះកាន់អារម្មណ៍ គឺចូលទៅតាមហើយតាំងនៅ ។ ព្រោះថា ធម៌ទាំង ៤

គឺសទ្ធា, សតិ, សមាធិ និងបញ្ញា រមែងឈានចុះកាន់អារម្មណ៍ គឺប្រាកដខាងក្នុងកុសល ។ ដោយហេតុនោះឯង ធម៌ គឺសទ្ធា ទើបព្រះអង្គត្រាស់ថា “**ឱកប្បនា** = ការធ្វើចិត្តឱ្យជឿស៊ប់” , ត្រាស់ហៅសតិថា “**អបិលាបនតា** = ភាពជាអ្នកមានចិត្តមិនរេរ៉ម៉ាម” , ត្រាស់ហៅសមាធិថា “**អវដ្ឋិតិ** = ការតាំងចិត្តមាំ”; ត្រាស់ហៅបញ្ញាថា “**បរិយោគាហនា** = ការឆ្លុះមើល” ។

ចំណែកខាងក្នុងអកុសលធម៌ ៣ យ៉ាង គឺតណ្ហា, ទិដ្ឋិ និងអវិជ្ជា តែងឈានចុះកាន់អារម្មណ៍, ដោយហេតុនោះឯង ធម៌ទាំងឡាយនោះ ព្រះអង្គទើបត្រាស់ថា “ជាឱឃៈ” ; តែខាងអកុសលនេះ ឯកគ្គតានៃចិត្ត មិនជាសភាពមានកម្លាំង, ប្រៀបដូចបុគ្គលយកទឹកស្រោចទីមានធូលី ស្ថានទីក៏គ្មានធូលី ធូលីរមែងរំងាប់ទៅមួយភ្លែត, កាលធូលីស្ងួត ធូលីក៏តាំងឡើង (ហុយ) ជាប្រក្រតីទៀត យ៉ាងណា, ខាងអកុសល ឯកគ្គតានៃចិត្តមិនមានកម្លាំងច្រើន ក៏យ៉ាងនោះដែរ; ប្រៀបដូចបុរសយកក្អម (ឬឆ្នាំង) ស្រោចទឹកចុះក្នុងទីនោះ ហើយជីកដោយចប ធ្វើការជំ ញាំញី ផាត់ពណិ វីលាប ឱ្យប្រាកដដូចស្រមោល កាលប្រាកដក្នុងកញ្ចក់, កាលបើកន្លងទៅរយឆ្នាំ ក៏ជា

របស់វិចិត្រមួយរំពេចដូច្នោះ យ៉ាងណា ក្នុងចំណែកកុសល ឯកគ្គតានៃចិត្តជាធម្មជាតមានកម្លាំង ក៏យ៉ាងនោះដែរ ។

ធម៌ដែលឈ្មោះថា **អវិសាហារៈ** ព្រោះជាសត្រូវនឹងការរវើរវាយដែលប្រព្រឹត្តទៅដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆា, ចិត្តដែលប្រព្រឹត្តទៅដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆា ឈ្មោះថា រវើរវាយ, តែការរវើរវាយនេះ ដូចយ៉ាងនោះមិនមាន ព្រោះហេតុនោះ សភាវៈនោះទើបឈ្មោះថា **អវិក្ខេបៈ** ។ ចិត្តដែលឈ្មោះថា រវើរវាយទៅដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆាប៉ុណ្ណោះ, គឺឧទ្ធច្ចៈ និងវិចិកិច្ឆា នាំទៅផ្លូវនេះ និងផ្លូវនោះបាន, តែអវិក្ខេបៈនេះ ជាសភាវៈនៃចិត្ត ដែលមិនរាយមាយដោយអាការយ៉ាងនោះ ព្រោះហេតុនោះទើបឈ្មោះថា ភាពជាអ្នកមានចិត្តមិនរាយមាយ = **អវិសាហដមានសតា** ។

ពាក្យថា “**សមថៈ**” បានដល់ សមថៈ ៣ យ៉ាង គឺ

- **ចិត្តសមថៈ** ស្ងប់ចិត្ត
- **អធិករណសមថៈ** ស្ងប់អធិករណ៍

៳**សព្វសង្ខារសមថៈ** ស្ងប់ក្នុងសង្ខារទាំងអស់ ។

បណ្ដាសមថៈទាំង ៣ នោះ ឯកគ្គតានៃចិត្ត (ចិត្តទៀងទាត់) ក្នុងសមាបត្តិ ៨ ឈ្មោះថា ចិត្តសមថៈ; ពិតណាស់ ព្រោះអាស្រ័យចិត្តសមថៈនោះ ការកម្រើកនៃចិត្ត ការញាប់ញ័រ រមែងស្ងប់ គឺចូលទៅរំងាប់; ព្រោះហេតុដូច្នោះ សមថៈនោះ ទើបត្រាស់ហៅថា "**ចិត្តសមថៈ**" ។ សមថៈ ៧ មានសម្មុខាវិន័យជាដើម ឈ្មោះថា អធិករណសមថៈ ។ ព្រោះអាស្រ័យអធិករណសមថៈនោះ អធិករណ៍នោះ រមែងស្ងប់ គឺរំងាប់, ព្រោះហេតុដូច្នោះ សមថៈនោះ ទើបត្រាស់ហៅថា "**អធិករណសមថៈ**" ។ មួយទៀត សង្ខារទាំងអស់អាស្រ័យព្រះនិព្វានចូលទៅរំងាប់ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះនិព្វាននោះ ព្រះអង្គទើបត្រាស់ហៅថា "**សព្វសង្ខារសមថៈ**" ។ ក្នុងអត្ថនេះ ទ្រង់ប្រាថ្នាយកចិត្តសមថៈ; ចិត្តសមថៈនោះ ឈ្មោះថា **សមាធិន្ទ្រិយ** ព្រោះភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណៈនៃសមាធិ ។ ដែលឈ្មោះថា **សមាធិពលៈ** ព្រោះការមិនញាប់ញ័រទៅក្នុងឧទ្ធច្ចៈ; សមាធិតាមការពិត ឈ្មោះថា **សម្មាសមាធិ**, សមាធិខាងកុសល ឈ្មោះថា **និយ្យានិកសមាធិ** =

សមាធិដែលនាំចេញ ។

**ក្នុងនិទ្ទេសនៃសទ្ធិន្ទ្រិយ** ធម៌ដែលឈ្មោះថា **សទ្ធា** ព្រោះការជឿពុទ្ធគុណជាដើម, ម្យ៉ាងទៀត ឈ្មោះថា **សទ្ធា** ព្រោះជឿ គឺប្រព្រឹត្តទៅកាន់រតនៈមានពុទ្ធរតនៈជាដើម ។ អាការនៃការជឿ ឈ្មោះថា **សទ្ទហនា** ។ ដែលឈ្មោះថា **ឱកប្បនា** (បង្អោនចិត្តជឿមាំ) ព្រោះឈានចុះ ដូចការទម្លាយហើយជ្រៀតចូលទៅក្នុងពុទ្ធគុណជាដើម ។ ដែលឈ្មោះថា **អភិបសាទ** (ជ្រះថ្លាខ្លាំង) ព្រោះជាហេតុឱ្យសត្វទាំងឡាយជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះពុទ្ធគុណជាដើម, ឬខ្លួនឯងរមែងជ្រះថ្លាយ៉ាងក្រៃលែង ។ ឥឡូវនេះព្រោះព្រះមានព្រះភាគ ត្រាទ្រង់ប្រារព្ធបរិយាយដទៃ ដោយបទសមាស (ការបំប្រួញ) នៃសិទ្ធិន្ទ្រិយជាដើម ទើបទ្រង់កាន់យកបទថា **អាទិ** មកធ្វើការចែកបទ, សេចក្តីនេះ ជារឿងធម្មតាក្នុងព្រះអភិធម្ម ព្រោះហេតុដូច្នោះទើបទ្រង់ត្រាស់ពាក្យថា **“សទ្ធា”** ទៀត ។ ម្យ៉ាងទៀត ឥន្ទ្រិយនៃស្ត្រីហៅថា ឥត្ថិន្ទ្រិយ យ៉ាងណា, សទ្ធិន្ទ្រិយនេះ យ៉ាងនោះ មិនមាន ។ ក៏ឥន្ទ្រិយនេះ គឺសទ្ធាប៉ុណ្ណោះ ទើបឈ្មោះថា សទ្ធិន្ទ្រិយ ដោយអាការយ៉ាងនេះ

ទើបត្រាស់ថា **"សទ្ធា"** ដូច្នេះទៀត ដើម្បីឱ្យដឹងសភាវៈដែលធ្វើឱ្យក្រៃលែងជាង ។ ក្នុងទំនងដូចគ្នានេះ គប្បីជ្រាបការប្រកបពាក្យសម្រាប់បទថា **អាទិ** ក្នុងនិទ្ទេសនៃបទទាំងពួងទៀត ។ ធម្មជាតដែលឈ្មោះថា **សទ្ធិន្ទ្រិយ** ព្រោះធ្វើភាវៈជាធំ ក្នុងលក្ខណៈនៃអធិមោក្ខ (ការបង្អោនចិត្តជឿ); ដែលឈ្មោះថា **សទ្ធាពលៈ** ព្រោះការមិនញាប់ញ័រក្នុងភាពមិនមែនសទ្ធា ។

**ក្នុងនិទ្ទេសនៃវីរិយិន្ទ្រិយ** ពាក្យថា **"ចេតសិកោ"** នេះ ពោលដើម្បីសម្ដែងដល់វីរិយៈ ជាចេតសិកដោយនិយម, មែនហើយ វីរិយៈនេះ សូម្បីពោលហើយថា "ជាកាយិកៈ" គឺប្រព្រឹត្តទៅផ្លូវកាយ ព្រោះកើតឡើងដល់បុគ្គលអ្នកដើរចង្ក្រមជាដើម ក្នុងសូត្រទាំងឡាយមានជាអាទិ៍ថា "ម្នាលភិក្ខុទាំងឡាយ សូម្បីវីរិយៈណា ប្រព្រឹត្តទៅតាមផ្លូវកាយ, សូម្បីវីរិយៈនោះ ក៏ជាវីរិយសម្ពោជ្ឈង្គ; សូម្បីវីរិយៈណា ប្រព្រឹត្តទៅតាមផ្លូវចិត្ត, សូម្បីវីរិយៈនោះ ក៏ជាវីរិយសម្ពោជ្ឈង្គៈ; មែនពិត វីរិយៈនេះ តែងមកកាន់ឧទ្ទេសដោយ

ប្រការដូច្នេះ”[៥៣] ។ តែមិនប្រព្រឹត្តទៅផ្លូវកាយវិញ្ញាណទេ, ក៏ដើម្បីសម្ដែងថា វីរិយៈនោះ ប្រព្រឹត្តទៅផ្លូវចិត្តតែម្យ៉ាង ទើបត្រាស់ថា **“ចេតសិកោ** = ជាចេតសិក” ។ ពាក្យថា **“វីរិយារម្ភោ”** បានដល់ ការប្រារព្ធគឺព្យាយាម ។ ដោយបទថា **វីរិយារម្ភោ** នេះ លោកបដិសេធការប្រារព្ធសេចក្ដីព្យាយាមដែលសល់ក្រៅពីនេះ ។ មែនហើយ **អារម្ភ**សព្ទនេះ មកក្នុងអត្ថជាអនេក គឺ **កម្ម**, **អាបត្តិ**, **កិរិយា**, **វីរិយៈ**, **ហឹសា** = ការបៀតបៀន និង **វិកោបនៈ** = ការផ្ដាច់ផ្ដិល ។

ពិតណាស់ កម្មមកក្នុងពាក្យថា **“អារម្ភៈ”** ដូចក្នុងប្រយោគនេះថា ៖-

**“យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អារម្ភបច្ចយា**

**អារម្ភានំ និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ ។**

**ទុក្ខទាំងអស់យ៉ាងណាមួយកើត ព្រោះកម្មជាបច្ច័យ ព្រោះកម្ម**

---

[៥៣] សី. ម. ។

**រលត់ដោយមិនសល់ ទុក្ខរមែងមិនកើតឡើង”**[៥៤] ។

អាបត្តិមកក្នុងពាក្យថា **អារម្ភ** ក្នុងប្រយោគនេះថា “ភិក្ខុត្រូវអាបត្តិ នឹងជាអ្នកមានវិប្បដិសារី” [៥៤]។ កិរិយាមានការបោះបង្គោលបូជាយញ្ញ មកក្នុងពាក្យថា **អារម្ភៈ** ក្នុងប្រយោគនេះថា “មហាយញ្ញមានកិរិយាធំ, មានតែមហាយញ្ញនោះ មិនមានផលទេ” [៥៥]។ វីរិយៈក្នុងពាក្យថា **អារម្ភ** ក្នុងប្រយោគនេះថា “អ្នកទាំងឡាយចូរប្រឹងប្រែង, ចូរព្យាយាម, អ្នកទាំងឡាយចូរខ្វល់ខ្វាយក្នុងព្រះពុទ្ធសាសនា” [៥៦]។ ការបៀតបៀនមកក្នុងពាក្យថា **អារម្ភ** ក្នុងប្រយោគនេះថា “ជនទាំងឡាយបៀតបៀនសត្វឧទ្ទិស ព្រះសមណគោតម” ។ ការផ្តាច់ផ្តិលមានការកាត់ និងកាច់ជាដើម មកក្នុង

---

[៥៤] ខុ. សុ.។

[៥៤] អំ. បញ្ចក. (អារភតិសូត្រ), អភិ.។

[៥៥] សំ. ស., អំ. ចតុក្ក.។

[៥៦] ម. ម. ។

[៥៧] ទី. សី., ម. មូ. ។

អារម្ភៈ ក្នុងប្រយោគនេះថា “ព្រះសមណគោតម វៀរចាកដាច់ខាតពីការផ្តាច់ផ្តិលពីជគាម និងភូតគាម”[៥៧] ។ តែក្នុងនិទ្ទេសនេះ លោកបំណងយកវីរិយៈប៉ុណ្ណោះ, ព្រោះហេតុនោះ ទើបត្រាស់ថា **“វីរិយារម្ភោ**, អធិប្បាយថា អារម្ភៈ គឺការព្យាយាម” ។ មែនហើយ **វីរិយៈ** លោកត្រាស់ហៅថា “អារម្ភៈ” ព្រោះអំណាចនៃការស្រស់ស្រាយ; ពាក្យថា “**អារម្ភោ**” នេះ ជាបទសម្តែងសភាវៈរបស់វីរិយៈ ។ សភាវៈដែលឈ្មោះថា **និក្កមៈ** ដោយអំណាចនៃការចេញចាកការខ្ជិលច្រអូស ។ ដែលឈ្មោះថា **បរក្កមៈ**[៥៨] ដោយអំណាចនៃការឈានទៅកាន់ប្រយោជន៍យ៉ាងក្រៃលែងខាងមុខ ។ ដែលឈ្មោះថា **ឧយ្យាមៈ** ដោយអំណាចនៃការព្យាយាមចូលដល់ ។ ដែលឈ្មោះថា **វាយាមៈ** ដោយអំណាចនៃការឱបាត ។ ដែលឈ្មោះថា **ឧស្សាហៈ** ដោយអំណាចនៃការអត់ធន់ ។ ដែលឈ្មោះថា **ឧស្សោឡ្ហី** ដោយអំណាចនៃការឧស្សាហ៍យ៉ាងក្រៃលែង ។ ដែលឈ្មោះថា **ថាមៈ** ដោយសេចក្តីថា មាំ

---

[៥៨] ច្បាប់ខ្លះថា និក្ខម. ។

ទាំ ។ ដែលឈ្មោះថា **ធីតិ** ព្រោះទ្រទ្រង់ទុកនូវការតកុសល ដោយអំណាចនៃការទ្រទ្រង់ទុកនូវចិត្ត និងចេតសិកទាំងឡាយ ឬការប្រព្រឹត្តទៅ ដោយមិនដាច់ខ្សែ ។

ន័យមួយទៀត ក៏សភាវៈនោះ ឈ្មោះថា **និក្ខមៈ** ព្រោះអត្ថថា បន្ទោបង់នូវកាមទាំងឡាយ, ឈ្មោះថា **បរក្កមៈ** ព្រោះអត្ថថា កាត់គ្រឿងចងពន្ធ, ឈ្មោះថា **ឧយ្យាមៈ** ព្រោះអត្ថថា ការដកឱយៈ, ឈ្មោះថា **វាយាមៈ** ព្រោះអត្ថថា ដល់ត្រើយ, ឈ្មោះថា **ឧស្សាហៈ** ព្រោះអត្ថថា ជាប្រធាន, ឈ្មោះថា **ឧស្សោឡ្ហី** ព្រោះអត្ថថា ជាប្រធានធំ, ឈ្មោះថា **ធីតិ** ព្រោះអត្ថថា ធ្វើបានតាមត្រូវការ ។

វិរិយៈនោះ ក៏គឺការឧស្សាហ៍មិនរួញរា ដោយអំណាចនៃការមិនរាថយក្នុងបវត្តិកាលយ៉ាងនេះថា "សល់តែស្បែក សរសៃ និងឆ្អឹង ក៏ដោយ" [៥៩], អធិប្បាយថា ការឧស្សាហ៍មាំទាំ ការឧស្សាហ៍ខ្ជាប់ខ្ជួន ។ ក៏វិរិយៈនេះ មិន

---

[៥៩] ម. ម., សំ. និ. ។

ដាក់ឆន្ទៈ, មិនដាក់ធុរៈ, មិនឱ្យសេចក្តីខ្ជិលបានឱកាស, មិនលះសេចក្តីពេញចិត្ត, មិនរាថយក្នុងឋានជាគ្រឿងសាងកុសលកម្ម, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា "វិរិយៈមិនដាក់ឆន្ទៈ, មិនដាក់ធុរៈ" ។

ដូចយ៉ាងថា ក្នុងស្ថានទីមានភក់តាមធម្មជាតិ ម្ចាស់របស់គោពោលថា "ពួកអ្នកចូរយកគោដែលនាំធុរៈទៅបានមក, គោនោះ សូម្បីលុតជង្គង់ជ្រែងជើងលើផែនដី ក៏ស៊ូនាំទៅនូវនឹម, គឺមិនព្រមឱ្យនឹមធ្លាក់លើផែនដី យ៉ាងណា, វិរិយៈក៏យ៉ាងនោះដែរ មិនដាក់ចោល ផ្គងធុរៈទៅក្នុងឋានជាគ្រឿងសាងកុសលកម្ម, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា "វិរិយៈជាធមិផ្គងធុរៈយ៉ាងល្អ = **ធុរសម្បគ្គាហោ**" ។ ធមិដែលឈ្មោះថា **វីរិយិន្ទ្រិយ** ព្រោះគ្រងភាពជាធំក្នុងលក្ខណៈនៃការប្រុងប្រៀប ។ ដែលឈ្មោះថា **វីរិយពលៈ** ព្រោះមិនញាប់ញ័រក្នុងការខ្ជិលច្រអូស ។ ដែលឈ្មោះថា **សម្មាវាយាមៈ** ព្រោះការព្យាយាមក្នុងកុសលដែលនាំចេញចាកសង្សារវដ្តតាមសេចក្តីពិត ។

**ក្នុងនិទ្ទេសនៃសតិន្ទ្រិយ** ធម្មជាតដែលឈ្មោះថា **សតិ** ដោយអំណាចនៃការរឭក ។ ការរឭកនេះជាបទសម្តែងសភាវៈរបស់សតិ ។ ដែលឈ្មោះថា

**អនុស្សតិ** ដោយអំណាចនៃការតាមរឭក ព្រោះរឭករឿយៗ ។ ឈ្មោះថា **បដិស្សតិ** ដោយអំណាចនៃការរឭកចំពោះ ព្រោះការរឭក ដូចទៅតាមខាងមុខ ។ ម្យ៉ាងទៀត ពាក្យដែលពោលហើយនេះ គ្រាន់តែបន្ថែមដោយឧបសគ្គ ។ អាការដែលរឭកឈ្មោះថា **សរណតា** ក៏ព្រោះពាក្យថា “សរណតា” ជាឈ្មោះនៃការរឭកទាំង ៣, ព្រោះហេតុដូច្នោះ ដើម្បីបដិសេធពាក្យដែលជាឈ្មោះទាំង ៣ នោះ ទើបធ្វើ **សតិ**សព្ទ (គឺត្រាស់ដល់សតិ) ទៀត ។ ក្នុងទីនេះមានអធិប្បាយថា ភាវៈដែលរឭក គឺសតិ ។ សតិឈ្មោះថា **ធារណតា** ព្រោះទ្រទ្រង់ចាំវត្ថុដែលបានស្តាប់ និងបានរៀនមក ។ ភាវៈដែលមិនមមើមមាយ ឈ្មោះថា **អបិលាបនតា** ដោយអត្ថថា ឈានចុះ គឺហូរចូលទៅតាមអារម្មណ៍; ដូចជា**លាឡុកដាហៈ** (បំពង់ទឹកឃ្លោក) ជាដើម អណ្តែតលើទឹក មិនលិចទឹក យ៉ាងណា, សតិក៏យ៉ាងនោះដែរ តាំងនៅក្នុងអារម្មណ៍ មិនលិចចុះ ព្រោះសតិទៅតាមអារម្មណ៍ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា “**អបិលាបនតា** = ការមិនមមើមមាយ” ។ សតិឈ្មោះថា **អសម្មុស្សនតា** = ការមិនវង្វេង, ព្រោះការមិនវង្វេង ក្នុងការងារដែលធ្វើ

និងពាក្យនិយាយដែលកន្លងមកយូរបាន ។ សតិឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រងភាពជាធំក្នុងលក្ខណៈនៃការឧបដ្ឋាន និងលក្ខណៈនៃការបំភ្លឺ, ឥន្ទ្រិយ គឺសតិ ហៅថា **សតិន្ទ្រិយ** ។ សតិនោះឯង ជាឥន្ទ្រិយ ហៅថា **សតិន្ទ្រិយ**។ សតិ ឈ្មោះថា **សតិពលះ** ព្រោះមិនញាប់ញ័រក្នុងការប្រមាទ ។ សតិដែលឈ្មោះថា **សម្មាសតិ** ព្រោះជាការរឭកតាមសេចក្ដីពិត, ជាសតិនាំចេញ និងជាសតិក្នុងកុសល ។

**ក្នុងនិទ្ទេសនៃបញ្ញិន្ទ្រិយ** ធម៌ដែលឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ការប្រកាសឱ្យដឹង គឺធ្វើសេចក្ដីនោះៗ ឱ្យជាក់ច្បាស់ ។ ម្យ៉ាងទៀត ឈ្មោះថា **បញ្ញា** ព្រោះដឹងធម៌ទាំងឡាយដោយប្រការផ្សេងៗ មានការមិនទៀងជាដើមនោះៗ ។ ពាក្យនេះ ជាបទសម្ដែងសភាវៈនៃបញ្ញានោះ អាការដែលដឹងច្បាស់ ឈ្មោះថា **បជាននា** ។ បញ្ញា ឈ្មោះថា **វិចយៈ** ព្រោះពិចារណាធម៌មិនទៀងជាដើម ។ ពាក្យថា **"បវិចយៈ"** នេះ លោកបន្ថែមឧបសគ្គចូលមក ។ បញ្ញា ឈ្មោះថា **ធម្មវិចយៈ** ព្រោះពិចារណាធម៌ គឺសច្ចៈ ៤។

ធម៌ដែលឈ្មោះថា **សល្លក្ខណា** ដោយអំណាចនៃការកំណត់អនិច្ចលក្ខណៈជាដើមបាន ។ **សល្លក្ខណា** នោះឯង ត្រាស់ហៅថា "**ឧបលក្ខណា បច្ចុបលក្ខណា**" ដោយសេចក្តីផ្សេងៗ គ្នានៃឧបសគ្គ ។ ភាពជាបណ្ឌិត ឈ្មោះថា **បណ្ឌិច្ច** ។ ភាពជាបុគ្គលអ្នកឆ្លាត ឈ្មោះថា **កោសល្ល** ។ ភាពជាធម៌ដែលល្អិត ឈ្មោះថា **នេបុញ្ញ** ។ ភាវៈនៃការធ្វើឱ្យជាក់ច្បាស់នូវការមិនទៀងជាដើម ឈ្មោះថា **វេភព្យា** ។ បញ្ញាដែលឈ្មោះថា **ចិន្តា** ដោយអំណាចនៃការគិតថា មិនទៀងជាដើម ។ម្យ៉ាងទៀត ដែលឈ្មោះថា **ចិន្តា** ព្រោះកើតឡើងដល់បុគ្គលណា, រមែងញុំាងបុគ្គលនោះឱ្យគិតអនិច្ចលក្ខណៈជាដើម ។

ដែលឈ្មោះថា **ឧបបរិក្ខា** ព្រោះពិចារណាអនិច្ចលក្ខណៈជាដើម ។ ពាក្យថា "**ភូរិ**" ជាឈ្មោះរបស់ផែនដី ។ ពិតណាស់ បញ្ញានេះហៅថា **ភូរិ** ដូចផែនដី ព្រោះអត្ថថា តាំងមាំ និងទូលាយ; ព្រោះហេតុនោះ ទើបត្រាស់ហៅផែនដីថា "ភូរិ" បុគ្គលឈ្មោះថា **មានបញ្ញាដូចផែនដី** ព្រោះប្រកប

ដោយបញ្ញាដែលធំទូលំទូលាយស្មើដោយផែនដីនោះ[៦០] ។ ម្យ៉ាងទៀត ពាក្យថា "**ភូរិ**" នេះ ជាឈ្មោះរបស់បញ្ញា, បញ្ញា ឈ្មោះថា **ភូរិ** ព្រោះត្រេកអរក្នុងអត្ថដែលពិត ។ បញ្ញាដែលឈ្មោះថា **មេធា** ព្រោះទម្លាយ គឺបៀតបៀនកិលេស ដូចរន្ទះបាញ់ភ្នំថ្ម, ម្យ៉ាងទៀត ឈ្មោះថា **មេធា** ព្រោះរៀន និងទ្រទ្រង់ចាំទុកបានឆាប់រហ័ស ។ ដែលឈ្មោះថា **បរិណាយិកា** ព្រោះកើតឡើងដល់អ្នកណា, រមែងនាំអ្នកនោះ ឱ្យទៅក្នុងការបដិបត្តិប្រយោជន៍របស់ខ្លួន និងការចាក់ធ្លុះលក្ខណៈតាមសេចក្តីពិតក្នុងសម្បយុត្តធម៌ ។ បញ្ញាដែលឈ្មោះថា **វិបស្សនា** ព្រោះឃើញច្បាស់នូវធម៌ទាំងឡាយ ដោយអំណាចនៃអនិច្ចលក្ខណៈជាដើម ។

ដែលឈ្មោះថា **សម្បជញ្ញៈ** ព្រោះដឹងនូវអនិច្ចលក្ខណៈជាដើម ដោយប្រការផ្សេងៗ ដោយប្រពៃ ។ ដែលឈ្មោះថា **បតោទៈ** (ជន្លួញ) ព្រោះចាក់ចិត្តដែលកោងរត់ខុសផ្លូវ ឱ្យឡើងកាន់ផ្លូវ ដូចជន្លួញចាក់សេះសិន្ធព ដែលរត់

---

[៦០] ខុ. មហា. (សុទ្ធដ្ឋកសុត្តនិទ្ទេស) ។

ខុសផ្លូវ ឱ្យទៅត្រូវផ្លូវ ។ ជន្លួញ គឺបញ្ញានោះឯង ឈ្មោះថា**បញ្ញា គឺជន្លួញ** ។ ដែលឈ្មោះថា ឥន្ទ្រិយ ព្រោះគ្រងភាពជាធំក្នុងលក្ខណៈនៃការឃើញ, ឥន្ទ្រិយ គឺបញ្ញា ហៅថា **បញ្ញិន្ទ្រិយ** ។ បញ្ញានោះឯង ជាឥន្ទ្រិយ ក៏ឈ្មោះថា **បញ្ញិន្ទ្រិយ** ។ ដែលឈ្មោះថា **បញ្ញាពលៈ** ព្រោះមិនញាប់ញ័រក្នុងអវិជ្ជា ។ សស្ត្រា គឺបញ្ញានោះឯង ឈ្មោះថា **បញ្ញាសត្ថៈ** ព្រោះអត្ថថា កាត់កិលេស ។ បសាទ គឺបញ្ញានោះឯង ឈ្មោះថា **បញ្ញាបសាទៈ** ព្រោះអត្ថថា ខ្ពស់ក្រៃលែង។ ពន្លឺ គឺបញ្ញាឈ្មោះថា **បញ្ញាអាលោកៈ** ព្រោះអត្ថថា ភ្លឺ ។ ឱភាស គឺបញ្ញា ឈ្មោះថា **បញ្ញាឱភាសៈ** ព្រោះអត្ថថា ភ្លឺស្វាង ។ ប្រទីប គឺបញ្ញា ឈ្មោះថា **បញ្ញាបជ្ជោត** ព្រោះអត្ថថា រុងរឿង ។ មែនពិត បុគ្គលមានបញ្ញាអង្គុយហើយ ដោយបល្លង្កមួយ ហ្នឹងលោកធាតុក៏ភ្លឺដូចគ្នា, មានឱភាសដូចគ្នា មានការរុងរឿងដូចគ្នា, ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ពាក្យនោះទុក ។

ក៏បទនៃបញ្ញាទាំង ៣ នេះ សូម្បីបទមួយ ក៏សម្រេចសេចក្តីបាន ។ ព្រះមានព្រះភាគទ្រង់សម្តែងព្រះសូត្រទាំងឡាយ( ក្នុងអង្គុត្តរនិកាយ ចតុក្ក-

និបាត) តាមអធ្យាស្រ័យរបស់សត្វទាំងឡាយថា “ម្នាលភិក្ខុទាំងឡាយ ពន្លឺទាំងឡាយនេះមាន ៤ យ៉ាង ។ ពន្លឺ ៤ យ៉ាង គឺអ្វីខ្លះ? គឺពន្លឺព្រះចន្ទ្រ ១, ពន្លឺព្រះអាទិត្យ១, ពន្លឺភ្លើង ១ និងពន្លឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាពន្លឺទាំង ៤ នេះ ពន្លឺបញ្ញាប្រសើរលើស” ។ ម្នាលភិក្ខុទាំងឡាយ ឱភាសទាំងឡាយ ៤ នេះ

។ល។ ម្នាលភិក្ខុទាំងឡាយ ការរុងរឿងទាំងឡាយ ៤ នេះ ក៏ដូចគ្នា [៦១] ។

សូម្បីក្នុងនិទ្ទេសនេះ ព្រះអង្គក៏ធ្វើទេសនា ដោយសមគួរដល់ព្រះសូត្រនោះដូចគ្នា ។ ព្រោះថា អត្ថកាលចែកដោយអាការជាអនេក ឈ្មោះថាជាការចែកល្អហើយ, សត្វទាំងឡាយមួយពួក ត្រាស់ដឹងបានដោយអាការម្យ៉ាង និងមួយពួកទៀត ក៏ត្រាស់ដឹងដោយអាការដទៃ; ក៏រតនៈ គឺបញ្ញាហៅថា **បញ្ញារតនៈ** ដោយអត្ថថា ធ្វើសេចក្ដីត្រេកអរ, ដោយអត្ថថា ឱ្យសេចក្ដីត្រេកអរ, ដោយអត្ថថា ឱ្យកើតសេចក្ដីត្រេកអរ, ដោយអត្ថថា

[៦១] អំ. ចតុក្ក. ។

សេចក្តីអរនៃចិត្ត, ដោយអត្ថថា ប្រាកដដោយលំបាក, ដោយអត្ថថា ថ្លឹង (ប្រៀប) មិនបាន, ដោយអត្ថថា ជាគ្រឿងប្រើរបស់សត្វអ្នកមិនថោកថយ ។ ដែលឈ្មោះថា **អមោហៈ** ព្រោះជាហេតុឱ្យសត្វទាំងឡាយមិនវង្វេង ឬថា តួបញ្ញាខ្លួនឯង មិនវង្វេងក្នុងអារម្មណ៍, ឬថា វត្ថុនោះ ត្រឹមតែមិនវង្វេងប៉ុណ្ណោះ ។ **បទនៃធម្មវិចយៈ** មានសេចក្តីតាមដែលពោលហើយនោះឯង ។ សួរថា ព្រោះហេតុអ្វី ទើបត្រាស់ធម្មវិចយៈនេះទៀត? ឆ្លើយថា ដើម្បីសម្តែងអមោហៈជាសត្រូវ និងមោហៈ; ព្រោះហេតុដូច្នោះ ទើបត្រាស់ធម្មវិចយៈនេះថា "ធម៌ណាឈ្មោះថា អមោហៈ, អមោហៈនោះ មិនមែនជាធម៌ដទៃក្រៅអំពីមោហៈតែម្យ៉ាង, ដែលពិតជាសត្រូវនឹងមោហៈផង ឈ្មោះថា **អមោហៈ** ពោលគឺធម្មវិចយៈនោះ ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងទីនេះ"។ ទិដ្ឋិដែលពិត ជាគ្រឿងនាំចេញចាកភព និងជាកុសល ឈ្មោះថា "សម្មាទិដ្ឋិ"។

**ក្នុងនិទ្ទេសនៃជីវិតិន្ទ្រិយ** ព្រះបាលីថា "**យោ តេសំ អរូបីនំ ធម្មានំ អាយុ**" ដូច្នេះ សេចក្តីថា សភាវៈធម៌ដែលឈ្មោះថា **អាយុ** ព្រោះអត្ថថា

ជាគ្រឿងតសម្បយុត្តធម៌ដែលជាអរូបទាំងឡាយនោះ ។ ពិតមែនហើយ កាលអាយុនោះមាន អរូបធម៌ទាំងឡាយ រមែងមានតទៅ ប្រព្រឹត្តទៅ, ដំណើរទៅទូទៅ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា **"អាយុ"** , បទថា **"អាយុ"** នេះ ជាបទសម្តែងសភាវៈនៃអាយុនោះ; ក៏ព្រោះកាលអាយុនៅមានប៉ុណ្ណោះ អរូបធម៌ទាំងនោះ ទើបតាំងនៅ, នាំទៅ, ឱ្យនាំទៅ, ឃ្លាតទៅ និងប្រព្រឹត្តទៅរក្សា, ព្រោះហេតុដូច្នោះ ទើបត្រាស់ពាក្យជាដើមថា **"ឋិតិ"** ។ ចំណែកអត្ថនៃពាក្យក្នុងបទនេះដូច្នេះ ៖-

ដែលឈ្មោះថា **ឋិតិ** ព្រោះជាហេតុឱ្យតាំងនៅ ។ ដែលឈ្មោះថា **យបនា** ព្រោះនាំទៅ ។ ដែលឈ្មោះថា **យាបនា** ក៏ដូចគ្នាដែរ ។ តែព្រះអង្គទ្រង់ធ្វើបទមុនឱ្យខ្លី ដោយអំណាចនៃសត្វអ្នកត្រាស់ដឹង ដោយអាការយ៉ាងនោះ ។ ដែលឈ្មោះថា **ឥរិយនា** ព្រោះជាហេតុឱ្យឃ្លាតទៅ ។ ដែលឈ្មោះថា **វត្តនា** ព្រោះជាហេតុឱ្យប្រព្រឹត្តទៅ ។ ដែលឈ្មោះថា **បាលនា** ព្រោះរក្សាទុក ។ ដែលឈ្មោះថា **ជីវិត** ព្រោះជាហេតុឱ្យសត្វរស់នៅ ។

ដែលឈ្មោះថា **ជីវិតិន្ទ្រិ** ព្រោះគ្រងភាពជាធំក្នុងលក្ខណៈនៃការអនុបាល ។

**ក្នុងនិទ្ទេសនៃហិរិពលៈ** ព្រះបាលីថា **“យំ តស្មិំ សមយេ”** ដូច្នេះ សេចក្ដីថា ក្នុងសម័យនោះ... ដោយធមិណា ។ ម្យ៉ាងទៀត លោកធ្វើឱ្យជាលិង្គវិបល្លាសហើយ គប្បីជ្រាបសេចក្ដីថា “ក្នុងសម័យនោះ ធមិណា” ក៏បាន។ បទថា **“ហិរិយិតព្វេន”** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថទុតិយាវិភត្តិ, អធិប្បាយថា រមែងខ្មាស គឺរង្កៀសធមិ មានកាយទុច្ចរិតជាដើម ដែលសមគួរដល់ការខ្មាស ។ បទថា **“បាបកានំ”** បានដល់ លាមក ។

បទថា **“អកុសលានំ ធម្មានំ”** បានដល់ ធមិដែលកើតពីការមិនឆ្លាត ។ សូម្បីពាក្យថា **“សមាបត្តិយា”** នេះ ក៏ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ, អធិប្បាយថា ខ្មាស គឺរង្កៀសនូវការដល់ព្រម ការបានចំពោះ និងការវិបូណិនៃ (អកុសល) ធមិទាំងឡាយនោះ ។

**ក្នុងនិទ្ទេសនៃឱត្តប្បៈ** បទថា **“ឱត្តប្បិតព្វយុត្តកេន”** [៦២] ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃហេតុ, អធិប្បាយថា ញញើតកោតក្រែង គឺខ្លាចទុច្ចរិត

[៦២] ច្បាប់ខ្លះថា ឱត្តប្បិតព្វេន ។

មានកាយទុច្ចរិតជាដើម ដែលគួរដល់ការខ្លាចក្រែង ដែលជាហេតុនៃការគួរខ្លាចក្រែង និងការចូលដល់ មានប្រការតាមដែលពោលហើយ ដែលជាហេតុនៃការខ្លាចក្រែង ។

**ក្នុងនិទ្ទេសនៃអលោភៈ** ធម៌ដែលឈ្មោះថា **អលោភៈ** នេះ ព្រោះការមិនល្មោភ, ម្យ៉ាងទៀត ឈ្មោះថា **អលោភៈ** ព្រោះមិនលោភ ។ បទថា **អលោភៈ** នេះ ជាបទសម្ដែងសភាវៈនៃការមិនលោភនោះ ។ អាការដែលមិនលោភឈ្មោះថា**អលុព្ភនា** = កិរិយាដែលមិនលោភ; បុគ្គលអ្នកបរិបូណ៌ដោយការលោភ ឈ្មោះថា **អ្នកល្មោភ**, បុគ្គលអ្នកមិនល្មោភ ឈ្មោះថា **អលុព្ភតៈ** = អ្នកមិនល្មោភ, ភាវៈនៃបុគ្គលអ្នកមិនល្មោភ ឈ្មោះថា **ភាវៈនៃការមិនល្មោភ**, ភាវៈដែលឈ្មោះថា **អសារាគៈ** = ការមិនត្រេកត្រអាល, ព្រោះមិនត្រេកអរដោយបដិបក្សចំពោះការត្រេកអរ ។ អាការដែលមិនត្រេកត្រអាលហើយ ឈ្មោះថា **អសារជ្ជនា** កិរិយាមិនត្រេកត្រអាល ។ ភាវៈនៃអ្នកមិនត្រេកត្រអាលហើយ ឈ្មោះថា **អសារជ្ជិតត្តៈ** = ភាពជាអ្នកមិនត្រេក

ត្រអាល ។ សភាវៈដែលឈ្មោះថា **អនភិជ្ឈា** ព្រោះមិនសំឡឹងរំពៃ ។ បទថា **“អលោភោ កុសលមូលំ”** បានដល់ កុសលមូល គឺអលោភៈ ។ ពិតមែនហើយ អលោភៈ ឈ្មោះថា **កុសលមូល** ព្រោះអត្ថថា ជាមូល គឺជាបច្ច័យដល់កុសលធម៌ទាំងឡាយខ្លះ, ឈ្មោះថា **កុសលមូល** ព្រោះកុសលនោះផង, ជាមូលផង ដោយអត្ថថា ជាបច្ច័យដូច្នេះខ្លះ ។

**ក្នុងនិទ្ទេសនៃអទោសៈ** សភាវៈដែលឈ្មោះថា **អទោសៈ** ព្រោះមិនប្រទូស្តរ៉ាយ ។ ម្យ៉ាងទៀត ដែលឈ្មោះថា **អទោសៈ** ព្រោះមិនប្រទូស្តខ្លះ, បទថា **អទោសៈ** នេះ ជាបទសម្ដែងសភាវៈរបស់ទោសៈនោះ ។ អាការដែលមិនប្រទូស្ត ឈ្មោះថា **អទុស្សនា** = កិរិយាដែលមិនប្រទូស្ត ។ ភាវៈនៃបុគ្គលអ្នកមិនប្រទូស្ត ឈ្មោះថា **អទុស្សិតត្តៈ** = ភាពមិនប្រទូស្ត ។ សភាវៈដែលឈ្មោះថា **អព្យាបាទ** ព្រោះមិនព្យាបាទ ដោយជាសត្រូវនឹងព្យាបាទ ។ សភាវៈដែលឈ្មោះថា **អព្យាបជ្ជៈ** = ការមិនបៀតបៀន ព្រោះមិនបៀតបៀន ដោយជាសត្រូវនឹងសេចក្ដីទុក្ខ ដែលកើតអំពីសេចក្ដីក្រោធ ។ កុសល

មូល គឺ **អទោសៈ** ឈ្មោះថា **អទោសៈ** ជាឫសរបស់កុសល, កុសលមូលនោះ មានសេចក្តីតាមដែលពោលហើយនុ៎ះឯង ។

**ក្នុងនិទ្ទេសនៃកាយបស្សទ្ធិជាដើម** ខន្ធ ៣ (វេទនា, សញ្ញា និង សង្ខារ) ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងពាក្យថា "**កាយ**" ដូច្នេះនេះ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបត្រាស់ថា "**វេទនាខន្ធស្ស**" ជាដើម ។ សភាវៈដែលឈ្មោះថា **បស្សទ្ធិ** ព្រោះជាហេតុនៃធម៌ទាំងនោះស្ងប់ គឺប្រាសចាកការក្រវល់ក្រវាយ ដល់ការស្រឡះ ។ បទទី ២ **(បដិប្បស្សទ្ធិ)** ទ្រង់បន្ថែមឧបសគ្គ ។ អាការដែលស្ងប់ ឈ្មោះថា **បស្សម្ភនា** = កិរិយាដែលស្ងប់ ។ បទទី ២ **(បដិប្បស្សម្ភនា)** ក៏ទ្រង់បន្ថែមឧបសគ្គ ។ ភាវៈនៃខន្ធ ៣ ដែលស្ងប់ ព្រោះបរិបូណ៌ដោយបស្សទ្ធិ ឈ្មោះថា **បដិប្បស្សម្ភិតត្តៈ** = ភាពជាអ្នកស្ងប់រំងាប់ ។ ការស្ងប់រំងាប់នៃការក្រវល់ក្រវាយរបស់កិលេស របស់ខន្ធ ៣ លោកពោលទុកដោយបទទាំងអស់, ការស្ងប់រំងាប់នូវការក្រវល់ក្រវាយរបស់វិញ្ញាណក្ខន្ធ លោកពោលទុកដោយន័យទី ២ ។

អាការនៃភាពស្រាល ឈ្មោះថា **លហុតា** ។ ពាក្យថា “**លហុបរិណាមតា**” សេចក្តីថា ធមិទាំងឡាយនោះ ឈ្មោះថា **លហុបរិណាមៈ** = ការប្រែប្រួលទៅរហ័ស, ព្រោះធមិទាំងនោះ ប្រែប្រួលទៅរហ័ស, ភាវៈនៃលហុតបរិណាមធមិទាំងនោះ ឈ្មោះថា **លហុបរិណាមតា** អធិប្បាយថា អាចប្រែប្រួល ដោយឆាប់រហ័ស ។ ពាក្យថា “**អគរុតា**” ជាពាក្យបដិសេធសេចក្តីធ្ងន់, គឺមិនមែនជាភារៈធ្ងន់ ។ ពាក្យថា “**អទិត្ថនតា**” បានដល់ មិនរឹងត្អឹង ព្រោះមិនមានភារៈធ្ងន់ គឺកិលេស មានថីនៈ និងមានះជាដើម ។

ម្យ៉ាងទៀត ការមិនរឹងត្អឹងនៃភារៈធ្ងន់ របស់កិលេស មានថីនៈ និងមានះជាដើម ឈ្មោះថា **អទិត្ថនតា** ។ ព្រះមានជោគត្រាស់អាការ គឺសេចក្តីស្រាលនៃខន្ធទាំង ៣ នោះ ដោយន័យដំបូង, ត្រាស់អាការ គឺសេចក្តីស្រាលនៃវិញ្ញាណក្ខន្ធ ដោយន័យទី ២ ។

ភាពទន់ ឈ្មោះថា **មុទុតា** ។ ពាក្យថា “**មទ្ទវតា**” សេចក្តីថា ការស្និទ្ធ និងការរលីង ត្រាស់ហៅថា **មទ្ទវៈ**, ភាវៈនៃមទ្ទវៈនោះ ឈ្មោះថា

**មន្ទុនតា** ។ ភាវៈដែលមិនរឹងរូស ( **អកក្ខឡះ**) ឈ្មោះថា **អកក្ខឡតា** ។

ភាវៈដែលមិនរឹងត្អឹងឈ្មោះថា **អកថិនតា** ។ សូម្បីក្នុងនិទ្ទេសនេះ ព្រះមានព្រះភាគក៏ត្រាស់ថា អាការ គឺការទន់ភ្លន់នៃខន្ធ ៣ ដោយន័យដំបូង និងរបស់វិញ្ញាក្ខន្ធ ដោយន័យក្រោយ ។

ការសម្រេចនៃការងារ ឈ្មោះថា **កម្មញ្ញតា**, អធិប្បាយថា ភាពគួរដល់ការងារ គឺការគួរដល់ការប្រកបក្នុងការធ្វើកុសល ។ ពីរបទនៅសល់ លោកបន្ថែមមកដោយអំណាចនៃព្យញ្ជនៈដោយពិត ។ ពិតណាស់ សូម្បីបទទាំង ២ ព្រះអង្គក៏ត្រាស់អាការ គឺភាពគួរដល់ការងារនៃខន្ធទាំង ៣ ដោយន័យដំបូង និងត្រាស់អាការ គឺការគួរដល់ការងារនៃវិញ្ញាណក្ខន្ធ ដោយន័យក្រោយ ។

ភាពនៃការស្ទាត់ ឈ្មោះថា **បគុណតា** គឺមិនទុរន់ទុរា, មិនឈឺ ( មិនត្អូញត្អែរ) ។ បទដែលនៅសល់ ជាបទដែលបន្ថែមមក ដោយអំណាចនៃព្យញ្ជនៈ ។ សូម្បីក្នុងនិទ្ទេសនេះ ក៏ត្រាស់ការស្ទាត់ជំនាញ មិនទុរន់ទុរានោះឯង នៃខន្ធ ៣ ដោយន័យមុន, ត្រាស់ការស្ទាត់ជំនាញ មិនទុរន់ទុរា នៃ

វិញ្ញាណក្ខន្ធ ដោយន័យក្រោយ ។

ភាពនៃការត្រង់ ឈ្មោះថា **ឧជុកតា**, គឺការប្រព្រឹត្តទៅដោយអាការដ៏ត្រង់ ។ ភាវៈនៃខន្ធ ៣ ដែលត្រង់ និងវិញ្ញាណក្ខន្ធ ដែលត្រង់ ហៅថា **ឧជុកតា** ។ ការបដិសេធនៃការក្រងិកក្រងក់ ដូចមូត្រគោ (ទឹកនោមគោ) ឈ្មោះថា **អជិម្ហតា** = ស្មោះត្រង់ ។ បទថា **“អវង្កត”** បានដល់ បដិសេធការកោងដូចវង់ចន្ទ (អឌ្ឍចន្ទ) ។ បទថា **“អកុដិលតា”** បានដល់ បដិសេធការកោង ដូចចុងនង្គ័ល ។ ពិតណាស់ បុគ្គលណា ធ្វើបាបហើយពោលថា “អញមិនបានធ្វើ” , បុគ្គលនោះ ឈ្មោះថា **ជាអ្នកកោងដូចមូត្រគោ** (ទឹកនោមគោ) ព្រោះការពទ្ធពែន ។ អ្នកណាធ្វើបាបហើយនិយាយថា “អញមិនខ្លាចបាបទេ” អ្នកនោះ ឈ្មោះថា **កោងដូចវង់ព្រះចន្ទ** ព្រោះកោងដោយច្រើន; អ្នកណាកំពុងធ្វើបាប តែពោលថា “អ្នកណាមិនខ្លាចបាប” , អ្នកនោះ ឈ្មោះថា **កោងដូចចុងនង្គ័ល** ព្រោះមិនកោងពេក ។

ម្យ៉ាងទៀត កម្មទ្វារ ៣ របស់បុគ្គលណាមិនបរិសុទ្ធ, បុគ្គលនោះ

ឈ្មោះថា **ជាអ្នករវៀចដូចទឹកមូត្រគោ** ។ សូម្បីកម្មទ្វារទាំង ២ ណាមួយ មានដល់បុគ្គលណា មិនបរិសុទ្ធ, បុគ្គលនោះ ឈ្មោះថា **ជាអ្នកកោងដូចវង់ព្រះចន្ទ** ។ កម្មទ្វារណាមួយរបស់បុគ្គលមិនបរិសុទ្ធ, បុគ្គលនោះ ឈ្មោះថា **ជាអ្នករវៀចដូចជន្ទោលនង្គ័ល** (ចុងនង្គ័ល) ។

ចំណែកអាចារ្យអ្នករៀនទីឃនិកាយ ពោលថា "ភិក្ខុខ្លះក្នុងវ័យទាំងអស់ ប្រព្រឹត្តអនេសនៈ ២១* និងអគោចរ ៦*, ភិក្ខុនេះ ឈ្មោះថា **ជាអ្នកកោងដូចទឹកមូត្រគោ** ។ ភិក្ខុខ្លះក្នុងបឋមវ័យបំពេញចតុប្បារិសុទ្ធិសីល, ជាអ្នកខ្មាស រង្កៀសសេចក្តីអាក្រក់ ត្រូវការសិក្សា, ក្នុងមជ្ឈិមវ័យ និងបច្ឆិមវ័យ ជាភិក្ខុដូចរូបមុន, ភិក្ខុនេះ ឈ្មោះថា **ជាអ្នកកោងដូចវង់ព្រះចន្ទ** ។ ភិក្ខុខ្លះក្នុងបឋមវ័យក្តី មជ្ឈិមវ័យក្តី បំពេញចតុប្បារិសុទ្ធិសីល មានការខ្មាស

---

* ការស្វែងរកមិនសមគួរ មានការឱ្យឫស្សី និងស្លឹកឈើជាដើម។ (សេចក្តីពិស្តារ គប្បីជ្រាបក្នុងគម្ពីរវិសុទ្ធិមគ្គ និងបរមត្ថជោតិកា អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋ ត្រង់មេត្តសូត្រ) ។

* អគោចរ កន្លែងដែលបព្វជិតមិនគួរត្រាច់ទៅ មានៈ ស្រីពេស្យាចារ ១, ស្រីមេម៉ាយ ១, ស្រីក្រមុំចាស់ ១, មនុស្សខ្ទើយ ១, រោងសុរា ១ និងកន្លែងភិក្ខុនី ១ (មូលដីកា) ។

មានការរង្កៀសបាប ត្រូវការសិក្សា, តែក្នុងបច្ឆិមវ័យ ជាភិក្ខុដូចរូបមុន, ភិក្ខុនេះ ឈ្មោះថា **ជាអ្នកកោងដូចចុងនង្គ័ល** ។ ភាវៈនៃបុគ្គលអ្នកកោងយ៉ាងនេះ ដោយអំណាចនៃកិលេសនោះ ព្រះមានជោគទ្រង់ត្រាស់ហៅថា '**ជិម្ហតា** = ការក្រឃិកក្រងក់, **វង្កតា** = ការកោង, **កុដិលតា** = ការង' ដូច្នេះ; ព្រះមានជោគទ្រង់ត្រាស់ការមិនក្រឃិកក្រងក់ជាដើម ដោយបដិសេធការក្រឃិកក្រងក់ជាដើមនោះ ហើយទ្រង់សម្ដែងដោយជាខន្ធាធិដ្ឋាន ។ ពិតមែនហើយ ការមិនក្រឃិកក្រងក់ជាដើមនេះ មានដល់ខន្ធទាំងឡាយ, មិនមានដល់បុគ្គលទេ; ដោយបទទាំងនេះ សូម្បីបទទាំងអស់យ៉ាងនេះ ព្រះមានព្រះភាគត្រាស់អាការ គឺការត្រង់ ១ ដោយន័យមុន, ត្រាស់អាការ គឺការត្រង់នៃវិញ្ញាណក្ខន្ធ ដោយន័យក្រោយ ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ព្រះអង្គទ្រង់ត្រាស់អាការៈ គឺការត្រង់នៃអរូបធម៌ទាំងឡាយ ព្រោះការមិនមានកិលេស។ ឥឡូវនេះ និទ្ទេសដែលព្រះភគវាត្រាស់ហើយដោយសង្ខេបនៃធម៌ ឈ្មោះថា យេវាបនកៈនោះឯង, ដែលសម្ដែងក្នុងធម្មុទ្ទេសវារៈ ដោយអប្បនាវារៈ ដែលត្រាស់ថា "**យេ វា បន**" នោះដូច្នេះ ៕

ចប់កថាសម្ដែងអំពីនិទ្ទេសវារៈ

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ជាចំណែកចប់កថាពោលដោយការកំណត់ធម៌ ប្រដាប់ដោយបរិច្ឆេទ ៨ បរិច្ឆេទ គឺឧទ្ទេសវារៈ ៤ បរិច្ឆេទ, មានបុច្ឆា ១, សមយនិទ្ទេស ១, ធម្មុទ្ទេស ១, អប្បនា ១ និងក្នុងនិទ្ទេសវារៈ ៤ បរិច្ឆេទ មានបុច្ឆា ១, សមយនិទ្ទេស ១, ធម្មុទ្ទេស ១ និងអប្បនា ១ ដូច្នេះឯង ។

# អធិប្បាយសង្គហវារៈ*

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមសង្គហវារៈដោយពាក្យជាដើមថា “**តស្មឹ ខោ បន សមយេ ចត្តារោ ខន្ធា ហោន្តិ** = ក៏សម័យនោះឯងខន្ធ ៤ រមែងមាន” ដូច្នេះ, ក៏ក្នុងសង្គហវារៈនោះ មាន ៣ យ៉ាង គឺឧទ្ទេស = សម្ដែងឡើង, និទ្ទេស = សម្ដែងចេញ និងបដិនិទ្ទេស = សម្ដែងចែកចេញ ។

បណ្ដាសង្គហវារៈទាំង ៣ នោះ វារៈដែលមានពាក្យជាដើម យ៉ាងនេះថា “**តស្មឹ ខោ បន សមយេ ចត្តារោ ខន្ធា** = ក៏ក្នុងសម័យនោះ ខន្ធ ៤ រមែងមាន” គប្បីជ្រាបថា ជាឧទ្ទេស, វារៈដែលមានពាក្យជាដើមថា “**កតមេ តស្មឹ សមយេ ចត្តារោ ខន្ធា** = ខន្ធ ៤ រមែងមានក្នុងសម័យនោះ តើដូចម្ដេច?” គប្បីជ្រាបថា ជានិទ្ទេស, វារៈដែលមានពាក្យជាដើមថា “**កតមោ តស្មឹ សមយេ វេទនាខន្ធោ** = វេទនាខន្ធ មានក្នុងសម័យនោះ តើដូចដូចម្ដេច?” គប្បីជ្រាបថា ជាបដិនិទ្ទេស ។

បណ្ដាវារៈទាំងឡាយនោះ វារៈពោលដោយនិទ្ទេស មានពាក្យថា “**ចត្តារោ ខន្ធា**” ជាដើម មានកោដ្ឋាសៈ ២៣ ។ គប្បីជ្រាបសេចក្ដីនៃកោដ្ឋាសៈទាំងនោះ ដូចតទៅនេះ ៖-

កាមាវចរមហាកុសលចិត្តដួងទី ១ កើតឡើងក្នុងសម័យណា, ក្នុង

---

* បាលី ហៅថា កោដ្ឋាសវារៈ ។

សម័យនោះ ធម៌ទាំងឡាយច្រើនជាង ៥០ ដែលមកក្នុងព្រះបាលី កើតឡើងដោយអំណាចនៃអង្គរបស់ចិត្ត ព្រោះវៀរ**យេវាបនកធម៌** កាលប្រមូលចូលគ្នាសូម្បីទាំងអស់ ឈ្មោះថា **ខន្ធ ៤** ដោយអត្ថថា ជាកង ឈ្មោះថា **ជាអាយតនៈ ២** ប៉ុណ្ណោះ ដោយអត្ថថាជាទីត តាមដែលពោលមកហើយក្នុងខាងក្រោយ, ឈ្មោះថា **ជាធាតុ ២** ដូចគ្នានុ៎ះឯង ដោយអត្ថថា ជាសភាវៈ,ដោយអត្ថថាជាសុញ្ញតៈ និងដោយអត្ថថា ជានិស្សត្ត; ក្នុងធម៌ទាំងឡាយនោះ ឈ្មោះថា **ជាអាហារមាន ៣** ប៉ុណ្ណោះ ពោលដោយអត្ថដែលនាំមកពោល គឺជាបច្ច័យ. ធម៌ដែលនៅសល់ មិនមែនជាអាហារឡើយ ។

សួរថា ធម៌ដែលនៅសល់ទាំងនោះ មិនមែនជាបច្ច័យដល់គ្នានឹងគ្នាឬ? ឬថា មិនជាបច្ច័យដល់រូបដែលមានធម៌នោះជាសមុដ្ឋានឬ? ឆ្លើយថា មិនជាបច្ច័យមិនមែនទេ, ក៏ប៉ុន្តែធម៌ទាំងនេះ ជាបច្ច័យយ៉ាងនោះក៏បាន, ដោយប្រការដទៃក៏បាន; ព្រោះហេតុដូច្នោះ កាលបើបច្ច័យមាន ក៏ជាបច្ច័យលើសទៅ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា “ធម៌ទាំងនោះជាអាហារ” ។

សួរថា ត្រាស់ថាដូចម្តេច? ឆ្លើយថា បណ្តាអាហារទាំងនោះ ផស្សាហារជាបច្ច័យដល់ធម៌ទាំងឡាយណា មានចិត្ត និងចេតសិកដ៏សេស, នឹងជាបច្ច័យដល់ធម៌ទាំងឡាយនោះ, នឹងនាំមកនូវវេទនា ៣ ។ មនោសញ្ចេតនាហារ ជា

បច្ច័យដល់ធមិទាំងឡាយនោះ, នឹងនាំមកនូវភព ៣ ។ វិញ្ញាណាហារជា បច្ច័យដល់ធមិទាំងឡាយនោះ, នឹងនាំមកនូវបដិសន្ធិ នាម និងរូប ។

សួរថា វិញ្ញាណាហារនោះ ជាវិបាកតែម្យ៉ាង, ចំណែកវិញ្ញាណនេះជា កុសលវិញ្ញាណ មិនមែនទេឬ? ឆ្លើយថា ជាកុសលវិញ្ញាណក៏ពិតមែនហើយ ប៉ុន្តែថា កុសលវិញ្ញាណនោះ លោកក៏ហៅថា "វិញ្ញាណាហារ" ដូចគ្នាដែរ ព្រោះជាសភាវៈដូចគ្នានឹងវិបាកវិញ្ញាណាហារនោះ, ម្យ៉ាងទៀត ធមិទាំង ៣ នេះត្រាស់ហៅថា "អាហារ" ព្រោះអត្ថថា ជាធមិឧបត្ថម្ភ ។ ពិតណាស់ ធមិទាំងនេះជាបច្ច័យ ដោយជាឧបត្ថម្ភកប្បច្ច័យ ដល់សម្បយុត្តធមិទាំង ឡាយ ដូចកវឡិង្ការាហារជាបច្ច័យដល់រូបកាយ; ព្រោះហេតុនោះឯង ព្រះ អង្គទើបត្រាស់ថា "អរូបាហារជាបច្ច័យដល់សម្បយុត្តធមិ និងដល់រូបទាំង ឡាយដែលមានអាហារនោះជាសមុដ្ឋាន ដោយអាហារប្បច្ច័យ" [៦៣] ។

ន័យមួយទៀត ក៏ធមិទាំង ៣ នេះ ព្រះមានព្រះភាគត្រាស់ហៅថា "អាហារ" ; ដូចកវឡិង្ការាហារជាបច្ច័យពិសេស ដល់រូបកាយរបស់សត្វ ទាំងឡាយអ្នកមានកវឡិង្ការាហារ; ក្នុងនាមកាយផស្សៈ ជាបច្ច័យពិសេស ដល់វេទនា, មនោសញ្ចេតនាជាបច្ច័យពិសេសដល់វិញ្ញាណ, វិញ្ញាណជាបច្ច័យ ពិសេសដល់នាមរូប ។ ដូចយ៉ាងដែលព្រះភគវន្តមុនិត្រាស់ថា "ម្នាលភិក្ខុ

[៦៣] អភិ. ។

ទាំងឡាយ កាយនេះតាំងនៅបាន ព្រោះអាហារ, អាស្រ័យអាហារទើបតាំងនៅ, មិនអាស្រ័យអាហារតាំងនៅមិនបាន" [៦៤]; ដូចដែលត្រាស់ថា "ព្រោះផស្សៈជាបច្ច័យទើបមានវេទនា, ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ, ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប" [៦៥]។

ក៏ធម៌ ៨ ប៉ុណ្ណោះ (សទ្ធា, វិរិយៈ, សតិ, សមាធិ, មនះ, សោមនស្ស និងជីវិត) ឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ជាអធិបតី, ធម៌ដែលនៅសល់មិនឈ្មោះថា **ឥន្ទ្រិយ**; ព្រោះហេតុដូច្នោះ ទើបត្រាស់ថា **"ឥន្ទ្រិយ ៨ មានក្នុងសម័យនោះ"** ។ ធម៌ ៥ ប៉ុណ្ណោះ ឈ្មោះថា **អង្គឈាន** ព្រោះអត្ថថា ចូលទៅសម្លឹង; ព្រោះហេតុនោះ ទើបត្រាស់ថា **"ឈានមានអង្គ ៥"** ។ ធម៌ ៥ ប៉ុណ្ណោះ ឈ្មោះថា **ជាអង្គមគ្គ** ព្រោះអត្ថថា នាំចេញ និងព្រោះអត្ថថា ជាហេតុ; ព្រោះហេតុនោះ ទើបត្រាស់ថា **"មគ្គមានអង្គ ៥ "**។ ពិតណាស់ អរិយមគ្គមានអង្គ ៨ ក៏ពិតមែនហើយ, តែថាអង្គមគ្គក្នុងលោកិយចិត្ត មិនបានវិរតិ ៣ ព្រមគ្នាទេ, ព្រោះហេតុនោះ ទើបត្រាស់ថា **"មគ្គមានអង្គ ៥"**។

សួរថា មគ្គដែលជាបុព្វភាគនៃវិបស្សនា ក៏ជាមគ្គ ៨ ដូចលោកុត្តរមគ្គ

---

[៦៤] សំ. ម.។

[៦៥] សំ. និ.។

ដូចក្នុងសូត្រនេះថា "ម្នាលភិក្ខុ ពាក្យថា **យថាគតមគ្គោតិ ខោ មគ្គោ ហោតិ** នេះជាឈ្មោះរបស់អរិយមគ្គប្រកបដោយអង្គ ៨" [៦៦] ព្រោះសេចក្តីនេះ ជាការសម្តែងតាមយថាគតសព្ទថា "**អដ្ឋង្គិកោ**" សូម្បីលោកិយមគ្គ ក៏គប្បីប្រកបដោយអង្គ ៨ មិនមែនទេឬ?

ឆ្លើយថា លោកិយមគ្គមិនគប្បីប្រកបដោយអង្គ ៨; ព្រោះឈ្មោះថា **សុត្តន្តិកទេសនា** នេះជាបរិយាយទេសនា; ដោយហេតុនោះឯង ព្រះមានព្រះភាគទើបត្រាស់ថា "ចំណែកកាយកម្ម វចីកម្ម និងអាជីវៈរបស់លោកបរិសុទ្ធល្អហើយក្នុងខាងដើម" [៦៧]។ ចំណែកទេសនានេះ ជានិប្បរិយាយទេសនា; ព្រោះលោកិយចិត្តមិនមានវិរតិ ៣ ព្រមគ្នាទេ, ព្រោះហេតុដូច្នោះទើបត្រាស់ថា ក្នុងលោកិយមគ្គ បានមគ្គមានអង្គ ៥ ប៉ុណ្ណោះ ។

ក៏ធម៌ ៧ ប៉ុណ្ណោះ (សទ្ធា, វីរិយៈ, សតិ, សមាធិ, បញ្ញា, ហិរិ និងឱត្តប្បៈ) ឈ្មោះថា **ពលៈ** ព្រោះអត្ថថា មិនញាប់ញ័រ; ធម៌ ៣ ប៉ុណ្ណោះ (អលោភៈ, អទោសៈ និងអមោហៈ) ឈ្មោះថា **ជាហេតុ** ព្រោះអត្ថថា **ជាមូល**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **ផស្សៈ** ព្រោះអត្ថថា **ពាល់ត្រូវ**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **វេទនា** ព្រោះអត្ថថា **សោយអារម្មណ៍**, ធម៌មួយ

---

[៦៦] សំ. សឡា. ។

[៦៧] ម. ឧ. ។

ប៉ុណ្ណោះ ឈ្មោះថា **សញ្ញា** ព្រោះអត្ថថា **ចាំបាន**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **ចេតនា** ព្រោះអត្ថថា **តាំងចិត្ត**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **ចិត្ត** ព្រោះអត្ថថា **គិត និងធ្វើឱ្យវិចិត្រ**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **វេទនាខន្ធ** ព្រោះអត្ថថា **ជាកង** និងព្រោះអត្ថថា **សោយអារម្មណ៍**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **សញ្ញាខន្ធ** ព្រោះអត្ថថា **ជាកង** និងព្រោះអត្ថថា **ចាំបាន**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **សង្ខារក្ខន្ធ** ព្រោះអត្ថថា **ជាកង** និងព្រោះអត្ថថា **តាក់តែង**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **វិញ្ញាណក្ខន្ធ** ព្រោះអត្ថថា **ជាកង** និងព្រោះអត្ថថា **គិត និងធ្វើឱ្យវិចិត្រ**, ធម៌នោះឯង ឈ្មោះថា **មនាយតនៈ** ព្រោះអត្ថថា **ដឹងច្បាស់** និងព្រោះអត្ថថា **ជាអាយតនៈ** តាមដែលពោលហើយក្នុងខាងក្រោយ, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **មនិន្ទ្រិយ** ព្រោះអត្ថថា **ដឹងច្បាស់** និងព្រោះអត្ថថា **ជាអធិបតី**, ធម៌មួយប៉ុណ្ណោះ ឈ្មោះថា **មនោវិញ្ញាណធាតុ** ព្រោះអត្ថថា **ដឹងច្បាស់** និងព្រោះអត្ថថា **ជាសភាវៈ ជាសុញ្ញតៈ និងជានិស្សត្ត** ធម៌ដែលនៅសល់ មិនមែនជាធម៌ (តាមដែលពោលមកទេ); ធម៌ទាំងអស់ដែលនៅសល់ វៀរចិត្តចេញ **ឈ្មោះថា ជាធម្មាយតនៈមួយ និងជាធម្មធាតុមួយ**នោះឯង ព្រោះអត្ថថា **ជាអាយតនៈ** តាមដែលពោលមកហើយ ។

ក៏ពោលដោយអប្បនាវារៈនេះថា **"យេ វា បន តស្មឹ សមយេ"** សូម្បីក្នុងទីនេះ លោកសង្គ្រោះ គឺរួមយក**យេវាបនកធម៌** តាមដែលពោលហើយ ក្នុងខាងដើមចូលផង; គឺថា **យេវបនកធម៌** ក្នុងទីនេះ យ៉ាងណា, ក្នុងទីទាំងពួង ក៏យ៉ាងនោះដែរ; ព្រោះថា តអំពីនេះទៅ ខ្ញុំនឹងមិនពិចារសូម្បីនូវធម៌មានប្រមាណប៉ុណ្ណោះ, បណ្ឌិតគប្បីជ្រាបវារៈក្នុងនិទ្ទេស និងបដិនិទ្ទេសទាំងឡាយដោយន័យតាមដែលពោលមកហើយ ក្នុងខាងដើមនុ៎ះឯង; សូម្បីពាក្យថា **កោដ្ឋាសវារៈ** ក៏ជាឈ្មោះរបស់សង្គហវារៈនុ៎ះឯង ៕

ចប់សង្គហវារៈ

---

# អធិប្បាយសុញ្ញតវារៈ
# ចិត្តដួងទី ១

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ចាប់ផ្ដើមសុញ្ញតវារៈ មានពាក្យថា **"តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ"** , សុញ្ញតវារៈនោះកំណត់ទុក ២ យ៉ាង ដោយអំណាចនៃឧទ្ទេស និងនិទ្ទេស ។ បណ្ដាឧទ្ទេស និងនិទ្ទេសទាំងនោះ វារៈដែលពោលដោយឧទ្ទេសចាត់ទុកជា ២៤ ចំណែក រួមទាំងបទថា **"ធម្មា ហោន្តិ"** , ក៏ក្នុងចំណែកទាំងពួង លោកមិនបានកំណត់រាប់ថា**ជា ៤ ជា ២ និងជា ៣"** ឡើយ ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះកំណត់

ទុកក្នុងសង្គហវារៈហើយ; ព្រោះថា ធម៌ទាំងឡាយ ដែលកំណត់ទុកក្នុងសង្គហវារៈនោះឯង លោកក៏ពោលទុកសូម្បីក្នុងសុញ្ញតវារៈនោះដែរ, មែនហើយ ក្នុងសុញ្ញតវារៈនេះ មិនមែនសត្វ ឬភាវៈ ឬក៏អត្តា, ក៏ធម៌ទាំងឡាយត្រាស់ដើម្បីសម្តែងសុញ្ញតា (សូន្យ) នេះថា "ធម៌ទាំងនេះ ត្រឹមតែជាធម៌មិនមានសារៈ មិនជាបរិណាយកៈ" , ព្រោះហេតុនោះ ក្នុងវារៈនៃឧទ្ទេសនេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ៖-

ក្នុងសម័យណា កាមាវចរមហាកុសលចិត្តដួងទី ១ កើតឡើង ធម៌ច្រើនជាង ៥០ ដែលកើតឡើងដោយអង្គប្រកបរបស់ចិត្ត ក្នុងសម័យនោះធម៌នោះឯង មានដោយអត្ថថាជាសភាវៈ, មិនមែនអ្វីៗដទៃ គឺមិនមែនសត្វ, មិនមែនភាវៈ, មិនមែនជីវៈ, មិនមែនបោសៈ (មនុស្សប្រុស) មិនមែនបុគ្គល ។ ក៏ធម៌នោះឈ្មោះថា **ខន្ធ** ព្រោះអត្ថថា ជាគង ។ ក្នុងបទទាំងពួងគប្បីជ្រាបការប្រកាសសេចក្តីដោយន័យមុននោះឯង មានប្រការដូច្នេះ ។

ក៏ព្រោះអង្គឈានដទៃចាកឈាន ឬថា អង្គមគ្គដទៃចាកមគ្គមិនមាន, ព្រោះហេតុដូច្នោះ ក្នុងទីនេះ ព្រះមានជោគទើបត្រាស់ថា **"ឈានរមែងមាន, មគ្គរមែងមាន"** ។ ពិតណាស់ ដែលឈ្មោះថា **ឈាន** ក៏ព្រោះអត្ថថាចូលទៅសម្លឹង = **ឧបនិជ្ឈាយនដ្ឋេន**, តាមពិត ដែលឈ្មោះថា **មគ្គ** ព្រោះអត្ថថា ជាហេតុនោះឯង = **ហេតុដ្ឋេន**, សត្វ ឬភាវៈយ៉ាងណាមួយដទៃ មិន

មាន; គប្បីជ្រាបការប្រកបសេចក្ដីក្នុងបទទាំងពួងយ៉ាងនេះ ដោយប្រការដូច្នេះ ។ និទ្ទេសវារៈមានសេចក្ដីងាយស្រួលទាំងអស់ ។

ចប់សុញ្ញតវារៈ និងការពណ៌នាអត្ថនៃបឋមចិត្ត
ដែលអធិប្បាយប្រដាប់ដោយមហាវារៈទាំង ៣

## អធិប្បាយចិត្តដួងទី ២

ឥឡូវនេះ ដើម្បីសម្ដែងមហាកុសលចិត្តមានដួងទី ២ ជាដើម ទើបផ្ដើមពាក្យជាដើមថា **"កតមេ ធម្មា"** ទៀត ។ សូម្បីក្នុងចិត្តទាំងអស់នោះ គប្បីជ្រាបមហាវារៈក្នុងមួយដួង ៣ វារៈៗ ដោយន័យដែលពោលហើយក្នុងបឋមចិត្ត និងមិនមែនមហាវារៈតែម្យ៉ាងប៉ុណ្ណោះទេ, សូម្បីអត្ថនៃបទទាំងពួង ដូចនឹងពាក្យដែលពោលក្នុងបឋមចិត្ត ក៏គប្បីជ្រាបដោយន័យដែលពោលហើយដូចគ្នា ។ ព្រោះថា ខាងមុខពីនេះទៅ ខ្ញុំនឹងធ្វើការពណ៌នាតាមលំដាប់បទ; ខាងមុខគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃចិត្តដួងទី ២ មុន ។

ពាក្យថា **"សសង្ខារេន"** នេះប៉ុណ្ណោះ ដែលជាពាក្យនៅមិនធ្លាប់ពណ៌នា, គប្បីជ្រាបអត្ថនៃពាក្យថា **សសង្ខារេន** នោះ ។ ធម៌ដែលឈ្មោះថា **សសង្ខារ** (ការបបួល), ព្រោះប្រព្រឹត្តទៅដោយសង្ខារ, អធិប្បាយថា មានសង្ខារនោះ គឺមានការប្រកប, មានឧបាយ, មានបច្ច័យជាពួក ។

ពិតមែន បឋមចិត្ត (មហាកុសលចិត្តដួងទី ១) កើតឡើងដោយពួកនៃបច្ច័យមានអារម្មណ៍ជាដើមណា, ចិត្តដួងទី ២ នេះ ក៏កើតឡើងដោយពួកនៃបច្ច័យមានប្រយោគ, មានឧបាយនោះដូចគ្នា ។

គប្បីជ្រាបការកើតឡើងនៃចិត្តដួងទី ២ នោះ យ៉ាងនេះថា ៖-

"ភិក្ខុរូបខ្លះ ក្នុងព្រះធម្មវិន័យនេះ អាស្រ័យនៅក្នុងទីបំផុតនៃវិហារ (ជាយវិហារ) កាលដល់វេលាបោសលានព្រះចេតិយ ឬដល់វេលាបម្រើព្រះថេរៈ ឬក៏ដល់ថ្ងៃស្តាប់ធម៌ គិតថា 'កាលយើងទៅហើយត្រឡប់មក នឹងឆ្ងាយណាស់, អញនឹងមិនទៅ' ដូច្នេះ ហើយគិតទៀតថា ឈ្មោះថា ការមិនទៅបោសលានព្រះចេតិយ ឬការមិនទៅបម្រើព្រះថេរៈ ឬការមិនទៅស្តាប់ព្រះធម៌ មិនសមគួរដល់ភិក្ខុទេ, អញនឹងទៅ" ទើបទៅ ។ កុសលចិត្តដែលកើតឡើងដល់ភិក្ខុនោះ អ្នកធ្វើប្រយោគរបស់ខ្លួន ឬត្រូវអ្នកដទៃសម្តែងទោសក្នុងការមិនធ្វើវត្តជាដើម និងអានិសង្សក្នុងការធ្វើ ហើយពោលបង្រៀន ឬដល់ភិក្ខុដែលត្រូវព្រះថេរៈបង្គាប់ឱ្យធ្វើថា 'អ្នកចូរមក, ចូរធ្វើវត្តនេះ' ឈ្មោះថា **កើតឡើងដោយមានសង្ខារ**, មានពួកនៃបច្ច័យ" ៕

**ចប់ចិត្តដួងទី ២**

## អធិប្បាយចិត្តដួងទី ៣

ក្នុងចិត្តដួងទី ៣ បទថា “**ញាណវិប្បយុត្តំ**” សេចក្ដីថា ចិត្តមិនប្រកបដោយញាណ ឈ្មោះថា **ញាណវិប្បយុត្ត**; មែនហើយ សូម្បីចិត្តជាញាណវិប្បយុត្តនេះ រីករាយត្រេកអរហើយក្នុងអារម្មណ៍, តែថា ចិត្តដួងទី ៣ នេះ មិនមានញាណជាគ្រឿងកំណត់; ព្រោះហេតុដូច្នោះ ចិត្តដែលជាញាណវិប្បយុត្តនេះ បណ្ឌិតគប្បីជ្រាបថា កើតឡើងក្នុងកាលដែលពួកក្មេងតូចៗ ឃើញភិក្ខុហើយថ្វាយបង្គំ ដោយគិតថា “ព្រះថេរៈនេះជារបស់យើង” ដូច្នេះ និងក្នុងកាលផ្សេងៗ មានការថ្វាយបង្គំព្រះចេតិយ និងការស្ដាប់ធម៌ជាដើម ដោយន័យនោះឯង; ក៏ក្នុងព្រះបាលី ចិត្តដួងទី ៣ នេះ មិនមានបញ្ហាក្នុងទី ៧ កន្លែង, ពាក្យនៅសល់ប្រព្រឹត្តទៅតាមប្រក្រតី គឺដូចនឹងពាក្យដែលពោលមកហើយនោះឯង ៕

ចប់ចិត្តដួងទី ៣

## អធិប្បាយចិត្តដួងទី ៤

សូម្បីក្នុងចិត្តដួងទី ៤ ក៏មានន័យដូចគ្នានេះដែរ; តែចិត្តដួងទី ៤ នេះ ព្រោះព្រះបាលីថា “**សសង្ខារេន** = ការបបួល” គប្បីជ្រាបថា មានក្នុងកាលដែលមាតាបិតាចាប់សីសៈ (ក្បាល) ក្មេងតូចៗ ឱ្យថ្វាយបង្គំព្រះចេតិយជា

ដើម; សូម្បីក្មេងទាំងឡាយនោះ មិនប្រាថ្នាថ្វាយបង្គំ ក៏រីករាយត្រេកអរ ៕

ចប់ចិត្តដួងទី ៤

# អធិប្បាយចិត្តដួងទី ៥

ក្នុងចិត្តដួងទី ៥ បទថា “**ឧបេក្ខាសហគតំ**” បានដល់ សម្បយុត្ត ដោយឧបេក្ខាវេទនា, ព្រោះថា ឧបេក្ខាសហគតៈនេះ រមែងជាចិត្តកណ្តាលក្នុងអារម្មណ៍, ចិត្តដួងទី ៥ នេះ មានបញ្ញាជាគ្រឿងកំណត់ដោយពិត ។ ក៏ក្នុងចិត្តដួងទី ៥ នេះ ក្នុងបាលីព្រះភគវាត្រាស់ថា “ឧបេក្ខា រមែងមាន” ក្នុងពួក ៤ នៃឈាន, “ឧបេក្ខិន្ទ្រិយរមែងមាន” ក្នុងពួក ៨ នៃឥន្ទ្រិយ ហើយទ្រង់ធ្វើទេសនាដោយការបដិសេធវត្ថុ ដែលគួរត្រេកអរ និងមិនគួរត្រេកអរ, សុខ និងទុក្ខក្នុងនិទ្ទេសនៃបទថា **វេទនា** ជាដើម សូម្បីទាំងអស់ ហើយត្រាស់អទុក្ខមសុខវេទនា, គប្បីជ្រាបអទុក្ខមសុខវេទនានោះ ជាឧបេក្ខិន្ទ្រិយដោយអំណាចនៃការគ្រងភាពជាធំក្នុងលក្ខណៈនៃមជ្ឈត្តា ។ ក៏កាលពោលដោយលំដាប់នៃបទ មិនមានបីតិក្នុងឋានមួយឡើយ, ព្រោះហេតុដូច្នោះ ធម៌ ៥៥ លោកទើបឡើងកាន់យកព្រះបាលី ដោយអំណាចនៃអង្គប្រកបរបស់ចិត្ត; គប្បីជ្រាបវិនិច្ឆ័យក្នុងកោដ្ឋាសៈទាំងពួង និងក្នុងវារៈទាំងពួង ដោយ

អំណាចនៃធម៌ទាំងនោះ ៕

**ចប់ចិត្តដួងទី ៥**

## អធិប្បាយចិត្តដួងទី ៦ ជាដើម

គប្បីជ្រាបចិត្តដួងទី ៦ ទី ៧ ទី ៨ ដោយន័យដែលពោលហើយ ក្នុងចិត្តដួង ទី២ ទី៣ និងទី ៤ នោះឯង ។ ពិតមែនហើយ ក្នុងចិត្តដួងទី ៦ ទី ៧ ទី ៨ នេះ ការប្តូរទៅនៃវេទនា និងការបាត់បីតិតែម្យ៉ាង រមែងមាន, ពាក្យនៅសល់ និងន័យនៃការកើតឡើងដូច្នោះដែរ ។ សូម្បីក្នុងការបរិកម្មរបស់ករុណា និងមុទិតា ការកើតឡើងនៃចិត្តដួងទី ៦ ទី ៧ ទី ៨ នេះ បានទទួលរង (អនុញ្ញាត) ហើយក្នុង**មហាអដ្ឋកថា**តែម្តង ។ ចិត្តទាំងនេះ ឈ្មោះថា **កាមាវចរកុសលចិត្ត ៨ ដួង** ៕

## កថាសម្តែងអំពីបុញ្ញកិរិយាវត្ថុជាដើម

សូម្បីកាមាវចរកុសលចិត្តទាំងអស់នោះ បណ្ឌិតគប្បីសម្តែងដោយបុញ្ញកិរិយាវត្ថុ ១០ ប្រការ ។ សួរថា សម្តែងដូចម្តេច? ឆ្លើយថា ឈ្មោះថាបុញ្ញកិរិយាវត្ថុ ១០ នោះ គឺ

**១. ទានមយៈ** បុញ្ញកិរិយាវត្ថុសម្រេចដោយទាន

**២.សីលមយៈ** បុញ្ញកិរិយាវត្ថុសម្រេចដោយសីល

**៣.ភាវនាមយៈ** បុញ្ញកិរិយាវត្ថុសម្រេចដោយភាវនា

**៤.អបចិតិសហគតៈ** បុណ្យដែលសហគតៈ (ប្រកប) ដោយអបចិតៈ (ការគោរពឱនលំទោន)។

**៥.វេយ្យាវច្ចសហគតៈ** បុណ្យដែលសហគតៈដោយការខ្វល់ខ្វាយ

**៦.បត្តានុប្បទានមយៈ** បុណ្យសម្រេចដោយការផ្សាយចំណែកបុណ្យ

**៧.អព្ភានុមោទនមយៈ** បុណ្យសម្រេចដោយការអនុមោទនា

**៨.ទេសនាមយៈ** បុណ្យសម្រេចដោយការសម្ដែងធម៌

**៩.សវនមយៈ** បុណ្យសម្រេចដោយការស្ដាប់ព្រះធម៌

**១០.ទិដ្ឋុជុកម្មៈ** បុញ្ញកិរិយាវត្ថុ (សម្រេច) ដោយការធ្វើទិដ្ឋិ (ការយល់ឃើញ) ឱ្យត្រង់* ។

បណ្ដាបុញ្ញកិរិយាវត្ថុទាំងនោះ ទាននោះឯង ឈ្មោះថា **ទានមយៈ** ការធ្វើបុណ្យ (**បុញ្ញកិរិយា**) ផង, ការធ្វើបុណ្យនោះជាវត្ថុ (ទីតាំង) នៃអានិសង្សទាំងឡាយនោះៗផង, ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **បុញ្ញកិរិយាវត្ថុ**។ ក្នុងបុញ្ញកិរិយាវត្ថុដែលនៅសល់ ក៏ន័យនេះដែរ។

---

* មូល. បានដល់ កម្មស្សកតាញ្ញាណ = បញ្ញាពិចារណាឃើញនូវសត្វទាំងឡាយមានកម្មជារបស់ខ្លួន។

បុញ្ញកិរិយាវត្ថុទាំងនោះ កាលបុគ្គលឱ្យបច្ច័យជាដើម ក្នុងបច្ច័យ ៤ មានចីវរជាដើម ឬបណ្ដាអារម្មណ៍ទាំង ៦ មានរូបជាដើម ឬទានវត្ថុ ១០ មានការឱ្យបាយជាដើមនោះៗ, ចេតនាដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ គឺ កាលខាងដើម ១, ក្នុងកាលបរិច្ចាគ ១ និងក្នុងការតាមរលឹកដល់ដោយចិត្ត សោមនស្សក្នុងកាលខាងក្រោយ ១; ចាប់ដើមពីការកើតឡើងនៃបច្ច័យជាដើមនោះៗ ឈ្មោះថា បុញ្ញកិរិយាវត្ថុ សម្រេចដោយការឱ្យ (**ទានមយៈ**) ។

ចេតនាដែលប្រព្រឹត្តទៅរបស់អ្នកសមាទានសីល ៥ ឬសីល ៨ ឬក៏សីល ១០ ឬថា របស់អ្នកចូលទៅកាន់វិហារដោយគិតថា "អញនឹងបួស" ដូច្នេះក្ដី អ្នកកំពុងបួសក្ដី អ្នកញ៉ាំងមនោរថឱ្យដល់ទីបំផុត ហើយពិចារណាថា "អញបួសហើយជាការល្អណាស់ហ្ន៎!" ក្ដី អ្នកសង្រួមព្រះបាតិមោក្ខក្ដី អ្នកពិចារណាបច្ច័យទាំងឡាយ មានចីវរជាដើមក្ដី អ្នកសង្រួមទ្វារ មានចក្ខុទ្វារជាដើម ក្នុងរូបជាដើមដែលមកកាន់គន្លងក្ដី អ្នកជម្រះនូវអាជីវៈឱ្យបរិសុទ្ធក្ដី ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** សម្រេចដោយសីល (**សីលមយៈ**) ។

ចេតនាដែលប្រព្រឹត្តទៅរបស់អ្នកពិចារណាចក្ខុ ដោយភាពមិនទៀង ជាទុក្ខ ជាអនត្តា, អ្នកពិចារណាសោតៈ ។ល។ អ្នកពិចារណាមនៈ, អ្នកពិចារណារូបទាំងឡាយ ។ល។ អ្នកពិចារណាធម៌ទាំងឡាយ, អ្នកពិចារណាចក្ខុវិញ្ញាណ ។ល។ អ្នកពិចារណាមនោវិញ្ញាណ, អ្នកពិចារណាចក្ខុសម្ផស្ស ។ល។

អ្នកពិចារណាមនោសម្ផស្ស, អ្នកពិចារណាវេទនា ដែលកើតពីចក្ខុសម្ផស្ស ។ល។ អ្នកពិចារណា វេទនាដែលកើតពីមនោសម្ផស្ស, អ្នកពិចារណារូបសញ្ញា ។ល។ អ្នកពិចារណាជរាមរណៈ ។ល។ ដោយភាពជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ដោយឧបាយនៃវិបស្សនា (**វិបស្សនាមគ្គេន**) ដែលព្រះសារីបុត្រពោលទុកក្នុង**បដិសម្ភិទាមគ្គ** [៦៨], ឬថា សូម្បីចេតនាទាំងអស់ដែលមិនដល់អប្បនាក្នុងអារម្មណ៍ ៣៨ យ៉ាង ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** សម្រេចដោយភាវនា (**ភាវនាមយះ**) ។

គប្បីជ្រាបបុញ្ញកិរិយាវត្ថុ **ដែលសហគតៈដោយការឱនលំទោន** ព្រោះឃើញអ្នកធំ ហើយក្រោកទទួល ការទទួលបាត្រ ចីវរ ការអភិវាទ និងការជៀសផ្លូវឱ្យជាដើម ។

គប្បីជ្រាបបុញ្ញកិរិយាវត្ថុ **ដែលសហគតៈដោយការខ្វល់ខ្វាយ** ក្នុងការខ្វល់ខ្វាយផ្លូវកាយ ដោយអំណាចនៃការធ្វើវត្ត និងធ្វើវត្តបដិបត្តិដល់ភិក្ខុអ្នកចាស់ជាងក្តី ដោយឃើញភិក្ខុអ្នកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ហើយទទួលបាត្រ និមន្តឱ្យចូលទៅទទួលភិក្ខាក្នុងស្រុកក្តី ដោយបានឮពាក្យថា "អ្នកចូរទៅ, អ្នកចូរនាំបាត្រមកឱ្យភិក្ខុទាំងឡាយ" ដូច្នេះហើយ ប្រញាប់ទៅនាំបាត្រមកឱ្យជាដើមក្តី ។

---

[៦៨] ខុ. បដិ. ។

កាលបុគ្គលឱ្យទាន ធ្វើការបូជាដោយគ្រឿងក្រអូបជាដើម ហើយឱ្យចំណែកបុណ្យថា "សូមចំណែកបុណ្យ ចូរមានដល់បុគ្គលឈ្មោះឯណោះ" ឬថា "សូមចំណែកបុណ្យ ចូរមានដល់សព្វសត្វទាំងឡាយ " គប្បីជ្រាបថា ជាបុញ្ញកិរិយាវត្ថុដែលកើតឡើងអំពីការឱ្យចំណែកបុណ្យ ។ សួរថា ក៏កាលបុគ្គលឱ្យចំណែកបុណ្យនេះ បុណ្យមិនអស់ទៅហើយឬ? ឆ្លើយថា មិនអស់ទៅទេ; ដូចយ៉ាងថា បុគ្គលអុជប្រទីបឡើងមួយដួង ហើយក៏ញ៉ាំងប្រទីបមួយពាន់ដួងឱ្យភ្លឺរុងរឿងបាន ព្រោះប្រទីបមួយដួងនោះ អ្នកណាមួយមិនគប្បីនិយាយថា ប្រទីបមួយដួងដំបូងអស់ទៅហើយ, តែថា ពន្លឺនៃប្រទីបដួងក្រោយៗ និងប្រទីបដួងដំបូងរួមគ្នាហើយ ក៏ជាពន្លឺភ្លឺក្រៃលែង យ៉ាងណា, កាលណាបុគ្គលឱ្យនូវចំណែកបុណ្យ ក៏យ៉ាងនោះដែរ ឈ្មោះថា បុណ្យទាំងឡាយដែលថយចុះទៅ រមែងមិនមាន, គប្បីជ្រាបថា រឹងរឹតតែចម្រើនឡើងប៉ុណ្ណោះ ។

គប្បីជ្រាបបុញ្ញកិរិយាវត្ថុ ដែលកើតឡើងអំពីការអនុមោទនា ដោយអំណាចនៃការអនុមោទនាចំណែកបុណ្យដែលបុគ្គលដទៃឱ្យហើយ ឬដោយបុញ្ញកិរិយាដទៃៗ ដោយការពោលថា "**សាធុ** = ល្អ, **សុដ្ឋុ** = ល្អ"* ។

ភិក្ខុមួយរូបតាំងនៅក្នុងសេចក្តីត្រូវការ ដោយគិតថា "ជនទាំងឡាយ

---

* ច្បាប់ខ្លះថា សាធុ, សាធុ ។

នឹងដឹងអញថា ‘ជាធម្មកថិក’ ដោយអាការយ៉ាងនេះ” ហើយជាអ្នកធ្ងន់ (ច្រើន) ដោយលាភទើបសម្ដែងធម៌, ការសម្ដែងធម៌នោះ មិនមានផលច្រើនទេ។ ចំណែកភិក្ខុមួយរូបមិនសង្ឃឹមផលតបវិញ សម្ដែងធម៌ដែលខ្លួនជំនាញដល់ជនទាំងឡាយដទៃ ដោយឧបាយដែលសម្រេចវិមុត្តិ, ការសម្ដែងនេះ ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** សម្រេចដោយការសម្ដែង (**ទេសនាមយៈ**)។

ភិក្ខុមួយរូប កាលស្ដាប់ធម៌រមែងស្ដាប់ដោយគិតថា “ជនទាំងឡាយនឹងដឹងអញថា ‘**ជាអ្នកមានសទ្ធា**’ ដោយប្រការដូច្នេះ” ការស្ដាប់នេះ មិនមានផលច្រើនទេ ។ ចំណែកភិក្ខុមួយរូប ស្ដាប់ធម៌ដោយចិត្តទន់ភ្លន់ ផ្សាយទៅនូវប្រយោជន៍ថា “ផលច្រើននឹងមានដល់អញ ដោយអាការយ៉ាងនេះ” , ការស្ដាប់ធម៌នោះ ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** សម្រេចដោយការស្ដាប់ (**សវនមយៈ**) ។

កាលបុគ្គលធ្វើសេចក្ដីយល់ឃើញឱ្យត្រង់ ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** ដែលកើតពីការធ្វើសេចក្ដីយល់ឃើញឱ្យត្រង់ ។ តែលោកទីឃភាណកាចារ្យពោលថា “ទិដ្ឋុជុកម្មជាលក្ខណៈនិយម (គឺគ្រឿងសម្គាល់នៃសេចក្ដីសម្បូណ៌) របស់បុញ្ញកិរិយាទាំងអស់; ព្រោះថា កាលបុគ្គលធ្វើបុណ្យយ៉ាងណាមួយរមែងជាបុណ្យមានផលច្រើន ព្រោះសេចក្ដីយល់ឃើញដ៏ត្រង់នោះឯង”។

ក៏បណ្ដាបុញ្ញកិរិយាវត្ថុទាំងឡាយនោះ បុញ្ញកិរិយាវត្ថុដែលជាទានមយៈ

រមែងកើតឡើងដល់បុគ្គលអ្នកគិតថា “អញនឹងឱ្យទាន” ដូច្នេះសិន, កាលបុគ្គលកំពុងឱ្យទានបុញ្ញកិរិយាវត្ថុដែលជាទានមយៈ ក៏កើតឡើង, កាលបុគ្គលពិចារណាថា “ទានគឺអញឱ្យហើយ” បុញ្ញកិរិយាវត្ថុដែលជាទានមយៈ ក៏កើតឡើង; ធម្មតាថា បុញ្ញកិរិយាវត្ថុដែលជាទានមយៈ នឹងមានបាន ក៏ព្រោះធ្វើចេតនា ៣ គឺបុព្វចេតនា, មុញ្ចនចេតនា និងអបរចេតនា ឱ្យជាចំណែកតែមួយ ។ សូម្បីសីលមយៈ ក៏រមែងកើតដល់បុគ្គលអ្នកគិតថា “អញនឹងបំពេញសីល” សីលមយៈក៏រមែងកើតឡើង ក្នុងពេលដែលកំពុងបំពេញសីលឱ្យបរិបូណ៌ សីលមយៈក៏រមែងកើតឡើង, កាលពិចារណាថា “អញបានបំពេញសីលហើយ” សីលមយៈក៏រមែងកើតឡើង; ធម្មតាថា បុញ្ញកិរិយាវត្ថុដែលជាសីលមយៈ នឹងមានបាន ក៏ព្រោះធ្វើចេតនាសូម្បីទាំងពួងនោះ ជាចំណែកតែមួយ ។ ល ។ សូម្បីបុញ្ញកិរិយាវត្ថុដែលជាទិដ្ឋុជុកម្មៈ កាលកើតរមែងកើតដល់បុគ្គលអ្នកគិតថា “អញនឹងធ្វើសេចក្តីយល់ឃើញឱ្យត្រង់” , បុគ្គលអ្នកកំពុងធ្វើសេចក្តីយល់ឃើញឱ្យត្រង់ ទិដ្ឋុជុកម្មៈក៏រមែងកើតឡើង, កាលបុគ្គលអ្នកពិចារណាថា “សេចក្តីយល់ឃើញ គឺអញធ្វើឱ្យត្រង់ហើយ” ទិដ្ឋុជុកម្មៈ ក៏រមែងកើតឡើង ។ ធម្មតា បុញ្ញកិរិយាវត្ថុដែលជាទិដ្ឋុជុកម្មៈ នឹងមានបាន ព្រោះធ្វើចេតនា សូម្បីទាំងអស់នោះ ឱ្យជាចំណែកតែមួយ; ក៏បុញ្ញកិរិយាវត្ថុក្នុងព្រះសូត្រមានមកត្រឹមតែ ៣ ប៉ុណ្ណោះ ។

គប្បីជ្រាបការសង្គ្រោះសូម្បីបុញ្ញកិរិយាវត្ថុក្រៅនេះ ចូលក្នុងបុញ្ញកិរិយា

វត្ថុ ៣ នោះ; ពិតណាស់ ការប្រព្រឹត្តឱនលំទោន និងការខ្វល់ខ្វាយ រមែងសង្គ្រោះជាសីលមយៈ* ។ ការឱ្យចំណែកបុណ្យ និងការអនុមោទនាចំណែកបុណ្យ សង្គ្រោះចូលក្នុងទានមយៈ ។ ការសម្ដែងធម៌ ការស្ដាប់ធម៌ និងទិដ្ឋុជុកម្ម សង្គ្រោះចូលក្នុងភាវនាមយៈ ។ ចំណែកជនទាំងឡាយណា ពោលថា "ទិដ្ឋុជុកម្ម ជាលក្ខណៈនៃការសម្បូណ៌ជាងបុញ្ញកិរិយាទាំងពួង" ដូច្នេះ, ទិដ្ឋុជុកម្មរបស់ជនទាំងនោះ ក៏រមែងដល់ការសង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ ។ បុញ្ញកិរិយាវត្ថុទាំងនេះ ពោលដោយសង្ខេប មាន ៣ ពោលដោយពិស្ដារមាន ១០ ដោយប្រការដូច្នេះ ។

បណ្ដាបុញ្ញកិរិយាវត្ថុទាំងនោះ កាលបុគ្គលគិតថា "អញនឹងឱ្យទាន" ដូច្នេះ រមែងគិតដោយកាមាវចរកុសលចិត្ត ៨ ដួង ដួងណាមួយ ដោយពិត, សូម្បីកាលឱ្យ (ទាន) ក៏រមែងឱ្យដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយពិត, សូម្បីពិចារណាថា "ទានគឺអញឱ្យហើយ" ក៏រមែងពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយដូចគ្នា; សូម្បីកាលគិតថា "អញនឹងបំពេញសីលឱ្យបរិបូណ៌" ក៏គិតដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយនោះឯង, សូម្បីកាលកំពុងបំពេញសីល ក៏បំពេញ

---

* មូលដីកាថា ពាក្យនេះ លោកពោលហើយដោយអំណាចនៃចារិត្តសីល (ចារិត្តវសេន) = សីលដែលបុគ្គលគប្បីប្រព្រឹត្ត ។

ដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយនោះឯង សូម្បីកាលពិចារណាថា “សីលអញបំពេញហើយ” ក៏ពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយដូចគ្នា; សូម្បីកាលគិតថា “អញនឹងចម្រើនភាវនា” ក៏គិតដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយនោះឯង, សូម្បីការចម្រើនភាវនា ក៏ចម្រើនដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយនោះឯង, សូម្បីពិចារណាថា “ភាវនាអញចម្រើនហើយ” ក៏ពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយដូចគ្នា ។

សូម្បីកាលគិតថា “អញនឹងធ្វើការទន់ភ្លន់ចំពោះអ្នកធំ” ដូច្នេះ ក៏គិតដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយនោះឯង, សូម្បីកាលធ្វើ ក៏ធ្វើដោយកាមាវចរកុសលចិត្ត ៨ ដួងនោះដួងណាមួយ, សូម្បីពិចារណាថា “ការទន់ភ្លន់គឺអញធ្វើហើយ” ក៏ពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះដួងណាមួយ; សូម្បីកាលគិតថា “អញនឹងធ្វើកម្ម គឺការខ្វល់ខ្វាយផ្លូវកាយ” ដូច្នេះក្តី, កាលធ្វើក្តី, កាលពិចារណាថា “អញធ្វើការខ្វល់ខ្វាយហើយ” ដូច្នេះក្តី ក៏ពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ; កាលគិតថា “អញនឹងឱ្យចំណែកបុណ្យ” ក្តី, កាលកំពុងឱ្យក្តី, កាលពិចារណាថា “ចំណែកបុណ្យ គឺអញឱ្យហើយ” ក្តី; កាលគិតថា “អញនឹងអនុមោទនាចំណែកបុណ្យ ឬកុសលដែលនៅសល់” ក្តី ក៏គិតដោយកាមា

វចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ, កាលអនុមោទនាក្តី ក៏អនុមោទនាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ, កាលពិចារណាថា "ពាក្យអនុមោទនា គឺអញអនុមោទនាហើយ" ក៏ពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ; សូម្បីកាលគិតថា "អញនឹងសម្តែងធម៌" ក៏គិតដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ ។ កាលសម្តែងក្តី ក៏សម្តែងដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ កាលពិចារណាថា "អញសម្តែងធម៌ទេសនាហើយ" ក្តី ក៏ពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ; កាលគិតថា "អញនឹងស្តាប់ធម៌" ក្តី ក៏គិតដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ, កាលស្តាប់ក្តី ក៏ស្តាប់ដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ; កាលគិតថា "អញស្តាប់ធម៌ហើយ" ក្តី ក៏ពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ, កាលគិតថា "អញនឹងធ្វើទិដ្ឋិឱ្យត្រង់" ក្តី ក៏គិតដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ, កាលធ្វើទិដ្ឋិ ឱ្យត្រង់ក្តី ក៏ធ្វើដោយកាមាវចរកុសលចិត្ត ញាណសម្បយុត្ត ៤ ដួងនោះ ដួងណាមួយ; កាលពិចារណាថា "ទិដ្ឋិដ៏ត្រង់ គឺអញធ្វើហើយ" ក្តី ក៏ពិចារណាដោយកាមាវចរកុសលចិត្ត ៨ ដួងនោះ ដួងណាមួយ ៕

## សម្ដែងអំពីអនន្ត វត្ថុមិនមានទីបំផុត ៤ យ៉ាង

ក្នុងឋាន (នៃកាមាវចរកុសលចិត្ត ៨) នេះ លោកកាន់យក ដោយ អនន្ត ៤ យ៉ាង; ពិតណាស់ **អនន្ត** មាន ៤ យ៉ាង គឺ

**១.អាកាសោ អនន្តោ** អាកាសមិនមានទីបំផុត

**២.ចក្កវាឡានិ អនន្តានិ** ចក្រវាឡមិនមានទីបំផុត

**៣.សត្តនិកាយោ អនន្តោ** ពួកសត្វមិនមានទីបំផុត

**៤.ពុទ្ធញ្ញាណំ អនន្តំ** ពុទ្ធញ្ញាណមិនមានទីបំផុត ។

មែនហើយ ការកំណត់អាកាសថា "ក្នុងទិសបូព៌ា ឬទិសបស្ចិម ក្នុងទិសឧត្តរ ក្នុងទិសទក្សិណ មានប៉ុណ្ណេះរយយោជន៍ ឬប៉ុណ្ណេះពាន់យោជន៍" ដូច្នេះ រមែងមិនបាន ។ សួរថា គេយកញញួរដែកប៉ុនភ្នំសិនេរុ ធ្វើផែនដីឱ្យបែកជាចំណែក ហើយបោះទៅ ញញួរដែកក៏គប្បីធ្លាក់ទៅខាងក្រោម ដោយពិត; មិនមានទីរងទទួលទុកបានទេ; ឈ្មោះថា **អាកាស** ជាអនន្ត គឺមិនមានទីបំផុតយ៉ាងនេះ ។

សូម្បីការកំណត់ចក្រវាឡទាំងឡាយថា មានច្រើនរយ ឬច្រើនពាន់ ឬថា ច្រើនសែនចក្រវាឡ រមែងមិនបាន ។ មែនពិត ប្រសិនបើថា ស្ដេចមហាព្រហ្មទាំង ៤ អង្គ អ្នកកើតក្នុងអកនិដ្ឋភព អ្នកប្រកបដោយភាពរហ័ស អាចឆ្លងសែនចក្រវាឡ ទៅដោយពេលត្រឹមតែប៉ុនគ្រាប់ព្រួញដ៏លឿនរហ័ស

របស់ពួកខ្មាន់ធ្នូ អ្នកមានកម្លាំងខ្លាំងក្លា អាចឆ្លងម្លប់ត្នោតត្រង់ទទឹង គប្បីរត់ទៅដោយរហ័សនោះ ដោយគិតថា "អញនឹងមើលទីបំផុតនៃចក្រវាឡ" ដូច្នេះ, ស្តេចមហាព្រហ្មទាំងនោះ មិនទាន់ឃើញទីបំផុតនៃចក្រវាឡ ក៏គប្បីបរិនិព្វានបាត់; ឈ្មោះថា **ចក្រវាឡ** ទាំងឡាយជាអនន្ត (គឺមិនមានទីបំផុត) យ៉ាងនេះ ។

ក៏ប្រមាណនៃសត្វដែលនៅក្នុងទឹក និងនៅលើគោកទាំងឡាយ ក្នុងចក្រវាឡទាំងឡាយ មានប្រមាណប៉ុណ្ណេះ រមែងមិនមាន, **ពួកសត្វទាំងឡាយ** ឈ្មោះថាជាអនន្ត (គឺមិនមានទីបំផុត) យ៉ាងនេះ ។

**ពុទ្ធញ្ញាណ** ឈ្មោះថា អនន្ត (គឺមិនមានទីបំផុត) ជាងអនន្តទាំង ៣ នោះដោយពិត ។ កុសលចិត្តដែលជាកាមាវចរ សហគតៈដោយសោមនស្ស ជាញាណសម្បយុត្ត ជាអសង្ខារិក កើតឡើងច្រើនដល់សត្វមួយ (ប្រភេទ) របស់សត្វទាំងឡាយដែលមិនមានប្រមាណ ក្នុងចក្រវាឡដែលរកប្រមាណមិនបាន ដោយប្រការដូច្នេះ, កុសលចិត្តច្រើនដួងរមែងកើតឡើងដល់សត្វច្រើន ។ សូម្បីកុសលចិត្តទាំងអស់នោះ ឈ្មោះថា រមែង**ដល់ចំណែកតែមួយ** ដោយអត្ថថា ជាកាមាវចរ, ដោយអត្ថថា ជាសហគតៈ ដោយអត្ថថា ជាសោមនស្ស, ដោយអត្ថថា ជាញាណសម្បយុត្ត, ដោយអត្ថថា ជាអសង្ខារិក; មហាចិត្តដែលសហគតៈដោយសោមនស្ស ជាតិហេតុកៈ ជាអសង្ខារិក មាន

តែមួយដួងប៉ុណ្ណោះ, មហាចិត្ត ជាអសង្ខារិក ក៏ដូចគ្នាដែរ ។ល។ ចិត្តដែលសហគតៈដោយឧបេក្ខាញាណវិប្បយុត្ត ជាទុហេតុកៈ ជាសសង្ខារិកក៏ដូចគ្នា ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់កំណត់កាមាវចរកុសលចិត្តសូម្បីទាំងអស់ ដែលកើតឡើងដល់សត្វទាំងឡាយ មិនមានប្រមាណ ក្នុងចក្រវាឡ ដែលមិនមានប្រមាណយ៉ាងនេះ ដោយសព្វញ្ញុតញ្ញាណ ដូចថ្លឹងដោយជញ្ជីងធំ ដូចដាក់ក្នុងនាឡិហើយរាប់ដូច្នោះ ទ្រង់ធ្វើឱ្យជាចំណែក ៨ ចំណែកប៉ុណ្ណោះ ហើយទ្រង់សម្តែងចិត្តទាំងឡាយនោះថា មាន ៨ ប៉ុណ្ណោះ ដោយសភាវៈដូចគ្នា ។

ក្នុងឋាននេះ ឈ្មោះថា **ការប្រមូលមកនូវបុណ្យ ៦ យ៉ាង** ដែលទ្រង់កាន់យកទៀត; ពិតណាស់ បុណ្យធ្វើដោយខ្លួនឯង = **សយង្ការំ** ក៏មាន, បុណ្យដែលអ្នកដទៃធ្វើ = **បរង្ការំ** ក៏មាន, បុណ្យដែលធ្វើដោយដៃរបស់ខ្លួន = **សាហត្ថិកំ** ក៏មាន, បុណ្យដែលបញ្ជាឱ្យអ្នកដទៃធ្វើ = **អាណត្តិកំ** ក៏មាន បុណ្យដែលធ្វើដោយការដឹង = **សម្បជានកតំ** ក៏មាន, បុណ្យដែលធ្វើដោយការមិនដឹង = **អសម្បជានកតំ** ក៏មាន ។ បណ្តាបុណ្យទាំង ៦ នោះ បុណ្យដែលធ្វើតាមធម្មតារបស់ខ្លួនឈ្មោះថា **សយង្ការំ** ។ បុណ្យដែលឃើញអ្នកដទៃធ្វើ ក៏ធ្វើឈ្មោះថា **បរង្ការំ** ។ បុណ្យដែលធ្វើដោយដៃខ្លួនឯង ឈ្មោះថា **សាហត្ថិកំ** ។ បុណ្យដែលប្រើឱ្យបុគ្គលដទៃធ្វើ ឈ្មោះថា **អាណត្តិកំ** ។ បុណ្យដែលជឿកម្ម និងផលហើយធ្វើឈ្មោះថា **សម្បជានកតំ** ។ បុណ្យដែល

មិនដឹង ( មិនជឿ) កម្មក្តី ផលក្តី ហើយធ្វើ ឈ្មោះថា **អសម្បជានកតំ** ។

បណ្តា**បុណ្យទាំង ៦** នោះ ក៏បុគ្គលកាលធ្វើដោយខ្លួនឯង ក៏រមែងធ្វើដោយកុសលចិត្ត ៨ ដួងនេះ ដួងណាមួយនោះឯង, កាលធ្វើអាស្រ័យអ្នកដទៃក្តី កាលធ្វើដោយដៃខ្លួនឯងក្តី កាលប្រើបុគ្គលដទៃឱ្យធ្វើក្តី ក៏មែងធ្វើដោយកុសល ចិត្ត ៨ ដួងនេះ ដួងណាមួយដូចគ្នា, តែការធ្វើដោយការដឹង រមែងធ្វើប្រកបដោយញាណ ៤៧ ដួង, ការធ្វើដោយការមិនដឹង រមែងធ្វើមិនប្រកបដោយញាណ ៤ ដួង ។

សូម្បីក្នុងឋាននេះ ព្រះមានព្រះភាគទ្រង់កាន់យក **ទក្ខិណាវិសុទ្ធិ ៤ យ៉ាង** ដទៃទៀត គឺ

១-ការដែលបច្ច័យទាំងឡាយកើតឡើងដោយធមិ **ធម្មិកៈ**

២-ចេតនាមានកម្លាំងខ្លាំង **ចេតនាមហត្តៈ**

៣-ដល់ព្រមដោយវត្ថុ **វត្ថុសម្បត្តិ**

៤-ភាពជាអ្នកច្រើនលើសដោយគុណ **គុណាតិរេកតា** ។

បណ្តាទក្ខិណាវិសុទ្ធិ ៤ យ៉ាងនោះ បច្ច័យទាំងឡាយដែលកើតឡើងដោយប្រពៃតាមធមិ ឈ្មោះថា **ធម្មិកៈ**, ក៏កាលបុគ្គលជឿមាំស៊ប់ ហើយឱ្យ ឈ្មោះថា **ចេតនាមហត្តៈ**, ភាពនៃបុគ្គលអ្នកទទួលជាព្រះខីណាស្រព ឈ្មោះថា **វត្ថុសម្បត្តិ**, ការដែលព្រះខីណាស្រពអង្គនោះឯង ចេញពីនិរោធសមា

បត្តិ ឈ្មោះថា **គុណាតិរេកតា** ។ កាលបុគ្គលអាចប្រមូលទក្ខិណាវិសុទ្ធិ ៤ នេះមកហើយឱ្យកាមាវចរកុសល រមែងឱ្យវិបាកក្នុងអត្តភាពនេះដោយពិត, ដូចកាមាវចរកុសលដែលឱ្យវិបាកដល់បុណ្ណកសេដ្ឋី នាយកាលវលិយៈ និងនាយមាលាការឈ្មោះសុមនៈជាដើម * ។

ក៏កាលពោលដោយសង្ខេប សូម្បីកាមាវចរកុសលចិត្តទាំងអស់នោះ ឈ្មោះថា **តែមួយប៉ុណ្ណោះ** ដោយអត្ថថា **ចិត្ត** និង **វិចិត្រ** ព្រោះធ្វើឱ្យវិចិត្រ ។ ពោលដោយអំណាចនៃវេទនាមាន ២ យ៉ាង គឺសហគតៈដោយ **សោមនស្ស** និងសហគតៈដោយ**ឧបេក្ខា**, **អសង្ខារិកមហាចិត្ត** ដែលសហគតៈដោយ **សោមនស្ស** ជា **ញាណសម្បយុត្ត** និង**អសង្ខារិក** មហាចិត្តដែលសហគតៈដោយ **ឧបេក្ខា** ជា **ញាណសម្បយុត្ត** ជា ៤ យ៉ាង, ដោយអំណាចនៃការសម្តែងចែកញាណ ឈ្មោះថា **តែមួយប៉ុណ្ណោះ** ព្រោះអត្ថថា **ជាសម្បយុត្ត** និងអត្ថថា **ជាអសង្ខារិក** ។ **សសង្ខារិក** ជាញាណសម្បយុត្ត **អសង្ខារិក** ដែលជា**ញាណវិប្បយុត្ត** និង**សសង្ខារិក** ដែលជា**ញាណវិប្បយុត្ត** ក៏ដូចគ្នា; ដោយប្រការដូច្នេះ ក្នុងកាមាវចរកុសលចិត្តនេះ ទើបមាន ៤ យ៉ាង ដោយអំណាចនៃការសម្តែង ការចែកញាណ ពោលដោយការចែកអសង្ខារ និង

---

* រឿងបុណ្ណកសេដ្ឋី និងសុមនមាលាការ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងធម្មបទដ្ឋកថា ។ រឿងកាលវលិយៈ គប្បីជ្រាបក្នុងអដ្ឋកថា ទេវទហសូត្រ មជ្ឈិមនិកាយ (បបញ្ចសូទនី) ។

សសង្ខារហើយ ក៏បានកុសលចិត្ត ៨ ដួងប៉ុណ្ណោះ គឺអសង្ខារិក ៤ ដួង, សសង្ខារិក ៤ ដួង ។ ព្រះមានព្រះភាគព្រះអង្គទ្រង់ជាសព្វញ្ញូ, ទ្រង់ជាអ្នកប្រសើរជាងគណៈទាំងឡាយ, ទ្រង់ជាមុនី, ជាអ្នកប្រសើរបំផុត, ទ្រង់ជ្រាបកាមាវចរកុសលចិត្តទាំងនោះ តាមសេចក្ដីពិតហើយ ទើបទ្រង់ប្រាប់, សម្ដែង, បញ្ញត្តិ, តាំងទុក, បើកបង្ហាញ, ចែក និងទ្រង់ធ្វើឱ្យងាយដូច្នេះឯង ។

**និទ្ទេសសម្ដែងអំពីកាមាវចរកុសលចិត្ត**

**ក្នុងអដ្ឋកថាធម្មសង្គហៈឈ្មោះអដ្ឋសាលិនី**

**ចប់ដោយបរិបូរណ៍**

# អធិប្បាយអំពីរូបាវចរកុសល

## ពណ៌នាអំពីបឋមជ្ឈានចតុក្កន័យ

ឥឡូវនេះ ដើម្បីនឹងសម្តែងរូបាវចរកុសល ព្រះមានព្រះភាគទើបទ្រង់ផ្តើមពាក្យជាដើមថា “**កតមេ ធម្មា កុសលា** = ធមិជាកុសលតើដូចម្តេច? ” ។ បណ្តាពាក្យទាំងនោះ ពាក្យថា “**រូបូបបត្តិយា មគ្គំ ភាវេតិ** = ព្រះយោគាវចរចម្រើនមគ្គ ដើម្បីចូលដល់រូបភព” សេចក្តីថា រូបភពលោកហៅថា **រូប** ។ ពាក្យថា “**ឧបបត្តិ** = ការចូលដល់” បានដល់ ការបង្កើត គឺការកើត, គឺថា ការកើតព្រម ។ ពាក្យថា “**មគ្គោ**” បានដល់ឧបាយ ។ ក៏ការសម្គាល់នូវពាក្យសម្តី ក្នុងពាក្យថាមគ្គនេះ ដូច្នេះ ៖-

សភាវធមិដែលឈ្មោះថា **មគ្គ** ព្រោះអត្ថថា រមែងស្វែងរក គឺរមែងស្វះស្វែងរក, រមែងឱ្យកើត និងរមែងឱ្យសម្រេចនូវការចូលដល់នោះ ។ មានអធិប្បាយថា “ការចូលដល់, ការបង្កើត, ការកើត និងការកើតព្រមរមែងមានក្នុងរូបភពដោយមគ្គណា, ព្រះយោគាវចររមែងចម្រើនមគ្គនោះ ” ។

សួរថា ក៏ការចូលដល់រូបភពដោយមគ្គនេះ បានដោយការនិយមឬ?

ឆ្លើយថា មិនមែនដោយការនិយមទេ ។

ព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរចម្រើនសមាធិ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានចិត្តតាំងនៅមាំហើយ រមែងដឹងច្បាស់ រមែងដឹងព្រម និងរមែងឃើញតាមសេចក្តីពិត”[៦៩] ព្រោះថា សូម្បីការឈានកន្លងរូបភព ដោយចំណែកនៃការត្រាស់ដឹង រមែងមិនមាន ក៏ប៉ុន្តែ ឈ្មោះថា មគ្គដទៃក្រៅអំពីមគ្គនេះ ដើម្បីការចូលដល់រូបភព រមែងមិនមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “ព្រះយោគាវចរចម្រើនមគ្គដើម្បីចូលដល់រូបភព”។ ម្យ៉ាងទៀត កាលបើពោលដោយអត្ថ មគ្គនេះ ជាចេតនាក៏មាន ជាធម៌សម្បយុត្តដោយចេតនាក៏មាន, មានទាំង ២ គឺទាំងជាចេតនា ទាំងជាធម៌ដែលសម្បយុត្តដោយចេតនា ។

ពិតមែនហើយ **ចេតនា** ឈ្មោះថា **មគ្គ** ដូចក្នុងប្រយោគនេះថា “ម្នាលសារីបុត្រ យើង(តថាគត) រមែងដឹងទូទៅដល់នរក និងមគ្គ (ចេតនា) ដែលឱ្យសត្វទៅកាន់នរក”[៧០] ។

ធម៌ដែលសម្បយុត្តដោយចេតនា ឈ្មោះថា មគ្គ (ផ្លូវ) ដូចក្នុងប្រយោគនេះថា “ធម៌ទាំងនេះ គឺសទ្ធា ហិរិ កុសល និងទាន ជាដំណើរផ្លូវរបស់សប្បុរស, ក៏សប្បុរសរមែងពោលផ្លូវនេះថា ជាផ្លូវទិព្វ ព្រោះថា

---

[៦៩] សំ. ខ., សំ. ម. ។

[៧០] ម. ម. ។

បុគ្គលរមែងទៅកាន់ទេវលោកដោយផ្លូវនេះ”[៧១] ។

ចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី ឈ្មោះថា **មគ្គ** ដូចក្នុងព្រះសូត្រទាំងឡាយ **មានសង្ខាររូបបត្តិសូត្រ**ជាដើមថា “ម្នាលភិក្ខុទាំងឡាយ នេះជាមគ្គ, នេះជាបដិបទា”[៧២] ។ ប៉ុន្តែ ក្នុងទីនេះ ទ្រង់ប្រាថ្នាយកធម៌ដែលសម្បយុត្តដោយចេតនា ព្រោះព្រះបាលីថា **“ឈានំ”** ។ ប៉ុន្តែព្រោះចេតនាសម្បយុត្តដោយឈាន រមែងជាហេតុឱ្យបដិសន្ធិ ព្រោះហេតុនោះ ចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី រមែងសមគួរដូចគ្នា ។

ពាក្យថា **ភាវេតិ** រមែងចម្រើន បានដល់ រមែងឱ្យកើត គឺឱ្យបង្កើត គឺថា ឱ្យច្រើន ។ សេចក្តីនៃការចម្រើន (ភាវនា) ក្នុងទីនេះ មានត្រឹមតែប៉ុណ្ណោះសិន ។ ប៉ុន្តែ ក្នុងទីដទៃ សេចក្តីនៃឧបសគ្គ មានសេចក្តីដោយឡែកម្យ៉ាងទៀត គឺ **សម្ភាវនា** ការលើកតម្កើង **បរិភាវនា** ការអប់រំ **វិភាវនា** ការចង្អុលបង្ហាញ ។

បណ្តាបទទាំង៣នោះ សេចក្តីនេះថា “ម្នាលឧទាយី សាវ័កទាំងឡាយរបស់តថាគតក្នុងសាសនានេះ រមែងលើកតម្កើងតថាគតក្នុងអធិសីលថា

[៧១] អំ. អដ្ឋក. ។

[៧២] ម. ឧ. ។

‘ព្រះសមណគោតម មានសីលប្រកបដោយសីលក្ខន្ធយ៉ាងក្រៃលែង” [៧៣] ដូច្នេះ ឈ្មោះថា **សម្ភាវនា** បានដល់ ការជឿដ៏មាំទាំ ។ សេចក្ដីនេះថា “សមាធិដែលសីលអប់រំហើយ រមែងមានផលច្រើន មានអានិសង្សច្រើន, បញ្ញាដែលសមាធិអប់រំហើយ រមែងមានផលច្រើន រមែងមានអានិសង្សច្រើន, ចិត្តដែលបញ្ញាអប់រំហើយ រមែងរួចចាកផុតអាសវៈទាំងឡាយ ដោយប្រពៃមែនពិត” [៧៤] ឈ្មោះថា **បរិភាវនា** បានដល់ “ការអប់រំ” ។ សេចក្ដីនេះថា “អញ្ជើញលោកចង្អុលបង្ហាញនូវរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណចុះ” ឈ្មោះថា **វិភាវនា** បានដល់ ការចង្អុលបង្ហាញធ្វើជាបញ្ញា ។

ចំណែកបដិបទានេះថា “ម្នាលឧទាយី នៅមានចំណុចដទៃទៀត តថាគតបានប្រាប់បដិបទាដល់សាវ័កទាំងឡាយ ដោយប្រការដែលសាវ័កទាំងឡាយរបស់តថាគត បដិបត្តិតាមហើយ ឈ្មោះថា រមែងចម្រើនសតិប្បដ្ឋាន ៤” ឈ្មោះថា សម្រេចហើយដោយភាវនា ព្រោះអត្ថថា ឱ្យកើត គឺឱ្យចម្រើន ។ ក្នុងទីនេះ បដិបទានេះប៉ុណ្ណោះ ទ្រង់ប្រាថ្នាយកហើយ ព្រោះហេតុនោះ ទើបត្រាស់ថា **ភាវេតិ** បានដល់ “រមែងឱ្យកើត គឺឱ្យបង្កើតឡើង ឱ្យចម្រើនឡើង” ។

---

[៧៣] ម. ម. ។

[៧៤] ទី. ម. ។

សួរថា ព្រោះហេតុអ្វី ក្នុងកាមាវចរកុសលនិទ្ទេស ទ្រង់ធ្វើទេសនាមានធម៌ជាប្រធាន ប៉ុន្តែ ក្នុងរូបាវចរនិទ្ទេសមិនធ្វើដូចគ្នាយ៉ាងនោះទេ គឺទ្រង់បានធ្វើទេសនាមានបុគ្គលជាប្រធានទៅវិញ? ឆ្លើយថា ព្រោះនឹងជម្រះបដិបទាឱ្យហ្មត់ចត់ ។ ពិតមែន រូបាវចរនិទ្ទេសនេះ ព្រះយោគាវចរគប្បីជម្រះឱ្យហ្មត់ចត់បានដោយបដិបទាណាមួយ ក្នុងចំណោមបដិបទាទាំង ៤ បើវៀរចាកបដិបទាចេញហើយ នឹងកើតដូចកាមាវចរ មិនបានឡើយ ។ ម្យ៉ាងទៀត កាលបដិបទានេះនៅមាន បុគ្គលអ្នកបដិបត្តិទើបមាន ព្រោះហេតុដូច្នោះ ដើម្បីសម្ដែងសេចក្ដីនោះ ទើបទ្រង់សម្ដែងទេសនាដែលមានបុគ្គលជាប្រធាន ហើយត្រាស់ថា "ព្រះយោគាវចរចម្រើនមគ្គ ដើម្បីចូលដល់រូបភព" ។

ពាក្យថា **"វិវិច្ចេវ កាមេហិ"** សេចក្ដីថា ស្ងាត់ហើយ គឺវៀរហើយ គឺថាឃ្លានកន្លងហើយចាកកាមទាំងឡាយ ។ ក៏**ឯវ**សព្ទ ក្នុងពាក្យថា **វិវិច្ចេវ កាមេហិ** នេះ គប្បីជ្រាបថា ប្រើក្នុងអត្ថថា និយម ប្រាកដ ។ ក៏ព្រោះ**ឯវ**សព្ទមានអត្ថថា ប្រាកដដូច្នោះ ទើបទ្រង់សម្ដែងនូវការដែលកាមទាំងឡាយ សូម្បីមិនមានក្នុងសម័យដែលចូលបឋមជ្ឈាននោះ ជាបដិបក្ខចំពោះបឋមជ្ឈាននោះ នឹងសម្ដែងដល់ការសម្រេចបឋមជ្ឈាននោះ ដោយការលះកាមបានហើយ ។ សួរថា តើយ៉ាងណា? ឆ្លើយថា ក៏កាលបុគ្គលកំណត់ទៅយ៉ាងនេះថា ស្ងាត់ចាកកាមទាំងឡាយដូចនេះ ឈាននេះទើបប្រាកដ ។ ក៏ឯ

កាមទាំងឡាយជាបដិបក្ខចំពោះឈាននេះពិត ព្រោះកាមទាំងឡាយនៅមាន ឈានក៏ប្រព្រឹត្តទៅមិនបាន ប្រៀបដូចកាលសេចក្តីងងឹតនៅមាន ឯពន្លឺភ្លឺស្វាងនៃប្រទីបក៏មិនមាន, ការសម្រេចឈាននោះបាន ព្រោះការលះកាមទាំងនោះ ប្រៀបដូចការលះច្រាំងនេះ (ត្រើយខាងអាយ) ទើបទៅដល់ច្រាំងនោះ (ត្រើយខាងនាយ) បាន ព្រោះហេតុដូច្នោះ **ឯវ**សព្ទនោះ ទើបធ្វើសេចក្តីថា ប្រាកដ ។

ក្នុងបឋមជ្ឈាននោះ ទើបមានពាក្យជំទាស់ថា ព្រោះហេតុអ្វី **ឯវ** សព្ទនេះ លោកពោលទុកក្នុងបទខាងដើមប៉ុណ្ណោះ, មិនពោលទុកក្នុងបទខាងក្រោយ, ព្រះយោគាវចរគ្រាន់តែស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយគប្បីចូលឈានបានឬ? ឆ្លើយថា សេចក្តីនេះ មិនគប្បីយល់ឃើញយ៉ាងនេះទេ ព្រោះថា **ឯវ**សព្ទនេះ លោកពោលទុកក្នុងបទខាងដើម ព្រោះការជម្រុះចេញនូវកាមនោះ ។ ព្រោះថា ឈាននេះជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយនោះឯង ព្រោះជាហេតុឈានកន្លងនូវកាមធាតុ និងព្រោះជាបដិបក្ខចំពោះកាមរាគៈ; ដូចយ៉ាងដែលត្រាស់ទុកថា "នេក្ខម្មៈ គឺការលាស់ចេញចាកកាមទាំងឡាយនេះ"[៧៥] ។ ម្យ៉ាងទៀត **ឯវ**សព្ទនេះ សូម្បីក្នុងបទក្រោយ ក៏គួរ

---

[៧៥] ទី. បា., ខុ. ឥតិ. ។

នាំមកពោលទុកក្នុងទីនេះ ដូចដែលត្រាស់ទុកថា **“ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ** = ម្នាលភិក្ខុទាំងឡាយ សមណៈទីមួយ មានក្នុងធម្មវិន័យនេះប៉ុណ្ណោះ សមណៈទីពីរក៏មានក្នុងធម្មវិន័យនេះដូចគ្នា[៧៦] ។ ព្រោះនរណាៗ ក៏មិនលះអកុសលធម៌ ពោលគឺនីវរណៈ សូម្បីពួកដទៃវៀរចាកកាមនេះហើយ ក៏មិនអាចចូលឈាននេះបាន; គប្បីប្រើ **ឯវ** សព្ទនេះ សូម្បីក្នុងបទទីពីរនេះថា **“វិវិច្ចេវ កាមេហិ វិវិច្ចេវ អកុសលេហិ ធម្មេហិ”** ក៏ដោយ ព្រះតម្រាស់ដែលមិនទូទៅថា **វិវិច្ច** នេះ វិវេកទាំងអស់មានតទង្គវិវេកជាដើម និងកាយវិវេកជាដើម រមែងរួមចុះសូម្បីក្នុងបទទាំងពីរក៏ពិតមែនហើយ; ប៉ុន្តែថា ក្នុងទីនេះ គប្បីឃើញវិវេក ៣ ប៉ុណ្ណោះ គឺកាយវិវេក ចិត្តវិវេក និងវិក្ខម្ភនវិវេក ។

ក៏ដោយបទថា **កាមេហិ** នេះ វត្ថុកាមទាំងឡាយ ដែលត្រាស់ទុកក្នុងនិទ្ទេសដោយន័យជាដើមថា “វត្ថុកាមតើដូចម្តេច? គឺរូបដែលគួរពេញចិត្ត”[៧៧] ។ ឯកិលេសកាមទាំងឡាយ ត្រាស់ទុកក្នុងនិទ្ទេសនោះ ក្នុងវិភង្គយ៉ាងនេះថា “ឆន្ទៈ ឈ្មោះថា កាម, រាគៈ ឈ្មោះថា កាម, ឆន្ទរាគៈ ឈ្មោះថា កាម, សង្កប្បកាមៈ ឈ្មោះថា រាគៈ, កាមសង្កប្បរាគៈ ឈ្មោះថា កាម,

---

[៧៦] ម. មូ., អំ. ចតុក្ក. ។

[៧៧] ខុ. មហា. (កាមសុត្តនិទ្ទេស) ។

ធម៌ទាំងនេះ ហៅថា កាម" [៧៨], អកុសលទាំងអស់នោះ គប្បីឃើញថារួមគ្នាក្នុងទីនេះឯង ។ ក៏កាលបើដូច្នេះ ត្រង់ពាក្យថា **វិវិច្ចេវ កាមេហិ** = ស្ងាត់ចាកកាមទាំងឡាយ នឹងគប្បីមានសេចក្តីថា ស្ងាត់ហើយចាកវត្ថុកាមទាំងឡាយខ្លះ ក៏សមគួរ ។ ដោយពាក្យថា **វិវិច្ចេវ កាមេហិ** នោះ ត្រាស់ថា ជាកាយវិវេក ។

ពាក្យថា "**វិវិច្ច អកុសលេហិ ធម្មេហិ** = ស្ងាត់ហើយចាកអកុសលទាំងឡាយ" អធិប្បាយថា ស្ងាត់ហើយចាកកិលេសកាមទាំងឡាយ ឬអកុសលធម៌ទាំងអស់ដូច្នេះក៏សមគួរ ។ ដោយពាក្យថា **វិវិច្ច អកុសលេហិ ធម្មេហិ** នោះ ត្រាស់ដល់ចិត្តវិវេក ។ ក៏បណ្តាបទទាំង ២ នោះ បទដំបូងរមែងត្រាស់ការលះសេចក្តីសុខក្នុងកាម ព្រោះត្រាស់ដល់ការស្ងាត់ចាកវត្ថុកាមទាំងឡាយនោះ, បទទីពីរ ត្រាស់ដល់ការអធិប្បាយ ដល់ការកំណត់សេចក្តីសុខក្នុងនេក្ខម្មៈ ព្រោះត្រាស់ដល់ការស្ងាត់ចាកកិលេសកាមទាំងឡាយ ។ ក៏ព្រោះត្រាស់ដល់ការស្ងាត់ចាកវត្ថុកាម និងកិលេសកាម ដោយប្រការដូច្នេះឯង គប្បីជ្រាបគោលសេចក្តីថា បណ្តាពាក្យទាំងនោះ ដោយបទដំបូង ត្រាស់ការលះសង្កិលេសវត្ថុ, បទទីពីរ ត្រាស់ការលះសង្កិលេស ។ បទដំបូង ត្រាស់ការលះហេតុនៃការស្មាក់ស្មើរ មិននឹងនរ, បទទីពីរ ត្រាស់ការលះហេតុនៃ

---

[៧៨] ខុ. មហា. (កាមសុត្តនិទ្ទេស), អភិ. ។

ភាពជាពាល; ដោយបទដំបូង ត្រាស់បយោគសុទ្ធិ, បទទីពីរត្រាស់អប់រំអធ្យាស្រ័យនៃចិត្តដូចនេះក៏មាន ។ ក្នុងកាម តាមពាក្យថា **កាមេហិ** នេះ ក្នុងចំណែកវត្ថុកាម មានន័យត្រឹមតែប៉ុណ្ណេះជាមុន ។ ចំណែកក្នុងកិលេសកាម កាមច្ឆន្ទៈនោះឯង មានប្រភេទមិនមែនតិច ដោយពាក្យជាដើមយ៉ាងនេះ គឺឆន្ទៈ ឈ្មោះថា កាម, រាគៈ ឈ្មោះថា កាម, លោកប្រាថ្នាយកថា កាម ។ ក៏កាមច្ឆន្ទៈនោះ សូម្បីរាប់បញ្ចូលជាមួយអកុសលធម៌ ប៉ុន្តែ ព្រោះជាបដិបក្ខចំពោះអង្គឈាន ទើបត្រាស់ទុកចំណែកមួយក្នុងវិភង្គ ដោយន័យមានជាអាទិ៍ថា "បណ្តាកាមទាំងនោះ កាមច្ឆន្ទៈ តើដូចម្តេច?" ។

ន័យមួយទៀត កាមត្រាស់ទុកក្នុងបទដំបូង ព្រោះជាកិលេសកាម, ក្នុងបទទីពីរត្រាស់ទុក ព្រោះរាប់បញ្ចូលក្នុងអកុសល ។ ក៏ព្រោះកាមនោះចែកចេញមិនមែនតិច ទើបមិនត្រាស់ថា "**កាមតោ**" ទេ, ប៉ុន្តែត្រាស់ថា "**កាមេហិ**" ។ ម្យ៉ាងទៀត សូម្បីមានពួកធម៌ដទៃដែលជាអកុសលធម៌ ប៉ុន្តែត្រាស់ចំពោះនីវរណធម៌ប៉ុណ្ណោះ ដោយទ្រង់កាន់យកនីវរណៈជាសត្រូវ និងរារាំងអង្គឈានខាងលើទុកក្នុងវិភង្គ ដោយន័យមានជាអាទិ៍ថា "ក្នុងមាតិកាទាំងនោះ ធម៌ជាអកុសលតើដូចម្តេច? គឺកាមច្ឆន្ទៈ" [៧៩] ។ ពិតមែនហើយ នីវរណៈធម៌ទាំងឡាយជាសត្រូវចំពោះអង្គឈាន, អធិប្បាយថា នីវរណៈ

[៧៩] អភិ. ។

ទាំងឡាយជាបដិបក្ខ, ជាតួកម្ចាត់, ជាតួពិឃាតអង្គឈានទាំងនោះ ។ ពិត យ៉ាងនោះមែនហើយ ក្នុងគម្ពីរ **បេដកៈ**[៨០] បានពោលទុកថា “សមាធិជាបដិបក្ខចំពោះកាមច្ឆន្ទៈ, បីតិជាបដិបក្ខចំពោះព្យាបាទ, វិតក្កៈជាបដិបក្ខចំពោះថីនមិទ្ធ, សុខជាបដិបក្ខចំពោះឧទ្ធច្ចកុក្កុច្ចៈ, វិចារៈជាបដិបក្ខចំពោះវិចិកិច្ឆា” ដោយអាការយ៉ាងនេះ ក្នុងបទទាំង ២ នោះ រមែងត្រូវបានត្រាស់វិវេកជាគ្រឿងសង្កត់កាមច្ឆន្ទៈ ដោយបទថា “**វិវិច្ចេវ កាមេហិ**” នេះ ត្រាស់វិវេកជាគ្រឿងសង្កត់នីវរណៈទាំង ៥ ដោយបទថា “**វិវិច្ច អកុសលេហិ**” ។

ម្យ៉ាងទៀត ពោលដោយន័យ ដែលនៅមិនទាន់បានអធិប្បាយ រមែងត្រូវបានត្រាស់វិវេកជាគ្រឿងសង្កត់កាមច្ឆន្ទៈ ដោយបទទីមួយ **វិវិច្ចេវ កាមេហិ** រមែងត្រូវបានត្រាស់វិវេកជាគ្រឿងលះនីវរណៈដែលនៅសល់ ដោយបទទីពីរ (**វិវិច្ច អកុសលេហិ**) ។ ម្យ៉ាងទៀត បណ្តាអកុសលមូល ៣ យ៉ាង រមែងត្រូវបានត្រាស់វិវេកដោគ្រឿងសង្កត់លោភៈ ដែលជាអារម្មណ៍នៃកាមគុណ ៥ ប្រភេទ ដោយបទទីមួយ **វិវិច្ចេវ កាមេហិ**, ដោយបទទីពីរ **វិវិច្ច អកុសលេហិ** រមែងត្រូវបានត្រាស់វិវេកជាគ្រឿងសង្កត់ទោសៈ និងមោហៈជាអារម្មណ៍ដែលផ្សេងគ្នាដោយអាឃាតវត្ថុជាដើម ។ ម្យ៉ាងវិញទៀត បណ្តាធម៌ទាំងឡាយមានឱឃៈជាដើម ដោយបទដំបូង **វិវិច្ចេវ កាមេហិ** រមែង

[៨០] អដ្ឋ. យោ. ពន្យល់ថា គម្ពីរនេះ អធិប្បាយដោយព្រះមហាកច្ចាយនៈ ។

ត្រូវបានត្រាស់វិវេកដែលជាគ្រឿងសង្កត់កាមោឃៈ, កាមយោគៈ, កាមាសវៈ, កាមុបា្បទាន, អភិជ្ឈាកាយគន្ថៈ និងកាមរាគសញ្ញោជនៈ; ដោយបទទីពីរ **វិវិច្ច អកុសលេហិ** រមែងត្រូវបានត្រាស់វិវេកជាគ្រឿងសង្កត់ឱឃៈ, យោគៈ, អាសវៈ, ឧបាទាន, គន្ថៈ និងសញ្ញោជនៈដែលនៅសល់; ម្យ៉ាងទៀត ដោយបទដើម **វិវិច្ចេវ កាមេហិ** រមែងត្រូវបានត្រាស់វិវេកជាគ្រឿងសង្កត់តណ្ហា និងធម៌ដែលសម្បយុត្តដោយតណ្ហានោះ, ដោយបទទីពីរ **វិវិច្ច អកុសលេហិ** រមែងត្រូវបានត្រាស់វិវេក ជាគ្រឿងសង្កត់អវិជ្ជា និងធម៌ដែលសម្បយុត្តដោយអវិជ្ជានោះ ។ ន័យម្យ៉ាងទៀត ដោយបទដំបូង **វិវិច្ចេវ កាមេហិ** គប្បីជ្រាបថា ត្រាស់វិវេកជាគ្រឿងសង្កត់ចិត្ត ៨ ដួង ដែលសម្បយុត្តដោយលោភៈ, ដោយបទទីពីរ **វិវិច្ច អកុសលេហិ** រមែងត្រូវបានត្រាស់វិវេកជាគ្រឿងសង្កត់អកុសលចិត្ត ៤ ដួងដែលនៅសល់ ។ ការប្រកាសសេចក្តីក្នុងពាក្យនេះថា "**វិវិច្ចេវ កាមេហិ, វិវិច្ច អកុសលេហិ ធម្មេហិ**" ប៉ុណ្ណេះជាមុនសិន ៕

## សម្តែងអំពីអង្គឈាន

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងអង្គដែលបឋមជ្ឈានលះបានហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឥឡូវនេះ ដើម្បីសម្តែងសម្បយោគធម៌

ទើបត្រាស់ពាក្យជាដើមថា **"សវិតក្កំ សវិចារំ"** ។ បណ្តាបទទាំងនោះ ឈានត្រាស់ហៅថា **"សវិតក្កៈ សវិចារៈ"** ព្រោះការប្រព្រឹត្តទៅរួមជាមួយវិតក្កៈ និងវិចារៈ ឈ្មោះថា ដល់ភាវៈ ជារូបាវចរ ព្រោះសម្បយោគដោយអប្បនា ដោយការចែកលក្ខណៈជាដើម តាមដែលបានពោលអំពីខាងដើម, ប្រៀបដូចដើមឈើដែលមានផ្កា និងផ្លែដូច្នោះ ។ ប៉ុន្តែនៅក្នុងវិភង្គ លោកធ្វើទេសនាជាបុគ្គលាធិដ្ឋាន ដោយន័យមានជាអាទិ៍ថា "ព្រះយោគាវចរ ជាអ្នកចូលដល់ហើយ, ចូលដល់ព្រមហើយ ដោយវិតក្កៈនេះ, ដោយវិចារៈនេះ" [៨១] ។ ចំណែកសេចក្តីនៅក្នុងវិភង្គនោះ គប្បីយល់ឃើញតាមដែលពោលហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **វិវេកជំ** នេះ សេចក្តីស្ងាត់លោកហៅថា **វិវេក**, អធិប្បាយថា ប្រាសចាកនីវរណៈ ។ ន័យម្យ៉ាងទៀត ឈ្មោះថា **"វិវេក"** ព្រោះស្ងាត់ហើយ, អធិប្បាយថា គំនរធម៌ដែលសម្បយុត្តដោយឈានស្ងាត់ចាកនីវរណៈ ។ បីតិ និងសុខ ឈ្មោះថា **វិវេកជៈ** កើតអំពីវិវេក ព្រោះអត្ថថា កើតអំពីវិវេកនោះ ឬកើតក្នុងវិវេកនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បីតិ សុខំ** នេះ សេចក្តីថា បីតិ និងសេចក្តីសុខជាពាក្យដែលខ្ញុំអធិប្បាយទុកខាងដើមហើយនោះឯង ។ បណ្តាបីតិ

---

[៨១] អភិ. ។

និងសុខទាំងពីរនេះ បីតិ ៥ យ៉ាងមានប្រការតាមដែលពោលហើយ **ផរណា បីតិ** ជាឫសគល់នៃ**អប្បនាសមាធិ** ចម្រើនឡើងបានជាអង្គប្រកបរបស់សមាធិ លោកបំណងយកថា បីតិក្នុងអត្ថនេះ បីតិនេះ និងសុខនេះ មានចំពោះឈាន នេះ, ឬក្នុងឈាននោះ ព្រោះហេតុដូច្នោះ ឈាននេះ លោកទើបហៅថា មានបីតិ និងសុខដូចនេះ ។

ម្យ៉ាងវិញទៀត បីតិ និងសុខ ឈ្មោះថា **បីតិសុខ** ដូចសព្ទថា **ធម៌** និង **វិន័យ** ឈ្មោះថា **ធម្មវិន័យជាដើម** ។ បីតិ និងសុខ កើតអំពីវិវេក រមែង មានចំពោះឈាននេះ, ឬក្នុងឈាននេះ ព្រោះហេតុនោះ ឈាននោះ ទើប ឈ្មោះថា **មានបីតិ** និង**សុខ** ដែលកើតអំពីវិវេក ដូចពណ៌នាមកនេះ ។ ម្យ៉ាងដូចថា ឈានមានបីតិ និងសុខកើតអំពីវិវេក យ៉ាងណា, បីតិ និងសុខ កើតក្នុងអង្គឈាននេះ ក៏កើតអំពីវិវេកដូច្នោះដូចគ្នា ។ ម្យ៉ាងវិញទៀត បីតិ និងសុខនោះ មានចំពោះឈាននេះ ព្រោះហេតុដូច្នោះ លោកពោលថា បីតិ និងសុខកើតអំពីវិវេកដោយបទមួយប៉ុណ្ណោះ ក៏សមគួរ ។ ប៉ុន្តែនៅក្នុងវិភង្គ លោកពោលទុកដោយន័យជាដើមថា “សុខនេះ សហគតៈដោយបីតិនេះ” [៨២] ។ ចំណែកសេចក្តី គប្បីយល់ឃើញតាមន័យវិភង្គនោះចុះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **បឋមជ្ឈានំ** នេះ ដូចតទៅ ៖-

---

[៨២] អភិ. ។

ឈានដែលឈ្មោះថា **ទីមួយ** ព្រោះរាប់តាមលំដាប់ ។ ឈ្មោះថា **ទីមួយ** ព្រោះកើតឡើងមុនដូច្នេះក៏មាន ។ ឈ្មោះថា **ទីមួយ** ព្រោះព្រះយោគាវចរគប្បីចូលមុនដូច្នេះក៏មាន ។ ការកំណត់នេះមិនមែនច្បាស់លាស់ ព្រោះព្រះយោគាវចរ អ្នកបានសមាបត្តិ ៨ មានវសីប្រព្រឹត្តិមកហើយ រមែងអាចដើម្បីនឹងចូលឈានតាំងតែអំពីដើម រហូតដល់ទីបំផុតក៏បាន, អាចចូលឈាន ធ្វើតាំងតែអំពីខាងចុងបំផុតមកដល់ខាងដើមក៏បាន, អាចចូលឈានមួយខាងក្នុងចន្លោះក៏បាន, ក៏ឈាននោះ ឈ្មោះថា **ទីមួយ** ព្រោះអត្ថថា កើតឡើងមុនដោយប្រការដូច្នេះ ។

បទថា **“ឈានំ”** បានដល់ ឈាន ២ យ៉ាង គឺអារម្មណូបនិជ្ឈាន និង លក្ខណូបនិជ្ឈាន ។ បណ្ដាឈានទាំងពីរនោះ សមាបត្តិ ៨ រមែងចូលទៅសម្លឹងអារម្មណ៍ មានបឋវីកសិណជាដើម ព្រោះហេតុនោះ ឈាននោះ ទើបដល់នូវការរាប់ថា **“ជាអារម្មណូបនិជ្ឈាន”** ។ ចំណែកវិបស្សនា មគ្គ និងផល ឈ្មោះថា **លក្ខណូបនិជ្ឈាន** ។ បណ្ដាវិបស្សនាមគ្គផលទាំងនោះ វិបស្សនា ឈ្មោះថា **លក្ខណូបនិជ្ឈាន** ព្រោះការចូលទៅសម្លឹងលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ **មគ្គ** ឈ្មោះថា **លក្ខណូបនិជ្ឈាន** ព្រោះកិច្ចដែលវិបស្សនាធ្វើហើយសម្រេចដោយមគ្គ ។ ចំណែកផល ឈ្មោះថា **លក្ខណូបនិជ្ឈាន** ព្រោះចូលទៅសម្លឹងលក្ខណៈ ដែលជាសេចក្ដីពិត គឺនិរោធសច្ចៈ,

បណ្ដាអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈានទាំងពីរនោះ ក្នុងទីនេះ លោកប្រាថ្នាយកអារម្មណូបនិជ្ឈាន ព្រោះហេតុដូច្នោះ ឈាននោះ គប្បីជ្រាបថា ឈ្មោះថា **ឈាន** ព្រោះចូលទៅសម្លឹងអារម្មណ៍ ឬព្រោះជាគ្រឿងដុតនូវធមិដែលជាសត្រូវដូចនេះ ។

បទថា **"ឧបសម្បជ្ជ"** បានដល់ ចូលដល់ហើយ គឺសម្រេចហើយ ។ ម្យ៉ាងវិញទៀត អធិប្បាយថា ឱ្យចូលដល់ហើយ ឬឱ្យសម្រេចហើយ ។ ប៉ុន្តែនៅក្នុងវិភង្គពោលថា "បទថា **ឧបសម្បជ្ជ** បានដល់ ការបាន ការបានចំពោះ ការសម្រេច ការសម្រេចព្រម ការពាល់ត្រូវ ការធ្វើឱ្យជាក់ច្បាស់ ការចូលដល់បឋមជ្ឈាន" ។ សេចក្ដីនៃឈាននោះ គប្បីយល់ឃើញដូចនៅក្នុងវិភង្គនោះចុះ ។

បទថា **"វិហរតិ"** បានដល់ ការបរិបូណ៌នៃឈានមានប្រការតាមដែលពោលហើយថា ដោយការនៅនៃឥរិយាបថ ដ៏សមគួរដល់ឈាននោះ រមែងឱ្យសម្រេចការញាប់ញ័រ, ការប្រព្រឹត្តទៅ, ការរក្សា, ការដំណើទៅ, ការឱ្យដើរទៅ, ការត្រាច់ទៅ, និងការតាំងនៅនៃអត្តភាព; សមដូចពាក្យដែលត្រាស់ទុកនៅក្នុងវិភង្គថា "បទថា **វិហរតិ** បានដល់ រមែងកម្រើក, រមែងប្រព្រឹត្តទៅ, រមែងឃុំគ្រង, រមែងដំណើរទៅ, រមែងឱ្យដំណើរទៅ, រមែងត្រាច់ទៅ, រមែងនៅ; ព្រោះហេតុនោះ ទើបត្រាស់ថា **វិហរតិ**" ៕

## សម្តែងអំពីបឋវីកសិណ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“បឋវីកសិណំ ”** នេះ ដូចតទៅ ៖-

សូម្បីបឋវីមណ្ឌល រង្វង់មូលនៃផែនដី លោកក៏ហៅថា បឋវីកសិណ ព្រោះអត្ថថា ជាវត្ថុសម្រាប់សម្លឹង ។ សូម្បីនិមិត្តដែលបានហើយ ព្រោះអាស្រ័យបឋវីកសិណនោះ ក៏ឈ្មោះថា បឋវីកសិណ ។ សូម្បីឈានដែលបានចំពោះហើយក្នុងនិមិត្ត ក៏ឈ្មោះថា **បឋវីកសិណ** ។ បណ្តាសេចក្តីទាំងនោះ ឈានគប្បីជ្រាបថា ជាបឋវីកសិណ នៅក្នុងសេចក្តីនេះ ។ ក៏ក្នុងសេចក្តីថា ព្រះយោគាវចរចូលឈាន ពោលគឺបឋវីកសិណដូច្នេះ មានសេចក្តីសង្ខេបដូចនេះ ៖-

ក៏កុលបុត្រអ្នកប្រាថ្នាសម្រេចព្រះអរហត្ត ធ្វើបរិកម្មក្នុងបឋវីកសិណនេះ ហើយញ៉ាំងឈានពួក ៤, ឈានពួក ៥ ឱ្យកើតឡើងហើយ ចម្រើនវិបស្សនា មានឈានជាបទដ្ឋាន គប្បីធ្វើយ៉ាងណា? ជាខាងដើម គួរជម្រះសីល ៤ គឺបាតិមោក្ខសំវរសីល, ឥន្ទ្រិយសំវរសីល, អាជីវបារិសុទ្ធិសីល, និងបច្ចយសន្និស្សិតសីលឱ្យហ្មត់ចត់ជាមុន; កាលតាំងនៅក្នុងសីលល្អហើយ ក៏កាត់បលិពោធដែលមានក្នុងបលិពោធ ១០ ប្រការដែលមានអាវាសបលិពោធជាដើមនោះ ហើយចូលទៅរកកល្យាណមិត្តអ្នកឱ្យកម្មដ្ឋានគិតសញ្ជឹងនូវកម្មដ្ឋានដែលសមគួរដល់ចរិតរបស់ខ្លួន ក្នុងកម្មដ្ឋាន ៣៨ ប្រការដែលមានមក

ក្នុងព្រះបាលី; ប្រសិនបើបឋវីកសិណនេះ សមគួរដល់ចរិតរបស់ខ្លួន, ក៏គប្បីកាន់យកកម្មដ្ឋាននេះប៉ុណ្ណោះ លះវិហារដែលមិនសមគួរដល់ការចម្រើនឈាន នៅក្នុងវិហារដែលសមគួរ កាត់សេចក្ដីកង្វល់តូចៗ តិចតួច រក្សាបរិកម្ម និងនិមិត្តកសិណ វៀរចាកអសប្បាយ ៧ យ៉ាង[*] សេពសេនាសនៈសប្បាយ ៧ យ៉ាង, គប្បីធ្វើភាវនាវិធីទាំងអស់ ដែលមានអប្បនាកោសល ១០ យ៉ាង មិនឱ្យវិនាស, គប្បីបដិបត្តិដើម្បីសម្រេចឈាន; សេចក្ដីសង្ខេបមានត្រឹមតែប៉ុណ្ណោះ ។ ចំណែកសេចក្ដីពិស្ដារ គប្បីជ្រាបដោយន័យដែលពោលទុកនៅក្នុង **វិសុទ្ធិមគ្គ**[៨៣] ។ ម្យ៉ាងទៀត ក្នុងកសិណដទៃក្រៅអំពីនេះ ក៏គប្បីជ្រាបដូចនៅក្នុងបឋវីកសិណនេះ; ពិតមែនហើយ វិធីទាំងអស់នៃកម្មដ្ឋានទាំងពួង នៃវិធីចម្រើនភាវនា ខ្ញុំកាន់យកដោយន័យនៃអដ្ឋកថា ហើយពង្រីកសេចក្ដីឱ្យពិស្ដារនៅក្នុងវិសុទ្ធិមគ្គ, នឹងមានប្រយោជន៍អ្វីដោយវិធីចម្រើនកម្មដ្ឋាននោះក្នុងការដែលនឹងពោលដដែលៗ ទៀត នៅក្នុងទីនោះៗ ព្រោះហេតុដូច្នោះ ខ្ញុំនឹងមិនពង្រីកសេចក្ដីទៀតទេ ។ ប៉ុន្តែថា ខ្ញុំនឹងមិនធ្វើសេចក្ដីដែលមកក្នុងព្រះបាលីអំពីខាងដើមឱ្យបាត់បង់ទេ នឹងពណ៌នាតាមលំដាប់បទជាប់តគ្នាទៅ ។

---

[*] អដ្ឋ. យោ. គឺអាវាស ១, គោចរ ១, ពាក្យពោល ១, បុគ្គល ១, ភោជន ១, រដូវ ១, ឥរិយាបថ ១, ឯសប្បាយគ្រាន់តែផ្ទុយគ្នាប៉ុណ្ណោះ ។

[៨៣] វិសុទ្ធិ. ១/២៣២ ( បឋវីកសិណនិទ្ទេស) ។

បទថា **"តស្មឹំ សមយេ"** សេចក្ដីថា ក្នុងសម័យដែលចូលបឋមជ្ឈាននោះ; ធម៌ ៥៦ តាមលំដាប់មានប្រការតាមដែលពោលក្នុងកាមាវចរកុសលចិត្តដួងទីមួយទាំងនេះ គឺផស្សៈ ។ល។ **អវិក្ខេបៈ** រមែងមាន; ក៏សេចក្ដីប្លែកគ្នាក្នុងបឋមជ្ឈាននេះ មានសេចក្ដីតែម្យ៉ាង គឺធម៌ទាំង ៥៦ ទាំងនោះជាកាមាវចរ, ធម៌ ៥៦ ដែលពោលមកនេះ ជាមហគ្គតៈ ជារូបាវចរ ដោយអំណាចនៃចន្លោះភូមិ; ធម៌ដែលសល់ក្រៅអំពីនេះ មានដូចគ្នាទាំងអស់; ចំណែកយេវាបនកធម៌ និងធម៌ ៤ យ៉ាង មានឆន្ទៈជាដើម រមែងបានក្នុងឈាននេះ ។ កោដ្ឋាសវារៈ និងសុញ្ញតវារៈ រមែងប្រព្រឹត្តទៅតាមប្រក្រតីហ្នឹងហើយដូច្នេះឯង ។

ចប់បឋមជ្ឈាន

## អធិប្បាយអំពីទុតិយជ្ឈាន

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃទុតិយជ្ឈានតទៅ ៖-

បទថា **"វិតក្កវិចារានំ វូបសមា** ព្រោះវិតក្កវិចារៈស្ងប់" សេចក្ដីថា សេចក្ដីស្ងប់ គឺព្រោះការឈានកន្លងធម៌ទាំង ២ នេះ គឺវិតក្កៈ និងវិចារៈ មានអធិប្បាយថា ព្រោះសេចក្ដីដែលវិតក្កៈ និងវិចារៈមិនប្រាកដក្នុងឈានទី ២; ក្នុងឈានទាំង ២ នោះ ធម៌ដែលជាបឋមជ្ឈានទាំងអស់ រមែងមិនមាន

ក្នុងទុតិយជ្ឈានដោយពិត, ព្រោះថា ធម៌ទាំងឡាយ មានផស្សៈជាដើម ក្នុងបឋមជ្ឈានក៏ម្យ៉ាង, ក្នុងទុតិយជ្ឈាននេះក៏ម្យ៉ាង ក៏ពិតមែនហើយ, ប៉ុន្តែគប្បីជ្រាបថា ពាក្យដែលត្រាស់យ៉ាងនេះថា ព្រោះវិតក្កៈ និងវិតក្កៈស្ងប់ ដើម្បីសម្តែងថា ការសម្រេចទុតិយជ្ឈានជាដើម ជាយ៉ាងដទៃពីបឋមជ្ឈាន រមែងមានព្រោះឈានកន្លងអង្គគ្រោតគ្រាតៗ ។

ក្នុងបទថា “**អជ្ឈត្តំ** = ខាងក្នុង” នេះ លោកមានបំណងយកខាងក្នុងជារបស់ខ្លួនឯង; ប៉ុន្តែក្នុងវិភង្គបានត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះថា “ចំពោះខ្លួន ឈ្មោះថា **អជ្ឈត្តៈ**” ; ក៏ព្រោះបទថា **អជ្ឈត្តំ** នេះ លោកប្រាថ្នាយកបទថា **និយកជ្ឈត្តំ**, ព្រោះហេតុដូច្នោះ ក្នុងបទថា **អជ្ឈត្តំ** នេះ ទើបមានអធិប្បាយថា កើតក្នុងខាងក្នុងរបស់ខ្លួន, ឬថាកើតក្នុងសន្តានរបស់ខ្លួន ។ សទ្ធាហៅថា សេចក្តីថ្លាផូរផង់ ក្នុងបទថា **សម្បសាទនំ** នេះ ។ សូម្បីឈានក៏ហៅថា សេចក្តីថ្លាផូរផង់ ព្រោះប្រកបដោយសេចក្តីថ្លាផូរផង់, ដូចសំពត់ ឈ្មោះថា **សំពត់ខៀវ** ព្រោះប្រកបដោយពណ៌ខៀវ ។ ម្យ៉ាងវិញទៀត ព្រោះឈាននោះ ញ៉ាំងចិត្តឱ្យភ្លឺថ្លា ព្រោះប្រកបដោយសេចក្តីថ្លាផូរផង់ និងព្រោះការស្ងប់ការកម្រើក វិតក្កៈ និងវិចារៈ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា “**សម្បសាទនំ** សេចក្តីថ្លាផូរផង់” ។ ក៏ការកំណត់សេចក្តីនេះ គប្បីជ្រាបសេចក្តីសម្ពន្ធនៃបទយ៉ាងនេះថា “**សម្បសាទនំ ចេតសោ**” , ប៉ុន្តែក្នុងការ

កំណត់សេចក្ដីបទដំបូង បទថា **ចេតសោ** នេះ គប្បីប្រកបជាមួយនឹងបទ **ឯកោទិភាវំ** ។ ក្នុងបទនោះ មានការប្រកបសេចក្ដីដូចតទៅនេះ ៖-

សមាធិណា រមែងលេចឡើងជាឯក ព្រោះហេតុនោះ សមាធិនោះទើបឈ្មោះថា **ឯកោទិ**, អធិប្បាយថា សមាធិនោះ ជាភាវៈដ៏ប្រសើរលើសលេចធ្លោឡើង ព្រោះវិតក្កៈ និងវិចារៈមិនចម្រើន (កើត) ឡើងខាងក្នុង ។ ពិតមែន សូម្បីបុគ្គលអ្នកប្រសើរបំផុត គេក៏ហៅថា ជាឯកក្នុងលោកដូចនេះ។ ម្យ៉ាងវិញទៀត សូម្បីនឹងពោលថា សមាធិដែលវៀរវិតក្កៈ និងវិចារៈ ជាឯកមិនមានសមាធិណាលេចធ្លោជាងដូចនេះ ក៏គួរ ។ ន័យម្យ៉ាងទៀត សមាធិណារមែងញ៉ាំងសម្បយុត្តធម៌មិឱ្យលេចធ្លោឡើង ព្រោះហេតុនោះ សមាធិនោះទើបឈ្មោះថា **ឧទិ** គឺរមែងឱ្យសម្បយុត្តធម៌តាំងឡើង សមាធិនោះជាឯកព្រោះអត្ថថា ប្រសើរផង និងញ៉ាំងសម្បយុត្តធម៌មិឱ្យលេចធ្លោឡើងផង ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកោទិ** ។ ពាក្យថា **ឯកោទិ** នេះ ជាឈ្មោះរបស់សមាធិ ។ ទុតិយជ្ឈានណា រមែងញ៉ាំងសមាធិឈ្មោះថា **ឯកោទិ នេះឱ្យកើត** ឱ្យចម្រើន ព្រោះហេតុនោះ ទុតិយជ្ឈាននេះ ទើបឈ្មោះថា **ឯកោទិភាវៈ**; ក៏ព្រោះសមាធិនេះនោះជាឯក ជាសភាវៈដែលញ៉ាំងសម្បយុត្តធម៌មិឱ្យលេចធ្លោឡើង រមែងមានដល់ចិត្ត, មិនមែនមានដល់សត្វ មិនមែនមានដល់ជីវៈ; ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យនេះថា

**“ចេតសោ ឯកោទិភាវំ”** ។

សួរថា សទ្ធានេះ និងសមាធិ មានឈ្មោះថា **ឯកោទិ** នេះ សូម្បីជាបឋមជ្ឈានមិនមែនឬ កាលបើដូច្នោះ ព្រោះហេតុអ្វី ទុតិយជ្ឈាននេះ ព្រះមានព្រះភាគទើបត្រាស់ថា “ជាគ្រឿងថ្លាផូរផង់ និងជាឯកោទិភាវៈទៀត?” ឆ្លើយថា ព្រោះថា បឋមជ្ឈាននោះ នៅមិនទាន់ថ្លាផូរផង់ពិត ព្រោះកម្រើកដោយវិតក្កៈ និងវិចារៈ ដូចទឹកដែលល្អក់ព្រោះរលក; ព្រោះហេតុដូច្នោះ សូម្បីកាលសទ្ធាមាន ក៏មិនត្រាស់ថា **សម្បសាទនំ** សេចក្ដីថ្លាផូរផង់; ម្យ៉ាងទៀត សូម្បីសមាធិក្នុងបឋមជ្ឈាននេះ ក៏នៅមិនប្រាកដ ព្រោះនៅមិនទាន់ថ្លាផូរផង់ពិត; ព្រោះហេតុដូច្នោះ បឋមជ្ឈាននោះ ទើបមិនត្រាស់ថា ឯកោទិភាវៈ; ប៉ុន្តែនៅក្នុងទុតិយជ្ឈាននេះ សទ្ធាមានកម្លាំង បានឱកាស ព្រោះមិនមានវិតក្កៈ និងវិចារៈជាបលិពោធ (កង្វល់ចិត្ត) សូម្បីសមាធិក៏ប្រាកដ ព្រោះការបានសទ្ធាជាកម្លាំង និងជាមិត្តសំឡាញ់; ព្រោះហេតុដូច្នោះ ទុតិយជ្ឈាននេះប៉ុណ្ណោះ គប្បីជ្រាបថា ត្រាស់ទុកយ៉ាងនោះ ។ ចំណែកក្នុងវិភង្គត្រាស់ទុកត្រឹមតែប៉ុណ្ណេះថា “បទថា **សម្បសាទនំ** = ថ្លាផូរផង់’ បានដល់ សទ្ធា (ការជឿ), កិរិយាដែលជឿ, ការដាក់ចិត្តជឿ, ការជ្រះថ្លាដ៏ក្រៃលែង ។ ពាក្យថា “**ចេតសោ ឯកោទិភាវំ** = ធម៌ឯកលេចធ្លោឡើងដល់ចិត្ត” បាន

ដល់ ការតាំងនៅ ការតាំងមាំនៃចិត្ត ។ល។ "សម្មាសមាធិ" [៨៤] ។ គប្បីជ្រាបការពណ៌នាសេចក្ដីនេះ ជាមួយនឹងព្រះតម្រាស់ដែលត្រាស់ទុកយ៉ាងនោះ រមែងមិនខុស, ប្រៀបធៀបគ្នា រមែងស្របគ្នាបានដូច្នោះ ។

បទថា "**អវិតក្កំ អវិចារំ** = មិនមានវិតក្កៈ មិនមានវិចារៈ" មានវិគ្រោះថា ឈ្មោះថា **អវិតក្កៈ** (មិនមានវិតក្កៈ) ព្រោះអត្ថថា វិតក្កៈក្នុងទុតិយជ្ឈាននេះ ឬរបស់ទុតិយជ្ឈាននេះមិនមាន ព្រោះសេចក្ដីដែលវិតក្កៈនោះលះបានហើយដោយភាវនា ។ ឈ្មោះថា **អវិចារៈ** (មិនមានវិចារៈ) ដោយន័យនេះដូចគ្នាដែរ ។ សូម្បីនៅក្នុងវិភង្គក៏ត្រាស់ទុកថា "វិតក្កៈ និងវិចារៈនេះ រមែងស្ងប់រំងាប់, ចូលទៅរំងាប់, រលត់ទៅ, រលត់ទៅមិនមានសល់, ត្រូវធ្វើឱ្យវិនាសទៅ, ត្រូវធ្វើឱ្យស្ងួតទៅ, ត្រូវធ្វើឱ្យរីងស្ងួតទៅ, ត្រូវធ្វើឱ្យអស់ទៅ; ដោយហេតុនោះ ទើបត្រាស់ថា មិនមានវិតក្កៈ មិនមានវិចារៈ" [៨៥] ដោយប្រការដូច្នោះ ។

នៅក្នុងសេចក្ដីនេះ ប្រសិនបើមានអ្នកជំទាស់ ដោយពាក្យនេះថា "ព្រោះការចូលទៅស្ងប់វិតក្កៈ និងវិចារៈដូចនេះ ព្រះមានព្រះភាគត្រាស់ក៏សម្បូរណ៍ហើយមិនមែនឬ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបត្រាស់ថា

---

[៨៤] អភិ. ៧៨។

[៨៥] អភិ. ៧៨។

មិនមានវិតក្កៈមិនមានវិចារៈទៀត?” ឆ្លើយថា មែនសេចក្តីនេះសម្រេចហើយយ៉ាងនោះ; ប៉ុន្តែពាក្យថា មិនមានវិតក្កៈ មិនមានវិចារៈនេះ ជាពាក្យដែលសម្តែងសេចក្តីត្រង់ចំណុចនោះក៏មិនបាន, ខ្ញុំបានពោលទុកហើយមិនមែនឬថា “ព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា “**វិតក្កវិចារានំ វូបសមា**” ដូចនេះ ដើម្បីសម្តែងថា ការសម្រេចទុតិយជ្ឈានជាដើម ជាប្រភេទម្យ៉ាងក្រៅពីបឋមជ្ឈាន រមែងមានបាន ព្រោះឈានកន្លងអង្គគ្រោតគ្រាត១” ។

ម្យ៉ាងទៀត ពាក្យនេះជាហេតុសម្តែងភាវៈនៃសម្បសាទនៈ និងឯកោទិយ៉ាងនេះថា ទុតិយជ្ឈាននេះ ឈ្មោះថា **សម្បសាទនៈ** ព្រោះស្ងប់វិតក្កៈ និងវិចារៈ, មិនមែនចូលទៅស្ងប់កិលេសដែលកម្រើកតាមកាល, ឈាននោះ ឈ្មោះថា **ឯកោទិភាវៈ ព្រោះស្ងប់វិតក្កៈ និងវិចារៈ** មិនមែនលះនីវរណៈបានដូចឧបចារជ្ឈាន, មិនមែនអង្គឈានប្រាកដដូចបឋមជ្ឈានទេ ។ ម្យ៉ាងវិញទៀត ទុតិយជ្ឈាននេះ ឈ្មោះថា **អវិតក្កៈ អវិចារៈ** ព្រោះចូលទៅស្ងប់វិតក្កៈ និងវិចារៈ, មិនមែនព្រោះមិនមានខ្លួនឯង ដូចតតិយជ្ឈាន និងចតុត្ថជ្ឈាន និងដូចចក្ខុវិញ្ញាណជាដើម; ព្រោះហេតុដូច្នោះ ពាក្យថា មិនមានវិតក្កៈ មិនមានវិចារៈនេះ ជាពាក្យសម្តែងហេតុនៃសេចក្តីដែលទុតិយជ្ឈាននោះជាធម្មជាតិមិនមានវិតក្កៈ មិនមានវិចារៈ; មិនមែនជាពាក្យសម្តែងត្រឹមតែសេចក្តីមិនមានវិតក្កៈ មិនមានវិចារៈ ។ ចំណែកពាក្យថា “**អវិតក្កំ**

**អវិចារំ**” នេះ ជាពាក្យសម្តែងត្រឹមតែថា សេចក្តីមិនមានវិតក្កៈ និងវិចារៈប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគត្រាត្រាស់អវិតក្កៈ និងអវិចារៈហើយ ក៏គប្បីត្រាស់ទៀតដោយពិត ។

បទថា “**សមាធិជំ** = កើតអំពីសមាធិ” សេចក្តីថា កើតអំពីសមាធិក្នុងបឋមជ្ឈាន ឬអំពីសមាធិដែលសម្បយុត្តគ្នា; បណ្តាសមាធិ ២ នោះ សូម្បីឈានទីមួយ កើតអំពីសមាធិដែលសម្បយុត្តគ្នា ក៏ពិតមែនហើយ, ប៉ុន្តែ សមាធិនេះប៉ុណ្ណោះ រមែងគួរពោលពាក្យថា “**សមាធិ**” , ព្រោះជាសមាធិដែលមិនញាប់ញ័រខ្លាំងពេក ដោយដាក់វៀរចាកការកម្រើកនៃវិតក្កៈ និងវិចារៈ និងព្រោះជាហេតុឱ្យសមាធិថ្លាផូរផង់ល្អ; ព្រោះហេតុដូច្នោះ ដើម្បីពោលលើកតម្កើងទុតិយជ្ឈាននេះ ព្រះមានព្រះភាគទើបត្រាស់ពាក្យថា “**សមាធិជំ**” នេះតែម្តង ។ ពាក្យថា “**បីតិ សុខំ**” នេះ មានន័យតាមដែលបានពោលមកហើយ ។ ពាក្យថា “**ទុតិយំ**” នេះ ឈ្មោះថា **ទីពីរដោយលំដាប់នៃការរាប់** ។ ដែលឈ្មោះថា **ទីពីរ** ព្រោះអត្ថថា រមែងសម្រេចឈានទីពីរនេះ ដូច្នេះក៏បាន ។

ក្នុងពាក្យថា “**តស្មឹ សមយេ ផស្សោ ហោតិ**” ជាដើម គប្បីជ្រាបការបន្ថយបទវិតក្កៈ និងវិចារៈក្នុងឈានពួក ៥, គប្បីជ្រាបការបន្ថយបទសម្មាសង្កប្បៈក្នុងពួក ៥ នៃមគ្គ ។ គប្បីជ្រាបវិនិច្ឆ័យបទដែលមានការចែក

និងមិនមានការចែក ដោយអំណាចពួក ៥ នៃឈាន និងពួក ៥ នៃមគ្គទាំងនោះ ។ សូម្បីនៅក្នុងកោដ្ឋាសវារៈ ក៏មានព្រះបាលីមកថា “ឈានប្រកបដោយអង្គ ៣, មគ្គប្រកបដោយអង្គ ៤” ។ ពាក្យដែលសល់ក្រៅអំពីនេះ ដូចគ្នានឹងបឋមជ្ឈាននោះដែរ ៕

## ចប់ទុតិយជ្ឈាន

# អធិប្បាយអំពីតតិយជ្ឈាន

គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយជ្ឈាននិទ្ទេសដូចតទៅ

បទថា “**បីតិយា ច វិរាគា** = ព្រោះប្រាសចាកបីតិ” សេចក្ដីថា ការរង្កៀស ឬការឈានកន្លងនូវបីតិ មានប្រការតាមដែលពោលហើយឈ្មោះថា **វិរាគៈ** (ការប្រាសចាករាគៈ), ក៏**ចសព្ទ** ក្នុងចន្លោះសព្ទទាំងពីរមានអត្ថថា ប្រមូលមក, គឺរមែងប្រមូលមកនូវសេចក្ដីស្ងប់ ឬរមែងប្រមូលមកនូវភាពស្ងប់វិតក្កៈ និងវិចារៈ ។ ក្នុងការប្រមូលមកទាំង ២ នោះ ក្នុងកាលណា **ចសព្ទ**រមែងប្រមូលមកនូវសេចក្ដីស្ងប់ប៉ុណ្ណោះ, ក្នុងកាលនោះ គប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា ព្រោះប្រាសចាកនូវបីតិ និងព្រោះការស្ងប់ក្រៃលែងទៅបន្តិចម្ដងៗ ។ សេចក្ដីដែលប្រកបនេះ គប្បីយល់ឃើញថា វិរាគៈ (ការប្រាសចាកនូវរាគៈ) មានអត្ថថា រង្កៀស ។ ប៉ុន្តែថា ក្នុងកាល

ណា ចសទ្ទ រមែងប្រមូលមកនូវសេចក្ដីស្ងប់វិតក្កៈ និងវិចារៈ, ក្នុងកាលនោះ គប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា ព្រោះប្រាសចាកនូវបីតិ និងព្រោះភាពស្ងប់នូវវិតក្កៈ និងវិចារៈក្រៃលែងឡើងបន្តិចម្ដងៗ ។ ពោលដោយការប្រកបសេចក្ដីនេះ វិរាគៈ (ការប្រាសចាកនូវរាគៈ) មានអត្ថថា ឈានកន្លង, ព្រោះហេតុដូច្នោះ គប្បីយល់ឃើញសេចក្ដីនេះថា ព្រោះការឈានកន្លងនូវបីតិ និងព្រោះស្ងប់វិតក្កៈ និងវិចារៈដូចនេះ ។ ក៏វិតក្កៈ និងវិចារៈទាំងនេះស្ងប់ហើយក្នុងទុតិយជ្ឈាន ក៏ពិតមែន, ប៉ុន្តែលោកក៏ពោលពាក្យថា ព្រោះការស្ងប់វិតក្កៈ និងវិចារៈនេះទុក ដើម្បីអធិប្បាយគន្លងផ្លូវរបស់ឈាននេះ និងដើម្បីនឹងពោលសរសើរនូវឈាននេះ; ពិតមែន កាលពោលពាក្យថា **"វិតក្ក វិចារានំ ច វូបសមា"** តតិយជ្ឈាននេះរមែងប្រាកដច្បាស់ថា "ការចូលទៅស្ងប់វិតក្កៈ និងវិចារៈ ជាឧបាយ ជាគ្រឿងសម្រេចនូវឈាននេះពិតៗ" ។ ម្យ៉ាងដូចថាការលះ លោកពោលទុកក្នុងអរិយមគ្គទី ៣ យ៉ាងនេះថា ព្រោះលះសញ្ញោជនៈខាងក្រោម ៥ មានសក្កាយទិដ្ឋិជាដើម* សូម្បីដែលនៅមិនបានលះដូចនេះ រមែងជាការពោលទៅដល់គុណសេចក្ដីល្អ ដើម្បីឱ្យកើតការឧស្សាហ៍ដល់បុគ្គលអ្នកខ្វល់ខ្វាយ ដើម្បីសម្រេចមគ្គនោះ យ៉ាងណា, ការស្ងប់វិតក្កៈ និងវិចារៈ សូម្បីដែលនៅមិនស្ងប់តាមដែលបានត្រាស់ទុកក្នុងតតិយ-

---

* សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ កាមច្ឆន្ទៈ ១ ព្យាបាទ ២ (អដ្ឋ. យោ.) ។

ជ្ឈានេនះ រមែងជាការពោលសរសើរនូវគុណដូច្នោះ, ព្រោះហេតុនោះ ទើបត្រាស់សេចក្ដីនេះថា “ព្រោះឈានកន្លងនូវបីតិ និងព្រោះសេចក្ដីស្ងប់វិតក្កៈ និងវិចារៈទាំងឡាយ” ។

ក្នុងពាក្យថា “**ឧបេក្ខកោ ច វិហរតិ**” នេះ មានវិគ្រោះថា ធមិដែលឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា រមែងយល់ឃើញដោយការកើតឡើង *, អធិប្បាយថា រមែងឃើញស្មើ គឺឃើញដោយមិនធ្លាក់ទៅជាចំណែកខាងណា។ ព្រះយោគាវចរអ្នកបានសម្រេចដោយតតិយជ្ឈាន ត្រាស់ហៅថា **ឧបេក្ខកោ** (អ្នកចូលទៅសម្លឹង) ព្រោះប្រកបដោយឧបេក្ខា ដ៏បរិសុទ្ធ បរិបូរណ៍ មានកម្លាំងនោះ ៕

## សម្ដែងអំពីឧបេក្ខា ១០ យ៉ាង

ក៏ឧបេក្ខាមាន ១០ យ៉ាង គឺ

**១-ឆឡង្គុបេក្ខា** ឧបេក្ខារបស់ព្រះខីណាស្រព គឺតត្រមជ្ឈត្តតា

**២-ព្រហ្មវិហារុបេក្ខា** ឧបេក្ខាក្នុងព្រហ្មវិហារ គឺតត្រមជ្ឈត្តតា

**៣-ពោជ្ឈង្គុបេក្ខា** ឧបេក្ខាក្នុងសម្ពោជ្ឈង្គ គឺតត្រមជ្ឈត្តតា

---

* ឧប្បត្តិតោ ឥក្ខតីតិ ឧបេក្ខា ។

**៤.វីរិយុបេក្ខា** ឧបេក្ខា គឺសេចក្ដីព្យាម

**៥.សង្ខារុបេក្ខា** ឧបេក្ខាក្នុងឈាន និងវិបស្សនា គឺបញ្ញា

**៦.វេទនុបេក្ខា** ឧបេក្ខាវេទនា

**៧.វិបស្សនុបេក្ខា** ឧបេក្ខាក្នុងវិបស្សនា គឺបញ្ញា

**៨.តត្រមជ្ឈត្តុបេក្ខា** តត្រមជ្ឈត្តចេតសិក

**៩.ឈានុបេក្ខា** ឧបេក្ខាក្នុងឈាន គឺតត្រមជ្ឈត្តតា

**១០.បារិសុទ្ធិបេក្ខា** ឧបេក្ខាធ្វើសតិឱ្យបរិសុទ្ធ គឺតត្រមជ្ឈត្តតា ។

បណ្ដាឧបេក្ខាទាំង ១០ នោះ ឧបេក្ខាណាជាធម៌បរិសុទ្ធជាប្រក្រតី ក្នុងគន្លងនៃអារម្មណ៍ ៦ ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាក្នុងទ្វារ ៦ របស់ព្រះខីណាស្រព ជាអាការដែលមានមកក្នុងព្រះបាលីយ៉ាងនេះថា "ភិក្ខុអ្នកជាព្រះខីណាស្រពក្នុងធម្មវិន័យនេះ ឃើញរូបដោយចក្ខុហើយ មិនសប្បាយចិត្ត មិនអាក់អន់ចិត្ត, មានសតិ មានសេចក្ដីដឹងខ្លួនព្រងើយៗ ហើយ រមែងនៅ"[៨៦], ឧបេក្ខានេះ ឈ្មោះថា **ឆឡង្គុបេក្ខា** ។

ឧបេក្ខាណា មានអាការជាកណ្ដាលចំពោះសត្វទាំងឡាយ ដែលមានមកក្នុងព្រះបាលីយ៉ាងនេះថា "ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សព្វផ្សាយ

---

[៨៦] អំ. ចតុក្ក., ខុ. បដិ., ខុ. មហា. (បុរាភេទសុត្តនិទ្ទេស) ខុ. ចូឡ. ។

ទៅកាន់ទិសមួយ”[៨៧], ឧបេក្ខានេះ ឈ្មោះថា **ឧបេក្ខាក្នុងព្រហ្មវិហារ** ។

ឧបេក្ខាណា មានភាពជាកណ្ដាលក្នុងសហជាតធម៌ទាំងឡាយ ដែលមានមកក្នុងព្រះបាលីថា “ភិក្ខុចម្រើនឧបេក្ខាសម្ពោជ្ឈង្គ អាស្រ័យវិវេក”[៨៨], ឧបេក្ខានេះ ឈ្មោះថា **ឧបេក្ខាសម្ពោជ្ឈង្គ**។

ឧបេក្ខាណា ពោលគឺសេចក្ដីព្យាយាមដែលមិនខ្សោយ មិនខ្លាំងពេកទេ ដែលមកក្នុងព្រះបាលីយ៉ាងនេះថា “ភិក្ខុមានមនសិការនិមិត្តឧបេក្ខារហូតកាល”[៨៩], ឧបេក្ខានេះ ឈ្មោះថា **វិរិយុបេក្ខា**។

ឧបេក្ខាណា មានអាការជាកណ្ដាល មានការកំណត់ពិចារណានីវរណៈជាដើម ដែលមានមកក្នុងព្រះបាលីយ៉ាងនេះថា “សង្ខារុបេក្ខាប៉ុន្មាន រមែងកើតឡើងដោយអំណាចនៃសមាធិ សង្ខារុបេក្ខាប៉ុន្មាន រមែងកើតឡើងដោយអំណាចនៃវិបស្សនា?, សង្ខារុបេក្ខាទាំង ៨ យ៉ាង រមែងកើតឡើងដោយអំណាចនៃសមាធិ, សង្ខារុបេក្ខា ១០ យ៉ាងរមែងកើតឡើង ដោយអំណាចនៃវិបស្សនា”[៩០], ឧបេក្ខានេះ ឈ្មោះថា **សង្ខារុបេក្ខា**។

---

[៨៧] ទី. សី. ១៤; ម. ម. ។

[៨៨] ម. មូ., ម. ម. ។

[៨៩] អំ. តិក. ។

[៩០] ខុ. បដិ. ។

ឧបេក្ខាណា ដែលប្រកាសឱ្យដឹងក្នុងសេចក្ដីមិនមែនទុក្ខ មិនមែនសុខ ដែលមកក្នុងព្រះបាលីយ៉ាងនេះថា “កាមាវចរកុសលចិត្តសហគតដោយឧបេក្ខា រមែងកើតឡើងក្នុងសម័យណា” [៩១], ឧបេក្ខានេះ ឈ្មោះថា **វេទនូបេក្ខា**។

ឧបេក្ខាណា មានភាពជាកណ្ដាលក្នុងការស្រាវជ្រាវពិចារណា ដែលមកក្នុងព្រះបាលីយ៉ាងនេះថា “វត្ថុណាមាននៅហើយ, រមែងលះវត្ថុនោះចេញ, ភិក្ខុរមែងបានចំពោះនូវឧបេក្ខា” [៩២] ឈ្មោះថា **វិបស្សនូបេក្ខា** ។

ឧបេក្ខាណា ញ៉ាំងសហជាតធម៌ឱ្យប្រព្រឹត្តទៅស្មើៗ ដែលមានមកក្នុងយេវាបនកធម៌ទាំងឡាយ មានឆន្ទៈជាដើម, ឧបេក្ខានេះ ឈ្មោះថា **តត្រ-មជ្ឈត្តូបេក្ខា** ។

ឧបេក្ខាណា មានជាតិធ្លាក់ទៅក្នុងសេចក្ដីសុខនៃឈាននោះ សូម្បីជាសុខដ៏លើស ដែលមកក្នុងព្រះបាលីយ៉ាងនេះថា “ជាអ្នកសម្លឹង” [៩៣], ឧបេក្ខានេះ ឈ្មោះថា **ឈានូបេក្ខា**។

ឧបេក្ខាណា បរិសុទ្ធចាកបច្ចនិកធម៌ទាំងពួង មិនត្រូវខ្វល់ខ្វាយក្នុងការស្ងប់បច្ចនិកធម៌ ដែលមានមកក្នុងព្រះបាលីយ៉ាងនេះថា “ឈានទី ៤

---

[៩១] អភិ.។

[៩២] ម. ឩ. ។

[៩៣] ទី. សី. ១៤, ម. ម. ។

មានសតិបរិសុទ្ធ ព្រោះឧបេក្ខា” [៩៤] , ឧបេក្ខានេះ ឈ្មោះថា **បារិសុទ្ធិឧបេក្ខា**។

បណ្ដាឧបេក្ខាទាំង ១០ នោះ ឆឡង្គុបេក្ខា, ព្រហ្មវិហារូបេក្ខា, ពោជ្ឈង្គុបេក្ខា, តត្រមជ្ឈត្តុបេក្ខា, ឈានុបេក្ខា, បារិសុទ្ធិឧបេក្ខា ដោយអត្ថជាប្រភេទដូចគ្នា, គឺជាតត្រមជ្ឈត្តុបេក្ខា ។ ប៉ុន្តែថា សេចក្ដីប្លែកផ្សេងគ្នានៃឧបេក្ខាតាមដែលពោលមកនោះ ព្រោះបែងចែកប្រភេទនោះៗទុក; ដូចសេចក្ដីប្លែកផ្សេងគ្នានៃមនុស្សសូម្បីតែម្នាក់ គឺដោយជាក្មេង, ពេញវ័យ, ជាអ្នកធំ, ជាសេនាបតី និងជាព្រះរាជាជាដើម [៩៥], ព្រោះហេតុដូច្នោះ បណ្ដាឆឡង្គុបេក្ខាជាដើមទាំងនោះ ក្នុងទីណាមិនមានឆឡង្គុបេក្ខា គប្បីជ្រាបថា ក្នុងទីនោះ មានពោជ្ឈង្គុបេក្ខាជាដើម; ឬថា ក្នុងទីណាមិនមានពោជ្ឈង្គុបេក្ខា, គប្បីជ្រាបថា ក្នុងទីនោះ មានឆឡង្គុបេក្ខាជាដើម ។

ម្យ៉ាងទៀត ឧបេក្ខាទាំង ៦ នោះ ពោលដោយអត្ថមានភាវៈដូចគ្នាយ៉ាងណា, សូម្បីសង្ខារុបេក្ខា និងវិបស្សនុបេក្ខា ក៏ជាភាវៈដូចគ្នា ។ សង្ខារុបេក្ខា និងវិបស្សនុបេក្ខានោះ គឺបញ្ញានោះឯង ប៉ុន្តែចែកជា ២ ដោយអំណាចនៃកិច្ច ។ ដូចយ៉ាងថា កាលបុរសកាន់ឈើមានសណ្ឋានដូចជើងពពែ

---

[៩៤] អភិ. ។

[៩៥] វិសុទ្ធិ. ១ (បឋវីកសិណាទិទ្ទេស) ។

ស្វែងរកពស់ ដែលចូលទៅកាន់ស្រុកក្នុងវេលាល្ងាច ឃើញពស់នោះដេកលាក់ខ្លួនក្នុងគំនររបស់របរ ក៏សម្លឹងមើលដោយសង្ស័យថា “ពស់មែន ឬក៏មិនមែនទេហ្ន៎!” ឃើញគ្រឿងសម្គាល់ផ្កាចន្ទ ក៏អស់សេចក្ដីសង្ស័យ ទើបជាអ្នកព្រងើយកន្តើយក្នុងការដែលនឹងវិនិច្ឆ័យថា “ជាពស់ ឬមិនមែនពស់” យ៉ាងណា, កាលព្រះយោគាវចរអ្នកប្រារព្ធវិបស្សនា ឃើញត្រៃលក្ខណ៍ដោយវិបស្សនាញាណហើយ ជាអ្នកព្រងើយកន្តើយក្នុងការដែលនឹងពិចារណាសង្ខារទាំងឡាយជារបស់មិនទៀងជាដើម រមែងកើតឡើងនូវភាពជាអ្នកព្រងើយកន្តើយ (មជ្ឈត្តតា) នេះ, ឈ្មោះថា **វិបស្សនូឧបេក្ខា** ។

ដូចយ៉ាងថា កាលបុរសនោះ យកឈើមានសណ្ឋានដូចជើងពពែសង្កត់កពស់ហើយ ស្វែងរកអាការដែលនឹងផុតចាកភ័យថា “ដោយវិធីណាយើងនឹងចាប់ពស់នេះមិនលំបាក និងដោយឧបាយយ៉ាងណា ទើបមិនឱ្យពស់ខាំយើងបាន” ដូច្នេះ ការព្រងើយកន្តើយ (មជ្ឈត្តតា) ក្នុងការចាប់ ទើបមានយ៉ាងណា, កាលព្រះយោគាវចរឃើញភពទាំង ៣ ដូចភ្លើងឆេះទូទៅព្រោះឃើញត្រៃលក្ខណ៍ ក៏មានការព្រងើយកន្តើយ (មជ្ឈត្តតា) ក្នុងការប្រកាន់សង្ខារដូច្នោះដែរ, មជ្ឈត្តតានេះ ឈ្មោះថា **សង្ខារុបេក្ខា** ។ ដោយប្រការតាមដែលពោលមកនេះ សូម្បីសង្ខារុបេក្ខានឹងសម្រេចបាន ក៏ព្រោះវិបស្សនូបេក្ខាសម្រេចហើយដោយពិត ។ ក៏ឧបេក្ខា (គឺបញ្ញា) នេះចែកចេញ

ជា ២ យ៉ាង ដោយកិច្ចនេះ ពោលគឺការព្រងើយកន្តើយក្នុងការពិចារណា និងក្នុងការប្រកាន់ដូច្នេះ ។ ចំណែកវីរិយូបេក្ខា និងវេទនូបេក្ខា ដោយអត្ថផ្សេងគ្នា និងផ្សេងអំពីឧបេក្ខាដ៏សេសផង ។

បណ្ដាឧបេក្ខាទាំងនេះ តាមដែលពោលមកក្នុងទីនេះ លោកប្រាថ្នាយកឈានូបេក្ខា ។ ឈានូបេក្ខានោះ មានការតម្កល់ខ្លួនជាកណ្ដាល ជាលក្ខណៈ, មានការមិនត្រិះរិះដល់ជាកិច្ច, មានការមិនខ្វល់ខ្វាយជាបច្ចុប្បដ្ឋាន, មានការប្រាសចាកបីតិជាបទដ្ឋាន ។

ក្នុងអធិការនៃឈានទី ៣ នេះ ប្រសិនបើមានអ្នកជំទាស់ថា “ឈានូបេក្ខានេះ ដោយអត្ថ ក៏ជាតត្រមជ្ឈត្តតូបេក្ខាមិនមែនឬ, និងតត្រមជ្ឈត្តតូបេក្ខានោះ ក៏មាននៅក្នុងបឋមជ្ឈាន និងទុតិយជ្ឈាន ព្រោះហេតុនោះ សូម្បីក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ ឈានូបេក្ខានេះ ក៏គួរពោលថា ‘**ឧបេក្ខកោ ច វិហរតិ** អ្នកសម្លឹង’ ដូច្នេះ ព្រោះហេតុអ្វី ទើបមិនត្រាស់ឈានូបេក្ខាទុក?” ឆ្លើយថា ព្រោះបឋមជ្ឈាន និងទុតិយជ្ឈាននេះ មានកិច្ចនៅមិនទាន់ច្បាស់លាស់ ។ ពិតមែន កិច្ច គឺសេចក្ដីច្បាស់លាស់ក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះមិនមាន, ព្រោះត្រូវធម៌ដែលជាសត្រូវទាំងឡាយ មានវិតក្កៈជាដើមគ្របសង្កត់ហើយ; ប៉ុន្តែក្នុងតតិយជ្ឈាននេះមិនមានសត្រូវ គឺវិតក្កៈ វិចារៈ និងបីតិគ្របសង្កត់ទេ ប្រៀបដូចជាងើបក្បាលឡើងបានហើយ

មានកិច្ចដែលច្បាស់លាស់ហើយ ព្រោះហេតុដូច្នោះ ទើបពោលឈានូបេក្ខា ទុកក្នុងតតិយជ្ឈាននេះ ។

**ចប់ការពណ៌នាសេចក្ដីទាំងពួងនៃពាក្យថា “ឧបេក្ខកោ ច វិហរតិ” ត្រឹមតែប៉ុណ្ណេះ ។**

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា “**សតោ ច សម្បជានោ** = មានសតិ និងសម្បជញ្ញៈ” នេះដូចតទៅ ៖-

បុគ្គលណា រមែងរលឹកបាន ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា មានសតិ ។ បុគ្គលណារមែងដឹងទូទៅដោយប្រពៃ, ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **មានសម្បជានៈ** (អ្នកដឹងទូទៅដោយប្រពៃ) ។ ព្រះមានព្រះភាគត្រាស់សតិ និងសម្បជញ្ញៈ ទុកដោយបុគ្គលាធិដ្ឋាន ។ បណ្ដាសតិ និងសម្បជញ្ញៈនោះ សតិមានការរលឹកជាលក្ខណៈ, មានការមិនវង្វេងភ្លេចជារស (កិច្ច), មានការរក្សាជាបច្ចុប្បដ្ឋាន... សម្បជញ្ញៈមានការមិនវង្វេងអារម្មណ៍ (ការដឹងទូទៅដោយប្រពៃ) ជាលក្ខណៈ, មានការពិចារណា (ឬមានការដល់ច្រាំង) ជារស, មានការគិតជញ្ជឹងជាបច្ចុប្បដ្ឋាន... ។

បណ្ដាឈានទាំងនោះ សតិ និងសម្បជញ្ញៈនេះ សូម្បីមាននៅក្នុងឈានខាងដើមក៏ពិតមែនហើយ; ប៉ុន្តែថា កាលព្រះយោគាវចរមានសតិវង្វេងភ្លេច មិនមានសម្បជញ្ញៈ សូម្បីត្រឹមតែឧបចារជ្ឈាន ក៏រមែងមិន

សម្រេច, នឹងចាំបាច់ពោលទៅថ្វីដល់អប្បនា, ទោះយ៉ាងនោះ ព្រោះភាវៈសេចក្ដីដែលឈានទាំងឡាយ (បឋមជ្ឈាន ទុតិយជ្ឈាន) ទាំងនោះ ជាអង្គដ៏គ្រោតគ្រាត គន្លងផ្លូវទៅ (គតិ) របស់ចិត្តនឹងត្រូវជាផ្លូវសប្បាយ ដូចផ្លូវទៅរបស់បុគ្គលលើផែនដីដូច្នោះ, កិច្ចនៃសតិ និងសម្បជញ្ញៈ ក្នុងឈានខាងដើមៗ នោះ នៅមិនទាន់មានកម្លាំងខ្លាំងក្លា, ប៉ុន្តែព្រោះឈានទី ៣ នេះ ជាឈានមានអារម្មណ៍សុខុម ព្រោះលះអង្គឈានគ្រោតគ្រាតៗ បានការប្រព្រឹត្តទៅនៃចិត្តដែលជាកិច្ច (មុខនាទី) របស់សតិ និងសម្បជញ្ញៈផ្គងទុកហើយនោះ ដែលព្រះយោគីគប្បីប្រាថ្នា ដូចបុរសដើរទៅក្នុងកន្លែងមានបន្លាស្រួចដូច្នោះ ព្រោះហេតុនោះ សតិ និងសម្បជញ្ញៈ ទើបត្រាស់ទុកក្នុងតតិយជ្ឈាននេះប៉ុណ្ណោះ ។

គប្បីជ្រាបសេចក្ដីនេះ ឱ្យក្រៃលែងឡើងបន្ថែមទៅទៀតថា ៖-

ប្រៀបដូចកូនគោដែលនៅបៅដោះមេគោ កាលម្ចាស់ពង្រាត់ចេញទៅហើយ មិនរក្សាទុកដាក់ រមែងត្រឡប់មករកមេគោទៀត យ៉ាងណាមិញ, សុខក្នុងតតិយជ្ឈាននេះក៏ដូច្នោះដែរ ដែលព្រះយោគាវចរបន្សាត់ចាកបីតិបានហើយ សុខនោះមិនរក្សាទុកដោយសតិ និងសម្បជញ្ញៈ ក៏គប្បីត្រឡប់មករកបីតិទៀត សុខនោះក៏គប្បីសម្បយុត្តជាមួយនឹងបីតិដោយពិត ។ ម្យ៉ាងទៀត សត្វទាំងឡាយរមែងត្រេកអរក្នុងសុខ; ឯសុខនេះ (តតិយជ្ឈាន) ក៏មានសុខដ៏ពេញចិត្តក្រៃលែង, ព្រោះមិនមានសុខដទៃក្រៃលែងជាងនេះទេ; ប៉ុន្តែ

ដោយអានុភាពនៃសតិ និងសម្បជញ្ញៈក្នុងតតិយជ្ឈាននេះ មិនមានសេចក្ដីត្រេកអរក្នុងសុខ, មិនមែនដោយអានុភាពដទៃទៀយ ព្រោះហេតុដូច្នោះ ដើម្បីសម្ដែងនូវសេចក្ដីផ្សេងគ្នានៃសេចក្ដីនេះ ទើបត្រាស់ពាក្យថា សតិ និង សម្បជញ្ញៈទុកក្នុងតតិយជ្ឈាននេះតែម្ដង ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា "**សុខញ្ច កាយេន បដិសំវេទេតិ** = ក៏សោយសុខដោយនាមកាយ" នេះដូចតទៅ ៖-

ការចងចិត្តក្នុងការសោយចំពោះសេចក្ដីសុខរបស់បុគ្គលអ្នកដល់ព្រម ដោយតតិយជ្ឈាន រមែងមិនមាន ក៏ពិតមែនហើយ, ប៉ុន្តែថា ព្រោះសេចក្ដីសុខរបស់ព្រះយោគាវចរនោះសម្បយុត្តជាមួយនាមកាយ, ឬថា ព្រះយោគាវចរនោះ គប្បីសោយសុខណា សុខនោះដែលសម្បយុត្តជាមួយនាមកាយ, ឬ ព្រោះរូបដ៏ប្រណីតក្រៃលែង ដែលតាំងឡើងដោយនាមកាយនោះសម្ផស្ស (ពាល់) ត្រូវរូបកាយរបស់ព្រះយោគាវចរនោះ, សូម្បីលោកចេញចាកជ្ឈាន ហើយ ក៏នៅសោយសេចក្ដីសុខ ព្រោះភាពនៃកាយនោះ ដែលរូបប្រណីត ក្រៃលែងពាល់ត្រូវហើយ, ព្រោះហេតុដូច្នោះ កាលនឹងសម្ដែងសេចក្ដីនោះ ទើបត្រាស់ពាក្យថា "**សុខញ្ច កាយេន បដិសំវេទេតិ**" ។

ឥឡូវនេះ គប្បីជ្រាបអធិប្បាយក្នុងពាក្យថា "**យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារី** = ព្រះអរិយៈទាំងឡាយ រមែង

ពោលថា បុគ្គលអ្នកសម្លឹងព្រងើយៗ មានសតិនៅជាសុខ” ដូចតទៅៈ-

ព្រះអរិយៈទាំងឡាយមានព្រះពុទ្ធជាម្ចាស់ជាដើម តែងតែប្រាប់, តែងតែសម្ដែង, តែងតែបញ្ញត្ត, រមែងតែងតាំង, រមែងបើកបង្ហាញ, រមែងចែក, រមែងធ្វើឱ្យងាយ, រមែងប្រកាស, រមែងសរសើរនូវបុគ្គលអ្នកដល់ព្រមដោយតតិយជ្ឈាននោះ ព្រោះឈានណាជាហេតុ ព្រោះឈានណា ជាការណៈ ។

សួរថា រមែងសសើរដូចម្ដេច ?

ឆ្លើយថា រមែងសរសើរថា ជាអ្នកសម្លឹងព្រងើយៗ មានសតិនៅជាសុខ ។

បណ្ឌិតគប្បីជ្រាបការប្រកបសេចក្ដីក្នុងបញ្ហានោះ យ៉ាងនេះថា ព្រះយោគាវចរចូលដល់ឈានទី ៣ នោះហើយនៅ ។ ព្រោះហេតុអ្វី ព្រះអរិយៈទាំងឡាយ ទើបសរសើរព្រះយោគីនោះយ៉ាងនេះ? ព្រោះលោកជាអ្នកគួរដល់ការសសើរ ។ ពិតមែន ព្រះយោគាវចរនេះ ជាអ្នកសម្លឹងព្រងើយៗ ក្នុងតតិយជ្ឈានដែលមានសេចក្ដីសុខដ៏ពេញចិត្តក្រៃលែង សូម្បីដល់ទីបំផុតនៃសេចក្ដីសុខ ក៏មិនត្រូវការជាប់ចិត្តក្នុងសុខ ទាក់ទាញមកក្នុងតតិយជ្ឈាននោះ, និងឈ្មោះថា ជាអ្នកមានសតិ ព្រោះមានសតិតាំងមាំដោយប្រការដែលបីតិនឹងមិនកើតឡើង, និងរមែងសោយសេចក្ដីមិនសៅហ្មង ដែលព្រះ

អរិយៈប្រាថ្នា ដែលអរិយជនសេពហើយនោះដោយនាមកាយ, ព្រោះហេតុនោះ ព្រះយោគីនោះ ទើបគួរដើម្បីសសើរ ។ ដោយប្រការដូចពោលមកនេះ បណ្ឌិតគប្បីជ្រាបថា ព្រះអរិយៈជាម្ចាស់ទាំងនោះ កាលនឹងប្រកាសគុណដែលជាហេតុគួរដល់ការសរសើរយ៉ាងនេះ ព្រះយោគាវចរនោះ ជាអ្នកសម្លឹងព្រងើយៗ មានសតិនៅជាសុខ ព្រោះលោកគួរដល់ការសរសើរដូច្នេះ ។

ពាក្យថា **តតិយំ** ទី ៣ គឺឈ្មោះថា ជាទី ៣ ព្រោះរាប់តាមលំដាប់ ។ ឈាននេះ ឈ្មោះថា ទី ៣ ព្រោះអត្ថថា រមែងចូលដល់គ្រាទី ៣ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទដែលចែក និងមិនចែកក្នុងពាក្យជាដើមថា **“តស្មឹ សមយេ ផស្សោ ហោតិ”** ដូច្នេះ ក្នុងពួក ៥ នៃឈាននោះ ។ សូម្បីបទនៃបីតិ ក៏ត្រូវបន្ថយទៅដោយអំណាចនៃឈាននោះ ។ សូម្បីក្នុងកោដ្ឋាសវារៈ ក៏ត្រាស់ថា ឈានមានអង្គ ២ ពាក្យដ៏សេសដូចគ្នានឹងទុតិយជ្ឈាននោះដូច្នេះឯង ៕

**ចប់តតិយជ្ឈាន**

# អធិប្បាយអំពីចតុត្ថជ្ឈាន

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃចតុត្ថជ្ឈានដូចតទៅ ៖-

បទថា **"សុខស្ស ច បហានា ទុក្ខស្ស ច បហានា** = ព្រោះលះសុខ និងទុក្ខបាន" បានដល់ ការលះសុខផ្លូវកាយ និងទុក្ខផ្លូវកាយ ។ ពាក្យថា **"បុព្វេវ"** គឺការលះនោះ មានក្នុងកាលមុនតែម្តង, មិនមែនមានក្នុងខណៈនៃចតុត្ថជ្ឈានឡើយ ។ ពាក្យថា **"សោមនស្សទោមនស្សានំ អត្ថង្គមា** = ព្រោះសោមនស្ស និងទោមនស្សរលត់អស់ទៅ" សេចក្តីថា ព្រោះដល់ការតាំងនៅមិនបាននៃធមិទាំង ២ នេះ គឺសុខផ្លូវចិត្ត និងទុក្ខផ្លូវចិត្ត ពាក្យនេះលោកអធិប្បាយថា ព្រោះលះចេញហើយ ។

សួរថា : ក៏ការលះសុខ និងទុក្ខផ្លូវចិត្តទាំងនោះ មានក្នុងកាលណា?

ឆ្លើយថា : ក្នុងខណៈនៃឧបចារជ្ឈានទាំង ៤ ។

ពិតមែន ព្រះយោគាវចរលះសោមនស្សបាន ក្នុងខណៈនៃឧបចារៈរបស់ឈានទី ៤ ប៉ុណ្ណោះ, ចំណែកទុក្ខ ទោមនស្ស និងសុខរមែងលះបានក្នុងខណៈនៃឧបចារៈរបស់ឈានទីមួយ ទីពីរ និងទីបី ។ ដោយប្រការដូច្នេះ បណ្ឌិតគប្បីជ្រាបការលះសុខ ទុក្ខ សោមនស្ស និងទោមនស្ស សូម្បីមិនត្រាស់ទុកដោយលំដាប់នៃការលះអង្គឈានទាំងនោះ ប៉ុន្តែក៏ត្រាស់ក្នុងឈាន

ទី ៤ នេះ ដោយលំដាប់ឧទ្ទេសនៃឥន្ទ្រិយទាំងឡាយ ក្នុងឥន្ទ្រិយវិភង្គ[៩៦] នោះឯង ។

សួរថា ក៏អង្គឈានទាំងនោះ ព្រះយោគាវចររមែងលះបានក្នុងខណៈនៃឧបចារៈរបស់ឈាននោះៗសោត កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបត្រាស់ការរំលត់ក្នុងឈានទាំងឡាយយ៉ាងនេះថា **“ក៏ទុក្ខិន្ទ្រិយកើតឡើងហើយរមែងរលត់ទៅមិនមានចំណែកសល់ ក្នុងទីណា? ម្នាលភិក្ខុទាំងឡាយភិក្ខុក្នុងធម្មវិន័យនេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ ចូលបឋមជ្ឈាន មានវិតក្កៈ វិចារៈ បីតិ និងសុខកើតអំពីវិវេក ទុក្ខិន្ទ្រិយដែលកើតឡើងហើយ រមែងរលត់ទៅមិនមានចំណែកសេសសល់ ក្នុងទីនេះ... ក៏ទោមនស្សិន្ទ្រិយ ។ល។ សុខិន្ទ្រិយ ។ល។ សោមនស្សិន្ទ្រិយកើតឡើងហើយ រមែងរលត់ទៅមិនមានចំណែកសេសសល់ ក្នុងទីណា? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ចូលចតុត្ថជ្ឈាន មិនមានទុក្ខ មិនមានសុខ ព្រោះលះទុក្ខ និងសុខ និងរំលត់សោមនស្សទោមនស្សមុនៗ មានឧបេក្ខាជាហេតុឱ្យសតិបរិសុទ្ធ សោមនស្សិន្ទ្រិយដែលកើតឡើងហើយ រមែងរលត់ទៅ មិនមានចំណែកសេសសល់ក្នុងទីនេះ”**[៩៧] ។

---

[៩៦] អភិ. ។

ឆ្លើយថា ព្រោះសេចក្ដីរលត់ល្អក្រៃលែង ។

ដែលពិត ការរំលត់អង្គឈានទាំងនោះក្នុងបឋមជ្ឈានជាដើម ក៏ជាការរំលត់យ៉ាងល្អក្រៃលែងដូចគ្នា ប៉ុន្តែការរំលត់ក្នុងខណៈនៃឧបចារឈានមិនឈ្មោះថា **ការរំលត់ដែលល្អក្រៃលែង** ពិតយ៉ាងនោះមែន កាលទុក្ខិន្ទ្រិយរលត់ទៅហើយ ក្នុងឧបចារៈនៃបឋមជ្ឈាន ក្នុងអាវជ្ជនៈផ្សេងៗ ការកើតឡើងនៃទុក្ខិន្ទ្រិយ នឹងគប្បីមានបាន ព្រោះសម្ផស្សដែលកើតអំពីសត្វមានរបោមមូសជាដើម, ឬថា ព្រោះសេចក្ដីលំបាកដែលកើតអំពីការអង្គុយ ក្នុងទីដែលមិនស្មើ ចំណែកខាងក្នុងអប្បនា ទុក្ខន្ទ្រិយនោះមិនកើតឡើងឡើយ ។

ម្យ៉ាងទៀត ទុក្ខិន្ទ្រិយក្នុងឧបចារឈាននេះ នៅមិនទាន់រំលត់ឱ្យអស់រលីងទេ ព្រោះនៅមិនបានត្រូវបដិបក្ខធម៌ (គឺឈាន) ហាម ប៉ុន្តែថា ខាងក្នុងអប្បនា កាយទាំងពួងបានធ្លាក់ចុះកាន់សេចក្ដីសុខហើយ ដោយការផ្សព្វផ្សាយទៅនៃបីតិ, ទុក្ខិន្ទ្រិយរបស់ព្រះយោគាវចរអ្នកមានកាយដែលធ្លាក់ចុះហើយក្នុងសេចក្ដីសុខ រមែងជាធម៌រំលត់អស់មិនមានសេសសល់ ព្រោះត្រូវបដិបក្ខធម៌កម្ចាត់ហើយ ។

ម្យ៉ាងទៀត ទោមនស្សិន្ទ្រិយ សូម្បីព្រះយោគាវចរលះបានហើយក្នុងឧបចារៈនៃទុតិយជ្ឈាន ក្នុងអាវជ្ជនៈនៃចិត្តផ្សេងៗនោះ ទោមនស្សិន្ទ្រិយ

---

[៩៧] សំ. ម. ។

នេះ ក៏នឹងគប្បីកើតឡើង ព្រោះការលំបាកកាយ និងការចង្អៀតចង្អល់ចិត្ត ដែលមានវិតក្កៈ និងវិចារៈជាបច្ច័យនៅមាន, ប៉ុន្តែកាលមិនមានវិតក្កៈ និងវិចារៈ ទោមនស្សិន្ទ្រិយនឹងមិនកើតឡើង; ប៉ុន្តែកាលវិតក្កៈ និងវិចារៈនៅមានក្នុងទីណា ទោមនស្សិន្ទ្រិយក៏រមែងកើតឡើងក្នុងទីនោះ គឺថា វិតក្កៈ និងវិចារៈក្នុងឧបចារៈនៃទុតិយជ្ឈានដែលព្រះយោគាវចរនៅលះមិនបាន; ព្រោះហេតុដូច្នោះ ទោមនស្សិន្ទ្រិយ ក៏គប្បីកើតឡើងក្នុងទីនោះ ព្រោះសេចក្តីដែលវិតក្កៈ និងវិចារៈជាបច្ច័យដែលនៅលះមិនបាន, ចំណែកក្នុងទុតិយជ្ឈាន ទោមនស្សិន្ទ្រិយកើតឡើងមិនបានឡើយ ព្រោះភាពដែលវិតក្កៈ និងវិចារៈជាបច្ច័យនោះ លោកលះបានហើយ ។

ម្យ៉ាងទៀត ក្នុងឧបចារៈនៃតតិយជ្ឈាន សុខិន្ទ្រិយសូម្បីព្រះយោគាវចរលះបានហើយ នឹងគប្បីកើតឡើងដល់កាយដែលមានរូបដ៏ប្រណីត មានបីតិជាសមុដ្ឋានពាល់ត្រូវហើយ; ចំណែកក្នុងតតិយជ្ឈាន សុខិន្ទ្រិយនឹងកើតមិនបានឡើយ; ព្រោះថា បីតិដែលជាបច្ច័យដល់សុខក្នុងតតិយជ្ឈាន រមែងរលត់ទៅដោយប្រការទាំងពួង ។

ម្យ៉ាងទៀត ក្នុងឧបចារៈនៃចតុត្ថជ្ឈាន សោមនស្សិន្ទ្រិយសូម្បីព្រះយោគីលះហើយ ក៏គប្បីកើតឡើងបាន ព្រោះជាសភាវៈយ៉ាងជិត ចំពោះសុខ និងព្រោះនៅមិនទាន់ឈានកន្លងដោយប្រពៃ ដោយមិនមានឧបេក្ខាដែល

ដល់អប្បនា, ចំណែកក្នុងចតុត្ថជ្ឈាន សោមនស្សិន្ទ្រិយនឹងកើតមិនបានឡើយ; ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់កាន់យកដោយមិនមានចំណែកសេសសល់ក្នុងទីនោះៗ យ៉ាងនេះថា “ក៏ទុក្ខិន្ទ្រិយកើតឡើងហើយរមែងរលត់ទៅមិនមានចំណែកសល់ក្នុងទីនេះ”។

ក្នុងអធិការនៃចតុត្ថជ្ឈាននេះ មានអ្នកជំទាស់ថា “បើវេទនាទាំងនេះ សូម្បីព្រះយោគីលះហើយក្នុងឧបចារៈនៃឈាននោះៗ ដោយអាការយ៉ាងនេះ ព្រោះហេតុអ្វី ក្នុងទីនេះ ទើបនាំមកត្រាស់ម្ដងទៀត?” ឆ្លើយថា ដើម្បីឱ្យយល់បានងាយ ។ ពិតមែន វេទនាមិនមែនទុក្ខ មិនមែនសុខនេះណាដែលត្រាស់ទុកក្នុងអង្គនៃឈាននេះថា “មិនមែនទុក្ខ មិនមែនសុខ” , វេទនានោះសុខុមដឹងបានដោយលំបាក, នរណាៗ មិនអាចយល់បានដោយងាយ, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទើបទ្រង់នាំវេទនាទាំងអស់នេះមកទៀត ដើម្បីឱ្យកំណត់បានដោយងាយ ប្រៀបដូចនាយគោបាល ត្រូវការចាប់គោកាចមួយ ដែលនរណាៗមិនអាចដើម្បីនឹងចូលទៅចាប់ដោយវិធីណាមួយ ទើបដេញគោទាំងអស់ចូលទៅក្នុងក្រោលជាមួយគ្នា, ពេលនោះគេទើបដេញចេញទៅម្ដងមួយៗ វាក៏ចេញមកដោយលំដាប់ ទើបចង្អុលឱ្យចាប់វាថា “គោមួយនេះ គឺគោកាចនោះ, ពួកលោកចូរចាប់វា” យ៉ាងណាមិញ; សេចក្ដីនេះ ក៏ដូច្នោះដែរ ។

ព្រះមានព្រះភាគ គ្រាត្រាស់សម្ដែងវេទនាទាំងនេះ ដែលទ្រង់ប្រមូល

មកដោយអាការយ៉ាងនេះហើយ នរណា១ ក៏អាចដើម្បីនឹងឱ្យបុគ្គលកំណត់វេទនានោះបានថា "សភាវៈណាមិនមែនសុខ មិនមែនទុក្ខ មិនមែនសោមនស្ស មិនមែនទោមនស្ស, សភាវៈនេះជាអទុក្ខមសុខវេទនា" ។

ម្យ៉ាងទៀត គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់វេទនាទាំងនោះដើម្បីទ្រង់ចង្អុលដល់បច្ច័យនៃចេតោវិមុត្តិ គឺសេចក្ដីរួចផុតនៃចិត្ត ដែលមិនមានទុក្ខ និងសុខ; ព្រោះថា ការលះសុខ និងទុក្ខជាដើម ជាបច្ច័យដើម្បីចេតោវិមុត្តិនោះ; ម្យ៉ាង ដូចព្រះធម្មទិន្នាថេរីពោលថា **"ចត្តារោ ខោ អាវុសោ បច្ចយា អទុក្ខមសុខាយ ចេតោវិមុត្តិយា សមាបត្តិយា ។បេ។ សមាបត្តិយា** ម្នាលអ្នកដ៏មានអាយុ បច្ច័យនៃសមាបត្តិ ដែលជាចេតោវិមុត្តិ មិនមានទុក្ខ មិនមានសុខ មាន ៤ យ៉ាងដូច្នេះ, ម្នាលអ្នកដ៏មានអាយុ ភិក្ខុក្នុងព្រះធម្មវិន័យនេះ ចូលដល់ចតុត្ថជ្ឈាន ដែលមិនមានទុក្ខ និងសុខ ព្រោះលះសុខ និងទុក្ខ និងរំលត់សោមនស្សក្នុងកាលមុនចេញបានមានឧបេក្ខាជាហេតុឱ្យសតិបរិសុទ្ធ ម្នាលអ្នកដ៏មានអាយុ បច្ច័យនៃសមាបត្តិដែលជាចេតោវិមុត្តិ ដែលមិនមានទុក្ខ មិនមានសុខ ៤ យ៉ាងនេះឯង" [៩៨] ។

ម្យ៉ាងវិញទៀត គប្បីជ្រាបថា សំយោជនៈមានសក្កាយទិដ្ឋិជាដើម ដែលព្រះអរិយៈជាម្ចាស់លះបានហើយក្នុងមគ្គដទៃ (មានបឋមមគ្គជាដើម)

---

[៩៨] ម. មូ., ម. ម. ។

ព្រះមានព្រះភាគដើម្បីនឹងទ្រង់លើកតម្កើងមគ្គទី ៣ ទើបត្រាស់ថា លះហើយ ក្នុងមគ្គទី ៣ នោះ ដូច្នេះយ៉ាងណា, ដើម្បីទ្រង់លើកតម្កើងឈាននោះ ទើបត្រាស់ដល់អទុក្ខមសុខវេទនានោះក្នុងឈានទី ៤ នេះ ។ ឬម្យ៉ាងទៀត គប្បីជ្រាបថា ទ្រង់ត្រាស់អទុក្ខមសុខនោះ ដើម្បីសម្ដែងដល់សេចក្ដីនៃរាគៈ និងទោសៈជាសភាពឆ្ងាយក្រៃលែង ក្នុងឈានទី ៤ នេះ ដោយកម្ចាត់បច្ច័យបានហើយ; ពិតមែន បណ្ដាឈានទាំងនេះ សុខជាបច្ច័យដល់សោមនស្ស, សោមនស្សជាបច្ច័យដល់រាគៈ, ទុក្ខជាបច្ច័យដល់ទោមនស្ស, ទោមនស្សជាបច្ច័យដល់ទោសៈ; រាគៈ និងទោសៈព្រមទាំងបច្ច័យដែលចតុត្ថជ្ឈានកម្ចាត់ហើយ ព្រោះកម្ចាត់សេចក្ដីសុខជាដើមបានហើយ ព្រោះហេតុដូច្នោះ រាគៈ និងទោសៈ ទើបឈ្មោះថា **មាននៅក្នុងទីដ៏ឆ្ងាយក្រៃលែងដូច្នេះ** ។

ពាក្យថា **“អទុក្ខមសុខំ”** សេចក្ដីថា ឈ្មោះថា **អទុក្ខ** ព្រោះមិនមានទុក្ខ, ឈ្មោះថា **អសុខ** ព្រោះមិនមានសុខ ។ ដោយពាក្យថា **អទុក្ខមសុខំ** នេះ រមែងទ្រង់សម្ដែងវេទនាទី ៣ ដែលជាបដិបក្ខចំពោះទុក្ខ និងសុខក្នុងចតុត្ថជ្ឈាននេះ, មិនមែនទ្រង់សម្ដែងត្រឹមតែមិនទុក្ខ មិនសុខទេ; ប៉ុន្តែត្រាស់ថា មិនទុក្ខ មិនសុខ ឈ្មោះថា **វេទនាទី ៣**, ជាឧបេក្ខាដូច្នេះក៏មាន ។

ឧបេក្ខាវេទនានោះ គប្បីជ្រាបថា មានការសោយអារម្មណ៍ផ្ទុយគ្នានឹងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាលក្ខណៈ, មានភាពជាកណ្ដាល ជារស,

មានការមិនប្រាកដច្បាស់ជាបច្ចុប្បដ្ឋាន, មានការរលត់សេចក្ដីសុខជាបទដ្ឋាន ។

ពាក្យថា **“ឧបេក្ខាសតិបារិសុទ្ធិំ** មានសតិបរិសុទ្ធព្រោះឧបេក្ខា” បានដល់ មានសតិបរិសុទ្ធដែលឧបេក្ខាកើតឡើងហើយ; ព្រោះក្នុងឈាននេះ សតិបរិសុទ្ធល្អហើយ, ក៏ការបរិសុទ្ធរបស់សតិនេះ ដែលឧបេក្ខាធ្វើហើយ មិនមែនធម៌ដទៃធ្វើឱ្យទេ; ព្រោះហេតុនោះ ចតុត្ថជ្ឈាននេះ ទើបឈ្មោះថា **“មានសតិបរិសុទ្ធ** ព្រោះឧបេក្ខា” ។ **សូម្បីក្នុងវិភង្គ** ព្រះមានព្រះភាគក៏ត្រាស់ថា “សតិនេះដែលឧបេក្ខានេះ បើកហើយ ជាធម្មជាតិបរិសុទ្ធផូរផង់, ព្រោះហេតុនោះ ទើបត្រាស់ថា មានសតិបរិសុទ្ធព្រោះឧបេក្ខា”[៩៩] ។ ម្យ៉ាងទៀត សេចក្ដីបរិសុទ្ធនៃសតិក្នុងឈាននេះ រមែងមានបានដោយឧបេក្ខាណា, ឧបេក្ខានោះ ពោលដោយសេចក្ដី គប្បីជ្រាបថា ជាតត្រមជ្ឈត្តតាដូច្នេះ; ក៏ក្នុងចតុត្ថជ្ឈាននេះ សតិប៉ុណ្ណោះបរិសុទ្ធហើយដោយឧបេក្ខានោះត្រឹមតែម្យ៉ាង ក៏មិនបាន; ដែលពិតសម្បយុត្តធម៌ទាំងអស់ក៏បរិសុទ្ធ ព្រោះឧបេក្ខាដូចគ្នា ប៉ុន្តែត្រាស់ទេសនាទុកដោយលើក**សតិជាប្រធាន**; បណ្ដាឈានទាំងនោះ ឧបេក្ខានេះសូម្បីនឹងមាននៅក្នុងឈាន ៣ ទាប១ ក៏ពិតមែនហើយ, ប៉ុន្តែក៏មិនធ្វើឱ្យសតិ និងសម្បយុត្តធម៌បរិសុទ្ធថ្លាផូរផង់ឡើយ ប្រៀបដូចដួងព្រះចន្ទ សូម្បីនៅក្នុងពេលថ្ងៃ ក៏មិនបរិសុទ្ធថ្លាផូរផង់ ព្រោះពេលថ្ងៃ ត្រូវរស្មី

---

[៩៩] អភិ. ។

ព្រះអាទិត្យគ្របសង្កត់ និងព្រោះមិនបានរាត្រីដែលជាសភាគៈដោយរាត្រីភ្លឺថ្លាស្រឡះ ឬរាត្រីដែលឧបការៈដល់ខ្លួន យ៉ាងណា, សូម្បីដួងព្រះចន្ទ គឺតត្រមជ្ឈត្តតូបេក្ខានេះ ក៏ដូច្នោះដែរ ព្រោះត្រូវតេជះនៃធម៌ដែលជាសត្រូវ មានវិតក្កៈជាដើមគ្របសង្កត់ និងមិនបានរាត្រីដែលជាសភាគៈ គឺឧបេក្ខាវេទនា សូម្បីនឹងមាននៅក្នុងឈាន មានបឋមជ្ឈានជាដើម ក៏មិនបរិសុទ្ធ ប្រៀបដូចដួងព្រះចន្ទមិនបរិសុទ្ធផូរផង់ក្នុងវេលាថ្ងៃ រស្មីនៃដួងព្រះចន្ទក៏មិនបរិសុទ្ធ សូម្បីសហជាតធម៌មានសតិជាដើម ក៏មិនបរិសុទ្ធដូចគ្នា; ព្រោះហេតុដូច្នោះ ក្នុងឈានទាំងនោះ សូម្បីឈានមួយក៏មិនត្រាស់ថា “មានសតិបរិសុទ្ធ ព្រោះឧបេក្ខា” ; ប៉ុន្តែក្នុងចតុត្ថជ្ឈាននេះ ដួងព្រះចន្ទ គឺតត្រមជ្ឈត្តតូបេក្ខានេះ បរិសុទ្ធក្រៃលែងពេកណាស់ ព្រោះបានរាត្រី គឺឧបេក្ខាវេទនាជាសភាគៈ ព្រោះមិនត្រូវតេជះនៃសត្រូវមានវិតក្កៈជាដើមគ្របសង្កត់ ព្រោះហេតុដែលឧបេក្ខានោះជាធម៌បរិសុទ្ធ សូម្បីសហជាតធម៌មានសតិជាដើម ក៏បរិសុទ្ធផូរផង់ ដូចរស្មីនៃដួងព្រះចន្ទដែលបរិសុទ្ធហើយ; ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ចតុត្ថជ្ឈាននេះប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ថា “មានសតិបរិសុទ្ធ ព្រោះឧបេក្ខា” ។

ពាក្យថា **“ចតុត្ថំ”** ប្រែថា ទី ៤ ដោយលំដាប់នៃការរាប់ ។ ឈាននេះឈ្មោះថា **ឈានទី ៤** ព្រោះអត្ថថា រមែងសម្រេចក្នុងគ្រាទី ៤ ។ ក្នុងពាក្យថា **“ផស្សោ ហោតិ”** ជាដើម គប្បីជ្រាបក្នុងផស្សបញ្ចកៈ (ពួក ៥

នៃផស្សៈ) ពោលថាវេទនានោះជាឧបេក្ខាវេទនាប៉ុណ្ណោះ ។ មួយ៉ាងទៀត ក្នុងពួក ៥ នៃឈាន និងពួក ៨ នៃឥន្ទ្រិយ ក៏ត្រាស់ថា ជាឧបេក្ខា ជាឧបេក្ខិន្ទ្រិយនោះឯង ។ បទដែលសល់ក្រៅអំពីនេះ មិនមានក្នុងឈានទី ៣ សូម្បីក្នុងឈានទី ៤ នេះ ក៏មិនមានដូចគ្នា ។ សូម្បីក្នុងកោដ្ឋាសវារៈ ក៏ត្រាស់ថា **ឈានមានអង្គ ២** ពាក្យនេះ គប្បីជ្រាបដោយអំណាចនៃឧបេក្ខា និងចិត្តេកគ្គតាហ្នឹងហើយ ។ ពាក្យដ៏សេសទាំងពួង ដូចគ្នានឹងតតិយជ្ឈាននោះឯង ៕

ចប់ឈានចតុក្កន័យ

## អធិប្បាយអំពីឈានបញ្ចកន័យ

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមបញ្ចកន័យ (ន័យនៃឈានពួក ៥) ថា **“កតមេ ធម្មា កុសលា** = ធម៌ជាកុសលតើដូចម្ដេច?” ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់សម្ដែងឈានបញ្ចកន័យ? ឆ្លើយថា ព្រោះសម្ដែងតាមអធ្យាស្រ័យរបស់បុគ្គល និងព្រោះលំអរនៃទេសនា; បានឮថា ក្នុងទេវបរិស័ទដែលប្រជុំគ្នា វិតក្កៈរបស់ទេវតាពួកខ្លះប៉ុណ្ណោះ ប្រាកដជារបស់គ្រោតគ្រាត, ចំណែកវិចារៈ, បីតិ, សុខ, ឯកគ្គតាចិត្តប្រាកដជារបស់ស្ងប់; ព្រះសាស្ដាទ្រង់ចែកឈ្មោះទុតិយជ្ឈានមានអង្គ ៤ ដែលមិនមានវិតក្កៈ មានតែវិចារៈ ដោយអំណាចនៃសប្បាយដល់ទេវតាទាំងនោះ;

ពួកខ្លះមានវិចារៈ ប្រាកដជារបស់គ្រោតគ្រាត, បីតិ, សុខ, ឯកគ្គតាចិត្ត ប្រាកដជារបស់ស្ងប់; ព្រះសាស្តាក៏ទ្រង់ចែកឈ្មោះតតិយជ្ឈានមានអង្គ ៣ ដោយអំណាចនៃសប្បាយដល់ទេវតាទាំងនោះ; ពួកខ្លះ មានបីតិប្រាកដជារបស់គ្រោតគ្រាត, សុខ, ឯកគ្គតាចិត្ត ប្រាកដជារបស់ស្ងប់; ព្រះសាស្តាក៏ទ្រង់ចែកឈ្មោះចតុត្ថជ្ឈានមានអង្គ ២ ដោយអំណាចនៃសប្បាយដល់ទេវតាទាំងនោះ, ពួកខ្លះមានសុខប្រាកដជារបស់គ្រោតគ្រាត, ឧបេក្ខា និងឯកគ្គតាចិត្តប្រាកដដោយសេចក្ដីស្ងប់; ព្រះសាស្តាក៏ទ្រង់ចែកឈ្មោះបញ្ចមជ្ឈាន មានអង្គ ២ ដោយអំណាចនៃសប្បាយដល់ទេវតាទាំងនោះ; នេះឈ្មោះថា **អធ្យាស្រ័យរបស់បុគ្គល** ។

ចំណែកឈ្មោះថា **ទេសនាដែលដល់ភាពជាលំអរនៃទេសនា** ព្រោះធម្មធាតុ[*]ណា ដែលវេនេយ្យសត្វត្រាស់ដឹងល្អហើយ, ធម្មធាតុនោះ ព្រះតថាគតទ្រង់ត្រាស់ដឹងមកល្អហើយ; ព្រោះហេតុដូច្នោះ ព្រះសាស្តាទ្រង់ជាអ្នកសម្រេចដល់ភាពលំអរនៃទេសនា ព្រះអង្គឈ្លាសក្នុងវិធីទេសនា ព្រោះទ្រង់មានព្រះញាណធំ ទ្រង់កំណត់ទេសនាបានតាមព្រះបំណង, ដោយអំណាចនៃអង្គនោះៗ ក្នុងទីនេះទ្រង់ចែកបឋមជ្ឈានមានអង្គ ៥, ទុតិយជ្ឈានមាន

---

[*] អដ្ឋ. យោ. ពន្យល់ថា ធម្មជាតិណាទ្រទ្រង់ គឺដឹងនូវធម៌ ធម្មជាតិនោះ ឈ្មោះថា ធម្មធាតុ បានដល់ ព្រះសព្វញ្ញុតញ្ញាណ ។

អង្គ ៤ គឺមិនមានវិតក្កៈមានតែវិចារៈ, តតិយជ្ឈានមានអង្គ ៣, ចតុត្ថជ្ឈាន មានអង្គ ២, បញ្ចមជ្ឈានមានអង្គ ២ ហ្នឹងហើយ; នេះឈ្មោះថា **ទេសនាវិលាស** (លំអរនៃទេសនា) ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគទ្រង់សម្ដែងសមាធិ ៣ ពួកណា ក្នុងព្រះសូត្រថា "ម្នាលភិក្ខុទាំងឡាយ សមាធិ ៣ ពួកនេះ គឺ

**១-សវិតក្កសវិចារសមាធិ** សមាធិមានវិតក្កៈ និងវិចារៈ

**២-អវិតក្កវិចារមត្តសមាធិ** សមាធិមិនមានវិតក្កៈ មានតែវិចារៈ

**៣-អវិតក្កអវិចារសមាធិ** សមាធិមិនមានវិតក្កៈ មិនមានវិចារៈ"[១០០] ។

បណ្ដាសមាធិទាំងនោះ សវិតក្កសវិចារសមាធិ និងអវិតក្កអវិចារ-សមាធិ ព្រះមានព្រះភាគទ្រង់ចែកសម្ដែងទុកអំពីខាងដើមហើយ ។ ចំណែក អវិតក្កវិចារមត្តសមាធិ ទ្រង់នៅមិនទាន់បានសម្ដែងទុក; ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ដើម្បីសម្ដែងអវិតក្កវិចារមត្តសមាធិនោះ ទើបទ្រង់ផ្ដើមបញ្ចក ន័យនេះ ។ ក្នុងនិទ្ទេសនៃទុតិយជ្ឈានក្នុងបញ្ចកន័យនោះ បណ្ដាធមិទាំងឡាយ មានផស្សៈជាដើម ធមិមានត្រឹមតែវិតក្កៈប៉ុណ្ណោះ ដែលកាត់បន្ថយចុះ, ចំណែកក្នុងកោដ្ឋាសវារៈសេចក្ដីថា "ឈានមានអង្គ ៤, មគ្គមានអង្គ ៤" ដូច្នេះប៉ុណ្ណោះដែលប្លែកគ្នា; ពាក្យដែលសល់ទាំងអស់ ដូចគ្នានឹងបឋមជ្ឈាន

[១០០] ទី. បា. ។

នោះឯង ។ មួយវិញទៀត ឈានទី ២ ទី ៣ ទី ៤ ក្នុងចតុក្កន័យ, ជាឈានទី ៣ ទី ៤ ទី ៥ ក្នុងបញ្ចកន័យនេះ; ដើម្បីសម្តែងលំដាប់ ការសម្រេចឈានទាំងនោះ គប្បីជ្រាបន័យដូចតទៅនេះ ៖-

បានឮថា បុត្ររបស់អាមាត្យម្នាក់ ចេញចាកជនបទមកកាន់ព្រះនគរ ដើម្បីចូលទៅគាល់ព្រះរាជា, គេគាល់ព្រះរាជាត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ហើយបំផ្លាញទ្រព្យទាំងអស់ដោយការផឹកសុរាមួយថ្ងៃ; ពួកអ្នកលេងសម្រាតសំពត់គេដែលស្រវឹងស្រា, ហើយយកកន្ទេលឫស្សីចាស់មកគ្របទុក, ហើយយកចេញអំពីរោងសុរា; អ្នកដឹងវិជ្ជាមើលលក្ខណៈម្នាក់ឃើញគេដេកលក់កន្លែងគំនរសម្រាម ទើបសន្និដ្ឋានថា "បុរសនេះនឹងជាទីពឹងដល់មហាជនបាន, យើងគួរជួយបុរសនេះ" ទើបឱ្យមុជទឹក, ជម្រះរាងកាយ, ឱ្យស្លៀកដណ្តប់សំពត់សាច់គ្រោតគ្រាតមួយគូរ, ឱ្យលាបដោយទឹកក្រអូបទៀត, ឱ្យស្លៀកដណ្តប់សំពត់ទុកូលសាច់ល្អិត, ឱ្យឡើងកាន់ប្រាសាទ, ឱ្យបរិភោគភោជនយ៉ាងល្អ ហើយប្រគល់អ្នកថែរក្សាឱ្យ ដោយពាក្យថា "ពួកអ្នកចូរបម្រើអ្នកនេះ យ៉ាងនេះ" ហើយចៀសចេញទៅ ។

តអំពីនោះ ពួកអ្នកបម្រើទាំងនោះ ក៏លើកគេឱ្យឡើងកាន់ទីដេក, ក៏ដើម្បីការពារមិនឱ្យគេទៅរានផឹកសុរា អ្នកថែរក្សា ៤ នាក់ បានសង្កត់ដៃ និងជើងគេទុក; មនុស្សម្នាក់ច្របាច់ជើង, ម្នាក់យកផ្លិតស្លឹកត្នោតមកបក់, ម្នាក់

អង្គុយដេញពិណច្រៀងបំពេរ ។ គេបាត់នឿយហត់ ( មានកម្លាំង) ព្រោះលក់លើទីដេកបន្តិចហើយភ្ញាក់ឡើងមិនអាចទ្រាំនឹងការសង្កត់ដៃជើងបាន ទើបគម្រាមដោយពាក្យថា "នរណាមកសង្កត់ជើងសង្កត់ដៃយើង, ចូរចេញទៅ", មនុស្សទាំងនោះក៏ចេញទៅ ត្រឹមតែពាក្យមួយម៉ាត់ប៉ុណ្ណោះ; គេក៏ដេកលក់ទៅទៀត បន្តិចហើយក៏ភ្ញាក់ឡើង ទ្រាំការច្របាច់ជើងមិនបាន ទើបនិយាយថា "នរណាមកច្របាច់ជើងរបស់យើង, ចូរចេញទៅ" , សូម្បីបុគ្គលអ្នកច្របាច់ជើងនោះ ក៏ចៀសចេញទៅត្រឹមតែពាក្យមួយម៉ាត់នោះឯង; គេដេកលក់ទៅទៀត មួយស្របក់ភ្ញាក់ឡើង ទ្រាំនឹងខ្យល់បក់ដោយផ្លិតស្លឹកត្នោតប្រៀបដូចខ្យល់ដែលលាយដោយភ្លៀងមិនបាន ទើបនិយាយថា "នរណា, ចូរចេញទៅ" , សូម្បីបុគ្គលនោះ ក៏ចៀសចេញទៅត្រឹមតែពាក្យមួយម៉ាត់ប៉ុណ្ណោះ; គេដេកលក់បន្តិចទៀតទៅ ភ្ញាក់ឡើងទ្រាំនឹងសំឡេងភ្លេង ដូចលំពែងចាក់ត្រចៀកមិនបាន ទើបសំឡុតគម្រាមអ្នកដេញពិណ, សូម្បីអ្នកដេញពិណក៏ចៀសចេញទៅត្រឹមតែពាក្យមួយម៉ាត់ដូចគ្នា; ពេលនោះ គេលះឧបទ្ទវៈ ( ការរុកគួន) គឺសេចក្ដីរោយអស់កម្លាំង, ការត្រូវគេសង្កត់, ការគក់ច្របាច់, ការត្រូវខ្យល់បក់ និងភ្លេងប្រគំ ទើបដេកយ៉ាងសប្បាយ ភ្ញាក់ឡើងហើយបានទៅគាល់ព្រះរាជា; សូម្បីព្រះរាជា ក៏បានព្រះរាជទាននូវភាពជាធំឱ្យដល់គេ, គេបានជាទីពឹងដល់មហាជនកើតឡើងហើយ ។

ក្នុងរឿងនោះ គប្បីឃើញកុលបុត្រអ្នកគ្រប់គ្រងផ្ទះ ដល់នូវសេចក្តីសាបសូន្យទ្រុឌទ្រោម ព្រោះការវិនាសទៅនៃទ្រព្យជាអនេកនេះ ប្រៀបដូចបុត្រនៃអាមាត្យអ្នកដល់សេចក្តីទ្រុឌទ្រោមសាបសូន្យ ព្រោះវិនាសទៅដោយការផឹកនូវទឹកស្រវឹងនោះ ។ ព្រះតថាគតប្រៀបដូចបុគ្គលអ្នកចេះវិជ្ជាមើលលក្ខណៈ, ការដែលព្រះតថាគតទ្រង់សន្និដ្ឋានថា "កុលបុត្រនេះនឹងជាទីពឹងដល់មហាជនបាន, សមគួរនឹងបព្វជ្ជា" ប្រៀបដូចបុរសអ្នកចេះវិជ្ជាមើលលក្ខណៈសន្និដ្ឋានថា "បុគ្គលនេះ នឹងជាទីពឹងដល់មហាជន, សមគួរនឹងជួយសង្គ្រោះ" ។ បន្ទមកកុលបុត្របានបព្វជ្ជា ប្រៀបដូចបុត្រអាមាត្យនោះ បានមុជទឹកធ្វើការជម្រះរាងកាយ, បន្ទមកកុលបុត្រនេះ បានស្លៀកដណ្តប់សំពត់គឺសីល ១០ ដូចបុត្រអាមាត្យនោះ ស្លៀកដណ្តប់នូវសំពត់សាច់គ្រោតគ្រាត, ការដែលកុលបុត្រនេះ បានលាបស្រឡាបដោយទឹកក្រអូប គឺសីល មាន**បាដិមោក្ខសំវរសីល**ជាដើម ប្រៀបដូចបុត្រអាមាត្យនោះ បានលាបដោយទឹកក្រអូបទៀត, ការដែលកុលបុត្រនេះ បានស្លៀកដណ្តប់នូវសំពត់ទុកូលពស្ត្រ គឺដល់ព្រមដោយសីលវិសុទ្ធិតាមដែលពោលហើយ ប្រៀបដូចបុត្រអាមាត្យនោះ បានស្លៀកដណ្តប់សំពត់ទុកូលសាច់ល្អិតទៀត ។ ការដែលកុលបុត្រនេះ បានស្លៀកដណ្តប់សំពត់ទុកូល គឺ**សីលវិសុទ្ធិ** ឡើងកាន់ប្រាសាទ គឺ**សមាធិភាវនា** ប្រៀបដូចបុត្ររបស់អាមាត្យនោះ ស្លៀកដណ្តប់សំពត់សាច់ល្អិតឡើងកាន់ប្រាសាទ ។

តពីនោះ កុលបុត្រនេះ បានការបរិភោគអមតធម៌ មានសតិ និងសម្បជញ្ញៈជាដើម ដែលមានឧការៈចំពោះសមាធិ ប្រៀបដូចបុត្ររបស់អាមាត្យនោះបរិភោគអាហារយ៉ាងល្អ ។ ការដែលកុលបុត្រនេះ ត្រូវវិតក្កៈនិងវិចារៈលើកឡើងកាន់ឧបចារៈនៃឈាន ប្រៀបដូចបុត្រអាមាត្យនោះបរិភោគអាហារហើយ ត្រូវអ្នកបម្រើទាំងឡាយលើកឡើងកាន់ទីដំណេក ។ នេក្ខម្មវិតក្កៈរបស់កុលបុត្រនេះ គាបសង្កត់ចិត្តក្នុងអារម្មណ៍ ដើម្បីការពារនូវភាពប្រាថ្នាចំពោះកាមសញ្ញា ប្រៀបដូចបុរស ៤ នាក់សង្កត់ជើង សង្កត់ដៃបុត្រនៃអាមាត្យនោះទុក ដើម្បីមិនឱ្យទៅកាន់រោងផឹកសុរាទៀត, វិចារៈដែលបបោសអង្អែលចិត្ត ក្នុងអារម្មណ៍របស់កុលបុត្រនេះ ប្រៀបដូចបុរសច្របាច់ជើងរបស់អាមាត្យនោះ, បីតិដែលឱ្យដល់នូវភាពត្រជាក់ចិត្ត នៃកុលបុត្រនេះ ប្រៀបដូចការឱ្យបុរសយកផ្លិតស្លឹកត្នោតបក់ឱ្យបុត្ររបស់អាមាត្យនោះ ។ សោមនស្សអនុគ្រោះចិត្តរបស់កុលបុត្រនេះ ប្រៀបដូចអ្នកតន្ត្រី ធ្វើការអនុគ្រោះដល់សោតៈនៃបុត្រអាមាត្យនោះ, ការដែលកុលបុត្របន្ទោបង់នូវសេចក្ដីចុករោយអស់កម្លាំង គឺប្រាសចាកនីវរណៈ ដោយអាស្រ័យឧបចារជ្ឈាន ចូលដល់បឋមជ្ឈាននេះ ប្រៀបដូចបុត្ររបស់អាមាត្យនោះ បន្ទោបង់នូវភាពចុករោយអស់កម្លាំងបន្តិច ដោយការចូលទៅកាន់ទីដំណេកហើយដេកលក់ទៅ ។ ការដែលកុលបុត្រនេះ ចេញចាកបឋមជ្ឈាន ឃើញទោសនៃវិតក្កៈ ព្រោះទ្រាំនឹងវិតក្កៈគ្របសង្កត់ចិត្តមិនបាន ទើបលះវិតក្កៈចូលឈាន

ដែលអវិតក្កវិចារមត្តសមាធិ (មិនមានវិតក្កៈ មានត្រឹមតែវិចារៈ) ប្រៀបដូចការដែលបុត្ររបស់អាមាត្យដេកលក់ហើយ ភ្ញាក់ឡើងគម្រាមបុគ្គលអ្នកសង្កត់ដៃសង្កត់ជើង ព្រោះទ្រាំនឹងការសង្កត់ដៃសង្កត់ជើងមិនបាន ព្រោះបុគ្គលនោះចៀសចេញទៅ ទើបដេកលក់បានបន្តិចទៀត ។

បន្ទាប់ពីនោះ ការដែលកុលបុត្រនេះ ចេញចាកទុតិយជ្ឈានជាដើមរឿយៗ ឃើញទោសនៃវិចារៈជាដើម ដោយលំដាប់ ព្រោះមិនអាចទ្រាំនឹងវិចារៈជាដើម ដែលមានទោសតាមដែលបានពោលហើយ និងព្រោះលះវិចារៈជាដើមទាំងនោះ ទើបចូលឈានដែលមិនមានវិតក្កៈ, មិនមានវិចារៈ, មិនមានបីតិ, លះសោមនស្សបានហើយ ប្រៀបដូចបុត្រអាមាត្យនោះដេកលក់ហើយ ភ្ញាក់ឡើងរឿយៗ គម្រាមបុគ្គលអ្នកច្របាច់ជើងជាដើម ដោយលំដាប់តាមដែលបានពោលហើយ ព្រោះមិនអាចទ្រាំនឹងការគក់ច្របាច់ជើងជាដើម និងព្រោះអ្នកច្របាច់ជើងជាដើមទាំងនោះចេញទៅហើយ ទើបចូលដល់ការដេកលក់បន្តិចរឿយៗ ។ ក៏កាលកុលបុត្រនេះចេញចាកបញ្ចមជ្ឈាន ចូលដល់វិបស្សនាមគ្គ សម្រេចព្រះអរហត្ត ប្រៀបដូចបុត្ររបស់អាមាត្យនោះ ក្រោកអំពីទីដំណេកទៅគាល់ព្រះរាជា ហើយដល់ព្រមដោយឥស្សរិយយស ។ សូម្បីភាពដែលកុលបុត្រនេះសម្រេចព្រះអរហត្តហើយ ជាទីពឹងដល់ជនជាច្រើន គប្បីជ្រាបដូចសេចក្ដីដែលបុត្រនៃអាមាត្យនោះ បានឥស្សរិយយសហើយ ជាទីពឹងដល់ជនជាច្រើនដូច្នោះដែរ ។ ពិតមែន ដោយការកើតឡើងនៃព្រះអរហត្តមានប្រមាណប៉ុណ្ណោះ កុលបុត្រនេះ ក៏ឈ្មោះថា ជាបុញ្ញខេត្តដ៏កំពូល

ដូច្នេះឯង ៕

## ចប់ឈានបញ្ចកន័យ

ដោយពាក្យមានប្រមាណប៉ុណ្ណេះ រមែងជាការប្រកាសឈ្មោះសុទ្ធិកនវកៈ (ការបរិសុទ្ធិ ៩) ដែលផ្សេងគ្នាដោយឈានចតុក្កន័យ និងឈានបញ្ចកន័យ ប៉ុន្តែកាលបើពោលដោយអត្ថ សុទ្ធិកនវកៈនោះ គប្បីជ្រាបថាជាឈានបញ្ចកន័យនោះឯង ព្រោះឈានចតុក្កន័យរួមបញ្ចូលក្នុងឈានបញ្ចកន័យបានដែរ ។

## អធិប្បាយអំពីបដិបទា ៤

ឥឡូវនេះ ដើម្បីសម្តែងប្រភេទលំដាប់បដិបទា ព្រោះធម្មតាថាឈាននេះ រមែងសម្រេចដោយលំដាប់បដិបទានោះ ព្រោះហេតុដូច្នោះ ទើបទ្រង់ប្រារព្ធពាក្យមានជាអាទិ៍ថា **“កតមេ ធម្មា កុសលា”** ទៀត ។ ក្នុងបដិបទាទាំងនោះ ឈានដែលឈ្មោះថា **ទុក្ខាបដិបទា** ព្រោះអត្ថថា ឈាននោះបដិបត្តិលំបាក; ដែលឈ្មោះថា **ទន្ធាភិញ្ញា** ព្រោះឈាននោះដឹងបានដោយលំបាក; ដោយប្រការដូច្នេះ សូម្បីពាក្យទាំង ៣ គឺ “ទុក្ខាបដិបទា” ក្តី “ទន្ធាភិញ្ញា” ក្តី “បបរិកសិណ” ក្តី ជាឈ្មោះនៃឈានទាំងនោះ ។ សូម្បីក្នុងពាក្យជាដើមថា **ទុក្ខាបដិបទំ ខិប្បាភិញ្ញំ** ក៏មានន័យដូចគ្នាដែរ ។

បណ្ដាបដិបទាជាដើមទាំងនោះ ការចម្រើនឈានតាំងតែពីផ្ដើមតាំងចិត្តគ្រាដំបូង រហូតដល់ឧបចារៈនៃឈាននោះៗ កើតឡើងហើយប្រព្រឹត្តទៅ ហៅថា **“បដិបទា”** ។ ចំណែកបញ្ញាដែលប្រព្រឹត្តទៅតាំងតែពីឧបចារៈ រហូតដល់អប្បនា ហៅថា **“អភិញ្ញា”** ។ ក៏បដិបទានោះ រមែងជាទុក្ខដល់បុគ្គលខ្លះ, អធិប្បាយថា ឈ្មោះថា **បដិបត្តិលំបាក** មិនបានសេពនូវសេចក្ដីសុខ ព្រោះភាពនៃបច្ចនិកធម៌ មាននីវរណៈ ជាដើមធ្វើឱ្យហុយទ្រលោមឡើង ។ បដិបទារបស់បុគ្គលខ្លះជាសុខ ព្រោះមិនមានបច្ចនិកធម៌; សូម្បីអភិញ្ញារបស់បុគ្គលខ្លះ ក៏យឺតយូរ គឺជាធម្មជាតិទន់ មិនប្រព្រឹត្តទៅដោយលឿនរហ័សបាន, អភិញ្ញារបស់បុគ្គលខ្លះលឿន គឺមិនយឺត ប្រព្រឹត្តទៅដោយលឿនរហ័ស; ព្រោះហេតុដូច្នោះ បុគ្គលណា កាលសង្កត់កិលេសទាំងឡាយដោយវិបស្សនាញាណ តាំងតែអំពីដើមលំបាក រមែងសង្កត់បានដោយលំបាកព្រមទាំងសង្ខារ និងសម្បយោគ, បដិបទារបស់បុគ្គលនោះ ឈ្មោះថា **ទុក្ខា បដិបទា** (បដិបត្តិលំបាក) ។

ចំណែកបុគ្គលណា សង្កត់កិលេសបានហើយនៅអប់រំអប្បនា រមែងសម្រេចដល់ភាពជាអង្គឈានបាន ដោយការយឺតយូរ, បដិបទារបស់បុគ្គលនោះ ឈ្មោះថា **ទន្ធាភិញ្ញា** (ដឹងបានយឺតយូរ) ។ បុគ្គលណារមែងសម្រេចដល់ភាពជាអង្គឈានបានដោយលឿន, បដិបទារបស់បុគ្គលនោះ ឈ្មោះថា

**ខិប្បាភិញ្ញា** (ដឹងបានដោយលឿន) ។ បុគ្គលណា កាលសង្កត់កិលេសទាំងឡាយមិនលំបាក គឺសង្កត់បានដោយងាយ, បដិបទារបស់បុគ្គលនោះ ឈ្មោះថា **សុខាបដិបទា** (បដិបត្តិដោយស្រួល) ។

ក្នុងអធិការនៃឈានទាំងនោះ សប្បាយ និងអសប្បាយក្តី បុព្វកិច្ចមានការកាត់ផ្តាច់បលិពោធជាដើមក្តី អប្បនាកោសលក្តី ខ្ញុំអធិប្បាយទុកក្នុងចិត្តភាវនានិទ្ទេស ក្នុង**វិសុទ្ធិមគ្គ**[១០១] ហើយ; ក្នុងបដិបទាមានសប្បាយជាដើមទាំងនោះ បុគ្គលណាសេពនូវអសប្បាយ, បដិបទារបស់បុគ្គលនោះ ក៏ជាទុក្ខាបដិបទា និងទន្ធាភិញ្ញា ។ បុគ្គលណាសេពសប្បាយ បដិបទារបស់បុគ្គលនោះ ក៏ជាសុខាបដិបទា និងខិប្បាភិញ្ញា ។ ចំណែកបុគ្គលណាសេពអសប្បាយក្នុងចំណែកាខាងដើម រមែងសេពសប្បាយក្នុងវេលាខាងក្រោយ, ឬថា សេពសប្បាយក្នុង កាលជាចំណែកខាងដើម សេពអសប្បាយក្នុងកាលជាខាងក្រោយ, បណ្ឌិតគប្បីជ្រាបថា បដិបទា និងអភិញ្ញារបស់បុគ្គលនោះច្របូកច្របល់គ្នា ។ ម្យ៉ាង គប្បីជ្រាបថា ព្រះយោគាវចរមិនធ្វើបុព្វកិច្ចមានការកាត់ផ្តាច់បលិពោធជាដើមយ៉ាងនោះ ឱ្យសម្រេចមុនហើយ ចម្រើនភាវនា បដិបទារបស់គេ ជាទុក្ខាបដិបទា, ដោយបរិយាយផ្ទុយគ្នា ជាសុខាបដិបទា; ម្យ៉ាងទៀត កាលព្រះយោគាវចរមិនធ្វើអប្បនាកោសល្ល ឱ្យសម្រេច

---

[១០១] វិសុទ្ធិ. ១ (កម្មដ្ឋានគហណនិទ្ទេស និងបឋវីកសិណនិទ្ទេស) ។

អភិញ្ញារបស់គេ ក៏ជាទន្ធាភិញ្ញា, កាលធ្វើអប្បនាកោសល្លឱ្យសម្រេចអភិញ្ញារបស់គេ ក៏ជាខិប្បាភិញ្ញា ។

ម្យ៉ាងវិញទៀត គប្បីជ្រាបប្រភេទនៃបដិបទា និងអភិញ្ញាទាំងនោះ ដោយអំណាចនៃតណ្ហា និងអវិជ្ជា ដោយអំណាចនៃការបំពេញសមថៈ និងវិបស្សនា ។ ពិតមែន បដិបទារបស់បុគ្គលអ្នកត្រូវតណ្ហាគ្របសង្កត់ហើយ ជាទុក្ខាបដិបទា, បដិបទារបស់អ្នកមិនត្រូវតណ្ហាគ្របសង្កត់ទេ ជាសុខាបដិបទា; និងបដិទារបស់បុគ្គលអ្នកត្រូវអវិជ្ជាគ្របសង្កត់ហើយ ជាទន្ធាភិញ្ញា, បដិទារបស់អ្នកមិនត្រូវអវិជ្ជាគ្របសង្កត់ទេ ជាខិប្បាភិញ្ញា; ម្យ៉ាងទៀត បុគ្គលណាមិនសាងសេចក្ដីល្អទុកក្នុងសមថៈ; បដិបទារបស់បុគ្គលនោះ ជាទុក្ខាបដិបទា; បដិបទារបស់បុគ្គលអ្នកសាងសេចក្ដីល្អទុកក្នុងសមថៈ ជាសុខាបដិបទា ។ ក៏បុគ្គលណា មិនធ្វើអធិការទុកក្នុងវិបស្សនា បដិបទារបស់បុគ្គលនោះ ជាទន្ធាភិញ្ញា, បដិបទារបស់អ្នកធ្វើ អធិការទុកក្នុងវិបស្សនាជាខិប្បាភិញ្ញា ។

ម្យ៉ាងវិញទៀត គប្បីជ្រាបប្រភេទនៃបដិបទា និងអភិញ្ញាទាំងនោះ ដោយអំណាចនៃកិលេស និងឥន្ទ្រិយ ។ ពិតមែន បដិបទា និងអភិញ្ញារបស់បុគ្គលមានកិលេសខ្លាំងក្លា មានឥន្ទ្រិយខ្សោយ ក៏ជាទុក្ខាបដិបទា និងទន្ធាភិញ្ញា ។ ចំណែកបដិបទា និងអភិញ្ញារបស់អ្នកមានឥន្ទ្រិយចាស់ក្លា ក៏ជាខិប្បាភិញ្ញា ។ បដិបទា និងអភិញ្ញារបស់បុគ្គលអ្នកមានកិលេសខ្សោយ ឥន្ទ្រិយទន់ខ្សោយ ក៏ជាសុខាបដិបទា និងទន្ធាភិញ្ញា ។ ចំណែកបដិបទា និងអភិញ្ញា

របស់បុគ្គលអ្នកមានឥន្ទ្រិយចាស់ក្លា ក៏ជាខិប្បាភិញ្ញា ។

បណ្តាបដិបទា និងអភិញ្ញាទាំងនេះ ដោយប្រការដែលពោលមកនេះ បុគ្គលណា រមែងសម្រេចឈាន ព្រោះបដិបត្តិលំបាក និងត្រាស់ដឹងបានយឺតយូរ, ឈាននោះរបស់បុគ្គលនោះ ហៅថា "ទុក្ខាបដិបទាទន្ធាភិញ្ញា"។ សូម្បីពាក្យដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងអធិការនៃឈាននោះ បណ្ឌិតគប្បីជ្រាបថា "សតិជាសភាពសមគួរដល់បឋមជ្ឈានជាដើមនោះ រមែងតាំងនៅដោយប្រពៃ, បញ្ញាជាឋិតិភាគិនី មានចំណែកតាំងមាំ" និងគប្បីជ្រាបបដិបទាក្នុងការសង្កត់ទុកដោយសតិ តាមដែលពោលហើយយ៉ាងនេះ ឬដោយសេចក្តីប្រាថ្នាក្នុងឈាននោះៗ និងគប្បីជ្រាបអភិញ្ញា ក្នុងការអប់រំអប្បនារបស់អ្នកសម្រេចឧបចារៈនៃឈាននោះៗ។

ម្យ៉ាងទៀត បដិបទា និងអភិញ្ញា រមែងមានសូម្បីដោយអំណាចនៃការសម្រេចក៏បានដូចគ្នា ។ ព្រោះថា សូម្បីទុតិយជ្ឈានដែលបុគ្គលសម្រេចបឋមជ្ឈាន ដែលជាទុក្ខាបដិបទាទន្ធាភិញ្ញាហើយ ក៏ត្រូវសម្រេចដូចគ្នានោះឯង; សូម្បីតែក្នុងឈានទី ៣ និងឈានទី ៤ ក៏នៅក្នុងន័យនេះដែរ ។ គប្បីជ្រាបសេចក្តីផ្សេងគ្នា ៤ យ៉ាង ដោយអំណាចនៃបដិបទា សូម្បីក្នុងឈានបញ្ចកន័យ ក៏ដូចក្នុងឈានចតុក្កន័យដែរ ។ ព្រះមានព្រះភាគត្រាស់ឈាន ២ ន័យ ជាពួក ៩ ជា ៤ ព្រោះអំណាចនៃបដិបទា ដោយប្រការដូច្នេះ ។ ក្នុង

ឈាន ៩ ពួក បដិបទា ៤ ទាំងនោះ ពោលដោយព្រះបាលីបានចិត្ត ៣៦ ដួង, ប៉ុន្តែពោលដោយអត្ថ សេចក្តីបានចិត្ត ២០ ដួងប៉ុណ្ណោះ ព្រោះសេចក្តីដែលឈានចតុក្កន័យ ក៏រួមនៅក្នុងឈានបញ្ចកន័យដែរ ៕

**ចប់បដិបទា**

## អធិប្បាយអំពីអារម្មណ៍នៃឈាន ៤

ឥឡូវនេះ ឈ្មោះថា **ឈានមាន ៤ យ៉ាង** ដោយប្រភេទនៃអារម្មណ៍ ដូចប្រភេទនៃបដិបទា ព្រោះហេតុដូច្នោះ ដើម្បីនឹងទ្រង់សម្តែងប្រភេទនៃអារម្មណ៍របស់ឈាននោះ ទើបផ្តើមពាក្យជាដើមថា **"កតមេ ធម្មា កុសលា"** ទៀត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរូបាវចរកុសលជ្ឈាននោះ មានពាក្យជាដើមថា **"បរិត្តំ បរិត្តារម្មណំ** ឈានមានកម្លាំងតូច មានអារម្មណ៍ដ៏តូច" ដូចតទៅ ឈានណាមិនស្ទាត់ជំនាញ មានគុណតិច មិនអាចជាបច្ច័យដល់ឈានខាងលើបាន, ឈាននេះ ឈ្មោះថា **បរិត្ត**; ចំណែកជ្ឈានណា ប្រព្រឹត្តទៅក្នុងអារម្មណ៍មាននិមិត្តប៉ុនចង្អេរ ឬប៉ុនផ្តិលទឹក ដែលពង្រីកឡើងមិនបាន, ឈាននេះឈ្មោះថា **បរិត្ត**, អារម្មណ៍ជាបរិត្តរបស់ឈាននេះមាន ព្រោះហេតុនោះ ឈាននេះ ទើបឈ្មោះថា **បរិត្តារម្មណ៍** មានអារម្មណ៍ដ៏តូច ។ ឈានណា

ស្ទាត់ជំនាញអប់រំល្អហើយ, អាចជាបច្ច័យដល់ឈានខាងលើ, ឈាននេះឈ្មោះថា **អប្បមាណៈ** ។ ឈានណា ប្រព្រឹត្តទៅក្នុងអារម្មណ៍ដ៏ធំទូលាយ, ឈាននោះ ក៏ឈ្មោះថា **អប្បមាណៈ** ព្រោះកំណត់និមិត្តដែលចម្រើនបាន ។ អារម្មណ៍ជាអប្បមាណ មានដល់ឈាននោះ ព្រោះហេតុនោះ ឈាននោះទើបឈ្មោះថា អប្បមាណារម្មណ៍ អារម្មណ៍មិនមានប្រមាណ ។ ម្យ៉ាងទៀតគប្បីជ្រាបន័យដែលលាយបញ្ចូលគ្នា ព្រោះជាលក្ខណៈតាមដែលបានពោលហើយ; ព្រះមានព្រះភាគត្រាស់ធម៌ ៩ ពួកទុក ៤ ពួក សូម្បីដោយអំណាចនៃអារម្មណ៍ដូចពណ៌នាមកដូច្នេះ, ម្យ៉ាងទៀត ការរាប់ចិត្តក្នុងប្រភេទនៃអារម្មណ៍នេះ និងប្រភេទនៃបដិបទានោះឯងដូចគ្នា ៕

ចប់អារម្មណ៍របស់ឈាន ៤

## អធិប្បាយអំពីអារម្មណ៍ និងបដិបទាបញ្ចូលគ្នា

ឥឡូវនេះ ដើម្បីសម្តែងន័យ ១៦ ដង (វារៈ) បញ្ចូលដោយអារម្មណ៍និងបដិបទា ទើបទ្រង់ផ្តើមពាក្យជាដើមថា **"កតមេ ធម្មា កុសលា"** ។ បណ្តាន័យទាំងនោះ ឈានព្រះមានព្រះភាគត្រាស់ទុកក្នុងន័យដំបូង ឈ្មោះថា **ហីនៈ** ព្រោះហេតុ ៤ យ៉ាង គឺព្រោះជាទុក្ខាបដិបទា (បដិបត្តិលំបាក) ព្រោះជាទន្ធាភិញ្ញា (ដឹងបានយឺតយូរ) ព្រោះជាបរិត្ត (មិនជំនាញ) ព្រោះ

ជាបរិត្តារម្មណៈ ( មានអារម្មណ៍ដ៏តូច ) ; ឈានដែលត្រាស់ទុកក្នុងន័យទី ១៦ ឈ្មោះថា **បណីតៈ** ព្រោះហេតុ ៤ យ៉ាង គឺព្រោះជាសុខាបដិបទា, ព្រោះជាខិប្បាភិញ្ញា, ព្រោះជាអប្បមាណ ( ជំនាញ ) ព្រោះជាអបមាណារម្មណ៍ ( មានអារម្មណ៍ប្រមាណមិនបាន ) ។ ក្នុងន័យដ៏សេស ១៤ ន័យ គប្បីជ្រាបសេចក្តីជាហីនៈ និងបណីតៈដោយហេតុ ១ ហេតុ ២ និងហេតុ ៣ ។

សួរថា ក៏ន័យនេះលោកសម្តែងទុក ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះការកើតឡើងនៃឈាន ជាហេតុ ។

ពិតមែន ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងសុទ្ធិកជ្ឈាន ក្នុងបឋវីកសិណ ដោយអំណាចនៃឈានចតុក្កន័យ និងឈានបញ្ចកន័យ, ទ្រង់សម្តែងសុទ្ធិកបដិបទា និងសុទ្ធិការម្មណ៍ក្នុងបឋវីកសិណ ដោយអំណាចនៃឈានចតុក្កន័យ និងឈានបញ្ចកន័យដូចគ្នា, បណ្តាចតុក្កន័យ និងបញ្ចកន័យទាំងពីរនោះ ទេវតាពួកណា អាចដើម្បីនឹងត្រាស់ដឹងសុទ្ធិកជ្ឈាន ក្នុងបឋវីកសិណ ដែលព្រះអង្គទ្រង់សម្តែងដោយអំណាចនៃឈានចតុក្កន័យ, ក៏ទ្រង់សម្តែងចតុក្កន័យក្នុងសុទ្ធិកជ្ឈាន ដោយអំណាចនៃសប្បាយដល់ទេវតាពួកនោះ ។

ទេវតាពួកណា រមែងអាចដើម្បីនឹងត្រាស់ដឹងសុទ្ធិកជ្ឈាន ក្នុងបឋវីកសិណ ដែលព្រះអង្គទ្រង់សម្តែងដោយអំណាចនៃឈានបញ្ចកន័យ, ក៏ទ្រង់សម្តែងបញ្ចកន័យ ដោយអំណាចនៃសប្បាយដល់ទេវតាពួកនោះ ។

ទេវតាពួកណា រមែងអាចដើម្បីនឹងត្រាស់ដឹងសុទ្ធិកជ្ឈាន ក្នុងសុទ្ធិកបដិបទា និងក្នុងសុទ្ធិការម្មណ៍ ដែលទ្រង់សម្ដែងដោយអំណាចនៃចតុក្កន័យ ក៏ទ្រង់សម្ដែងចតុក្កន័យ ក្នុងសុទ្ធិកបដិបទា និងក្នុងសុទ្ធិការម្មណ៍ ដោយនៃអំណាចសប្បាយដល់ទេវតាពួកនោះ ។

ទេវតាពួកណា រមែងអាចដើម្បីនឹងត្រាស់ដឹងសុទ្ធិកជ្ឈាន ក្នុងសុទ្ធិកបដិបទា និងក្នុងសុទ្ធិការម្មណ៍ ដែលទ្រង់សម្ដែងដោយអំណាចនៃបញ្ចកន័យ, ក៏ទ្រង់សម្ដែងបញ្ចកន័យក្នុងសុទ្ធិកបដិបទា និងសុទ្ធិការម្មណ៍ ដោយអំណាចនៃសប្បាយដល់ទេវតាពួកនោះ ។ ព្រះមានព្រះភាគទ្រង់ធ្វើទេសនាដោយអំណាចនៃអធ្យាស្រ័យរបស់បុគ្គលតាមដែលពោលហើយ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ជាអ្នកទេសនាដ៏ពិរោះ ទ្រង់បែកធ្លុះធ្លាយខ្វះខ្វាយក្នុងបដិសម្ភិទា ទ្រង់មានទសពលញ្ញាណ និងវេសារជ្ជញ្ញាណដ៏បរិសុទ្ធ អាចកំណត់ទេសនាដោយអំណាចនៃន័យណាៗក៏បាន ព្រោះព្រះអង្គឈ្លាសក្នុងការបញ្ញត្តិធម៌ ដោយធម៌ទាំងឡាយដែលព្រះអង្គទ្រង់ត្រាស់ដឹងល្អហើយតាមសេចក្ដីពិត ព្រមទាំងរស និងលក្ខណៈ; ព្រោះហេតុដូច្នោះ ព្រះអង្គទើបទ្រង់ធ្វើទេសនា ដោយអំណាចនៃឈានសុទ្ធិក ចតុក្កន័យជាដើម ក្នុងបឋវីកសិណនោះ ព្រោះហេតុដែលទ្រង់ទេសនាដ៏ពីរោះនេះ (ទេសនាវិលាស) ។

ក៏ជនពួកណាមួយ ញ៉ាំងឈានឱ្យកើតឡើង, វៀរចាកអារម្មណ៍ និង

បដិបទា ក៏មិនអាចនឹងឱ្យឈានកើតឡើងបាន, ព្រោះហេតុដូច្នោះ ទើបត្រាស់ន័យអស់ ១៦ គ្រានេះ ព្រោះការសម្រេចឈានជាហេតុដោយការកំណត់ដោយពាក្យមានប្រមាណប៉ុណ្ណោះ; ដែលត្រាស់ពួក ៩ ទុក ២៥ ន័យ គឺសុទ្ធិកនវកៈ ១ ន័យ, បដិបទានវកៈ ៤ ន័យ, អារម្មណនវកៈ ៤ ន័យ, និងនវកៈ ១៦ ន័យនេះឯង ។ បណ្តានវកធម៌ ២៥ ន័យទាំងនោះ ក្នុងនវកៈនីមួយៗ មានន័យ ៥០ គឺចតុក្កន័យ ២៥ បញ្ចកន័យ ២៥ ។ បណ្តាន័យ ៥០ ទាំងនោះ ពោលដោយព្រះបាលីបានឈានចិត្ត ២២៥ ដួង គឺន័យ ២៥ ក្នុងក្នុងចតុក្កន័យបាន ១០០ ន័យ (២៥ x ឈាន ៤) ក្នុងបញ្ចកន័យបាន ១២៥ ន័យ; ប៉ុន្តែកាលបើពោលដោយអត្ថបានចិត្ត ១២៥ ដួងប៉ុណ្ណោះ ព្រោះភាវៈនៃឈានចតុក្កន័យ ក៏រួមបញ្ចូលក្នុងឈានបញ្ចកន័យដែរ ។ ក៏ក្នុងនិទ្ទេសនៃចិត្តតែមួយដួងៗ ក្នុងចិត្តទាំង ២២៥ ដួងនោះ ក្នុងព្រះបាលី មានមហាវារៈ គឺធម្មវវដ្ឋានជាដើមម្យ៉ាងៗ ៣ ។ ក៏មហាវារៈទាំងនោះ ក្នុងទីនោះៗ លោកសម្តែងដោយសង្ខេប ល្មមជាន័យប៉ុណ្ណោះដូច្នេះឯង ៕

**ចប់បឋវីកសិណ**

---

# អធិប្បាយអំពីអាលោកសិណជាដើម

ឥឡូវនេះ ឈានទព្វកនេះ រមែងកើតឡើងសូម្បីក្នុងអាលោកសិណជាដើម, ព្រោះហេតុដូច្នោះ ដើម្បីសម្តែងឈានទាំងនោះ ទើបទ្រង់ផ្តើមពាក្យជាដើមថា **"កតមេ ធម្មា កុសលា"** ទៀត ។ ក្នុងឈានទាំងនោះ ន័យរបស់បាលីទាំងអស់ ការអធិប្បាយសេចក្តី ការរាប់ចំនួនចិត្ត ការសង្ខេបវារៈ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងបឋវីកសិណហ្នឹងហើយ; ប៉ុន្តែន័យរបស់ភាវនាទាំងអស់ តាំងអំពីធ្វើបរិកម្មកសិណ ខ្ញុំប្រកាសទុកក្នុង**វិសុទ្ធិមគ្គ**[១០២] ទាំងអស់ ។ ក៏ប៉ុន្តែក្នុង**មហាសកុលុទាយិសូត្រ** លោកពោលកសិណទុក ១០ យ៉ាងក្នុងកសិណទាំង ១០ នោះ មហគ្គតវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាសក្តី, វិញ្ញានញ្ចាយតនសមាបត្តិដែលកើតឡើង ព្រោះធ្វើបរិកម្មក្នុងអាកាសនោះក្តី, រួមទេសនាទុកក្នុងអរូប ដោយប្រការទាំងពួង; ព្រោះហេតុដូច្នោះ វិញ្ញាណកសិណព្រះមានព្រះភាគទើបមិនត្រាស់ទុកក្នុងទីនេះឡើយ ។

ក៏កសិណុគ្ឃាដិមាកាស អាកាសដែលបើកកសិណទាំង ៩ ចេញ វៀរអាកាសកសិណក្តី, ខន្ធទាំងឡាយដែលប្រព្រឹត្តទៅ ព្រោះធ្វើអាកាសដែលបើកនោះឱ្យជាអារម្មណ៍ក្តី, បរិច្ឆេទាកាសមាននិមិត្តដែលគប្បីកាន់យកក្នុង

---

[១០២] វិសិទ្ធិ. ១ (កសិណនិទ្ទេស) ។

ប្រហោងជញ្ជាំងជាដើម យ៉ាងណាមួយក្តី, ឈានចតុក្កន័យ និងឈានបញ្ចកន័យដែលកើតឡើង ព្រោះធ្វើអាកាសនោះឱ្យជាអារម្មណ៍ក្តី ហៅថា **អាកាសកសិណ** ។ បណ្តាន័យរបស់អាកាសកសិណទាំង ៤ នោះ ន័យខាងដើម ២ ន័យដំបូង រួមនៅក្នុងអារូបទេសនា, ន័យចុងក្រោយ ២ ន័យ រួមនៅក្នុងរូបាវចរទេសនា; ដោយប្រការដូច្នេះ អាកាសកសិណ ទើបមិនពោលទុកក្នុងរូបាវចរទេសនានេះទេ ព្រោះសេចក្តីជារបស់ច្របូកច្របល់គ្នា, ប៉ុន្តែឈានដែលកើតឡើងក្នុងការកំណត់បរិច្ឆេទាកាស រមែងជាមគ្គ ព្រោះជាការចូលដល់រូបភព, ព្រោះហេតុដូច្នោះ ទើបគួរកាន់យកឈាននោះ; តែឈានដែលជាចតុក្កន័យ និងបញ្ចកន័យប៉ុណ្ណោះ រមែងកើតឡើងក្នុងបរិច្ឆេទាកាសនោះ, អរូបជ្ឈាន រមែងមិនកើតឡើងទេ ។

សួរថា ព្រោះហេតុអ្វី ទើបមិនកើតឡើង ?

ឆ្លើយថា ព្រោះមិនបើកកសិណចេញ ។

ពិតមែន អាកាសកសិណនោះសូម្បីបើកចេញរឿយៗ ក៏ជាអាកាសហ្នឹងហើយ រមែងមិនបាននូវការបើកកសិណឡើងក្នុងអរូបជ្ឈាននោះ; ព្រោះហេតុដូច្នោះ បរិច្ឆេទាកាសជ្ឈានដែលកើតឡើងក្នុងទីនោះ ទើបប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន, ជាហេតុ **គឺបាទនៃអភិញ្ញា, ជាបាទនៃវិបស្សនា**, មិនជាបាទឱ្យនិរោធទេ, ប៉ុន្តែថា ការរំលត់ដោយលំដាប់ ក្នុងរូបាវចរជ្ឈាននេះ

រហូតដល់បញ្ចមជ្ឈានជាហេតុនៃវដ្តៈប៉ុណ្ណោះ; ក៏ឈាននេះ (បរិច្ឆេទាកាស) យ៉ាងណា, សូម្បីឈានទាំងឡាយដែលកើតឡើងក្នុងកសិណមុន ក៏ដូច្នោះដែរ; ប៉ុន្តែថា ការដែលកសិណមុនជាបាទនៃនិរោធ ទើបជាការប្លែកគ្នាក្នុងបរិច្ឆេទាកាសនោះ ។ ពាក្យដ៏សេសក្នុងទីនេះ ពាក្យណាដែលគួរនឹងពោលក្នុងអាកាសកសិណ, ពាក្យទាំងអស់នោះ បានពោលទុកក្នុង**វិសុទ្ធមគ្គ** [១០៣] នោះឯង ។

ចំណែកព្រះយោគាវចរអ្នកប្រាថ្នាសម្តែងឫទ្ធិផ្សេងៗ មានន័យជាអាទិ៍ថា “សូម្បីបុគ្គលម្នាក់ក៏ជាច្រើនអ្នកបាន” ដូច្នេះ ធ្វើសមាបត្តិ ៨ ឱ្យកើតឡើងក្នុងកសិណ ៨ ដែលជាខាងដើមហើយគប្បីហ្វឹកហាត់ចិត្តដោយអាការ ១៤ ទាំងនេះ គឺ

**១-កសិណានុលោមតោ** ចូលឈានតាមលំដាប់កសិណ

**២-កសិណបដិលោមតោ** ចូលឈានបញ្ច្រាសកសិណ

**៣-កសិណានុលោមបដិលោមតោ** ចូលឈានតាមលំដាប់ និងបញ្ច្រាសកសិណ ។

**៤-ឈានានុលោមតោ** ចូលតាមលំដាប់ឈាន

**៥-ឈានបដិលោមតោ** ចូលបញ្ច្រាសលំដាប់ឈាន

---

[១០៣] វិសុទ្ធិ. ១ (សេសកសិណនិទ្ទេស) ។

**៦.ឈានានុលោមបដិលោមតោ** ចូលឈានតាមលំដាប់ និងបញ្ច្រាសត្រឡប់ឈាន ។

**៧.ឈានុក្កន្តិកតោ** ចូលឈានដោយកន្លងលំដាប់

**៨.កសិណុក្កន្តិកតោ** ចូលឈានដោយកន្លងកសិណ

**៩.ឈានកសិណុក្កន្តិកតោ** កន្លងទាំងឈាន និងកសិណ

**១០.អង្គសង្កន្តិតោ** ចូលឈាន ៥ ដោយឈានកន្លងអង្គ

**១១.អារម្មណសង្កន្តិតោ** ចូលឈានដោយប្តូរអារម្មណ៍

**១២.អង្គារម្មណសង្កន្តិតោ** ចូលតាមលំដាប់ឈាន និងកសិណ

**១៣.អង្គវវដ្ឋានតោ** កំណត់ដឹងអង្គឈាន

**១៤.អារម្មណវវដ្ឋានតោ** កំណត់ដឹងអារម្មណ៍ ។

រឿងពិស្តារនៃការហ្វឹកហាត់ចិត្តទាំងនោះ ខ្ញុំពោលទុកក្នុង**វិសុទ្ធិមគ្គ**[១០៤] នោះឯង; ក៏ព្រះយោគាវចរមិនធ្លាប់អប់រំមកអំពីមុនទេ ជាអាទិកម្មិកៈ (អ្នកផ្តើមធ្វើដំបូង) មិនហ្វឹកហាត់ចិត្តដោយអាការ ១៤ យ៉ាងនេះ នឹងញ៉ាំងការសម្តែងឫទ្ធិផ្សេងៗ ឱ្យសម្រេចដោយអាការដែលពោលមកនេះ នោះមិនមែនជាឋានៈដែលមានបានទេ; ពិតមែន សូម្បីការបរិកម្មកសិណរបស់ព្រះយោគាវចរអ្នកផ្តើមធ្វើដំបូងរមែងជាភារៈ (របស់លំបាក), ក៏បណ្តាអ្នកផ្តើមធ្វើបរិកម្មកសិណទាំងរយរូប ទាំងពាន់រូប តែមួយរូបប៉ុណ្ណោះ រមែងអាច ។

---

[១០៤] វិសុទ្ធិ. ២ (ឥទ្ធិវិធនិទ្ទេស) ។

ព្រះយោគាវចរអ្នកធ្វើកសិណបរិកម្មហើយ ការដែលនឹងធ្វើនិមិត្តឱ្យកើតឡើង ក៏ជាភារៈ (របស់លំបាក), បណ្តារយរូប ពាន់រូប តែមួយរូបប៉ុណ្ណោះរមែងអាច ។ កាលនិមិត្តកើតឡើងហើយ ពង្រីកនិមិត្តឱ្យចម្រើនឡើងហើយសម្រេចអប្បនា ក៏ជាភារៈ (របស់លំបាក), ក្នុងរយរូប ពាន់រូប **តែមួយរូបប៉ុណ្ណោះរមែងអាច**; សូម្បីអ្នកសម្រេចអប្បនាបានហើយ ការហ្វឹកហាត់ចិត្តដោយអាការ ១៤ ក៏ជាភារៈ (របស់លំបាក), ក្នុងរយរូប ពាន់រូប តែមួយរូបប៉ុណ្ណោះ រមែងអាច; សូម្បីអ្នកហ្វឹកហាត់ចិត្តដោយអាការ ១៤ យ៉ាងហើយ ឈ្មោះថា **ការសម្តែងឫទ្ធិផ្សេងៗ** ក៏ជាភារៈ (របស់លំបាក), ក្នុងរយរូប ពាន់រូប តែមួយរូបប៉ុណ្ណោះ រមែងអាច; សូម្បីអ្នកសម្តែងឫទ្ធិបានហើយ ឈ្មោះថា **ការចូលឈានបានដោយល្បឿនក៏ជាភារៈ** (របស់លំបាក), បណ្តារយរូប ពាន់រូប និងមានតែមួយរូបប៉ុណ្ណោះ ចូលឈានបានដោយលឿន; ដូច**ព្រះរក្ខិតត្ថេរ** អ្នកមានវស្សា ៨ ដោយការឧបសម្បទក្នុងលោកអ្នកមានឫទ្ធិប្រមាណបីសែនរូប អ្នកមកព្យាបាល**ព្រះមហារោហណគុត្តត្ថេរ** ដែលមានអាពាធក្នុងថេរម្ពត្ថលវិហារ; រឿងទាំងអស់ខ្ញុំឱ្យពិស្តារ**ក្នុងវិសុទ្ធិមគ្គ**[១០៥] នោះឯង ៕

ចប់កសិណកថា

[១០៥] វិសុទ្ធិ. ២ (ឥទ្ធិវិធនិទ្ទេស) ។

## អធិប្បាយអំពីអភិភាយតនៈ

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងរូបាវចរកុសល ក្នុងកសិណ ៨ ដោយអាការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងរូបាវចរកុសលពោលគឺអភិភាយតនៈដទៃទៀត ដែលប្រព្រឹត្តទៅក្នុងកសិណទាំង ៨ នេះ ព្រោះអភិភាយតនៈជាភាវៈដែលមិនដូចគ្នា ក្នុងភាវនា ក្នុងអារម្មណ៍ដែលមាននោះ ព្រោះហេតុដូច្នោះ ទើបផ្តើមពាក្យជាដើមថា **"កតមេ ធម្មា កុសលា"** ទៀត ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **កតមេ ធម្មេ** ជាដើម ។

បទថា **"អជ្ឈត្តំ អរូបសញ្ញី** មិនមានបរិកម្មរូបសញ្ញាខាងក្នុង" សេចក្តីថា វៀរបរិកម្មសញ្ញា ក្នុងអជ្ឈត្តិករូប ព្រោះការមិនបានអជ្ឈត្តិករូប ឬថា ព្រោះមិនមានអជ្ឈត្តិករូប ។ បទថា **"ពហិទ្ធា រូបានិ បស្សតិ"** សេចក្តីថា រមែងឃើញរូបក្នុងកសិណ ៨ ខាងក្រៅនោះ ដោយអំណាចនៃបរិកម្ម និងដោយអំណាចនៃអប្បនា ព្រោះការដែលធ្វើបរិកម្មក្នុងកសិណ ៨ ខាងក្រៅ ។ បទថា **"បរិត្តានិ** = ដ៏តូច" បានដល់មានអារម្មណ៍ពង្រីកមិនបាន ។ បទថា **"តានិ អភិភុយ្យ** គ្របសង្កត់នូវរូបទាំងនោះ" សេចក្តីថា បុគ្គលអ្នកក្រៃលែងដោយញាណ អ្នកមានញាណដ៏បរិសុទ្ធគិតថា "នឹងមានប្រយោជន៍អ្វីដែលខ្លួនគប្បីចូលសមាបត្តិ ក្នុងអារម្មណ៍ដ៏តូចនេះ, ព្រោះហេតុ

ដូច្នោះ រូបធម៌នេះ ទើបមិនមែនភារៈរបស់យើង” ដូច្នេះ ទើបគ្របសង្កត់ (វៀរ) រូបទាំងឡាយនោះចេញ ហើយចូលសមាបត្តិ, គឺញ៉ាំងអប្បនាឱ្យកើតឡើងក្នុងឈាននេះ ព្រមនឹងការកើតឡើងនៃនិមិត្ត ប្រៀបដូចបុគ្គលអ្នកបរិភោគអាហារ បានបាយមកត្រឹមតែមួយវែកក៏គិតថា “យើងនឹងគប្បីបរិភោគយ៉ាងម៉េច, ក្នុងភត្តត្រឹមតែមួយស្លាបព្រានេះ” ទើបរួមធ្វើជាមួយដុំប៉ុណ្ណោះ ។ ក៏បុព្វភាគរបស់ឈាននោះ លោកពោលទុកដោយបទនេះថា **“ជានាមិ បស្សាមិ** យើងរមែងដឹង រមែងឃើញ” ប៉ុន្តែលោកពោលទុកក្នុង**អដ្ឋកថាក្នុងនិកាយដែលមកទាំងឡាយថា** “លោកពោលដល់ការចងចិត្តរបស់ឈាននោះ ដោយបទថា **ជានាមិ បស្សាមិ** នេះ, ក៏ការចងចិត្តនោះ រមែងមានដល់ព្រះយោគាវចរចេញចាកសមាបត្តិហើយ, មិនមែនមានខាងក្នុងសមាបត្តិទេ” ។ បទថា **“អប្បមាណានិ”** បានដល់ មានអារម្មណ៍ដ៏ធំទូលាយ ។

ក្នុងពាក្យថា **អភិភុយ្យ** នេះ មានអធិប្បាយថា បុគ្គលអ្នកក្រៃលែងដោយញាណ អ្នកមានញាណដ៏បរិសុទ្ធ គិតថា “ប្រយោជន៍អ្វីដែលយើងនឹងចូលអរូបជ្ឈាននេះ, អរូបជ្ឈាននេះ មិនមានអារម្មណ៍ដ៏ធំទេ, ការធ្វើចិត្តឱ្យប្រាកដ (ឯកគ្គតាចិត្ត) មិនមែនជាភារៈរបស់យើងទេ” ព្រោះហេតុដូច្នោះ ទើបគ្របសង្កត់ (វៀរ) អារម្មណ៍នោះចេញ ហើយចូលសមាបត្តិ, គឺញ៉ាំងអប្បនាសមាបត្តិឱ្យកើតឡើងក្នុងអរូបជ្ឈាននេះ ព្រមនឹងឱ្យនិមិត្តកើតឡើង

ដូចបុគ្គលដែលស៊ីច្រើន បានភត្តដែលគេដួសឱ្យមួយចំណែក ក៏គិតថា "ចំណែកដទៃៗនៅមានទៀត ព្រោះហេតុដូច្នោះ ភត្តចំណែកនេះ នឹងធ្វើប្រយោជន៍អ្វីឱ្យដល់យើង" ទើបមិនឃើញភត្តចំណែកនោះជាច្រើនដូច្នោះ ។

ក្នុងពាក្យថា **"បរិត្តំ បរិត្តារម្មណំ អប្បមាណំ បរិត្តារម្មណំ** = មានកម្លាំងខ្សោយ មានអារម្មណ៍ដ៏តូច មានកម្លាំងខ្លាំង មានអារម្មណ៍ដ៏តូច" នេះ ទ្រង់មិនបានកាន់យកអរូបជ្ឈានមានអារម្មណ៍រកប្រមាណមិនបាន ព្រោះបានត្រាស់មកហើយថា "ជាបរិត្ត គឺមានកម្លាំងខ្សោយ" , ចំណែកក្នុងន័យទីពីរ ទ្រង់បានត្រាស់យកថា អរូបជ្ឈាននោះ មានអារម្មណ៍មិនមានប្រមាណ ព្រោះបានត្រាស់ខាងមុខថា **"អប្បមាណានិ"** ; ចំណែកក្នុង**អដ្ឋកថា** ក៏បានពោលថា "ក៏ក្នុងទីនេះ ទ្រង់មិនបានកាន់យកអារម្មណ៍ម្យ៉ាងៗ ៤ ទេ ប៉ុន្តែទ្រង់កាន់យកម្យ៉ាងៗ ២ ប៉ុណ្ណោះ, សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះការកាន់យកម្យ៉ាងៗ ៤ ទេសនាក៏នឹងត្រូវជា ១៦ ដង ។ ឯទេសនា ១៦ ដងក៏នឹងជាទេសនាដោយទូលំទូលាយ ដូចរោយគ្រាប់ល្ងលើកន្ទេលក្បុងឫស្សី, ក្នុងទីនេះ ព្រះអង្គមានអធ្យាស្រ័យដើម្បីនឹងទ្រង់ធ្វើទេសនាដល់សត្វត្រឹមតែ ៨ ដង, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា 'ព្រះអង្គទ្រង់កាន់យកម្យ៉ាងៗ ២ ប៉ុណ្ណោះ"។

បទថា **"សុវណ្ណទុព្វណ្ណានិ** = មានពណ៌ល្អ និងមិនល្អ" សេចក្តីថា មានពណ៌បរិសុទ្ធ និងមិនបរិសុទ្ធ ។ ពិតមែន អារម្មណ៍មានពណ៌ខៀវជាដើមដ៏បរិសុទ្ធ ទ្រង់បំណងយកថា ពណ៌ល្អ និងអារម្មណ៍មានពណ៌មិនបរិសុទ្ធ ទ្រង់

មានបំណងយកពណ៌មិនល្អក្នុងទីនេះ ។ ចំណែកក្នុង**អដ្ឋកថាដែលមានមកក្នុងនិកាយទាំងឡាយពោលថា** "ព្រះមានព្រះភាគទ្រង់សម្តែងអភិភាយតនៈទាំងនេះ ដោយអំណាចជាបរិត្តារម្មណ៍ និងអប្បមាណារម្មណ៍ប៉ុណ្ណោះថាជាអារម្មណ៍ដែលមានពណ៌ល្អ និងអារម្មណ៍ដែលមានពណ៌មិនល្អ" ។ មួយ៉ាងទៀត ក្នុងអភិភាយតនៈទាំង ៤ នេះ អភិភាយតនៈដែលជាបរិត្តារម្មណ៍ សមគួរដល់បុគ្គលអ្នកមានវិតក្កចរិត, អភិភាយតនៈដែលជាអប្បមាណារម្មណ៍ សមគួរដល់បុគ្គលអ្នកមានមោហចរិត, អភិភាយតនៈដែលមានពណ៌ល្អ សមគួរដល់បុគ្គលអ្នកមានទោសចរិត, អភិភាយតនៈដែលមានពណ៌មិនល្អ សមគួរដល់បុគ្គលអ្នកមានរាគចរិត; ព្រោះអារម្មណ៍ទាំងនោះ ជាសប្បាយដល់បុគ្គលទាំងនោះ និងការដែលអារម្មណ៍ទាំងនោះ ជាសប្បាយដល់បុគ្គលទាំងនោះ ខ្ញុំពោលទុកក្នុងចរិយានិទ្ទេស នៃគម្ពីរ**វិសុទ្ធិមគ្គ**[១០៦] ដោយពិស្តារហើយ ។

សួរថា ក៏ព្រោះហេតុអ្វី ក្នុងព្រះអភិធម្មនេះទើបត្រាស់ថា កាលដែលបុគ្គល មានសេចក្តីសម្គាល់ក្នុងរូបខាងក្នុងថា មិនមែនរូបក្នុងអភិភាយតនៈទាំង ៤ មិនត្រាស់ដូចដែលបានត្រាស់នៅក្នុងព្រះសូត្រដែលមានពាក្យជាដើមថា "បុគ្គលម្នាក់ មានការសម្គាល់ក្នុងរូបខាងក្នុងថាជារូប ឃើញរូបខាងក្រៅថា មានអារម្មណ៍ដ៏តូច"[១០៧] យ៉ាងនេះមែនដែរឬទេ ?

---

[១០៦] វិសុទ្ធិ. ១ (កម្មដ្ឋានគហននិទ្ទេស) ។

[១០៧] ទី. មហា., អំ. អដ្ឋក. ។

ឆ្លើយថា ព្រោះមិនគ្របសង្កត់ដល់រូបក្នុងខាងក្នុង; ពិតមែន នៅក្នុងព្រះសូត្រនោះ ឬនៅក្នុងព្រះអភិធម្មនេះត្រាស់ពាក្យជាដើមថា ឃើញរូបខាងក្រៅមានអារម្មណ៍ដ៏តូច ដូច្នេះ រូបខាងក្រៅនោះ ព្រះយោគាវចរគ្របសង្កត់បាន; ព្រោះហេតុដូច្នោះ ទើបត្រាស់ទុកក្នុងព្រះសូត្រខ្លះ ក្នុងព្រះអភិធម្មខ្លះថា "រូបខាងក្រៅទាំងនោះ គប្បីពោលដល់ដោយការកំណត់" ។

ក្នុងពាក្យថា **"អជ្ឈត្តអរូបសញ្ញី"** នេះ ត្រឹមតែជាភាពលំអរនៃទេសនារបស់ព្រះសាស្តាប៉ុណ្ណោះ ។ នេះជាការពណ៌នាតាមលំដាប់បទក្នុងអភិភាយតនៈទាំង ៤ ជាមុនសិន ។ ចំណែកសេចក្តីផ្សេងគ្នានៃបដិបទាក្នុងសុទ្ធិកន័យក្នុងទីនេះ គប្បីជ្រាបក្នុងអភិភាយតនៈតែម្យ៉ាងៗ ដោយន័យដែលពោលទុកក្នុងបបរិកសិណនោះឯង; ក៏បបរិកសិណក្នុងព្រះសូត្រនោះ អភិភាយតនៈមានអារម្មណ៍ ៤ យ៉ាង ក្នុងព្រះអភិធម្មនេះ មានអារម្មណ៍ ២ យ៉ាង; និងក្នុងបបរិកសិណនោះ សម្តែងអភិភាយតនៈទុក ១៦ វារៈ, អភិភាយតនៈក្នុងអភិធម្មនេះសម្តែងទុក ៨ វារៈ; ចំណុចសេចក្តីដែលនៅសល់ដូចគ្នាហ្នឹងហើយ; បណ្តាអភិភាយតនៈទាំង ៤ នេះ អភិភាយតនៈតែម្យ៉ាងៗមាននវកៈ ១៥ គឺសុទ្ធិកនវកៈ ១, បដិបទានវកៈ ៤, អារម្មណនវកៈ ២, នវកៈដែលមានអារម្មណ៍លាយគ្នា នឹងបដិបទាមាន ៨ ពួក គប្បីជ្រាបថា ក្នុងអភិភាយតនៈទាំង ៤ រួមជានវកៈ ៦០ ពួកគត់ ។

បទថា **"នីលានិ** = ខៀវ" ក្នុងអភិភាយតនៈទី ៥ ជាដើម ត្រាស់ទុកដោយការរួមអភិភាយតនៈទាំងអស់ ។ បទថា **"នីលវណ្ណានិ** = ពណ៌

ខៀវ” នេះត្រាស់ទុកដោយការប្រៀបធៀបថាដោយពណ៌ ជាពណ៌ខៀវសុទ្ធ, មានអធិប្បាយថា ខៀវមិនប្រាកដមានចន្លោះប្រហោង ខៀវមិនលាយអ្វី ជាពណ៌ខៀវសុទ្ធតែម្តង ។ បទថា “**នីលនិភាសានិ** = រស្មីពណ៌ខៀវ” នេះ ត្រាស់ដោយអំណាចការចាំងពន្លឺ, អធិប្បាយថា ការចាំងពន្លឺពណ៌ខៀវ ជាការ ប្រកបដោយរស្មីខៀវ ។ ដោយពាក្យថា រស្មីខៀវនេះ ព្រះមានព្រះភាគទ្រង់ សម្តែងដល់រូបទាំងនោះ ជារូបបរិសុទ្ធល្អហើយ; ព្រោះហេតុដូច្នោះ ទើប ត្រាស់អភិភាយតនៈទាំង ៤ នេះ ដោយអំណាចពណ៌ដ៏បរិសុទ្ធល្អហើយនោះ; សូម្បីក្នុងពាក្យជាដើមថា “**បីតានិ** = លឿង” ក៏គប្បីជ្រាបសេចក្តីដោយ ន័យនេះឯង; ក៏ការធ្វើកសិណក្តី, ការបរិកម្មក្តី, អប្បនាវិធីក្តី ក្នុងនីលកសិណ នេះ ដែលមានពាក្យជាដើមថា “ព្រះយោគាវចរអ្នកសិក្សានីលកសិណ រមែងកាន់យកនិមិត្តខៀវក្នុងផ្កាឈើ ឬក្នុងវត្ថុ ឬក៏ក្នុងវណ្ណធាតុ” ទាំងអស់ខ្ញុំ ពោលទុកដោយពិស្តារ ក្នុង**វិសុទ្ធិមគ្គ**[១០៨] នោះឯង ។ ក្នុងអភិភាយតនៈតែ ម្យ៉ាងៗ ក្នុងនីលកសិណនេះ គប្បីជ្រាបនវកៈ ២៥ នោះ ដូចនៅក្នុងបឋវី កសិណដូច្នោះដែរ ។

## ចប់អភិភាយតនកថា

[១០៨] វិសុទ្ធិ. ១ (សេសកសិណនិទ្ទេស) ។

## អធិប្បាយអំពីវិមោក្ខ ៣

ធម្មតា រូបាវចរកុសលនេះ រមែងកើតឡើងដោយអំណាចនៃអភិភាយតនៈ ព្រោះគ្របសង្កត់អាយតនៈ គឺអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ក៏មិនបាន, តាមពិត រូបាយតនៈនេះរមែងកើតឡើងដោយអំណាចនៃវិមោក្ខដែរ, ព្រោះហេតុដូច្នោះ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងន័យនោះ ព្រះមានព្រះភាគទើបទ្រង់ផ្ដើមពាក្យថា **“កតមេ ធម្មា កុសលា”** ទៀត ។

សួរថា ធម៌ គឺវិមោក្ខនេះ បណ្ឌិតគប្បីជ្រាបបានយ៉ាងដូចម្ដេច?

ឆ្លើយថា គប្បីជ្រាបបានដោយអត្ថថា រួចផុត ។ ដូចម្ដេចទៅ ឈ្មោះថា **អត្ថថា រួចផុតនេះ**? ក៏អត្ថថា រួចផុតនេះ ជាការរួចផុតយ៉ាងល្អពីបច្ចនីកធម៌ទាំងឡាយ និងជាការរួចផុតយ៉ាងល្អដោយអំណាចនៃសេចក្ដីត្រេកអរដ៏ក្រៃលែងក្នុងអារម្មណ៍ មានអធិប្បាយថា ធម៌ គឺវិមោក្ខនេះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយសេចក្ដីមិនជាប់ទាក់ទិនជាមួយបច្ចនីកធម៌ និងសេចក្ដីត្រេកអរដ៏ក្រៃលែងក្នុងអារម្មណ៍ ព្រោះសេចក្ដីមិនប្រកាន់ ដូចទារកស្រោតមានអវយវៈតូចធំដេកលើភ្លៅរបស់បិតាដូច្នោះ ។

ក៏ដើម្បីទ្រង់សម្ដែងរូបាវចរកុសល ដែលដល់ភាពជាវិមោក្ខ ដោយលក្ខណៈយ៉ាងនេះ ទើបទ្រង់ផ្ដើមន័យនេះ ។ បណ្ដាបទទាំងនោះ បទថា **“រូបី**

= មានរូប” មានវិគ្រោះថា ដែលឈ្មោះថា **រូបី** ព្រោះអត្ថថា រូបរបស់បុគ្គលនោះមាន គឺរូបជ្ឈានដែលឱ្យកើតឡើងក្នុងកោដ្ឋាសៈ មានសក់ជាដើមខាងក្នុង ។ ពិតមែន ព្រះយោគាវចរកាលធ្វើបរិកម្មនីលកសិណខាងក្នុង រមែងធ្វើត្រង់សក់ ឬត្រង់ទឹកប្រមាត់ ឬត្រង់ភ្នែក; ការនឹងធ្វើបរិកម្មបីតកសិណ រមែងធ្វើត្រង់ខ្លាញ់ខាប់ ឬត្រង់ស្បែក ឬត្រង់បាតដៃបាតជើង ឬត្រង់ភ្នែកពណ៌លឿង; កាលនឹងធ្វើបរិកម្មលោហិតកសិណ ក៏រមែងធ្វើត្រង់សាច់ ឬត្រង់ឈាម ឬត្រង់អណ្ដាត ឬត្រង់បាតដៃបាតជើង ឬត្រង់កន្លែងមានពណ៌ក្រហមនៃគ្រាប់ភ្នែក; កាលនឹងធ្វើបរិកម្មឱទាតកសិណ ក៏រមែងធ្វើត្រង់ឆ្អឹង ឬត្រង់ធ្មេញ ឬត្រង់ក្រចក ឬត្រង់កន្លែងពណ៌សនៃគ្រាប់ភ្នែក ។ ពាក្យថា “**រូបី**” នេះ ព្រះមានព្រះភាគត្រាស់សំដៅយកបុគ្គលម្នាក់ក្នុងបុគ្គលអ្នកដល់ព្រមដោយឈានដែលកើតឡើង ព្រោះធ្វើបរិកម្មដោយអាការយ៉ាងនេះ ។

បទថា “**ពហិទ្ធានិ រូបានិ បស្សតិ** = ឃើញរូបទាំងឡាយខាងក្រៅ” បានដល់ រមែងឃើញរូបមាននីលកសិណជាដើម សូម្បីខាងក្រៅដោយឈានចក្ខុ (ដោយចក្ខុគឺឈាន); ដោយពាក្យថា **រមែងឃើញរូបខាងក្រៅ** នេះ ទ្រង់សម្ដែងការបានឈានក្នុងកសិណវត្ថុ ទាំងខាងក្នុង ទាំងខាងក្រៅ ។

បទថា “**អជ្ឈត្តំ អរូបសញ្ញី** = មិនមានបរិកម្មសញ្ញាខាងក្នុងរូប” មានសេចក្ដីថា មិនមានការសម្គាល់ក្នុងរូបខាងក្នុង, អធិប្បាយថា បុគ្គលនោះមិនមានរូបាវចរជ្ឈាន ដែលឱ្យកើតឡើងក្នុងកោដ្ឋាសៈទាំងឡាយ មានសក់

ជាដើមរបស់ខ្លួន; ដោយពាក្យថា **មិនមានបរិកម្មខាងក្នុងរូប** នេះ ទ្រង់សម្ដែងដល់ព្រះយោគាវចរបានឈានក្នុងអារម្មណ៍ខាងក្រៅ ព្រោះធ្វើបរិកម្មក្នុងវត្ថុខាងក្រៅ ។ ដោយបទថា **"សុភំ** = ស្អាត" នេះ ទ្រង់សម្ដែងឈានទាំងឡាយ ក្នុងវណ្ណកសិណមានពណ៌ខៀវជាដើមដ៏បរិសុទ្ធល្អហើយ ។ បណ្ដាឈានដែលប្រព្រឹត្តទៅក្នុងវណ្ណកសិណទាំងនោះ ការនឹកគិតថា **"ស្អាត"** មិនមានក្នុងអប្បនាខាងក្នុង ក៏ពិតមែនហើយ, ប៉ុន្តែថា ព្រះយោគាវចរណាធ្វើសុភកសិណដ៏បរិសុទ្ធល្អហើយឱ្យជាអារម្មណ៍, ព្រះយោគាវចរនោះ ចងចិត្តក្នុងវណ្ណកសិណថា **"ស្អាត"** ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយចូលដល់បឋមជ្ឈាន; ទុតិយជ្ឈានជាដើម ក៏ដូចគ្នាដែរ; ព្រោះហេតុដូច្នោះ ទើបព្រះអង្គទ្រង់ធ្វើទេសនាទុកយ៉ាងនេះ ។ ប៉ុន្តែក្នុងបដិសម្ភិទាមគ្គលោកពោលថា "សភាវៈធម៌ដែលឈ្មោះថា **វិមោក្ខ** ព្រោះអត្ថថា ជាអ្នកបង្អោនទៅក្នុងពាក្យថា '**ស្អាត**' ដូច្នេះ ជាយ៉ាងណាដែរ? ភិក្ខុក្នុងធម្មវិន័យនេះ មានចិត្តសហគតៈ (ប្រកប) ដោយមេត្តាផ្សាយទៅកាន់ទិសមួយ ។ល។ សត្វទាំងឡាយ រមែងជាអ្នកមិនបដិកូល ព្រោះចម្រើនមេត្តា; ភិក្ខុមានចិត្តសហគតដោយ ករុណា... មុទិតា... ឧបេក្ខាផ្សាយទៅកាន់ទិសមួយ ។ល។ សត្វទាំងឡាយរមែងជាអ្នកមិនបដិកូល ព្រោះចម្រើនឧបេក្ខា; ព្រះមានព្រះភាគត្រាស់ពាក្យថា ឈ្មោះថា **វិមោក្ខ** ព្រោះអត្ថថា ជាអ្នកបង្អោនទៅក្នុង

អារម្មណ៍ថា '**ស្អាត**' ដោយប្រការដូច្នេះ"[១០៩] ; ប៉ុន្តែ ក្នុងព្រះអភិធម្មនេះ ព្រះអង្គទ្រង់បដិសេធន័យនោះ ព្រោះព្រហ្មវិហារមានមកក្នុងព្រះបាលីខាងមុខហ្នឹងហើយ ទ្រង់ត្រាស់អនុញ្ញាតសុភវិមោក្ខទុក ដោយអំណាចនៃនីលកសិណដ៏ល្អ, បីតកសិណដ៏ល្អ, លោហិតកសិណដ៏ល្អ, ឱទាតកសិណដ៏ល្អ, នីលកសិណដ៏បរិសុទ្ធ, បីតកសិណដ៏បរិសុទ្ធ, លោហិតកសិណដ៏បរិសុទ្ធ, ឱទាតកសិណដ៏បរិសុទ្ធប៉ុណ្ណោះ; ដោយប្រការដូច្នេះ ពាក្យថា "**កសិណ**" ឬពាក្យថា "**អភិភាយតនៈ**" ឬពាក្យថា "**វិមោក្ខ**" ក៏គឺរូបាវចរជ្ឈាននោះឯង ។ ពិតមែន រូបាវចរជ្ឈាននោះ ត្រាស់ថា ឈ្មោះថា **កសិណ** ព្រោះអត្ថថា ទូទៅដល់អារម្មណ៍, ឈ្មោះថា **អភិភាយតនៈ** ព្រោះអត្ថថា គ្របសង្កត់អារម្មណ៍, ឈ្មោះថា **វិមោក្ខ** ព្រោះអត្ថថា បង្អោនចិត្តទៅក្នុងអារម្មណ៍ និងព្រោះអត្ថថា រួចផុតចាកធម៌ដែលជាសត្រូវទាំងឡាយ; បណ្ដាទេសនាកសិណ អភិភាយតនៈ និងវិមោក្ខទាំងនោះ ទេសនាកសិណ គប្បីជ្រាបថា ត្រាស់ទុកដោយអំណាចនៃព្រះអភិធម្ម, ចំណែកទេសនា ២ យ៉ាង ក្រៅអំពីនេះ ត្រាស់ទុកដោយអំណាចការទេសនាក្នុងព្រះសូត្រ ។ នេះជាការពណ៌នាបទតាមលំដាប់ក្នុងវិមោក្ខនេះ; ប៉ុន្តែថា វិមោក្ខតែម្យ៉ាងៗ គប្បីជ្រាបនវកន័យ ៧៥ ពួក ដោយធ្វើជាចំណុចនីមួយៗ ២៥៧ ដូចបឋវីកសិណដែរ ៕

## ចប់វិមោក្ខកថា

---

[១០៩] ខុ. បដិ. ។

# អធិប្បាយអំពីព្រហ្មវិហារជ្ឈាន

ឥឡូវនេះ ដើម្បីសម្ដែងរូបាវចរកុសលប្រព្រឹត្តទៅដោយអំណាចនៃព្រហ្មវិហារមានមេត្តាជាដើម ព្រះមានព្រះភាគទើបទ្រង់ផ្ដើមពាក្យជាដើមថា "**កតមេ ធម្មា កុសលា**" ទៀត ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា "**កតមេ ធម្មា កុសលា**" ជាដើមនោះដូចតទៅ ៖-

ពាក្យថា "**មេត្តាសហគតំ** = សហគតៈដោយមេត្តា" បានដល់ប្រកបដោយមេត្តា; សូម្បីនៅក្នុងពាក្យថា សហគតៈដោយករុណាជាដើមខាងមុខ ក៏មានន័យដូចគ្នាដែរ ។ ក៏ព្រះយោគាវចរនោះបដិបត្តិហើយ ដោយវិធីណា ទើបចូលដល់ឈានដែលសហគតៈដោយមេត្តាជាដើម, វិធីនៃការចម្រើនមេត្តាជាដើមនោះ ខ្ញុំឱ្យពិស្ដារទុកក្នុង**វិសុទ្ធិមគ្គ**[១១០] ហើយ, ចំណែកសេចក្ដីនៃព្រះបាលីដែលនៅសល់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងបឋវីកសិណនោះឯង ។ ប៉ុន្តែក្នុងបឋវីកសិណ បានធម៌ ៩ ពួក រួមជា ២៥ ពួកប៉ុណ្ណោះ, ក្នុងព្រហ្មវិហារនេះ បានធម៌ ៧ ពួក រួមជា ២៥ ពួក ដោយអំណាចនៃព្រះបាលី មានពាក្យថា តិកជ្ឈាន (ឈានពួក ៣) និងចតុក្កជ្ឈាន (ឈានពួក ៤) ជាដើម ក្នុងព្រហ្មវិហារ ៣ ខាងដើម; តែមួយពួក១ បាន

[១១០] វិសុទ្ធិ. ២ (ព្រហ្មវិហារនិទ្ទេស) ។

២៩ ពួក ដោយអំណាចនៃឈានទី ៤ ក្នុងឧបេក្ខា; ប៉ុន្តែក្នុងឈានដែលសហគតៈដោយករុណា និងមុទិតារមែងមានយេវាបនកធម៌ទាំងនេះ គឺករុណា និងមុទិតាជាមួយនឹងធម៌ ៤ មានឆន្ទៈជាដើម ។

ម្យ៉ាងទៀត ភាពជាទុក្ខាបដិបទាជាដើមក្នុងព្រហ្មវិហារនេះ គប្បីជ្រាបការសង្កត់ព្យាបាទដោយមេត្តាជាមុន, គប្បីជ្រាបការសង្កត់វិហិង្សាដោយករុណា, គប្បីជ្រាបការសង្កត់អរតិ (ការមិនរីករាយ) ដោយមុទិតា, គប្បីជ្រាបការសង្កត់រាគបដិឃៈដោយឧបេក្ខា មានប្រការដូច្នេះ ។ ចំណែកសេចក្តីដែលប្លែកគ្នាថាជាបរិត្តារម្មណ៍ រមែងមិនមាន ដោយអំណាចនៃសត្វចំនួនច្រើនជាអារម្មណ៍, ចំណែកសេចក្តីជាអប្បមាណារម្មណ៍ រមែងមានដោយអំណាចមានសត្វច្រើនជាអារម្មណ៍ដូច្នេះ; ពាក្យដែលនៅសល់ដូចៗ គ្នាទាំងអស់ ។

**បណ្ឌិតគប្បីជ្រាបព្រហ្មវិហារទាំងនេះ ដែលព្រះមានព្រះភាគព្រះអង្គជាព្រហ្មដ៏ខ្ពង់ខ្ពស់ ត្រាស់ហើយដោយអំណាចនៃបាលី មានអាការយ៉ាងនេះ ជាមុនហើយ គប្បីជ្រាបសូម្បីតែបកិណ្ណកកថា ក្នុងព្រហ្មវិហារទាំងនេះ ឱ្យក្រៃលែងឡើងថែមទៀត**[១១១]។

ពិតមែនហើយ បណ្តាព្រហ្មវិហារ ៤ គឺ មេត្តា, ករុណា និងមុទិតា,

[១១១] វិសុទ្ធិ.២ (ព្រហ្មវិហារនិទ្ទេស) ។

ឧបេក្ខាទាំងនេះ ពោលដោយអត្ថ ធម៌ដែលឈ្មោះថា មេត្តា ព្រោះអត្ថថា តែងតែស្រឡាញ់រាប់អាន = **មេជ្ជតីតិ មេត្តា**, គឺថា **តែងតែស្នេហា = សិនេហតិ** ។ ម្យ៉ាងទៀត ដែលឈ្មោះថា **មេត្តា** ព្រោះអត្ថថា ធម៌នេះនៅមានក្នុងមិត្ត, ឬថា រមែងប្រព្រឹត្តិទៅដើម្បីមិត្ត ។ ធម៌ដែលឈ្មោះថា **ករុណា** ព្រោះអត្ថថា រមែងធ្វើហឫទ័យរបស់មហាជនទាំងឡាយឱ្យញាប់ញ័រ ព្រោះអ្នកដទៃមានទុក្ខ, ម្យ៉ាងទៀត ឈ្មោះថា **ករុណា** ព្រោះអត្ថថា រមែងបំបាត់ ឬរមែងបៀតបៀន គឺរមែងញុំាងទុក្ខរបស់អ្នកដទៃឱ្យវិនាស, ម្យ៉ាងទៀត ដែលឈ្មោះថា **ករុណា** ព្រោះអត្ថថា រមែងធ្វើឱ្យខ្ចាយទៅ ឱ្យចេញទៅ ដោយការផ្សាយទៅក្នុងសត្វអ្នកកំពុងមានសេចក្ដីទុក្ខ ។ ធម៌ដែលឈ្មោះថា **មុទិតា** ព្រោះអត្ថថា ជាគ្រឿងធ្វើឱ្យរីករាយរបស់អ្នកដល់ព្រមដោយមុទិតានោះ, ឬរមែងត្រេកអរដោយខ្លួនឯង, ឬថាត្រឹមតែសេចក្ដីត្រេកអរប៉ុណ្ណោះ ។ ធម៌ដែលឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា រមែងសំឡឹងមើលដោយការលះព្យាបាទមានជាអាទិ៍ថា "**អវេរា ហោន្តុ** សូមសត្វទាំងឡាយ ចូរជាអ្នកមិនមានពៀរវេរាចុះ" និងដោយការចូលដល់នូវភាពជាជាកណ្ដាល ។

ម្យ៉ាងទៀត ក្នុងព្រហ្មវិហារទាំងនេះ ពោលដោយលក្ខណៈជាដើម គប្បីជ្រាបថា ៖-

## លក្ខណាទិចតុក្កៈនៃមេត្តា

~**ហិតាការប្បវត្តិលក្ខណា** មេត្តាមានការប្រព្រឹត្តទៅដោយអាការដែលជាប្រយោជន៍ គឺការទំនុកបម្រុងជាលក្ខណៈ ។

~**ហិតូបសំហាររសា** មានការបង្អោនចូលទៅនូវប្រយោជន៍ ជាកិច្ច

~**អាឃាតវិនយបច្ចុប្បដ្ឋានា** មានការកម្ចាត់នូវការចងអាឃាត ជាបច្ចុប្បដ្ឋាន ។

~**សត្តានំ មនាបភាវទស្សនបទដ្ឋានា** មានការយល់ឃើញនូវវត្ថុដែលគួរពេញចិត្តរបស់សត្វ ជាបទដ្ឋាន ។

~**ព្យាបាទូបសមោ ឯតិស្សា សម្បត្តិ** មេត្តានេះមានការស្ងប់នូវព្យាបាទ ជាសម្បត្តិ ។

~**សិនេហសម្ភវោ វិបត្តិ** មានការកើតឡើងនៃសេចក្តីស្នេហាជាវិបត្តិ ។

## លក្ខណាទិចតុក្កៈនៃករុណា

~**ទុក្ខាបនយនាការប្បវត្តិលក្ខណា** មានការប្រព្រឹត្តទៅនៃអាការជួយបំបាត់ទុក្ខជាលក្ខណៈ ។

~**បរទុក្ខាសហនរសា** មានការកម្ចាត់ទុក្ខរបស់អ្នកដទៃជារស

~**អវិហិង្សាបច្ចុប្បដ្ឋានា** មានការមិនបៀតបៀនជាបច្ចុប្បដ្ឋាន

**ទុក្ខាភិភូតានំ អនាថភាវទស្សនបទដ្ឋានា** មានការឃើញសត្វអ្នកត្រូវទុក្ខគ្របសង្កត់ហើយជាអ្នកមិនមានទីពឹងជាបទដ្ឋាន ។

**វិហឹសូបសមោ ឯតិស្សា សម្បត្តិ** ករុណានេះមានការស្ងប់នូវការបៀតបៀនជាសម្បត្តិ ។

**សោកសម្ភវោ វិបត្តិ** មានការកើតឡើងនៃសេចក្តីសោកជាវិបត្តិ ។

## លក្ខណាទិចតុក្កៈនៃមុទិតា

**សត្តេសុ បមោទនលក្ខណា** មុទិតាមានការរីករាយចិត្តក្នុងសត្វទាំងឡាយជាលក្ខណៈ ។

**អនិស្សាយនរសា** មានការមិនប្រច្រណែនក្នុងសេចក្តីល្អជាកិច្ច

**អរតិវិឃាតបច្ចុប្បដ្ឋានា** មានការកម្ចាត់អរតិ (ការមិនរីករាយ) ជាបច្ចុប្បដ្ឋាន ។

**សត្តានំ សម្បត្តិទស្សនបទដ្ឋានា** មានការឃើញសម្បត្តិរបស់សត្វទាំងឡាយជាបទដ្ឋាន ។

**អរតិវូបសមោ ឯតិស្សា សម្បត្តិ** មុទិតានេះ មានការស្ងប់អរតិជាសម្បត្តិ ។

**បហាសសម្ភវោ វិបត្តិ** មានការកើតឡើងនៃសេចក្តីរីករាយ ភ្លើត

ភ្លើនជាវិបត្តិ ។

## លក្ខណាទិចតុក្កៈនៃឧបេក្ខា

~**សត្តេសុ មជ្ឈត្តាការប្បវត្តិលក្ខណា** ឧបេក្ខាមានការប្រព្រឹត្តទៅដោយអាការជាកណ្តាល ក្នុងសត្វទាំងឡាយជាលក្ខណៈ ។

~**សត្តេសុ សមភាវទស្សនរសា** មានការឃើញសត្វទាំងឡាយដោយសេចក្តីស្មើគ្នាជារស ។

~**បដិឃានុនយវូបសមបច្ចុប្បដ្ឋានា** មានការចូលទៅស្ងប់សេចក្តីក្រោធ និងសេចក្តីស្រឡាញ់ជាបច្ចុប្បដ្ឋាន ។

**...ឯវំ បវត្តកម្មស្សកតាទស្សនបទដ្ឋានា** មានការឃើញសត្វទាំងឡាយមានកម្មជារបស់ខ្លួន ដែលប្រព្រឹត្តទៅយ៉ាងនេះថា “សត្វទាំងឡាយមានកម្មជារបស់ខ្លួន, សត្វទាំងនោះនឹងមានសេចក្តីសុខ, ឬនឹងផុតចាកទុក្ខ, ឬនឹងមិនសាបសូន្យចាកសម្បត្តិ តាមការពេញចិត្តរបស់គេ” ជាបទដ្ឋាន ។

~**បដិឃានុនយវូបសមោ ឯតិស្សា សម្បត្តិ** ឧបេក្ខានោះ មានការស្ងប់នូវសេចក្តីក្រោធ និងសេចក្តីស្រឡាញ់ជាសម្បត្តិ ។

~**គេហនិស្សិតាយ អញ្ញាណុបេក្ខាយ សម្ភវោ វិបត្តិ** មានការកើតឡើងនៃអញ្ញាណុបេក្ខាដែលអាស្រ័យផ្ទះជាវិបត្តិ ។

ក៏សេចក្ដីសុខក្នុងវិបស្សនា និងភវសម្បត្តិជាសាធារណៈប្រយោជន៍របស់ព្រហ្មវិហារទាំង ៤ នោះ, ប៉ុន្តែការកម្ចាត់ព្យាបាទជាដើមជាប្រយោជន៍ចំពោះអង្គ (ដោយចំពោះ) ។ ពិតមែនហើយ នៅក្នុងអភិធម្មនេះ មេត្តាមានការកម្ចាត់ព្យាបាទជាប្រយោជន៍, ព្រហ្មវិហារ ៣ ក្រៅពីនេះ មានការកម្ចាត់សេចក្ដីបៀតបៀន សេចក្ដីមិនត្រេកអរ និងបដិឃៈជាប្រយោជន៍ ។ បញ្ហានេះសមដូចពាក្យដែលលោកពោលទុកថា **"ម្នាលអាវុសោទាំងឡាយ ព្រោះធម្មជាតិ គឺមេត្តាចេតោវិមុត្តិនេះ ជាគ្រឿងរលាស់ចេញនូវការព្យាបាទ..., ម្នាលអាវុសោទាំងឡាយ ព្រោះធម្មជាតិ គឺករុណាចេតោវិមុត្តិនេះ ជាគ្រឿងរលាស់ចេញនូវការបៀតបៀន..., ម្នាលអាវុសោទាំងឡាយ ព្រោះធម្មជាតិ គឺមុទិតាចេតោវិមុត្តិនេះ ជាគ្រឿងរលាស់ចេញនូវអរតិ...*, ម្នាលអាវុសោ**

---

* សញ្ញាចុចៗ ទាំងអស់នេះ បានពិនិត្យតាមលំអានបាលី មិនឃើញមានសេចក្ដីដែលត្រូវឱ្យប្រើសញ្ញាចុចៗ នេះទេ ប្រហែលលោកអ្នកប្រែមុនយល់ឃើញថា ព្រហ្មវិហារទាំង ៣ ខាងដើមនេះ មិនមែនតែអាចរលាស់ចេញនូវព្យាបាទជាដើមបានទេ គឺអាចរលាស់ចេញនូវអកុសលធម៌ដទៃៗ ទៀតបានទេដឹង? បានជាលោកប្រើសញ្ញានេះ ។ ឯឧបេក្ខាចេតោវិមុត្ត (ព្រហ្មវិហារទី ៤) លោកមិនបានប្រើសញ្ញាចុចៗនេះឡើយ ព្រោះមានតែឧបេក្ខាចេតោវិមុត្តិនេះទេ ដែលអាចរលាស់ចេញនូវរាគៈបានទេដឹង? (មតិរបស់អ្នកប្រែរៀបរៀង) ។

[១១២] ទី. បា., អំ. ឆក្ក. ។

**ទាំងឡាយ ព្រោះធម្មជាតិ គឺឧបេក្ខាចេតោវិមុត្តិនេះ, ជាគ្រឿងរលាស់ចេញនូវរាគៈ”**[១១២] ។

ក្នុងព្រហ្មវិហារទាំងនេះ **មានធម៌ដែលជាសឹកសត្រូវម្យ៉ាងៗ មាន ២** ដោយអំណាចនៃភាពជាសត្រូវជិត និងសត្រូវឆ្ងាយ; ពិតមែន **មេត្តាព្រហ្មវិហារ** មានរាគៈជាហេតុជិត ព្រោះយល់ឃើញថា ជាគុណស្មើគ្នា ដូចសត្រូវរបស់បុរសអ្នកត្រេចទៅជិតគ្នា, រាគៈនោះ រមែងបានឱកាសយ៉ាងរហ័ស, ព្រោះហេតុដូច្នោះ គប្បីរក្សាមេត្តាឱ្យល្អចាករាគៈនោះ; ព្យាបាទជាសត្រូវឆ្ងាយ ព្រោះសេចក្ដីជាសភាគៈ និងវិសភាគៈ ដូចសត្រូវរបស់បុរស ដែលអាស្រ័យនៅនាព្រៃរបោះមានភ្នំជាដើម, ព្រោះហេតុដូច្នោះ ព្រះយោគាវចរគប្បីផ្សព្វផ្សាយមេត្តាចេញទៅ ដោយប្រាសចាកសេចក្ដីខ្លាច (មិនខ្លាច) ចំពោះព្យាបាទនោះ; បញ្ហាដែលថា បុគ្គលដែលផ្សព្វផ្សាយមេត្តានឹងមានការក្រោធព្រមគ្នា នោះមិនមែនជាហេតុដែអាចមានបានឡើយ (**អដ្ឋានមេតំ**)* ។ ទោមនស្សអាស្រ័យផ្ទះដែលត្រាស់ទុកដោយន័យជាដើមថា **“បុគ្គលកាលសំឡឹងឃើញ (ពិចារណាមើល) ការមិនបានចំពោះនូវរូបដែលនឹងបានដោយចក្ខុដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ជាទីមនោរម្យនៃចិត្ត**

---

* ពាក្យថា អដ្ឋានមេតំ < អដ្ឋានំ = អឋានំ = អការណំ + ឯតំ > អដ្ឋានមេតំ ។

ប្រកបដោយលោកាមិស ដោយជារបស់ដែលខ្លួនមិនបានចំពោះ ឬនឹករលឹកដល់រូបដែលធ្លាប់បានចំពោះនៅក្នុងកាលមុន ដែលកន្លងទៅហើយ ដែលរលត់ទៅហើយ ដែលប្រែប្រួលទៅហើយ រមែងកើតទោមនស្ស ទោមនស្សដូច្នេះ យើង (តថាគត) ហៅថា ទោមនស្សដែលអាស្រ័យផ្ទះ”[១១៣] ដូច្នេះជាសត្រូវជិតរបស់**ករុណាព្រហ្មវិហារ** ព្រោះឃើញសេចក្តីវិបត្តិដូចគ្នា, ការបៀតបៀនជាសត្រូវឆ្ងាយ ព្រោះជាវិសភាគៈចំពោះសភាគៈ, ព្រោះហេតុដូច្នោះ ព្រះយោគាវចរគប្បីផ្សាយករុណា ដោយមិនមានភ័យអំពីសត្រូវឆ្ងាយគឺវិហិង្សានោះ បញ្ហាដែលថា ឈ្មោះថា **បុគ្គលដែលធ្វើករុណា** និងការបៀតបៀនសត្វដោយការប្រហារដោយបាតដៃជាដើមព្រមគ្នាដូច្នេះ នោះមិនមែនជាហេតុដែលអាចប្រព្រឹត្តិទៅបានឡើយ ។

សោមនស្សអាស្រ័យផ្ទះ ដែលត្រាស់ទុកដោយន័យថា “បុគ្គលកាលសំឡឹងឃើញ (ពិចារណាឃើញ)បានចំពោះនូវរូបដែលដឹង បានដោយចក្ខុដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ជាទីមនោរម្យនៃចិត្ត ដែលប្រកបដោយលោកាមិស ដោយជារបស់ដែលខ្លួនបានចំពោះ ឬនឹករលឹកដល់រូបដែលធ្លាប់បានចំពោះហើយនៅក្នុងកាលមុន ដែលកន្លងទៅហើយ ដែលរលត់ទៅហើយ ប្រែប្រួលទៅហើយ រមែងកើតសោមនស្ស; សោមនស្ស

---

[១១៣] ម. ឧ.។

ដូច្នេះ ហៅថា សោមនស្សអាស្រ័យផ្ទះ” [១១៤] ជាសត្រូវជិតរបស់មុទិតាព្រហ្មវិហារ ព្រោះយល់ថា ជាសម្បត្តិស្មើគ្នា, អរតិជាសត្រូវឆ្ងាយ ព្រោះជាវិសភាគៈ ចំពោះសភាគៈ, ព្រោះហេតុដូច្នោះ គប្បីចម្រើនមុទិតាទៅដោយការប្រាសចាកនូវសេចក្តីខ្លាចចំពោះសឹកសត្រូវនោះ; បញ្ហាដែលថា បុគ្គលដែលជាអ្នករីករាយត្រេកអរ និងជាអ្នកឡើយណាយក្នុងសេនាសនៈដែលស្ងាត់ និងនៅក្នុងកុសលធម៌ក្រៃលែងព្រមគ្នាដូច្នេះ មិនមែនជាឋានដែលនឹងអាចប្រព្រឹត្តទៅបានឡើយ ។

អញ្ញាណុបេក្ខាដែលអាស្រ័យផ្ទះ ដែលត្រាស់ដោយន័យជាដើមថា “ព្រោះឃើញរូបដោយចក្ខុ ឧបេក្ខាទើបកើតឡើងដល់បុថុជ្ជនអ្នកល្ងង់ខ្លៅនៅមិន ឈ្នះកិលេស នៅមិនឈ្នះវិបាក មិនឃើញទោស មិនបានស្តាប់ជាបុគ្គលក្រាស់ណែន; ឧបេក្ខាដូច្នេះនោះ មិនលះរូបទៅបានឡើយ, ព្រោះហេតុដូច្នោះ ទើបហៅថា ឧបេក្ខាអាស្រ័យផ្ទះ” [១១៥] ដូច្នេះ ជាសត្រូវជិតនៃឧបេក្ខាព្រហ្មវិហារ, ព្រោះជាធម៌ស្មើគ្នា ដោយអំណាចនៃការមិនពិចារណាដល់ទោស និងគុណ, រាគៈ និងបដិឃៈជាសត្រូវឆ្ងាយ ព្រោះជាវិសភាគៈចំពោះសភាគៈ, ព្រោះហេតុដូច្នោះ គប្បីផ្សាយឧបេក្ខាទៅ ដោយការប្រាសចាកនូវសេចក្តីខ្លាចចំពោះសឹកសត្រូវនោះ; ដែលឈ្មោះថា បុគ្គលដែលផ្សាយ

---

[១១៤] ម. ឧ.។

[១១៥] ម. ឧ.។

ឧបេក្ខាទៅ ការត្រេកអរ ការក្រោធព្រមៗគ្នា នោះមិនមែនជាហេតុដែលអាចប្រព្រឹត្តទៅបានឡើយ ។

ម្យ៉ាងទៀត ការពេញចិត្តប្រាថ្នាដើម្បីនឹងធ្វើ (កត្តុកម្យតាឆន្ទៈ) ជា**ខាងដើម**, ការសង្កត់នីវរណជាដើមជា**កណ្ដាល**, អប្បនាជា**បរិយោសាន**របស់ព្រហ្មវិហារសូម្បីទាំងអស់នោះ; សត្វមួយ ឬច្រើន **ជាអារម្មណ៍** របស់ព្រហ្មវិហារនេះដោយបញ្ញត្តិធម៌, អារម្មណ៍បញ្ញត្តិធម៌នោះ កាលដល់ឧបចារៈ ឬអប្បនាហើយ ទើបពង្រីកអារម្មណ៍បាន ។

ក្នុងអធិការដែលពោលអំពីព្រហ្មវិហារនោះ មានលំដាប់នៃការពង្រីកអារម្មណ៍ដូចតទៅនេះ

ព្រះយោគាវចរគប្បីកំណត់អាវាសមួយមុនដំបូងបង្អស់ហើយ គប្បីចម្រើនមេត្តាទៅក្នុងសត្វទាំងឡាយក្នុងអាវាសនោះ ដោយន័យថា **“ឥមស្មឹ អាវាសេ សត្តា អវេរា ហោន្តុ** សូមឱ្យសត្វទាំងឡាយនៅក្នុងអាវាសនេះចូរជាអ្នកមិនមានពៀរនឹងគ្នាចុះ” ជាដើម ដូចអ្នកស្រែដ៏ឆ្លាត កំណត់ស្ថានទីដែលខ្លួនគប្បីភ្ជួរហើយ ទើបភ្ជួរដូច្នោះ; ព្រះយោគាវចរគប្បីធ្វើចិត្តឱ្យទន់ និងគួរដល់ការងារក្នុងអាវាសនោះ ហើយគប្បីកំណត់អាវាស ២ កន្លែង; បន្ទាប់ពីនោះ ក៏កំណត់អាវាស ៣ កន្លែង, ៤ កន្លែង, ៥ កន្លែង, ៦ កន្លែង, ៧

កន្លែង, ៨ កន្លែង, ៩ កន្លែង, ១០ កន្លែង, ច្រក ១, ពាក់កណ្ដាលភូមិ, ភូមិមួយ, ជនបទមួយ, រដ្ឋមួយ និងទិសមួយ តាមលំដាប់; រហូតទូទាំងចក្រវាឡមួយ, ឬក្រៃលែងជាងនោះ ហើយចម្រើនមេត្តាចំពោះសត្វទៅក្នុងទីនោះៗ; ករុណាព្រហ្មវិហារជាដើមក៏ដូចគ្នាដែរ នេះជាលំដាប់នៃការពង្រីកអារម្មណ៍ក្នុងព្រហ្មវិហារ ៤ ដូច្នេះ ។

ក្នុងព្រហ្មវិហារទាំង ៤ នេះ ឧបេក្ខាព្រហ្មវិហារជាផលហូរចេញ របស់ព្រហ្មវិហារ ៣ ខាងដើម ប្រៀបដូចរូបសមាបត្តិជាផលដែលហូរចេញពីកសិណទាំងឡាយ, នេវសញ្ញានាសញ្ញាយតនៈជាផលដែលហូរចេញពីអរូបសមាធិ, **ផលសមាបត្តិជាផលដែលហូរចេញពីវិបស្សនា**, និរោធសមាបត្តិជាផលដែលហូរចេញពីសមថៈ និងវិបស្សនាទាំងឡាយដូច្នោះ; ម្យ៉ាងដូចថាបុគ្គលកសាងផ្ទះ បើនៅមិនទាន់បានលើកសរសរទាំងឡាយឡើងតាំងនៅមិនទាន់បានលើករនូតធ្នឹម និងមេដំបូលទេ ក៏មិនអាចនឹងលើកកំពូលផ្ទះតាំងទុកក្នុងអាកាសបានឡើយយ៉ាងណា, ព្រះយោគាវចរវៀរចាកតតិយជ្ឈានដែលកើតឡើងអំពីខាងដើមហើយ ក៏មិនអាចដើម្បីនឹងចម្រើនចតុត្ថជ្ឈានបានដូច្នោះដែរ, ប៉ុន្តែ ឧបេក្ខាព្រហ្មវិហារនេះ រមែងមិនកើតឡើងដល់បុគ្គលអ្នកញុំាងតតិយជ្ឈានឱ្យកើតឡើង ហើយក្នុងកសិណទាំងឡាយ ព្រោះជាអារម្មណ៍មានចំណែកមិនស្មើគ្នា ។

នៅក្នុងព្រហ្មវិហារទាំងនោះ ប្រសិនបើនឹងមានពាក្យសួរថា “ព្រោះហេតុអ្វី មេត្តា, ករុណា, មុទិតា និងឧបេក្ខា ទើបត្រាស់ថា ព្រហ្មវិហារ?, ព្រោះហេតុអ្វី ព្រហ្មវិហារទើបមាន ៤ និងលំដាប់របស់ព្រហ្មវិហារទាំងនោះមានយ៉ាងណាទៅ?, ព្រោះហេតុអ្វីនៅក្នុងវិភង្គទើបត្រាស់ហៅថា ជាអប្បមញ្ញាទៅវិញ” ។

ឆ្លើយថា ភាពជា**ព្រហ្មវិហារ** ក្នុងធម៌មានមេត្តាជាដើមទាំងនេះ គប្បីជ្រាបដោយអត្ថថា ប្រសើរ និងភាវៈជាធម៌មិនមានទោស ។

ពិតមែន ធម៌ទាំងនេះ ឈ្មោះថា ជាធម៌ជាទីនៅដ៏ប្រសើរ ព្រោះជាការបដិបត្តិដោយប្រពៃក្នុងសត្វទាំងឡាយ; ក៏ព្រហ្មទាំងឡាយ មានចិត្តប្រាសចាកទោសយ៉ាងណា, ព្រះយោគីទាំងឡាយអ្នកប្រកបដោយព្រហ្មវិហារទាំងនេះ រមែងជាអ្នកស្មើនិងព្រហ្មដូច្នោះដែរ ព្រោះហេតុដូច្នោះ ទើបត្រាស់ហៅធម៌ទាំងឡាយនោះថា “ព្រហ្មវិហារ” ព្រោះអត្ថថា ប្រសើរ និងជាធម៌ប្រាសចាកទោស ។

ចំណែកបញ្ហាមានពាក្យថា ព្រោះហេតុអ្វីទើបមាន ៤ ជាដើម មានពាក្យវិសជ្ជនាដូច្នេះ ៖-

**វិសុទ្ធិមគ្គាទិវសា ចតស្សោ**

**ហិតាទិអាការវសា បនាសំ**

**ករុណា បរត្ថន្តិ ច អប្បមាណោ**

**តា គោចរេ យេន តទប្បមញ្ញា ។**

ព្រហ្មវិហារ ឈ្មោះថា មាន ៤ ព្រោះជាផ្លូវដ៏បរិសុទ្ធជាដើម (វិសុទ្ធិមគ្គាទិវសា) ម្យ៉ាងទៀត លំដាប់នៃព្រហ្មវិហារទាំងនោះរមែងមាន ព្រោះអាការមានប្រយោជន៍ ទំនុកបម្រុងជាដើម និងព្រហ្មវិហារទាំងនោះ រមែងប្រព្រឹត្តិទៅក្នុងអារម្មណ៍ មិនមានប្រមាណ ព្រោះហេតុដូច្នោះ ទើបហៅថា អប្បមបញ្ញា[១១៦] " ។

ពិតមែនហើយ បណ្ដាព្រហ្មវិហារទាំងនោះ មេត្តាជាផ្លូវដ៏បរិសុទ្ធ (វិសុទ្ធិមគ្គ) របស់បុគ្គលអ្នកច្រើនទៅដោយព្យាបាទ, ករុណាជាផ្លូវដ៏បរិសុទ្ធរបស់បុគ្គលអ្នកច្រើនទៅដោយវិហិង្សា, មុទិតា ជាផ្លូវដ៏បរិសុទ្ធរបស់បុគ្គលអ្នកច្រើនទៅដោយអរតិ, ឧបេក្ខាជាផ្លូវដ៏បរិសុទ្ធរបស់បុគ្គលអ្នកច្រើនទៅដោយរាគៈ ។

ម្យ៉ាងទៀត មនសិការក្នុងសត្វទាំងឡាយរបស់ព្រហ្មវិហារក៏មាន ៤ យ៉ាងហ្នឹងហើយ ដោយអំណាចការបង្អោនចូលទៅនូវប្រយោជន៍ គឺការទំនុកបម្រុង ១, ការនាំចេញនូវវត្ថុមិនមានប្រយោជន៍ (ទុក្ខ) ១, ការត្រេកអរតាមជាមួយនឹងសម្បត្តិអ្នកដទៃ ១ និងការមិនចងចិត្ត ១ ។

---

[១១៦] វិសុទ្ធិ. ២ (ព្រហ្មវិហារនិទ្ទេស) ។

ម្យ៉ាងវិញទៀត ដូចយ៉ាងថា មាតាមានកូន ៤ នាក់ , បណ្ដាកូន ៤ នាក់ ជាកូនក្មេងម្នាក់, ជាកូនឈឺម្នាក់, ជាកូនកំឡោះក្រមុំម្នាក់ និងកំពុងប្រកបកិច្ចការទាំងពួងម្នាក់; មាតារមែងប្រាថ្នាឱ្យកូនតូចចម្រើនធំធាត់, មានការប្រាថ្នា កម្ចាត់នូវការឈឺចុកចាប់របស់កូនដែលឈឺ, មានការប្រាថ្នាឱ្យកូនដែលជាកំឡោះក្រមុំ តាំងនៅក្នុងសម្បត្តិនៃភាពជាកំឡោះក្រមុំរហូតកាលយូរ, និងមិនខ្វល់ខ្វាយកិច្ចការងារអ្វីៗ របស់កូនដែលប្រកបការងារ ហើយយ៉ាងណាមិញ, ព្រះយោគាវចរអ្នកមានអប្បមញ្ញាជាគ្រឿងជ្រក ក៏ដូច្នោះដែរ គប្បីចម្រើនទៅដោយអំណាចនៃអប្បមញ្ញា មានមេត្តាជាដើម ក្នុងសត្វទាំងពួង, ព្រោះហេតុដូច្នោះ អប្បមញ្ញាទើបមាន ៤ យ៉ាង ព្រោះអំណាចនៃផ្លូវដ៏ហ្មត់ចត់ជាដើមនេះ ។

ព្រះយោគាវចរអ្នកប្រាថ្នា នឹងចម្រើនអប្បមញ្ញាទាំង ៤ នោះ គប្បីបដិបត្តិក្នុងសត្វទាំងឡាយ ដោយអំណាចនៃការប្រព្រឹត្តទៅដោយអាការដែលជាប្រយោជន៍ គឺការទំនុកបម្រុងជាមុន, ព្រោះថា មេត្តាមានការប្រព្រឹត្តទៅដោយអាការជួយទំនុកបម្រុងដល់សត្វជាលក្ខណៈ, ប៉ុន្តែ ក៏គប្បីបដិបត្តិក្នុងសត្វទាំងឡាយ ដោយអំណាចនៃការប្រព្រឹត្តទៅនៃអាការដែលឃើញ ឬបានស្ដាប់ ឬកំណត់សត្វទាំងឡាយ អ្នកដែលត្រូវសេចក្ដីទុក្ខគ្រប

សង្កត់ដែលខ្លួនប្រាថ្នានឹងជួយទំនុកបម្រុងដោយប្រការដូច្នេះ ហើយជួយនាំទុក្ខចេញទៅ, ព្រោះថា ករុណា មានការប្រព្រឹត្តិទៅនៃអាការនាំទុក្ខចេញជាលក្ខណៈ; លំដាប់នោះ ក៏គប្បីបដិបត្តិក្នុងសត្វទាំងឡាយ ដោយអំណាចនៃការត្រេកអរក្នុងសម្បត្តិ ព្រោះឃើញសម្បត្តិ (គឺការដល់ព្រម) នៃសត្វដែលខ្លួនប្រាថ្នាជួយទំនុកបម្រុងហើយ មានទុក្ខទៅប្រាសហើយនោះ, ដោយថា មុទិតាមានការរីករាយចំពោះសម្បត្តិ អ្នកដទៃជាលក្ខណៈ; បន្ទាប់អំពីនោះទៅ ក៏គប្បីបដិបត្តិក្នុងសត្វទាំងឡាយ ដោយអាការនៃភាពជាកណ្តាល ពោលគឺភាពជាអ្នកព្រងើយកន្តើយ ព្រោះជាអ្នកមិនមានកិច្ចដែលគប្បីធ្វើទៀត, ព្រោះថា ឧបេក្ខាមានការប្រព្រឹត្តទៅនៃអាការ ដោយភាពជាកណ្តាលជាលក្ខណៈ; ព្រោះហេតុដូច្នោះ ទើបត្រាស់មេត្តាទុកមុន ដោយអំណាចនៃការប្រព្រឹត្តទៅដោយអាការមានការជួយទំនុកបម្រុងជាដើម, បន្ទាប់ពីនោះទៅ ក៏គប្បីជ្រាបថា លំដាប់នេះ គឺករុណា មុទិតា និងឧបេក្ខា ដោយប្រការដែលបានពោលមកនេះ ។

អប្បមញ្ញាទាំងអស់នេះ រមែងប្រព្រឹត្តិទៅក្នុងអារម្មណ៍មិនមានប្រមាណ, ពិតមែន សត្វមិនមានប្រមាណជាអារម្មណ៍របស់អប្បមញ្ញាទាំងនេះ, និងគប្បីចម្រើនមេត្តាជាដើម ក្នុងប្រទេសប៉ុណ្ណោះ សូម្បីចំពោះសត្វមួយដូច្នេះហើយ មិនកាន់យកប្រមាណយ៉ាងនេះឱ្យប្រព្រឹត្តិទៅដោយអំណាច

នៃការផ្សាយទៅទាំងអស់នោះឯង; ព្រោះហេតុដូច្នោះ ទើបត្រាស់ថា **“អប្បមញ្ញា”** ដោយហេតុនោះ ទើបខ្ញុំពោលថា ៖-

ព្រហ្មវិហារ ឈ្មោះថាមាន ៤ ព្រោះអំណាចជាផ្លូវដ៏ហ្មត់ចត់ជាដើម ម្យ៉ាងទៀត លំដាប់នៃព្រហ្មវិហារទាំងនោះរមែងមាន ព្រោះអាការមានប្រយោជន៍ជួយទំនុកបម្រុងជាដើម និងព្រហ្មវិហារទាំងនោះ រមែងប្រព្រឹត្តិទៅក្នុងអារម្មណ៍មិនមានប្រមាណ ព្រោះហេតុដូច្នោះ ទើបហៅថា អប្បមញ្ញា” ។

អប្បមញ្ញាទាំងនេះ សូម្បីមានអារម្មណ៍ជាលក្ខណៈតែម្យ៉ាងដូចគ្នា ព្រោះជាអារម្មណ៍មិនមានប្រមាណយ៉ាងនេះ, ប៉ុន្តែអប្បមញ្ញា ៣ ខាងដើម រមែងប្រព្រឹត្តិទៅក្នុងឈាន ៣ និងឈាន ៤ ។ ព្រោះហេតុអ្វី? ព្រោះឈានទាំងនោះនៅមិនប្រាសចាកសោមនស្ស ។ ព្រោះហេតុអ្វី អប្បមញ្ញា ៣ ខាងដើម ទើបមិនប្រាសចាកពីសោមនស្ស? ព្រោះអប្បមញ្ញា ៣ ខាងដើមជាធម៌រលាស់ចោលនូវព្យាបាទជាដើម ដែលមានទោមនស្ស ជាសមុដ្ឋានចេញទៅ; ចំណែកអប្បមញ្ញាចំណុចខាងក្រោយជាឈានមួយ ដែលមិនមានសោមនស្សសេសសល់; ព្រោះហេតុអ្វី? ព្រោះប្រកបដោយឧបេក្ខាវេទនា; ពិតមែន ឧបេក្ខាក្នុងព្រហ្មវិហារប្រព្រឹត្តិទៅ ដោយអាការជាកណ្តាលក្នុងសត្វ

ទាំងឡាយ វៀរឧបេក្ខាវេទនាចេញហើយ រមែងមិនអាចប្រព្រឹត្តិទៅបាន ឡើយ ។

ចប់ព្រហ្មវិហារកថា

## អដ្ឋសាលិនី អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះធម្មសង្គណី

## នៃអដ្ឋកថាចិត្តុប្បាទកណ្ឌ

## បឋមភាគ ២ ចប់